សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ដំណើរការប្រព្រឹត្តទៅនៃមជ្ឈត្តការពាណិជ្ជកម្ម នៅកម្ពុជា និងបញ្ហាប្រឈម

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤  ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **អ៊ឹង អាយឃីម**

លោក **ម៉ែន កែវស៊ីនហៃ**

ណែនាំដោយ

លោកគ្រូ **ភង ស៊ីផាន់ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **អ៊ឹង អាយឃីម** និងខ្ញុំបាទឈ្មោះ **ម៉េន កែវស៊ុនហៃ** ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលនឹងត្រូវបញ្ចប់ការសិក្សានៅក្នុងឆ្នាំ២០២៤។

**សូមគោរពប្រណិប័តន៍ និងសេចក្តីកត្តញ្ញូតាធម៌ចំពោះលោកឪពុក និងអ្នកម្តាយ**

លោកឪពុក **ធី មាឃ** និងអ្នកម្តាយ **ហួត ចាន់នី**

លោកឪពុក **ម៉េន សុផាន់ណារិទ្ធ** និងអ្នកម្តាយ **កែវ មុំរ៉ាវី**

កូនសូមលំឱនគោរពដោយកិច្ចប្រណិប័តន៍ និងកត្តញ្ញូតាធម៌ដ៏ឧត្តុង្គឧត្តមចំពោះលោកឪពុក និងអ្នកម្តាយ ដែលលោកទាំងពីរ បានផ្តល់ជីវិត និងបានលះបង់នូវកាយពល ខិតខំចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅ និងឧបត្ថម្ភគ្រប់បែបយ៉ាង ផ្តល់ជំនួយកម្លាំងចិត្ត និងការគាំទ្រទាំងផ្នែកស្មារតី ព្រមទាំងពុះពាររាល់ឧបសគ្គ គ្រប់បែបយ៉ាងដោយមិនត្អូញត្អែរ មិនខ្លាចនឿយហត់ ដើម្បីឱ្យកូនបានសិក្សារៀនសូត្រចាប់តាំងពីកុមារភាព និងបានបន្តការសិក្សារហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនាពេលបច្ចុប្បន្ន។ កូនពិតជាមានមោទនភាព និងមានការស្ងើចសរសើរចំពោះការលះបង់ដ៏ធំធេងក្រៃលែងនេះ ហើយ កូនសូមគោរពជូនពរលោកទាំងពីរឱ្យជួបតែពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

យើងខ្ញុំសូមថ្លែងនូវការគោរពដ៏ខ្ពង់ខ្ពស់ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមបណ្ឌិត **លុយ ចន្ទណ្ណា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស លោកព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច គ្រប់មុខវិជ្ជាទាំងអស់ ដែលលោកបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀនយើងខ្ញុំអស់ពីកម្លាំងកាយចិត្ត ដែលបានផ្ទេរចំណេះដឹង បទពិសោធន៍ និងទ្រឹស្តីផ្សេងៗជាច្រើនដែលជួយបង្កើនពុទ្ធិ សម្រាប់ធ្វើជាដើមទុនក្នុងការពិចារណា ថ្លឹងថ្លែងរហូតដល់យើងខ្ញុំមានឱកាសបានបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យ។

យើងខ្ញុំសូមធ្វើការគោរពដឹងគុណបំណាច់ដ៏ខ្ពង់ខ្ពស់ និងថ្លែងអំណរគុណចំពោះលោកគ្រូដឹកនាំសារណា **កង ស៊ីផាន់ណារ៉ា** យ៉ាងអនេកប្បការ ដែលលោកបានធ្វើការចំណាយពេលវេលាដ៏មានតម្លៃ និងកម្លាំងកាយចិត្តទទួលណែនាំសរសេរសារណានេះដោយមិនខ្លាចនឿយហត់ ដើម្បីជួយដឹកនាំ ពិភាក្សាពិនិត្យពិច័យតម្រង់ទិសក្នុងការស្វែងរក និងផ្តល់ឯកសារ បន្ទុកមួយចំនួនឱ្យប្រធានបទមួយនេះមានភាពផ្លូវការស្របតាមស្តង់ដារត្រឹមត្រូវដែលបានកំណត់ក្នុងការធ្វើកិច្ចការសារណានេះចាប់តាំងពីពេលចាប់ផ្តើម និងរហូតដល់ក្តីបញ្ចប់ស្ពាពរ។

ទន្ទឹមនឹងនេះ យើងខ្ញុំសូមថ្លែងអំណរគុណដល់ មជ្ឈត្តករ **ហួន សុខនីម** ប្រធានក្រុមប្រឹក្សាភិបាល នៃ **សាលសិក្សានីតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** លោកមេធាវី **ហាក់ សុនារិទ្ធ** ជាប្រធាន **ការិយាល័យមេធាវី ពិស្សុត & សហការី** កញ្ញាមេធាវី **សារិន មាសរក្សា** និងលោកមេធាវី **លី មានហួន** ជាសមាជិកគណៈមេធាវី និងជាមេធាវី នៃ **ការិយាល័យមេធាវី ពិស្សុត & សហការី** ដែលបានផ្តល់នូវឯកសារពាក់ព័ន្ធសម្រាប់ជាជំនួយនៅក្នុងសារណា និងបានផ្តល់នូវចំណេះដឹងពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែងទាក់ទងនឹងការដោះស្រាយវិវាទតាមរយៈយន្តការរបស់ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលជាចំណេះដឹងមូលដ្ឋានសំខាន់នៅក្នុងអត្ថបទសារណានេះ។

ជាចុងក្រោយនេះយើងខ្ញុំ សូមលើកដៃគោរពបួងសួងដល់បារមីវត្ថុសក្តិសិទ្ធិទាំងឡាយទាំងពួង សូមប្រសិទ្ធិពរជ័យ ជូនដល់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យទាំងអស់ឱ្យជួបតែសេចក្តីសុខ សុខភាពល្អ ព្រមទាំងសូមឱ្យលោកជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នៅក្នុងបរិបទសង្គមរស់នៅរបស់មនុស្សជាតិ តែងតែមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ទាំងផ្នែកសង្គមធម៌ និងធុរកិច្ចផ្សេងៗ។ ជាពិសេស ក្នុងសម័យកាលឌីជីថលនេះ កំណើនសេដ្ឋកិច្ចទីផ្សារកាន់តែកើនឡើង ជាហេតុនាំឱ្យវិស័យពាណិជ្ជកម្ម ក៏កាន់តែមានតម្រូវការខ្ពស់។ ការធ្វើពាណិជ្ជកម្មមានការទិញលក់ ការដោះដូរ ដែលអាចហៅបានថាជាការធ្វើនូវពាណិជ្ជកម្មរវាងមនុស្ស និងសង្គម។ ការធ្វើពាណិជ្ជកម្មនេះ បានរុញច្រានឱ្យមនុស្សទទួលបាននូវផលប្រយោជន៍ ទន្ទឹមនឹងនេះក៏បានបង្កើតឱ្យមាននូវវិវាទ ដែលជាទិដ្ឋភាពមួយទាក់ទងនឹងពាណិជ្ជកម្ម។

ដោយចរន្តនៃការរីកចម្រើនលូតលាស់នៃសង្គមជាតិ ការដោះស្រាយវិវាទដែលធ្វើឡើងតាមប្រព័ន្ធតុលាការក៏កាន់តែកើនឡើង ដូចនេះ ដើម្បីជាការសម្រួលដល់ការដោះស្រាយវិវាទនេះឱ្យមានភាពឆាប់រហ័ស និងដើម្បីធ្វើឱ្យវិស័យយុត្តិធម៌មានភាពរីកចម្រើន ការបង្កើតយន្តការសម្រាប់ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការពិតជាមានភាពចាំបាច់។ ប្រជាពលរដ្ឋអាចយកវិវាទទាំងនោះមកធ្វើការដោះស្រាយក្រៅប្រព័ន្ធតុលាការបាន ដូចជាការដោះស្រាយវិវាទតាមយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលជាយន្តការបច្ចេកទេសមួយដែលរាជរដ្ឋាភិបាលបានខិតខំធ្វើកិច្ចសហប្រតិបត្តិការរវាងស្ថាប័ន និងស្ថាប័ន រួមទាំងអង្គការអន្តរជាតិ ដើម្បីធ្វើយ៉ាងណាឱ្យសម្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលបានយុត្តិធម៌ ក៏ដូចជាស្របតាមគោលនយោបាយស្តីពីការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។ ដោយមានភាពចាំបាច់ ក៏ដូចជាការឆ្លើយតបទៅនឹងការចង់ទទួលបាននូវពុទ្ធិថ្មី និងឈ្វេងយល់ឱ្យកាន់តែមានភាពស៊ីជម្រៅអំពីការដោះស្រាយវិវាទពាណិជ្ជកម្មតាមយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូច្នេះ ក្រុមរបស់យើងខ្ញុំបានធ្វើការសម្រេចចិត្តជ្រើសយកប្រធានបទទាក់ទងនឹង "**ដំណើរការប្រព្រឹត្តទៅនៃមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា និងបញ្ហាប្រឈម**" ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងទុកជាឯកសារគោលមួយសម្រាប់ការសិក្សារបស់និស្សិត និងអ្នកសិក្សាជំនាន់ក្រោយ ឱ្យមានការយល់ដឹងកាន់តែជ្រៅអំពីយន្តការមួយនេះ ក៏ដូចជាបញ្ហាប្រឈមក្នុងការអនុវត្តមួយចំនួននូវយន្តការមួយនេះផងដែរ។

ទោះបីជាការសរសេរសារណាមួយនេះ ក្រុមរបស់យើងខ្ញុំបានខិតខំសម្រិតសម្រាំងក្នុងការសរសេរ និងពិនិត្យយ៉ាងណាក៏ដោយ ក៏នៅតែមានកំហុសឆ្គងទៅលើអក្ខរាវិរុទ្ធ និងកំហុសលើអត្ថន័យត្រង់កន្លែងណាមួយដោយអចេតនាជាក់ជាពុំខាន។ ជាចុងក្រោយនេះ ក្រុមរបស់យើងខ្ញុំសូមទទួលយកនូវរាល់ការរិះគន់ដើម្បីកែលម្អរាល់កំហុសខុសឆ្គងដោយអចេតនា ដែលមានក្នុងកិច្ចការស្រាវជ្រាវមួយនេះដោយក្តីរីករាយពីសំណាក់សាស្ត្រាចារ្យ សាស្ត្រាចារ្យរង សាស្ត្រាចារ្យជំនួយ លោកគ្រូ អ្នកគ្រូ ក៏ដូចជាសិស្សនិស្សិត និងអ្នកសិក្សាគ្រប់រូប

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** .......... ១

**១. លំនាំនៃការស្រាវជ្រាវ** .......... ១

**២. ចំណោទបញ្ហា** .......... ២

**៣. គោលបំណងនៃការស្រាវជ្រាវ** .......... ៣

**៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ** .......... ៣

**៥. សារៈសំខាន់នៃការស្រាវជ្រាវ** .......... ៣

**៦. វិធីសាស្ត្រស្រាវជ្រាវ** .......... ៤

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** .......... ៤

**ជំពូកទី១**

**ការរៀបចំ និងការប្រព្រឹត្តទៅមុនការចាប់ផ្តើមនៃមជ្ឈត្តការផ្តែកពាណិជ្ជកម្ម**

**១.១.កិច្ចព្រមព្រៀងផ្សះផ្សា** .......... ៥

**១.១.១. ការបង្កើតកិច្ចព្រមព្រៀងផ្សះផ្សា** .......... ៦

១.១.១.១. លក្ខខណ្ឌអានុភាព .......... ៦

១.១.១.២. លក្ខខណ្ឌសុពលភាព .......... ៧

**១.១.២. អានុភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា** .......... ៩

១.១.២.១.យុត្តាធិការដែលមានសមត្ថកិច្ច .......... ៩

១.១.២.២. អានុភាពនៃខចែងស្តីពីមជ្ឈត្តកម្មក្នុងកិច្ចសន្យា .......... ៩

**១.២. នីតិវិធីពន្លឿន** .......... ១០

**១.២.១. ការស្នើសុំដំណើរការនីតិវិធីពន្លឿន** .......... ១០

**១.២.២. ការដំណើរការនីតិវិធីពន្លឿន** .......... ១១

**១.២.៣. ការបញ្ឈប់នីតិវិធីពន្លឿន** .......... ១២

**១.៣. វិធានការបណ្តោះអាសន្ន** .......... ១២

១.៣.១. គោលបំណងនៃវិធានការបណ្ដោះអាសន្ន ............ ១២
១.៣.២. សំណើសុំវិធានការបណ្ដោះអាសន្ន ............ ១៣
១.៣.៣. ការចេញវិធានការបណ្ដោះអាសន្ន ............ ១៤

## ជំពូកទី២

## នីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

២.១. ការចាប់ផ្ដើមដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម............ ១៥
២.១.១.ការដាក់សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម............ ១៦
២.១.១.១. ការដាក់សេចក្តីជូនដំណឹងរបស់ភាគីប្តឹងទាមទារ............ ១៦
២.១.១.២. ការដាក់សេចក្តីជូនដំណឹងអំពីការឆ្លើយតបរបស់ភាគីឆ្លើយតប ............ ១៩
២.២. នីតិវិធីជ្រើសរើសមជ្ឈត្តករ............ ២១
២.២.១. មជ្ឈត្តករនៃវេទិកាមជ្ឈត្តកម្ម............ ២១
២.២.១.១. ការតែងតាំងមជ្ឈត្តករ ............ ២១
២.២.១.២. ការជំទាស់ទៅនឹងមជ្ឈត្តករ............ ២២
២.៣. ការប្រជុំបឋម ឬការប្រជុំត្រៀម ............ ២៤
២.៤. សេចក្ដីបង្គាប់នីតិវិធីរបស់វេទិកាមជ្ឈត្តកម្ម ............ ២៥
២.៤.១. ការកំណត់ទីកន្លែងនៃដំណើរការមជ្ឈត្តការ............ ២៦
២.៤.២. ការកំណត់លិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្ត ............ ២៦
២.៤.៣. ការកំណត់ភាសា............ ២៧
២.៤.៣.១. ភាសានៃដំណើរការមជ្ឈត្តការ............ ២៧
២.៤.៣.២. ភាសានៃមជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីបង្គាប់............ ២៧
២.៤.៤. កំណត់អំពីភស្តុតាង ............ ២៧
២.៤.៥. កំណត់អំពីសាក្សី ............ ២៨
២.៤.៦. ការដាក់សេចក្ដីថ្លែងទាមទារ............ ២៩

**២.៤.៧. ការដាក់សេចក្តីថ្លែងដោះសាចំពោះបណ្តឹងតប** ........ ៣០

**២.៥. សវនាការនៃវេទិកាមជ្ឈត្តកម្ម** ........ ៣០

**២.៥.១. សវនាការដោយផ្ទាល់មាត់** ........ ៣១

**២.៥.២. សវនាការដោយផ្អែកលើឯកសារ និងលិខិតស្នាម** ........ ៣១

**២.៦. នីតិវិធីចេញមជ្ឈត្តវិនិច្ឆ័យ** ........ ៣២

**២.៦.១. ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ** ........ ៣២

**២.៦.២. ការត្រួតពិនិត្យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ** ........ ៣៣

**២.៦.៣. ប្រភេទនៃមជ្ឈត្តវិនិច្ឆ័យ** ........ ៣៣

២.៦.៣.១. មជ្ឈត្តវិនិច្ឆ័យចុងក្រោយ ........ ៣៣

២.៦.៣.២. មជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន ........ ៣៤

២.៦.៣.៣. មជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀង ........ ៣៤

២.៦.៣.៤. មជ្ឈត្តវិនិច្ឆ័យដោយការបំពាន ........ ៣៤

**២.៦.៤. ការចេញមជ្ឈត្តវិនិច្ឆ័យ** ........ ៣៥

**២.៦.៥. អានុភាព និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ** ........ ៣៥

**២.៧. ការទទួលស្គាល់ និងការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ** ........ ៣៥

**២.៧.១. ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យ** ........ ៣៦

២.៧.១.១. ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យក្នុងប្រទេស ........ ៣៦

២.៧.១.២. ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យបរទេស ........ ៣៧

**២.៧.២. ការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ** ........ ៣៧

២.៧.២.១. ការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យក្នុងប្រទេស ........ ៣៧

២.៧.២.២. ការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យបរទេស ........ ៣៩

**ជំពូកទី៣**

**បញ្ហាប្រឈមក្នុងការអនុវត្តនីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**

**៣.១. បញ្ហាប្រឈមពាក់ព័ន្ធទៅនឹងកង្វះខាតព័ត៌មាន** .................... ៤១

**៣.១.១. កម្រៃសេវា** .................... ៤១

**៣.១.២. កង្វះភាពផ្សព្វផ្សាយការប្រើប្រាស់យន្តការ ម.ជ.ម.** .................... ៤២

**៣.២. បញ្ហាប្រឈមពាក់ព័ន្ធទៅនឹងការអនុវត្ត** .................... ៤៣

**៣.២.១. បញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងផ្សះផ្សា** .................... ៤៣

៣.២.១.១. បញ្ហាពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងផ្សះផ្សាដោយការយល់ច្រឡំ .................... ៤៤

៣.២.១.២. បញ្ហាពាក់ព័ន្ធនឹងការបកប្រែភាសា .................... ៤៤

៣.២.១.៣. បញ្ហាពាក់ព័ន្ធនឹងជម្រើសយុត្តាធិការរបស់គូភាគី .................... ៤៥

**៣.២.២. បញ្ហាប្រឈមពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងតប** .................... ៤៥

**៣.២.៣. បញ្ហាប្រឈមពាក់ព័ន្ធនឹងវិធានការបណ្តោះអាសន្ន** .................... ៤៦

**៣.២.៤. បញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ** .................... ៤៧

៣.២.៤.១. ការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ .................... ៤៧

៣.២.៤.២. ការជួយអន្តរាគមន៍ពីតុលាការ .................... ៤៧

៣.២.៤.៣. គ្មានទិន្នន័យចំពោះការទទួលស្គាល់ បដិសេធ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យ .................... ៤៨

**សេចក្តីសន្និដ្ឋាន** .................... ៤៩

**អនុសាសន៍** .................... ៥១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# ពន្យល់ពាក្យគន្លឹះ

នៅក្នុងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ក្រោមប្រធានបទ "**ដំណើរការប្រព្រឹត្តទៅនៃមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា និងបញ្ហាប្រឈម**" មួយនេះ នឹងមានការប្រើប្រាស់ពាក្យច្បាប់ និងពាក្យគន្លឹះមួយចំនួនដែលទាមទារការពន្យល់បន្ថែម។ ខាងក្រោមនេះជាការពន្យល់បន្ថែមទៅលើពាក្យច្បាប់ និងពាក្យគន្លឹះដែលនឹងត្រូវប្រើប្រាស់នៅក្នុងលទ្ធផលនៃការស្រាវជ្រាវទៅលើប្រធានបទសារណា ដោយដកស្រង់ចេញពីសន្ធានុក្រមពាក្យច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលរដ្ឋសភាអនុម័តកាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៦ ច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស ដែលរដ្ឋសភាអនុម័តនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ និងវិធានស្តីពីមជ្ឈត្តការចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១ ដែលបានឱ្យនិយមន័យពាក្យគន្លឹះដូចតទៅ។

- មជ្ឈត្តករ ៖ គឺជាការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្ម ហើយអាចស្ថិតនៅក្នុង ឬនៅក្រៅក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍។
- មជ្ឈត្តការ ៖ គឺជាប្រព័ន្ធដោះស្រាយវិវាទឯកជន ដែលគូភាគីវិវាទបានយកជម្លោះរបស់ខ្លួនទៅឱ្យតតិយជនហៅថា មជ្ឈត្តករ ដែលគូភាគីទុកចិត្តលើសមត្ថភាព និងជំនាញ។
- ពាណិជ្ជកម្ម ៖ ត្រូវបានបកស្រាយឱ្យបានទូលំទូលាយ ដើម្បីគ្របដណ្តប់លើធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្មទោះបីជាមានកិច្ចសន្យា ឬគ្មានកិច្ចសន្យាក៏ដោយ។
- វេទិកាមជ្ឈត្តកម្ម ៖ គឺជាវេទិកាមជ្ឈត្តកម្ម ដែលត្រូវបានបង្កើតឡើងដោយមានមជ្ឈត្តករមួយរូប ឬច្រើនរូប។
- តុលាការ ៖ គឺជាស្ថាប័ន ឬអង្គការនៃប្រព័ន្ធតុលាការរបស់ប្រទេសណាមួយ។
- កិច្ចព្រមព្រៀងផ្សះផ្សា ៖ គឺជាកិច្ចព្រមព្រៀងរវាងភាគីវិវាទក្នុងការធ្វើមជ្ឈត្តការវិវាទទាំងអស់ ឬវិវាទបែបណាមួយដែលកើតឡើង ឬដែលអាចកើតឡើងរវាងភាគីវិវាទនានា ដោយគោរពតាមទំនាក់ទំនងកំណត់ដោយច្បាប់ ទោះបីជាមានកិច្ចសន្យា ឬគ្មានក៏ដោយ។
- មជ្ឈត្តវិនិច្ឆ័យ ៖ គឺជាសេចក្តីសម្រេច របស់មជ្ឈត្តករណាមួយទោះមានការគ្រប់គ្រងដោយស្ថាប័នមជ្ឈត្តករអចិន្ត្រៃយ៍ក្តី ឬមិនមែនអចិន្ត្រៃយ៍ក្តី។

- សេចក្តីសម្រេចមជ្ឈត្តករបរទេស ៖ គឺជាសេចក្តីសម្រេចរបស់អង្គអាជ្ញាកណ្តាលមួយ ដែលបានធ្វើនៅក្នុងប្រទេសណាមួយផ្សេងពីព្រះរាជាណាចក្រកម្ពុជា ឬនៅក្រោមនីតិវិធីនៃច្បាប់របស់ប្រទេសមួយផ្សេងពីព្រះរាជាណាចក្រកម្ពុជា។
- អនុសញ្ញាទីក្រុងញូវយ៉ក ៖ គឺជាអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការទទួលស្គាល់នឹងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេសដែលបានធ្វើនៅទីក្រុងញូវយ៉ក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៥៨។
- គណៈកម្មាធិការតែងតាំង និងនីតិវិធី៖ គឺជាគណៈកម្មាធិការមួយរបស់ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) ដែលមានអំណាចក្នុងការតែងតាំងមជ្ឈត្តករ និងបំពេញកិច្ចការផ្សេងទៀតស្របតាមវិធានស្តីពីមជ្ឈត្តការ។
- មជ្ឈត្តករបន្ទាន់ ៖ គឺមជ្ឈត្តករដែលតែងតាំងស្របតាមប្រការ ១២ នៃវិធានស្តីពីមជ្ឈត្តការ។
- អគ្គលេខាធិការដ្ឋាន ៖ គឺជាអគ្គលេខាធិការដ្ឋានរបស់ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.)។
- ម.ជ.ម. ៖ គឺជាមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ដែលជាស្ថាប័នមិនស្វែងរកប្រាក់ចំណេញមួយមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ហើយត្រូវបានបង្កើតឡើងក្រោមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មឆ្នាំ ២០០៦។។
- វិធាន ៖ គឺជាវិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលត្រូវបានអនុម័តនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។

# សេចក្តីផ្តើម

## ១. លំនាំនៃការស្រាវជ្រាវ

នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់រូបរមែងជួបប្រទះការកើតមានឡើងនូវជម្លោះ ឬវិវាទតូចធំដែលតែងកើតចេញពីទំនាស់រវាងគ្នានឹងគ្នា ឬការមិនពេញចិត្តគ្នាលើរឿងអ្វីមួយ ដោយចៀសមិនផុតនៅពេលដែលមានវិវាទណាមួយកើតមានឡើង។ ពួកគេ គឺតែងតែស្វះស្វែងរកនូវដំណោះស្រាយសម្រាប់ដោះស្រាយវិវាទរបស់ខ្លួនឱ្យទាន់ពេលវេលា ហើយក្នុងការដោះស្រាយវិវាទនីមួយៗ គឺមានវិធីសាស្ត្រជាច្រើនខុសៗគ្នាទៅតាមទំហំ និងប្រភេទនៃវិវាទ វិវាទខ្លះជាប្រភេទវិវាទសាមញ្ញ និងមានទំហំតូចដែលអាចឱ្យគូភាគីនៃវិវាទធ្វើការដោះស្រាយដោយការចរចា ឬសម្របសម្រួលគ្នាបាន ដោយមិនចាំបាច់ស្វែងរកនូវភាគីទីបី អ្នកជួយសម្របសម្រួល ឬអាជ្ញាកណ្តាលមកជួយដោះស្រាយ។ ប៉ុន្តែ វិវាទខ្លះទៀតមានលក្ខណៈស៊ាំញ៉ាំ និងមានទំហំធំដែលធ្វើឱ្យគូភាគីវិវាទមិនអាចធ្វើការចរចា ឬសម្របសម្រួលគ្នាបានទេ មានន័យថាគឺគូភាគីវិវាទចាំបាច់ត្រូវការដំណោះស្រាយពីភាគីទីបី អ្នកជួយសម្របសម្រួល ឬអាជ្ញាកណ្តាល។ យ៉ាងណាមិញ ការទំនាក់ទំនងគ្នា ក្នុងវិស័យពាណិជ្ជកម្មក៏តែងតែកើតមានឡើងនូវវិវាទធំ តូចដូចគ្នាផងដែរ។ រីឯ ការដោះស្រាយវិវាទ ភាគីវិវាទ មានជម្រើសជាច្រើនដូចជា ការចរចា ការសម្របសម្រួល ការដោះស្រាយទ្វេភាគី សន្ធានកម្ម មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឬការដាក់បណ្តឹងទៅតុលាការ។ ជារួមមកវិញ ដំណោះស្រាយដែលបានរៀបរាប់ទាំងអស់នេះត្រូវបានគេបែងចែកជាពីរប្រភេទគឺការដោះស្រាយក្រៅប្រព័ន្ធតុលាការ និងការដោះស្រាយតាមប្រព័ន្ធតុលាការ។

តួយ៉ាង នៅក្នុងវិស័យពាណិជ្ជកម្មក៏ដូចគ្នាទៅនឹងវិស័យដទៃទៀតដែរ គឺមានមធ្យោបាយជាច្រើនដែលគូភាគីវិវាទអាចជ្រើសរើសយកមកប្រើប្រាស់សម្រាប់ដោះស្រាយវិវាទរបស់ខ្លួន។ យន្តការមជ្ឈត្តការត្រូវបានបង្កើតឡើងតាមរយៈអនុសញ្ញាទីក្រុងញូវយ៉កឆ្នាំ១៩៥៨ ហើយប្រទេសកម្ពុជាបានទទួលស្គាល់អនុសញ្ញាអង្គការសហប្រជាជាតិ ចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេសនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៦០ និងប្រកាសឱ្យប្រើច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញានេះនៅ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១។ ក្រោយមក រដ្ឋសភាកម្ពុជាបានអនុម័តច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៦ ដោយផ្អែកតាមច្បាប់គំរូស្តីពីមជ្ឈត្តការពាណិជ្ជកម្មរបស់គណៈកម្មការច្បាប់ពាណិជ្ជកម្មអន្តរជាតិ នៃអង្គការសហប្រជាជាតិ។ នៅឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា បានចេញអនុក្រឹត្យលេខ១២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដោយយោងតាមអនុក្រឹត្យនេះ មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាដោយមានការឧបត្ថម្ភគាំទ្រពីក្រសួងពាណិជ្ជកម្ម។ ការបង្កើតមជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺបានឆ្លុះបញ្ចាំងអំពីការវិវត្ត

នៃប្រព័ន្ធច្បាប់នៅក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មនៅប្រទេសកម្ពុជា។ ការដោះស្រាយវិវាទដែលមានលក្ខណៈឯកជននេះបានផ្តល់ទំនុកចិត្តដល់ពាណិជ្ជករ អ្នកវិនិយោគទុន និងពន្លឿនក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា។ បន្ថែមពីនេះ ដើម្បីធានាដំណើរការប្រព្រឹត្តទៅឱ្យបានរលូន និងប្រសិទ្ធភាពក្នុងការអនុវត្តតាមរយៈយន្តការមជ្ឈត្តការ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានបង្កើតលិខិតបទដ្ឋានគតិយុត្តចំនួន ៣ (បី) មានដូចជា វិធានស្តីពីមជ្ឈត្តការ ក្រមសីលធម៌ និងបទបញ្ជាផ្ទៃក្នុង របស់ ម.ជ.ម. ដែលបានចុះផ្សាយនៅក្នុងឆ្នាំ២០២១ និងត្រូវបានអនុវត្តមកដល់ពេលបច្ចុប្បន្ន។

យើងឃើញថានាពេលបច្ចុប្បន្ន មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលជាមធ្យោបាយមួយ ក្នុងចំណោមមធ្យោបាយជាច្រើនផ្សេងទៀតនៃការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ គឺកំពុងតែទទួលបាននូវការពេញនិយមពីសំណាក់ពាណិជ្ជករ និងវិនិយោគិន ទាំងក្នុងប្រទេស និងក្រៅប្រទេស ដែលត្រូវបានគេយកមកប្រើប្រាស់ច្រើនគួរឱ្យកត់សម្គាល់ ជាពិសេសគឺនៅអំឡុងពេលបីឆ្នាំចុងក្រោយនេះ។ មិនតែប៉ុណ្ណោះ មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវបានគេស្គាល់ថាជាវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលមានវ័យចំណាស់ជាងគេ និងមានការទទួលស្គាល់ច្រើនជាងវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្សេងទៀត ថែមទាំងបានដំណើរការយ៉ាងរលូនក្នុងវិស័យពាណិជ្ជកម្ម។

បន្ថែមពីលើនេះទៀតថា មជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺជាមធ្យោបាយមួយដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយវិវាទឯកជន ថែមទាំងរក្សាបាននូវការសម្ងាត់ ចំណាយពេលតិច (ឆាប់រហ័ស) ចំណាយប្រាក់តិច (សន្សំសំចៃ និងអាចបត់បែនបានតាមការព្រមព្រៀងរបស់គូភាគីវិវាទ)។ ជារួមមក ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលគូភាគីវិវាទអាចជឿជាក់បាន និងមានការទទួលស្គាល់ពីស្ថាប័នតុលាការ គឺមានតែជ្រើសយកយន្តការមជ្ឈត្តការតែប៉ុណ្ណោះ ជាពិសេសគឺក្នុងវិស័យពាណិជ្ជកម្ម នាពេលបច្ចុប្បន្ននេះ យន្តការមួយនេះត្រូវបានប្រើប្រាស់ច្រើនក្នុងវិស័យនេះ ដែលគេតែងហៅថា "**មជ្ឈត្តការផ្នែកពាណិជ្ជកម្ម**"។ យ៉ាងណាមិញ ទោះបីជាយន្តការតាមមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មានគុណសម្បត្តិច្រើនសម្រាប់ភាគីវិវាទក្នុងវិស័យពាណិជ្ជកម្មក៏ពិតមែន ប៉ុន្តែ បញ្ហាប្រឈមផ្សេងៗនៅតែកើតមាន និងការយល់ដឹងអំពីនីតិវិធីក្នុងការដោះស្រាយវិវាទតាមយន្តការមួយនេះពុំទាន់មានលក្ខណៈទូលំទូលាយនៅឡើយ។

## ២. ចំណោទបញ្ហា

ដូចនេះ តើមុននឹងអាចចាប់ផ្តើមមជ្ឈត្តការបាន ត្រូវមានលក្ខខណ្ឌអ្វីខ្លះ? តើការបង្កើតវេទិកាមជ្ឈត្តកម្មត្រូវបានរៀបចំឡើងរបៀបណា? តើដំណើរការមជ្ឈត្តការ និងសេចក្តីសម្រេចចេញពីមជ្ឈត្តករ ដែលហៅថា

"មជ្ឈត្តវិនិច្ឆ័យ" មានដំណើរការយ៉ាងណាដែរ? តើមានបញ្ហាប្រឈមអ្វីខ្លះដែលកើតមានឡើងក្នុងការអនុវត្តនូវមជ្ឈត្តការផ្នែកពាណិជ្ជកម្ម?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវក្នុងការសរសេរសារណានេះ ធ្វើឡើងក្នុងគោលបំណងដើម្បីពង្រីកចំណេះដឹងផ្នែកច្បាប់បន្ថែមពាក់ព័ន្ធនឹងដំណើរការរៀបចំប្រព្រឹត្តទៅនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងបញ្ហាប្រឈមក្នុងការអនុវត្ត។ ដោយហេតុថា ការផ្សព្វផ្សាយអំពីយន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមានលក្ខណៈចង្អៀត ជាពិសេស គឺការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយប្រើយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះតែម្តង។ យើងឃើញថាទិដ្ឋភាពសង្គមបច្ចុប្បន្ន បុគ្គលដែលមានវិវាទនឹងគ្នាតែងជ្រើសយកប្រព័ន្ធតុលាការក្នុងការដោះស្រាយជាជាងការលើកយកទៅដោះស្រាយនៅក្រៅប្រព័ន្ធតុលាការ ដែលជាហេតុនាំឱ្យសំណុំរឿងនៅតុលាការមានការកកស្ទះកាន់តែច្រើន។ ផ្ទុយទៅវិញ ការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជាផ្លូវសម្រាប់ដោះស្រាយវិវាទឱ្យមានភាពឆាប់រហ័ស ថែមទាំងអាចយកសេចក្តីសម្រេចរបស់មជ្ឈត្តករ ឬមជ្ឈត្តវិនិច្ឆ័យទៅអនុវត្តនៅបណ្តាប្រទេសនានាដែលជាសមាជិកដែលបានចុះហត្ថលេខាលើអនុសញ្ញាទីក្រុងញូវយ៉កថែមទៀតផង។ ផ្សារភ្ជាប់ជាមួយគ្នានេះផងដែរ រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងពង្រឹងវិស័យតុលាការ ដោយបានប្រជ្រៀតចូលនូវចំណេះដឹងអំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជាពិសេសការបង្កើតនូវស្ថាប័នមួយចំនួនសម្រាប់ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ហេតុដូច្នេះ គោលបំណងនៃការស្រាវជ្រាវនេះ គឺដើម្បីពង្រឹង ក៏ដូចជាផ្សព្វផ្សាទៅលើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជាពិសេស គឺការដោះស្រាយវិវាទតាមយន្តការនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះឱ្យកាន់តែមានការយល់ដឹងបន្ថែម និងធ្វើឱ្យមានការយល់ដឹងទូលំទូលាយជាងពីមុន។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការបង្ហាញពីប្រធានបទនេះ គឺធ្វើការស្រាវជ្រាវតែការដោះស្រាយវិវាទដោយមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា និងបញ្ហាប្រឈម ដែលមានដែនកំណត់ស្ថិតនៅក្រោមវិសាលភាពនៃបទដ្ឋានគតិយុត្តរបស់កម្ពុជាតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺជាយន្តការដែលមានភាពសម្ងាត់យ៉ាងខ្លាំង ហើយការផ្សព្វផ្សាយក៏ស្ថិតក្នុងកម្រិតទាបផងដែរ ដែលជាហេតុនាំឱ្យការយល់ដឹងទៅលើប្រធានបទនេះពុំសូវ

មានភាពទូលំទូលាយនៅឡើយ។ កន្លងមក យើងឃើញថាការលើកយកប្រធានបទនេះមកបកស្រាយ ឬចងក្រងជាសៀវភៅ ឬឯកសារនានាស្ថិតក្នុងកម្រិតមធ្យម ជាក់ស្តែង យើងឃើញថា នីតិករចំនួនតិចដែលបានធ្វើការតាក់តែងឯកសារអំពីយន្តការនៃការដោះស្រាយវិវាទតាមមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ប៉ុន្តែ យើងពុំទាន់ឃើញមានការលើកយកអំពីបញ្ហាប្រឈមនៃការអនុវត្តយន្តការនេះនៅឡើយ។ ដោយមើលឃើញពីភាពកម្រនៃអត្ថបទខាងលើ ទើបយើងខ្ញុំសម្រេចចិត្តលើកយកប្រធានបទនេះមកធ្វើការស្រាវជ្រាវ ដើម្បីជាការផ្តល់ពុទ្ធិឱ្យកាន់តែយល់ដឹងបន្ថែមអំពីយន្តការនៃការដោះស្រាយវិវាទតាមមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជាពិសេស បញ្ហាប្រឈមនៃការអនុវត្តនូវយន្តការមួយនេះ។ ហេតុដូច្នេះ ការលើកយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវក៏ដូចជាចងក្រងជាសារណានេះឡើង គឺបានផ្តល់នូវសារៈសំខាន់ដល់និស្សិត និងអ្នកសិក្សាជំនាន់ក្រោយឱ្យមានការយល់ដឹងបន្ថែមពាក់ព័ន្ធនឹងយន្តការមួយនេះ ជាពិសេស និស្សិតក៏អាចយល់ដឹងអំពីភាពលំបាកដែលជាបញ្ហាប្រឈមក្នុងការអនុវត្តផងដែរ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ក្នុងការស្រាវជ្រាវរបស់យើងខ្ញុំ គឺបានប្រើប្រាស់នូវវិធីសាស្ត្រមួយចំនួនរួមមាន ការធ្វើការសិក្សាពីសិក្ខាសាលា និងការចែករំលែករបស់មជ្ឈត្តករ ក៏ដូចជាការសាកសួរអំពីបទពិសោធន៍អំពីមជ្ឈត្តករផ្ទាល់។ បន្ថែមពីលើនេះ យើងខ្ញុំក៏បានធ្វើការស្រាវជ្រាវឯកសារពីគេហទំព័រ តាមបណ្ណាល័យ និងសៀវភៅនានា ជាពិសេស វិធានស្តីពីមជ្ឈត្តការ និងក្រមសីលធម៌សម្រាប់មជ្ឈត្តករ ព្រមទាំងបទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកណាណិជ្ជកម្ម ផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធ្វើការឆ្លើយតបទៅនឹងបញ្ហាខាងលើ យើងខ្ញុំធ្វើការរៀបចំរចនាសម្ព័ន្ធនៃការស្រាវជ្រាវប្រធានបទនេះ ដែលផ្តោតទៅលើ ៣ ជំពូកធំៗ ដូចជា៖

ជំពូកទី១ ៖ ការរៀបចំ និងការប្រព្រឹត្តទៅមុនការចាប់ផ្តើមនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ជំពូកទី២ ៖ នីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ជំពូកទី៣ ៖ បញ្ហាប្រឈមក្នុងការអនុវត្តនីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

# ជំពូកទី១

# ការរៀបចំ និងការប្រព្រឹត្តទៅមុនការចាប់ផ្តើម នៃមជ្ឈត្តការផ្ដែកពាណិជ្ជកម្ម

# ជំពូកទី១
# ការរៀបចំ និងការប្រព្រឹត្តទៅមុនការចាប់ផ្តើមនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម

ដំណើរការប្រព្រឹត្តទៅនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្មកម្ពុជា បានកំណត់យ៉ាងជាក់លាក់នៅក្នុងវិធានស្តីពីមជ្ឈត្តការ របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា អំពីបែបបទនីតិវិធីនៃការដោះស្រាយវិវាទពាណិជ្ជកម្ម ដែលភាគីវិវាទបានព្រមព្រៀងគ្នាដើម្បីឱ្យមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម (ម.ជ.ម.) មានយុត្តាធិការក្នុងការដោះស្រាយវិវាទរបស់គូភាគីស្របតាមការព្រមព្រៀងគ្នា។ ចំពោះដំណើរការនៃនីតិវិធីក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈយន្តការមជ្ឈត្តការផ្ទែកពាណិជ្ជកម្មនេះ មានភាពបត់បែន ដែលអនុញ្ញាតឱ្យគូភាគីវិវាទ អាចបង្កើតនូវនីតិវិធី ឬវិធានមួយតាមគោលបំណងរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់ក្នុងការឱ្យវេទិកាមជ្ឈត្តកម្មក្នុងការស្វែងរកដំណោះស្រាយលើសំណុំរឿងជាក់លាក់មួយ។[1] ដើម្បីឱ្យមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម អាចដំណើរការប្រព្រឹត្តទៅបាន ដាច់ខាតគូភាគីវិវាទត្រូវតែមានកិច្ចព្រមព្រៀងផ្សះផ្សាជាមុនសិន ព្រោះមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម គឺជាយន្តការមួយដែលដោះស្រាយទៅលើវិវាទដែលភាគីវិវាទស្ម័គ្រចិត្ត និងព្រមព្រៀងគ្នាក្នុងការយកវិវាទផ្ទែកពាណិជ្ជកម្មនោះមកកាន់មជ្ឈត្តការដោះស្រាយប៉ុណ្ណោះ ទើបមជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម មានសមត្ថកិច្ច ឬយុត្តាធិការ ក្នុងការដោះស្រាយវិវាទរបស់គូភាគីវិវាទនោះបាន។

ក្នុងជំពូកទី១ ការរៀបចំ និងការប្រព្រឹត្តទៅមុនការចាប់ផ្តើមនៃមជ្ឈត្តការផ្ទែកពាណិជ្ជកម្មនេះ យើងនឹងធ្វើការបកស្រាយបង្ហាញទៅលើទិដ្ឋភាពជាទូទៅយើងខ្ញុំនឹងបែងចែកចេញជាបីដំណាក់កាល ដូចជា **១.១.កិច្ចព្រមព្រៀងផ្សះផ្សា ១.២. នីតិវិធីពន្លឿន** និង**១.៣. វិធានការបណ្តោះអាសន្ន**។

## ១.១.កិច្ចព្រមព្រៀងផ្សះផ្សា

កិច្ចព្រមព្រៀងផ្សះផ្សា ជាកិច្ចព្រមព្រៀងរវាងភាគីវិវាទក្នុងការធ្វើមជ្ឈត្តការវិវាទទាំងអស់ ឬវិវាទបែបណាមួយដែលកើតឡើង ឬដែលអាចកើតឡើងរវាងភាគីវិវាទនានា ដោយគោរពតាមទំនាក់ទំនងកំណត់ដោយច្បាប់ ទោះបីជាមានកិច្ចសន្យា ឬគ្មានកិច្ចសន្យាក៏ដោយ។[2] ហើយកិច្ចព្រមព្រៀងផ្សះផ្សាអាចមានចែងនៅក្នុងកិច្ចព្រមព្រៀងរបស់គូភាគីស្រាប់ ឬអាចមាននៅក្នុងកិច្ចព្រមព្រៀងដោយឡែកណាមួយ។

[1] សៀវភៅ កម្រងវិធីសាស្ត្រគន្លឹះ នីតិវិធីមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម និពន្ធដោយលោក មជ្ឈត្តការ **ហួន សុខនីម** ចុះផ្សាយក្នុងឆ្នាំ២០២១ ទំព័រទី១ ។ (ចាប់ពីពេលនេះតទៅហៅថា សៀវភៅ កម្រងវិធីសាស្ត្រគន្លឹះ នីតិវិធីមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម)។

[2] ច្បាប់ស្តីពីមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម នៃលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦ មាត្រា២ ចំណុច ឃ ។ (ចាប់ពីពេលនេះតទៅហៅថា ច្បាប់ស្តីពីមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម ឆ្នាំ២០០៦) ។

**កិច្ចព្រមព្រៀងផ្សះផ្សា** ត្រូវបានបែងចែកជា ពីរប្រភេទ៖ ខចែងស្តីពីមជ្ឈត្តការដែលបានចែងនៅក្នុងកិច្ចសន្យា និងខចែងស្តីពីមជ្ឈត្តការដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងដោយឡែក។[3] មិនតែប៉ុណ្ណោះ កិច្ចព្រមព្រៀងផ្សះផ្សា គឺជាឯកសារដំបូង ដែលផ្តល់ជាមូលដ្ឋានសម្រាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្មក្នុងការដោះស្រាយវិវាទរបស់គូភាគី ឬជាភ្លើងខៀវសម្រាប់ភាគីវិវាទដាក់នូវ **សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម** មកអគ្គលេខាធិការដ្ឋាន នៃ ម.ជ.ម. ផងដែរ។[4] នៅក្នុងកិច្ចព្រមព្រៀងផ្សះផ្សា គូភាគីអាចជ្រើសរើសវិធានសម្រាប់គ្រប់គ្រងដំណើរការមជ្ឈត្តការ ទីកន្លែងមជ្ឈត្តការ ច្បាប់គ្រប់គ្រង ភាសា និងមជ្ឈត្តករ។

### ១.១.១. ការបង្កើតកិច្ចព្រមព្រៀងផ្សះផ្សា

គូភាគីវិវាទ អាចបង្កើតកិច្ចព្រមព្រៀងផ្សះផ្សា ឱ្យមានអានុភាពគតិយុត្តពេញលេញទៅបាន ក៏ត្រូវគោរព **១.១.១.១. លក្ខខណ្ឌអានុភាព** និង**១.១.១.២. លក្ខខណ្ឌសុពលភាព** ផងដែរ។

#### ១.១.១.១. លក្ខខណ្ឌអានុភាព

ចំពោះកិច្ចព្រមព្រៀងផ្សះផ្សា ក៏ត្រូវគោរពលក្ខខណ្ឌអានុភាព ដែលច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាផងដែរ ពោលគឺត្រូវមានលក្ខខណ្ឌចាំបាច់មួយចំនួនដូចជា៖ **ក. ការព្រមព្រៀង** និង**ខ. ទម្រង់ដែលច្បាប់បានកំណត់។**

**ក. ការព្រមព្រៀង**

កិច្ចព្រមព្រៀងផ្សះផ្សា អាចបង្កើតបានតាមរយៈការព្រមព្រៀងរបស់គូភាគីវិវាទ យោងតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៣៦ កថាខណ្ឌទី១ ចែងថា កិច្ចសន្យាមានអានុភាពដោយសារសំណើ និងស្វីការត្រូវគ្នា។ ចំពោះ ការព្រមព្រៀងរបស់គូភាគីវិវាទ ក៏ជាចំណុចសំខាន់ផងដែរ សម្រាប់ពិចារណាថា គូភាគីវិវាទ ពិតជាមានឆន្ទៈពិតប្រាកដយកវិវាទរបស់ខ្លួន ដែលអាចកើតមាននាពេលអនាគតយកមកដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការតាមរយៈ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មកម្ពុជា។ ទោះបីជា គូភាគីវិវាទ ព្រមព្រៀងគ្នាដើម្បីយកវិវាទរបស់ខ្លួនមកដោះស្រាយតាម ម.ជ.ម. ក្តី ប៉ុន្តែ គូភាគីវិវាទក៏ត្រូវគោរពបែបបទទៅតាម **ខ. ទម្រង់ដែលច្បាប់បានកំណត់** ផងដែរ។

**ខ. ទម្រង់ដែលច្បាប់បានកំណត់**

កិច្ចព្រមព្រៀងផ្សះផ្សា ដាច់ខាតត្រូវធ្វើជាលាយលក្ខណ៍អក្សរ បើមិនដូច្នេះទេ កិច្ចសន្យានេះ ធ្វើឡើងមិនមានអានុភាពតាមផ្លូវច្បាប់នោះទេ។ កិច្ចព្រមព្រៀងផ្សះផ្សា ជាលាយលក្ខណ៍អក្សរ សំដៅលើកិច្ចព្រមព្រៀងដែលស្ថិតក្នុងឯកសារ ចុះហត្ថលេខាដោយភាគីវិវាទ ឬដែលស្ថិតនៅក្នុងការផ្ទេរលិខិតស្នាម ឬមធ្យោបាយទូរគមនាគមន៍តាមប្រព័ន្ធអេឡិចត្រូនិច ដែលផ្តល់កំណត់ត្រាបញ្ជាក់ពីការព្រមព្រៀងគ្នា ឬដែលស្ថិតនៅក្នុង

[3] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា៧ កថាខណ្ឌទី១

[4] វិធានស្តីពីមជ្ឈត្តការ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១ ប្រការ ៧.១. ។ (ចាប់ពីពេលនេះតទៅហៅថា វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១) ។

ការប្តូរគ្នាទៅវិញទៅមកនូវពាក្យទាមទារ ឬពាក្យដោះសាដែលក្នុងនោះ ភាគីវិវាទមួយបានទាមទារ ហើយមិនត្រូវបានបដិសេធដោយភាគីវិវាទម្ខាងទៀត។ សេចក្តីយោងក្នុងកិច្ចសន្យា និង ឯកសារមួយដែលមានប្រការស្តីពីមជ្ឈត្តការអាចក្លាយជាកិច្ចព្រមព្រៀងផ្សះផ្សាបាន ល្គឹកណាកិច្ចសន្យានោះសរសេរជាលាយលក្ខណ៍អក្សរ ហើយសេចក្តីយោងនោះគឺជាប្រការដែលក្លាយជាផ្នែកមួយនៃកិច្ចសន្យា។ [5]

ហេតុដូចនេះ កិច្ចព្រមព្រៀងផ្សះផ្សា គឺត្រូវតែធ្វើឡើយជាលាយលក្ខណ៍អក្សរ និងមានហត្ថលេខារបស់គូភាគីវិវាទទាំងអស់ដែលបានព្រមព្រៀងគ្នា ទើបមានអានុភាពតាមផ្លូវច្បាប់។

**១.១.១.២. លក្ខខណ្ឌសុពលភាព**

ទោះបីជាគូភាគី បង្កើតកិច្ចព្រមព្រៀងផ្សះផ្សា គោរពទៅតាមលក្ខខណ្ឌអានុភាព គ្រប់លក្ខខណ្ឌក៏ពិតមែន ប៉ុន្តែកិច្ចព្រមព្រៀងផ្សះផ្សានេះ អាចមានសុពលភាពពេញលេញទៅតាមផ្លូវច្បាប់ ដាច់ខាតគូភាគីវិវាទក៏ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីផងដែរ ពោលគឺចំណុចដែលត្រូវគោរពតាមមានដូចជា៖ **ក. គ្មានមូលហេតុនៃការលុបចោល** និង**ខ. កម្មវត្ថុនៃវិវាទ**។

**ក. គ្មានមូលហេតុនៃការលុបចោល**

**ក.១. សមត្ថភាពភាគី**

ភាគីដែលបង្កើតកិច្ចព្រមព្រៀងផ្សះផ្សា ត្រូវតែមានសមត្ថភាព ក្នុងការចុះកិច្ចព្រមព្រៀង បើមិនដូច្នោះទេ កិច្ចព្រមព្រៀង នឹងគ្មានសុពលភាពឡើយ។ សមត្ថភាព គឺសំដៅទៅលើសមត្ថភាពនៃការយល់ដឹងក្នុងការបង្ហាញឆន្ទៈក្នុងការចុះកិច្ចព្រមព្រៀង។ សមត្ថភាពក្នុងការបង្ហាញឆន្ទៈនេះ ក៏ជាចំណុចសំខាន់មួយដែរដោយភាគីវិវាទ ដាច់ខាតត្រូវមានសមត្ថភាព ក្នុងការចុះកិច្ចព្រមព្រៀង ដើម្បីឱ្យកិច្ចព្រមព្រៀងមានសុពលភាព។ មិនតែប៉ុណ្ណោះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានបង្ហាញដែរថាបុគ្គល ដែលអាចបង្កើតកិច្ចសន្យា ឬកិច្ចព្រមព្រៀងមួយបាន លុះណាតែបុគ្គលនោះមាននូវសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ដែលអាចយល់ដឹង និងវិនិច្ឆ័យ អំពីលទ្ធផលរបស់ខ្លួនតាមផ្លូវច្បាប់ទៅលើអ្វីដែលខ្លួនបានប្រព្រឹត្ត។[6] ទៀតសោត ច្បាប់បានកំណត់ថាកិច្ចព្រមព្រៀង ដែលបង្កើតឡើងជាមួយជនដេលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព គឺមានមូលហេតុនៃការលុបចោល មានន័យថាកិច្ចព្រមព្រៀងនោះមិនមានសុពលភាពពេញលេញនោះទេ។ ហេតុដូច្នេះ ដើម្បី

---

[5] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា៧ កថាខណ្ឌទី២

[6] ក្រមរដ្ឋប្បវេណី នៃលេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា១៤។ (ចាប់ពីពេលនេះតទៅហៅថា "ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧") ។

ធានាថា កិច្ចព្រមព្រៀងផ្សះផ្សា មានសុពលភាពពេញលេញតាមផ្លូវច្បាប់ គូភាគីវិវាទ ត្រូវមានសមត្ថភាពខាងឆន្ទៈ និងមានសមត្ថភាពក្នុងការចុះកិច្ចព្រមព្រៀងផងដែរ។

**ក.២. គ្មានវិការៈក្នុងការបង្ហាញឆន្ទៈ**

ការបង្កើតកិច្ចព្រមព្រៀងផ្សះផ្សានេះ គូភាគីវិវាទ ត្រូវតែមានឆន្ទៈពិតប្រាកដ និងគ្មានវិការៈក្នុងការបង្ហាញឆន្ទៈណាមួយក្នុងការបង្កើតកិច្ចព្រមព្រៀងផ្សះផ្សានោះឡើយ។ យោងតាមក្រមរដ្ឋប្បវេណី បង្ហាញយ៉ាងច្បាស់ថា វិការៈក្នុងការបង្ហាញឆន្ទៈ រួមមាន៖ ការភ័ន្តច្រឡំ ការឆបោក ព័ត៌មានមិនពិត ការរំលោភលើស្ថានភាព ការគម្រាមកំហែង និងអំពើកេងចំណេញហួសហេតុ។ ក្នុងករណី គូភាគីវិវាទ បង្កើតកិច្ចព្រមព្រៀងផ្សះផ្សាដោយមានវិការៈក្នុងការបង្ហាញឆន្ទៈដោយប្រការណាមួយ កិច្ចព្រមព្រៀងផ្សះផ្សានេះ នឹងត្រូវចាត់ទុកថាគ្មានសុពលភាពពេញលេញទៅតាមផ្លូវច្បាប់ ឬចាត់ទុកថាមោឃៈតាំងពីដំបូង កាលបើអ្នកបង្ហាញឆន្ទៈមានវិការៈបានលុបចោលកិច្ចព្រមព្រៀងផ្សះផ្សានេះ។[7] ក្នុងករណីនេះ បទប្បញ្ញត្តិស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវយកមកអនុវត្ត នៅពេលចាប់ផ្តើមមជ្ឈត្តការ ឬការបញ្ចប់ដំណើរការមជ្ឈត្តការ។

នៅពេលចាប់ផ្តើមមជ្ឈត្តការ ភាគីម្ខាងអាចស្នើសុំឱ្យតុលាការ បញ្ឈប់ដំណើរការមជ្ឈត្តការដោយផ្អែកលើមូលដ្ឋានថា កិច្ចព្រមព្រៀងផ្សះផ្សាត្រូវទុកជាមោឃៈ។[8]

ការបញ្ចប់ដំណើរការមជ្ឈត្តការ ភាគីម្ខាងអាចស្នើសុំឱ្យតុលាការបដិសេធទទួលស្គាល់ និងប្រតិបត្តិសេចក្តីសម្រេចរបស់មជ្ឈត្តការ ដោយផ្អែកលើមូលដ្ឋានថា កិច្ចព្រមព្រៀងផ្សះផ្សាត្រូវទុកជាមោឃៈ។[9]

**ខ. កម្មវត្ថុនៃវិវាទ**

ចំពោះកម្មវត្ថុនៃវិវាទ ភាគីត្រូវកំណត់ឱ្យបានច្បាស់ថា វិវាទដែលគូភាគី ប្រគល់ឱ្យមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដោះស្រាយគឺស្ថិតក្រោមសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្ម។ ក្នុងការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះ កម្មវត្ថុនៃវិវាទត្រូវតែទាក់ទងនឹងធុរកិច្ចផ្នែកពាណិជ្ជកម្ម និងស្ថិតក្រោមសមត្ថកិច្ចរបស់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ទើបអាចយកច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មកអនុវត្តបាន។ យ៉ាងណាមិញ យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បានឱ្យនិយមន័យពាក្យថា **"ពាណិជ្ជកម្ម"** ត្រូវបានកំណត់ឱ្យបកស្រាយទូលំទូលាយ ដើម្បីគ្របដណ្តប់លើធុរកិច្ច ដែលមានប្រភេទពាណិជ្ជកម្មទោះបីជាមានកិច្ចសន្យា ឬគ្មានកិច្ចសន្យាក៏ដោយ។ ធុរកិច្ចដែលមានប្រភេទពាណិជ្ជកម្មមានជាអាទិ៍ ៖ កិច្ចការជំនួញដើម្បី

[7] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៣៥៨ កថាខណ្ឌទី២

[8] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា៨

[9] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា៤៤

ផ្គត់ផ្គង់ ឬការផ្លាស់ប្តូរទំនិញ ឬសេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬទីភ្នាក់ងារពាណិជ្ជកម្ម ការទិញ-លក់គណនីក្រុមហ៊ុន ការជួលទីតាំង ឬសម្ភារៈវត្ថុ ការងារស្ថាបនា ការពិគ្រោះយោបល់ វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬសម្បទាន ក្រុមហ៊ុនចំរុះ និងប្រភេទផ្សេងៗទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវអាកាស ផ្លូវទឹក ផ្លូវគោក។[10] ប្រសិនបើ វិវាទដែលគូភាគី ប្រគល់ជូនមជ្ឈត្តកការផ្នែកពាណិជ្ជកម្ម មិនមែនជាវិវាទពាណិជ្ជកម្មទេ មជ្ឈត្តកការផ្នែកពាណិជ្ជកម្មមិនមានយុត្តាធិការ ក្នុងការដោះស្រាយវិវាទនោះទេ។ ហេតុដូច្នេះ មុនពេលដែលគូភាគី សម្រេចចិត្តកំណត់ ខចែងស្តីពីមជ្ឈត្តការ ឬចុះកិច្ចព្រមព្រៀងផ្សះផ្សា ត្រូវតែដឹងច្បាស់ថាសកម្មភាពដែលគូភាគីបានបង្កើតគឺជាសកម្មភាពពាណិជ្ជកម្ម។

### ១.១.២. អានុភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា

#### ១.១.២.១.យុត្តាធិការដែលមានសមត្ថកិច្ច

ក្នុងករណីដែល ភាគីវិវាទទាំងអស់បានព្រមព្រៀងគ្នាក្នុងការបង្កើតនូវកិច្ចព្រមព្រៀងផ្សះផ្សាហើយនោះ គឺមានន័យថា ភាគីវិវាទទាំងអស់មានឆន្ទៈរួមគ្នាក្នុងការបញ្ជូនវិវាទខ្លួនទៅកាន់ មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជាអ្នកមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទ។ ដូចនេះ តាមរយៈកិច្ចព្រមព្រៀងផ្សះផ្សា តុលាការពុំមានសមត្ថកិច្ចក្នុងការដោះស្រាយបណ្តឹងវិវាទនេះទេ ប្រសិនបើកិច្ចព្រមព្រៀងផ្សះផ្សាបានបំពេញនូវលក្ខខណ្ឌសុពលភាព ពោលគឺត្រូវបញ្ជូនវិវាទនេះទៅកាន់មជ្ឈត្តការដែលជាអ្នកមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទនេះ[11]យោងតាមច្បាប់ស្តីពីមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាមានសំណើពីភាគីវិវាទណាមួយក៏ដោយដំណើការរបស់វេទិកាមជ្ឈត្តកម្មអាចចាប់ផ្តើម ឬបន្តបានជាធម្មតា ហើយតុលាការត្រូវបង្វែរសមត្ថកិច្ចជូនវេទិកាមជ្ឈត្តកម្មវិញផងដែរ។ [12]វៀរលែងតែករណីដែល តុលាការរកឃើញថា កិច្ចព្រមព្រៀងផ្សះផ្សានោះត្រូវ ចាត់ទុកជាមោឃៈ ឬពុំអាចយកមកអនុវត្តបានទើបតុលាការមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទនេះ។ [13]

#### ១.១.២.២. អានុភាពនៃខចែងស្តីពីមជ្ឈត្តកម្មក្នុងកិច្ចសន្យា

ចំពោះកិច្ចព្រមព្រៀងផ្សះផ្សា ឬកិច្ចសន្យាដែលមាន ខចែងស្តីពីមជ្ឈត្តការ គឺកិច្ចព្រមព្រៀងផ្សះផ្សានោះ មានលក្ខណៈដាច់ដោយឡែកពីកិច្ចសន្យា។ ក្នុងករណីថា កិច្ចសន្យាដែលគូភាគីបង្កើតឡើង មិនមាន

---

[10] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា២ ចំណុច ឈ

[11] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា៨ កថាខណ្ឌទី១

[12] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា៨ កថាខណ្ឌទី២

[13] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦មាត្រា៧ កថាខណ្ឌទី១

សុពលភាព ឬត្រូវទុកជាមោឃៈ ដោយប្រការណាមួយក៏ដោយ ក៏កិច្ចព្រមព្រៀងផ្សះផ្សា មិនបានអស់សុពលភាព ឬមិនត្រូវបានមោឃៈឡើយ។ បន្ថែមពីនេះ វេទិកាមជ្ឈត្តកម្ម អាចសម្រេចទៅតាមសមត្ថកិច្ចរបស់ខ្លួនក្នុងនោះមានការជំទាស់នានាដែលទាក់ទិននឹងអត្ថិភាព ឬសុពលភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា។ សម្រាប់គោលដៅនេះ ខចែងស្តីពីមជ្ឈត្តការ ដែលបង្កើតបានជាផ្នែកមួយនៃកិច្ចសន្យា ត្រូវចាត់ទុកថាជាកិច្ចព្រមព្រៀងដោយឡែក ដែលមិនទាក់ទិនទៅនឹងលក្ខខណ្ឌដទៃទៀតក្នុងកិច្ចសន្យាឡើយ។[14] លើសពីនេះទៅទៀត វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៤.៣. កិច្ចសន្យា និងខចែងស្តីពីមជ្ឈត្តកម្ម បានបញ្ជាក់យ៉ាងច្បាស់ថា ៖ **សម្រាប់គោលបំណងនៃប្រការ ៣៤ (ទឡ្ហីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម) ប្រសិនបើខចែងស្តីពីមជ្ឈត្តកម្មជាផ្នែកមួយនៃកិច្ចសន្យា ខចែងស្តីពីមជ្ឈត្តកម្មនោះ ត្រូវចាត់ទុកជាការព្រមព្រៀងដោយឡែក ដែលមិនទាក់ទងនឹងលក្ខខណ្ឌ និងខចែងផ្សេងទៀតនៃកិច្ចសន្យាឡើយ។ ការសម្រេចរបស់វេទិកាមជ្ឈត្តកម្មដែលចាត់ទុកកិច្ចសន្យាថាមោឃៈ និងអសារឥតការ មិននាំឱ្យខចែងស្តីពីមជ្ឈត្តកម្មនោះបាត់សុពលភាពឡើយ។[15]**

ហេតុដូច្នេះ កិច្ចព្រមព្រៀងផ្សះផ្សា ឬខចែងស្តីពីមជ្ឈត្តការ នៅតែមានសុពលភាពជានិច្ច ទោះបីជាវេទិកាមជ្ឈត្តកម្ម ឬតុលាការ រកឃើញកិច្ចសន្យាដែលគូភាគីវិវាទបានបង្កើតមិនមានសុពលភាព ឬកិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈ និងអាសារឥតការក៏ដោយ។

## ១.២. នីតិវិធីពន្លឿន

នីតិវិធីពន្លឿន គឺជានីតិវិធីពិសេសសម្រាប់ដំណើរការនីតិវិធីមជ្ឈត្តការឱ្យបានលឿន និងមានភាពឆាប់រហ័ស។ លក្ខណៈពិសេសនេះ ត្រូវបានបញ្ចូលនៅក្នុងវិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ផងដែរ។ ផ្អែកតាមវិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ គូភាគីវិវាទអាចស្នើសុំដំណើរការនីតិវិធីពន្លឿនដើម្បីឱ្យភាគីវិវាទចំណាយពេលវេលា និងប្រាក់កាស តិចជាងនីតិវិធីធម្មតា ជាពិសេសចំពោះវិវាទដែលមានទំហំទឹកប្រាក់តិច។

### ១.២.១. ការស្នើសុំដំណើរការនីតិវិធីពន្លឿន

នៅមុនពេលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត ភាគីវិវាទអាចដាក់សំណើសុំទៅអគ្គលេខាធិការដ្ឋានឱ្យអនុវត្តដំណើរការមជ្ឈត្តការតាមដំណើរការនីតិវិធីពន្លឿន ក្នុងករណីកាលៈទេសៈណាមួយដូចខាងក្រោម៖

១. តម្លៃកម្មវត្ថុនៃវិវាទមានតម្លៃមិនលើស ៣ លាន ដុល្លារអាមេរិក ដោយ រាប់បញ្ចូលសរុបទាំងអស់តម្លៃកម្មវត្ថុនៃការទាមទារ បណ្តឹងតប និងដោះសាតាមការកាត់កងនានា

២. គូភាគីវិវាទបានព្រមព្រៀងយកនីតិវិធីពន្លឿន ឬ

[14] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា២៤ ចំណុច១

[15] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ៣៤.៣.

៣. ក្នុងករណីពិសេសបន្ទាន់ខ្លាំង។

ផ្អែកតាមវិធាននេះ ភាគីណាមួយអាចស្នើសុំទៅអគ្គលេខាធិការដ្ឋាន របស់ ម.ជ.ម. ដើម្បីឱ្យដំណើរការមជ្ឈត្តការនៅក្នុងសំណុំរឿងរបស់ខ្លួន តាមដំណើរការនីតិវិធីពន្លឿន នៅមុនពេលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើតតែប៉ុណ្ណោះ។ ភាគីស្នើសុំនោះត្រូវបង្ហាញ នូវមូលហេតុណាមួយ ដូចជា តម្លៃកម្មវត្ថុនៃវិវាទតិចជាង ឬស្មើ ៣ (បី) លានដុល្លារអាមេរិក ឬភាគីវិវាទបានព្រមព្រៀងជ្រើសរើសយកនីតិវិធីពន្លឿន ឬក្នុងករណីពិសេសបន្ទាន់ខ្លាំង។[16]

ចំពោះវិវាទដែលមានកម្មវត្ថុនៃវិវាទលើសពី ៣ (បី) លានដុល្លារអាមេរិក ភាគីវិវាទអាចដំណើរការមជ្ឈត្តការតាមនីតិវិធីពន្លឿនបាន ប្រសិនបើគូភាគីវិវាទព្រមព្រៀងជ្រើសរើសយកនីតិវិធីពន្លឿន ឬភាគីស្នើសុំអាចបង្ហាញនូវស្ថានភាពពិសេសបន្ទាន់ខ្លាំង។ ករណីពិសេសបន្ទាន់ខ្លាំងនេះ មិនមានកំណត់ជាក់លាក់នៅក្នុងវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នោះទេ។ ក្នុងករណីនេះ គូភាគីត្រូវបង្ហាញនូវស្ថានភាពពិសេសបន្ទាន់ខ្លាំង ទៅខាងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដើម្បីពិចារណាលើកាលៈទេសៈ ស្ថានភាពពិសេសបន្ទាន់ខ្លាំងនេះ។

### ១.២.២. ការដំណើរការនីតិវិធីពន្លឿន

សំណើសុំអនុវត្តដំណើរការនីតិវិធីពន្លឿន នឹងត្រូវសម្រេចដោយគណៈកម្មាធិការតែងតាំង និងនីតិវិធីបន្ទាប់ពីបានពិចារណាលើយោបល់របស់គូភាគីវិវាទ និងបានសំណើសុំអនុវត្តដំណើរការនីតិវិធីពន្លឿនពិនិត្យលើកាលៈទេសៈរបស់សំណុំរឿងថានឹងត្រូវសម្រេច ដោយគណៈកម្មាធិការតើត្រូវអនុវត្តដំណើរការមជ្ឈត្តការស្របតាមដំណើរការនីតិវិធីពន្លឿនដែរ ឬ។

ប្រសិនបើគណៈកម្មាធិការតែងតាំង និងនីតិវិធីយល់ស្របតាមសំណើឱ្យអនុវត្តដំណើរ ការនីតិវិធីពន្លឿននេះ នោះនីតិវិធីខាងក្រោមនឹងត្រូវអនុវត្ត៖

ក. អគ្គលេខាធិការដ្ឋាន អាចកែប្រែពេលវេលាកំណត់ណាមួយក្រោម វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១

ខ. សំណុំរឿងត្រូវបញ្ជូនទៅវេទិកាមជ្ឈត្តកម្ម នៃមជ្ឈត្តករ ១ (មួយ) រូប លើក លែងតែកិច្ចសន្យាមជ្ឈត្តកម្មកំណត់យកវេទិកាមជ្ឈត្តកម្ម នៃមជ្ឈត្តករ ៣ (បី) រូប។ អគ្គលេខាធិការដ្ឋាន នឹងស្នើឱ្យគូភាគីវិវាទព្រមព្រៀងបញ្ជូនសំណុំរឿងទៅវេទិកាមជ្ឈត្តកម្ម នៃមជ្ឈត្តករ ១ (មួយ) រូប។ ប្រសិនបើគូភាគីមិនមានការព្រមព្រៀង នោះសំណុំរឿងនេះនឹងត្រូវបញ្ជូនទៅវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ៣ (បី) រូបវិញ។

[16] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ៩.១.

គ. បន្ទាប់ពីពិភាក្សាជាមួយគូភាគី វេទិកាមជ្ឈត្តកម្មអាចសម្រេចថាវិវាទនោះត្រូវសម្រេចដោយផ្អែកលើតែឯកសារ ឬទាមទារឱ្យមានសវនាការសម្រាប់ការសាកសួរសាក្សី និងអ្នកជំនាញ ក៏ដូចជាការទាញហេតុផលផ្ទាល់មាត់។

ឃ. មជ្ឈត្តវិនិច្ឆ័យស្ថាពរ ត្រូវចេញក្នុងអំឡុងពេល ២៧០ (ពីររយចិតសិប) ថ្ងៃប្រតិទិន គិតចាប់ពីថ្ងៃដែលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត លើកលែងតែកាលៈទេសៈពិសេស ដែលគណៈកម្មាធិការតែងតាំង និងនីតិវិធី ពន្យារពេលវេលាកំណត់សម្រាប់ការចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរនោះ។

#### ១.២.៣. ការបញ្ឈប់នីតិវិធីពន្លឿន

ភាគីវិវាទណាមួយ អាចស្នើសុំទៅកាន់វេទិកាមជ្ឈត្តកម្មឱ្យដំណើរការមជ្ឈត្តការលែងប្រព្រឹត្តទៅស្របទៅតាមនីតិវិធីពន្លឿន។ ក្នុងករណីនេះ វេទិកាមជ្ឈត្តកម្មត្រូវផ្តល់ឱកាសដល់គូភាគីវិវាទបញ្ចេញមតិរបស់ខ្លួន ព្រមទាំងពិនិត្យព័ត៌មានបន្ថែមដែលអាចមាននៅពេលបន្ទាប់ ហើយពិភាក្សាជាមួយគណកម្មាធិការតែងតាំង និងនីតិវិធី មុននឹងធ្វើការសម្រេចទៅលើសំណើសុំបញ្ឈប់នីតិវិធីពន្លឿននោះ។ ប្រសិនបើវេទិកាមជ្ឈត្តកម្មឯកភាពទៅលើសំណើសុំបញ្ឈប់នីតិវិធីពន្លឿន នោះវេទិកាមជ្ឈត្តកម្មត្រូវបន្តដំណើរការតាមនីតិវិធីមជ្ឈត្តការធម្មតាបន្តទៀត។[17]

### ១.៣. វិធានការបណ្តោះអាសន្ន

តាមសំណើរបស់ភាគីវិវាទណាមួយ វេទិកាមជ្ឈត្តកម្មអាចចាត់វិធានការបណ្តោះអាសន្នតាមរយៈការចេញមជ្ឈត្តវិនិច្ឆ័យដែលមានមូលហេតុ ឬសេចក្តីបង្គាប់នៅពេលណាមួយមុនពេលចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ។

#### ១.៣.១. គោលបំណងនៃវិធានការបណ្តោះអាសន្ន

វិធានការបណ្តោះអាសន្នមានលក្ខណៈជាវិធានការដែលចាំបាច់ និងបន្ទាន់ដែលមិនត្រូវប៉ះពាល់ដល់សេចក្តីសម្រេចស្ថាពររបស់វេទិកាមជ្ឈត្តកម្មចំពោះអង្គសេចក្តីនៃសំណុំរឿងឡើយ។ ជាធម្មតានៅក្នុងអំឡុងពេលដោះស្រាយវិវាទ ភាគីអាចនឹងចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនមុនពេល នីតិវិធីដោះស្រាយវិវាទចប់ជាស្ថាពរ ដែលវិធានការបណ្តោះអាសន្នរួមមានជាអាទិ៍ នូវសេចក្តីបង្គាប់នានាដូចខាងក្រោម៖

(ក) ដើម្បីថែរក្សា និងស្តារស្ថានភាពឡើងវិញក្នុងពេលដែលវិវាទមិនទាន់ត្រូវបានដោះស្រាយ

(ខ) ដើម្បីចំណាត់ការសកម្មភាពក្នុងគោលបំណងរារាំង ឬទប់ស្កាត់ការធ្វើសកម្មភាព ដែលអាចបង្កឱ្យមានការខូចខាតបច្ចុប្បន្ន ឬបន្ទាន់ ឬសេចក្តីលម្មៀងចំពោះដំណើរការមជ្ឈត្តការ

[17] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ៩.៤.

(គ) ដើម្បីផ្ដល់មធ្យោបាយក្នុងការថែរក្សាទ្រព្យសម្បត្តិដែលអាចទាក់ទងនឹង ការបំពេញតាមមជ្ឈត្តវិនិច្ឆ័យបន្ទាប់ ឬ

(ឃ) ដើម្បីរក្សាទុកភស្តុតាងដែលអាចពាក់ព័ន្ធ និងដែលមានសារៈសំខាន់សម្រាប់ការដោះស្រាយវិវាទ។

### ១.៣.២. សំណើសុំវិធានការបណ្ដោះអាសន្ន

មុនពេលការបង្កើតវេទិកាមជ្ឈត្តកម្ម ភាគីវិវាទដែលមានបំណងស្នើសុំវិធានការបណ្ដោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ អាចដាក់សំណើសុំវិធានការបណ្ដោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់នោះទៅអគ្គលេខាធិដ្ឋាន នៅពេលដាក់ ឬក្រោយពេលដាក់សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម។ ភាគីវិវាទត្រូវបញ្ជូនសំណៅចម្លងនៃសំណើនោះមួយច្បាប់ទៅភាគីផ្សេងទៀតទាំងអស់ ក្នុងពេលដំណាលគ្នាពេលដែលដាក់សំណើសុំវិធានការបណ្ដោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់។ សំណើសុំវិធានការបណ្ដោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ត្រូវមានព័ត៌មាន ដូចខាងក្រោម៖

(ក) លក្ខណៈនៃវិធានការដែលបានស្នើ

(ខ) មូលហេតុដែលភាគីវិវាទដែលស្នើសុំ មានសិទ្ធិទទួលបានវិធានការនោះ និង

(គ) សេចក្ដីថ្លែងដែលបញ្ជាក់ថា ភាគីផ្សេងទៀតទាំងអស់បានទទួលសំណៅចម្លងនៃសំណើសុំវិធានការបណ្ដោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ ឬបើគ្មានទេ សេចក្ដីថ្លែងពិពណ៌នាអំពីចំណាត់ការដែលបានធ្វើរួចដោយសុចរិត និងស្មោះត្រង់ដើម្បីប្រគល់សំណៅចម្លងនៃសំណើ ឬសេចក្ដីជូនដំណឹងទៅភាគីវិវាទផ្សេងទៀតទាំងអស់។[18]

រាល់សំណើសុំវិធានការបណ្ដោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវការបង់កម្រៃសេវានៃការស្នើសុំវិធានការបណ្ដោះអាសន្នចេញ ដោយមជ្ឈត្តករបន្ទាន់រួមមាន៖ កម្រៃសេវាស្នើសុំ និងកម្រៃសេវាមជ្ឈត្តករបន្ទាន់ និងការចំណាយផ្សេងៗ សម្រាប់ដំណើរការនីតិវិធីដោយយោងតាមតារាងកម្រៃសេវា របស់ ម.ជ.ម.។ ក្នុងកាលៈទេសៈពិសេស អគ្គលេខាធិការដ្ឋានអាចបង្កើនកម្រៃសេវា នៃការស្នើសុំវិធានការបណ្ដោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ពីភាគីវិវាទដែល ធ្វើការដាក់សំណើ។ ប្រសិនបើកម្រៃសេវាបន្ថែមមិនត្រូវបានបង់តាមកាលកំណត់ដោយអគ្គលេខាធិការដ្ឋានទេ សំណើនោះត្រូវចាត់ទុកថាបានដក។[19]

[18] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ១០.

[19] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ១១.

### ១.៣.៣. ការចេញវិធានការបណ្ដោះអាសន្ន

ផទិកាមជ្ឈត្តកម្មត្រូវផ្ដល់វិធានការបណ្ដោះអាសន្នតាមការស្នើសុំ តែក្នុងករណីដែលផទិកាមជ្ឈត្តកម្មយល់ថាវិធានការបណ្ដោះអាសន្ននោះត្រូវការជាចាំបាច់ និងបន្ទាន់។ ប្រសិនបើផទិកាមជ្ឈត្តកម្មកំណត់ថាបញ្ហានោះមិនចាំបាច់ និងបន្ទាន់ដែលត្រូវសម្រេចដោយវិធានការបណ្ដោះអាសន្នទេនោះ ផទិកាមជ្ឈត្តកម្មត្រូវបដិសេធសំណើនោះទាំងស្រុង ឬដោយផ្នែកហើយផទិកាមជ្ឈត្តកម្មអាចកំណត់ថាបញ្ហានោះត្រូវសម្រេចនៅក្នុងមជ្ឈត្តកម្មលើអង្គសេចក្ដី។

ផទិកាមជ្ឈត្តកម្មអាចចាត់ទុកសំណើសុំវិធានការបណ្ដោះអាសន្នថាមានភាពចាំបាច់ និងបន្ទាន់ប្រសិនបើភាគីវិវាទដែលស្នើសុំវិធានការបណ្ដោះអាសន្នអាច បង្ហាញថា៖

(ក) ការខូចខាតដែលមិនអាចត្រូវបានជួសជុលដោយសំណងក្នុងមជ្ឈត្តវិនិច្ឆ័យទំនងជានឹងកើតមានឡើង ប្រសិនបើវិធានការបណ្ដោះអាសន្នមិនត្រូវបានចាត់ឡើង ហើយការខូចខាតនោះមានលក្ខណៈធ្ងន់ធ្ងរជាងការខូចខាតរបស់ ភាគីវិវាទម្ខាងទៀតដែលអាចទទួលរងដោយសារវិធានការបណ្ដោះអាសន្ន ប្រសិនបើវិធានការបណ្ដោះអាសន្ននោះត្រូវបានផ្ដល់ឱ្យ និង

(ខ) មានលទ្ធភាពសមហេតុសមផលដែលភាគីស្នើសុំនឹងឈ្នះលើអង្គសេចក្ដីនៃ ការទាមទារ។ ការកំណត់អំពីលទ្ធភាពនេះមិនប៉ះពាល់ដល់ឆន្ទានុសិទ្ធិរបស់ ផទិកាមជ្ឈត្តកម្មក្នុងការធ្វើសេចក្ដីសម្រេចណាមួយនាពេលបន្ទាប់ឡើយ។[20]

ដើម្បីចេញវិធានការបណ្ដោះអាសន្ន ផទិកាមជ្ឈត្តកម្មអាចតម្រូវថាការចេញវិធានបណ្ដោះអាសន្នត្រូវមានការធានាសមស្របណាមួយ ដែលផ្ដល់ដោយភាគីវិវាទដែលបានស្នើ ដើម្បីធានាសោហ៊ុយចំណាយ ឬការខូចខាតនានាដែលទទួលរងដោយភាគីវិវាទម្ខាងទៀតដោយសារ វិធានការបណ្ដោះអាសន្ន ដែលចេញដោយផទិកាមជ្ឈត្តកម្ម។

ភាគីវិវាទដែលស្នើសុំវិធានការបណ្ដោះអាសន្ន អាចត្រូវទទួលខុសត្រូវចំពោះសោហ៊ុយ ចំណាយ និងការខូចខាត ដែលកើតចេញពីវិធានការបណ្ដោះអាសន្ន ទៅភាគីម្ខាងទៀត ប្រសិនបើនាពេលក្រោយមកផទិកាមជ្ឈត្តកម្មយល់ឃើញថា នៅក្នុងកាលៈទេសៈជាទូទៅ វិធានការបណ្ដោះអាសន្នមិនគួរត្រូវបានផ្ដល់ឱ្យនោះឡើយ។ ផទិកាមជ្ឈត្តកម្ម អាចសម្រេចឱ្យសងសោហ៊ុយចំណាយ និងការខូចខាតទាំងនោះ នៅក្នុងពេលណាមួយនៃដំណើរការមជ្ឈត្តការ។

[20] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៤៣.៦.

# ជំពូកទី២
# នីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

# ជំពូកទី២
# នីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

បន្ទាប់ពីបានស្វែងយល់អំពីនីតិវិធីក្នុងការអនុវត្ត មុនពេលចាប់ផ្តើមដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្មរួចមក នៅក្នុងជំពូកទី២ នេះ យើងខ្ញុំនឹងលើកឡើងអំពីចំណុចសំខាន់ដែលជានីតិវិធីអំពីនីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលនឹងចាប់ផ្តើមឡើងតាមរយៈការដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញពីភាគីប្តឹងទាមទារ។ ក្រោយពីនេះគូភាគី ឬគណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវតែងតាំងមជ្ឈត្តករដើម្បីដឹកនាំនីតិវិធីនៃវេទិកាមជ្ឈត្តកម្ម ហើយគូភាគីត្រូវកំណត់អំពីរបៀបដំណើរការសវនាការ ដែលហៅថាការប្រជុំបឋម ឬការប្រជុំត្រៀម។ ក្រោយពីបញ្ចប់ ការប្រជុំបឋម ឬការប្រជុំត្រៀម វេទិកាមជ្ឈត្តកម្មនឹងចេញសេចក្តីបង្គាប់នីតិវិធី ដែលជាការកំណត់កាលបរិច្ឆេទច្បាស់លាស់ អំពីនីតិវិធីលម្អិតសម្រាប់នីតិវិធីនីមួយៗនៃសំណុំរឿងមជ្ឈត្តការ។ បន្ថែមពីនេះ ក្នុងសវនាការនៃវេទិកាមជ្ឈត្តកម្ម នឹងត្រូវចាប់ផ្តើមឡើងរហូតបញ្ចប់ដោយការចេញសេចក្តីសម្រេចរបស់មជ្ឈត្តករដែលហៅថាមជ្ឈត្តវិនិច្ឆ័យ។ ហេតុដូច្នេះ នៅក្នុងជំពូកទី២ នេះនឹងធ្វើការបកស្រាយទៅលើចំណុចសំខាន់ៗមានដូចជា **២.១. ការចាប់ផ្តើមដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ២.២. នីតិវិធីជ្រើសរើសមជ្ឈត្តករ ២.៣. ការប្រជុំបឋម ឬការប្រជុំត្រៀម ២.៤. សេចក្តីបង្គាប់នីតិវិធីរបស់វេទិកាមជ្ឈត្តកម្ម ២.៥. សវនាការនៃវេទិកាមជ្ឈត្តកម្ម និង២.៦. ការចេញមជ្ឈត្តវិនិច្ឆ័យ និងបណ្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ។**

## ២.១. ការចាប់ផ្តើមដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ដំណើរការមជ្ឈត្តការត្រូវបានចាប់ផ្តើម ដោយការដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញរបស់ភាគីប្តឹងទាមទារ។ ភាគីប្តឹងទាមទារ ត្រូវបញ្ជូនសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មមកអគ្គលេខាធិការដ្ឋាន ម.ជ.ម. ដោយត្រូវរៀបរាប់អំពីចំណុចឱ្យបានច្បាស់លាស់ដូចដែលយើងខ្ញុំបានសរសេរក្នុង**ចំណុច ២.១.១. ការដាក់សេចក្តីជូនដំណឹងរបស់ភាគីប្តឹងទាមទារ** នៃសារណានេះ។

សេចក្តីជូនដំណឹងនេះ គឺជាការជូនដំណឹងទៅភាគីម្ខាងទៀតដែលជាភាគីឆ្លើយតប អំពីវិវាទដែលកើតមានឡើងដោយភាគីប្តឹងទាមទារបានដាក់ពាក្យប្តឹង។ នៅពេលខ្លឹមសារនៃសេចក្តីជូនដំណឹងត្រូវបានពិនិត្យថាត្រឹមត្រូវ និងគ្រប់គ្រាន់ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នឹងធ្វើការជូនដំណឹងដល់ភាគីវិវាទទាំងអស់អំពីការទទួលបាននូវសេចក្តីជូនដំណឹងនេះ ហើយជាទូទៅវេទិកាមជ្ឈត្តកម្ម ត្រូវបានចាប់ផ្តើមនៅពេលដែលភាគីប្តឹងទាមទារបានដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញទៅកាន់អគ្គលេខាធិការដ្ឋាន ម.ជ.ម. ។

ហេតុដូច្នេះ នៅក្នុង **ចំណុច ២.១. ការចាប់ផ្តើមដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម** នេះយើងខ្ញុំនឹងធ្វើការបកស្រាយទៅលើចំណុចសំខាន់ៗ ដូចជា **២.១.១. ការដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ២.១.២. នីតិវិធីជ្រើសរើសមជ្ឈត្តករ ២.១.៣. ការប្រជុំបឋម ឬការប្រជុំត្រៀម** និង**២.១.៤. សេចក្តីបង្គាប់នីតិវិធីរបស់វេទិកាមជ្ឈត្តកម្ម**។

### ២.១.១.ការដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម

ការដាក់សេចក្តីជូនដំណឹងរបស់គូភាគីវិវាទ ចំពោះគូវិវាទដែលបានមានបំណងដាក់វិវាទរបស់ខ្លួនដើម្បីដោះស្រាយតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺភាគីប្តឹងទាមទារត្រូវបញ្ជូនសេចក្តីជូនដំណឹងរបស់ខ្លួនទៅអគ្គលេខាធិការដ្ឋាននៃ ម.ជ.ម. នូវសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម។ ដោយឡែក ចំពោះភាគីវិវាទម្ខាងទៀតដែលត្រូវបានគេហៅថា ភាគីឆ្លើយតប ត្រូវឆ្លើយតបក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃនៃប្រតិទិន បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម។[21] អាស្រ័យហេតុនេះ ដើម្បីអាចឱ្យវិវាទរបស់ខ្លួនអាចដំណើរការតាមមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានជាដំបូងភាគីវិវាទត្រូវដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ដែលនឹងមានការកំណត់នៅក្នុង **២.១.១.១. ការដាក់សេចក្តីជូនដំណឹងរបស់ភាគីប្តឹងទាមទារ** និង**២.១.១.២. ការដាក់សេចក្តីជូនដំណឹងតបរបស់ភាគីឆ្លើយតប**។

#### ២.១.១.១. ការដាក់សេចក្តីជូនដំណឹងរបស់ភាគីប្តឹងទាមទារ

នៅក្នុងដំណើរការនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវបានចាត់ទុកថាចាប់ផ្តើមកាលបរិច្ឆេទ នៃការដាក់សំណុំឯកសារជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញ ដោយភាគីបណ្តឹងទាមទារបញ្ជូនសេចក្តីជូនដំណឹងអំពីវេទិកាមជ្ឈត្តកម្មទៅកាន់អគ្គលេខាធិការដ្ឋាន នៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.)។ នៅគ្រប់ករណីទាំងអស់ ភាគីវិវាទត្រូវជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញ ដោយមានបង្ហាញអំពីព័ត៌មានច្បាស់លាស់មានដូចជា៖

(ក) សេចក្តីថ្លែងដែលបញ្ជាក់ថា វិវាទត្រូវបានដាក់ឱ្យដោះស្រាយតាមមជ្ឈត្តកម្ម

(ខ) ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ លេខទូរសារ សារអេឡិចត្រូនិច និងអាសយដ្ឋាននៃមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិច ផ្សេងទៀត ប្រសិនបើមានព័ត៌មានទាំងនេះរបស់គូភាគីវិវាទ និងរបស់អ្នកតំណាងរបស់គូភាគីវិវាទ ប្រសិនបើមាន

[21] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៧.

(គ) សញ្ជាតិ ឬប្រសិនបើតម្រូវព័ត៌មានអំពីអត្តសញ្ញាណក្រុមហ៊ុនរបស់គូភាគីវិវាទប្រសិនបើស្គាល់

(ឃ) សេចក្តីយោងនៃខចែងស្តីពីមជ្ឈត្តកម្ម ឬកិច្ចសន្យាមជ្ឈត្តកម្មដោយឡែកដែលយកមកប្រើ និងភ្ជាប់សំណៅចម្លងនៃខចែងស្តីពីមជ្ឈត្តកម្ម ឬកិច្ចសន្យាមជ្ឈត្តកម្មដោយឡែកនោះ

(ង) សេចក្តីយោងនៃកិច្ចសន្យាឬទំនាក់ទំនងផ្សេងៗដែលកើតចេញពី ឬដែលទាក់ទងនឹងវិវាទ និងភ្ជាប់សំណៅចម្លងនៃកិច្ចសន្យាទាំងនោះ ប្រសិនបើអាច

(ច) សេចក្តីថ្លែងសង្ខេប ដែលពិពណ៌នាអំពីលក្ខណៈ និងកាលៈទេសៈនៃវិវាទការទាមទារ ឬការសង្គ្រោះដែលទាមទារ និងប្រសិនបើអាច ភ្ជាប់តម្លៃបឋមនៃការទាមទារ ដែលភាគីប្តឹងទាមទារមានបំណងដាក់ស្នើ

(ឆ) ចំនួនមជ្ឈត្តករដែលបានព្រមព្រៀង ឬនៅក្នុងករណីដែលមិនមានការព្រមព្រៀងទេនោះ ចំនួនមជ្ឈត្តករដែលស្នើសុំដែលត្រូវមានចំនួន ១ (មួយ) រូប ឬ៣ (បី) រូប និង

(ជ) សេចក្តីថ្លែង ឬសំណើបន្ថែមផ្សេងៗ ពាក់ព័ន្ធនឹងដំណើរការមជ្ឈត្តការ រួមបញ្ចូលទាំងច្បាប់ដែលត្រូវអនុវត្ត ភាសាសម្រាប់ដំណើរការមជ្ឈត្តការ និងលក្ខណសម្បត្តិនិងសញ្ជាតិរបស់មជ្ឈត្តករដែលបានព្រមព្រៀង ឬដែលចង់បាន ប្រសិនបើមាន។

ដោយមិនគិតអំពីភាសាដែលត្រូវប្រើក្នុងដំណើរការមជ្ឈត្តការ ស្របតាមប្រការ៣៣.១ (ភាសានៃដំណើរការមជ្ឈត្តការ) សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មត្រូវធ្វើជា ភាសាសម្រាប់មជ្ឈត្តកម្ម និងបកប្រែជាភាសាខ្មែរ ឬភាសាអង់គ្លេស។ សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មត្រូវមានភ្ជាប់មកជាមួយនូវការបង់ប្រាក់សម្រាប់ កម្រៃសេវាចុះបញ្ជីសំណុំរឿងដែលអាចជា មូលប្បទានបត្រ ឬការផ្ទេរចូលគណនីធនាគារកំណត់ណាមួយរបស់ ម.ជ.ម.។[22]

គោលការណ៍ខាងលើនេះ គឺមានគោលបំណងទាញយកនូវព័ត៌មានដែលគ្រប់គ្រាន់ពេញលក្ខណៈដើម្បីអាចឱ្យភាគីឆ្លើយតប ធ្វើការឆ្លើយតបទៅនឹងការទាមទារ របស់ភាគីប្តឹងទាមទារទៅតាមគ្រប់ចំណុចជាការតម្រូវដែលគេចង់បាន ព្រមទាំងបំពេញមុខងារ និងតួនាទីរបស់ខ្លួនស្របតាមវិធាននានា ក្នុងការធានានូវការគោរពតាមអនុលោមភាពនៅក្នុងការបង្កើតឡើងវេទិកាមជ្ឈត្តកម្ម និងការកំណត់សកម្មភាពចាំបាច់ទាំងឡាយសម្រាប់ដំណើរការមជ្ឈត្តការលើសំណុំរឿងនោះ។[23]

[22] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៧.១.

[23] សៀវភៅ កម្រងវិធីសាស្ត្រគន្លឹះនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០២១ ទំព័រទី១៩

ការដាក់សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម ជាទម្រង់សង្ខេបដែលមានខ្លឹមសាររៀបរាប់ត្រឹមការតម្រូវអប្បបរមារបស់វិធានស្ដីពីមជ្ឈត្តការដោយមិនចាំបាច់ផ្ដល់នូវខ្លឹមសារ ឬភ្ជាប់ភស្តុតាងច្រើនលើកពីអ្វីដែលវិធានបានតម្រូវជាក់លាក់នោះ។ ម៉្យាងទៀត ការដាក់បញ្ជូនសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម ជាទម្រង់ពិស្ដារលម្អិតដែលមានខ្លឹមសារគ្រប់ជ្រុងជ្រោយដោយមានភ្ជាប់ទាំងភស្តុតាង ឬវត្ថុតាងពាក់ព័ន្ធ គឺនឹងត្រូវធ្វើជាសេចក្ដីថ្លែងការណ៍ពេញលេញអំពីសំណុំរឿងនៅពេលដំណើរការវេទិកាមជ្ឈត្តកម្ម។

ផ្ទុយទៅវិញ ចំពោះការរៀបចំតាក់តែងសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មតាមទម្រង់វែងដែលមានលក្ខណៈខ្លឹមសារលម្អិតពិស្ដារ អាចជាករណីមួយចាំបាច់សម្រាប់ការកាត់បន្ថយចំនួនជុំនៃការដាក់ជូនសំណុំឯកសារ និងលិខិតស្នាមពាក់ព័ន្ធដែលនឹងត្រូវដាក់បន្ថែមនាពេលក្រោយៗមកទៀត។ នៅក្នុងករណីនេះ វាគឺជាកត្តាជំរុញឱ្យដំណើរការនៃនីតិវិធីមជ្ឈត្តការអាចពន្លឿនទៅមុខបានកាន់តែឆាប់រហ័ស។ លើសពីនេះទៅទៀត ចំពោះការផ្ដល់ព័ត៌មានបន្ថែមក៏អាចបង្កើតនូវផលប៉ះពាល់ ទៅលើសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មចំពោះភាគីឆ្លើយតបផងដែរ។

ព័ត៌មានពិស្ដារលម្អិតបន្ថែមអាចនឹងធ្វើឱ្យគូភាគីវិវាទ និងវេទិកាមជ្ឈត្តកម្មមានឱកាសក្នុងការផ្ដោតការយកចិត្តទុកដាក់លើចំណុចវិវាទសំខាន់ៗ ក្នុងសំណុំរឿងបានកាន់តែឆាប់រហ័សតាមដែលអាចធ្វើទៅបាន ជាហេតុនាំឱ្យគេអាចសម្រួលបានកាន់តែឆាប់រហ័សក្នុងការរៀបចំសេចក្ដីថ្លែងអំពីលក្ខខណ្ឌយោង និងក៏មានភាពឆាប់រហ័សក្នុងការចាប់ផ្ដើមរៀបចំការប្រជុំសន្និសីទអំពីការគ្រប់គ្រងចាត់ចែងសំណុំរឿងផងដែរ។

ក្នុងករណីភាគីវិវាទជាអ្នកប្ដឹងទាមទារបានដាក់សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម ប៉ុន្តែមានលក្ខណៈមិនពេញលេញអគ្គលេខាធិការដ្ឋាននៃ ម.ជ.ម. អាចស្នើសុំឱ្យភាគីប្ដឹងទាមទារបំពេញបន្ថែមនូវចំណុចខ្វះខាតទាំងនោះក្នុងអំឡុងពេលសមស្របណាមួយដែលកំណត់ដោយអគ្គលេខាធិការដ្ឋាន។ នៅពេលដែលសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មត្រូវបានបំពេញចប់សព្វគ្រប់ហើយ សេចក្ដីជូនដំណឹងនោះ ត្រូវបានចាត់ទុកថាបានដាក់ក្នុងថ្ងៃដែលអគ្គលេខាធិការដ្ឋានបានទទួលនូវសំណៅឯកសារដំបូង។ អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅភាគីវិវាទបន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងពេញលេញអំពីមជ្ឈត្តកម្ម។[24] ប៉ុន្តែ ប្រសិនបើភាគីប្ដឹងទាមទារខកខានមិនបានដាក់សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញ អគ្គលេខាធិការដ្ឋានត្រូវបិទសំណុំរឿងនោះ ដោយមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ របស់ភាគីប្ដឹងទាមទារក្នុងការដាក់ពាក្យបណ្ដឹងទាមទារដដែលនាថ្ងៃក្រោយ តាមរយៈសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មផ្សេងឡើយ។

[24] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៧.៥.

### ២.១.១.២. ការដាក់សេចក្ដីជូនដំណឹងអំពីការឆ្លើយតបរបស់ភាគីឆ្លើយតប

ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មរួចមក ភាគីឆ្លើយតប ត្រូវដាក់បញ្ជូនសេចក្ដីជូនដំណឹងអំពីការឆ្លើយតបទៅអគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម. ដោយមានភ្ជាប់នូវព័ត៌មានច្បាស់លាស់ដែលត្រូវមានព័ត៌មានដូចខាងក្រោមៈ

(ក) ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ លេខទូរសារ អាសយដ្ឋានសារ អេឡិចត្រូនិច និង អាសយដ្ឋាននៃមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀត របស់ភាគីឆ្លើយតបនិង អ្នកតំណាងរបស់ខ្លួនប្រសិនបើមាន និងប្រសិនបើព័ត៌មានទាំងនេះខុសពីព័ត៌មានដែល មានក្នុងសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម

(ខ) សញ្ជាតិ ឬប្រសិនបើតម្រូវអត្តសញ្ញាណក្រុមហ៊ុនរបស់គូភាគីវិវាទប្រសិនបើមាន និង ប្រសិនបើព័ត៌មានទាំងនេះខុសពីព័ត៌មានដែលមានក្នុងសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម

(គ) ការបញ្ជាក់សង្ខេបអំពីការទទួលយក ឬការបដិសេធចំពោះការទាមទារទាំងស្រុង ឬដោយផ្នែក

(ឃ) សេចក្ដីថ្លែងសង្ខេប ដែលពិពណ៌នាអំពីលក្ខណៈ និងកាលៈទេសៈនៃបណ្ដឹងតប ឬការ ដោះសាតាមការកាត់កង ដែលភាគីឆ្លើយតបមានបំណងបញ្ជូន និងប្រសិនបើអាចត្រូវ ភ្ជាប់តម្លៃបឋមនៃបណ្ដឹងតប ឬការដោះសាតាមការកាត់កងនោះ

(ង) ចំនួនមជ្ឈត្តករដែលបានព្រមព្រៀង ឬនៅក្នុងករណីដែលមិនមានការព្រមព្រៀងទេនោះ ចំនួនមជ្ឈត្តករដែលបានស្នើដែលត្រូវមានចំនួន ១ (មួយ) រូប ឬ៣ (បី) រូប និង

(ច) ប្រសិនបើមាន សេចក្ដីថ្លែងការណ៍ ឬសំណើបន្ថែមផ្សេងៗ ដែលពាក់ព័ន្ធនឹងដំណើរការ មជ្ឈត្តការ រួមបញ្ចូលទាំងច្បាប់ដែលត្រូវអនុវត្ត ភាសាសម្រាប់ដំណើរការមជ្ឈត្តការ និង លក្ខណសម្បត្តិ និងសញ្ជាតិរបស់មជ្ឈត្តករ ដែលបានតម្រូវ ឬដែលជាការឆ្លើយតបចំពោះ សេចក្ដីថ្លែង ឬសំណើនានា ដែលមានក្នុងសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម។

ហើយសេចក្ដីជូនដំណឹងអំពីការឆ្លើយតបត្រូវធ្វើជាភាសានៃមជ្ឈត្តការ និងត្រូវបកប្រែជាភាសាខ្មែរ ឬ ភាសាអង់គ្លេស។[25] ក្នុងគ្រប់ករណីទាំងអស់ សេចក្ដីជូនដំណឹងអំពីការឆ្លើយតបត្រូវតែមានព័ត៌មានច្បាស់លាស់ ហើយរាល់សេចក្ដីជូនដំណឹងអំពីការឆ្លើយតបទាំងអស់អាចមានភ្ជាប់ជាមួយនឹងសេចក្ដីថ្លែងដោះសា ដែលអាចរួម មានទាំងបណ្ដឹងតប ឬការដោះសា និងឯកសារយោងនានា។ ម្យ៉ាងវិញទៀត បើភាគីប្ដឹងទាមទារមិនទាន់បានដាក់ សំណើសុំដំណើរការនីតិវិធីពន្លឿនទេ ភាគីឆ្លើយតបអាចដាក់សំណើសុំដំណើរការនីតិវិធីពន្លឿនដូចមានកំណត់ក្នុង

[25] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៨.១.

ប្រការ៩ (ដំណើរការនីតិវិធីពន្លឿន) បានដោយភ្ជាប់សំណើនោះមកជាមួយសេចក្តីជូនដំណឹងអំពីការឆ្លើយតប។ ប៉ុន្តែ ប្រសិនបើភាគីប្តឹងទាមទារបានដាក់សំណើសុំដំណើរការនីតិវិធីពន្លឿនរួចហើយភាគីឆ្លើយតបគ្រាន់តែធ្វើការផ្តល់យោបល់លើសំណើនោះ ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិនបន្ទាប់ពីបានទទួលសំណើសុំនេះ។[26]

ក្នុងករណីដែលសេចក្តីជូនដំណឹងអំពីមជ្ឍត្តកម្ម ដែលមានភ្ជាប់មកនូវជាមួយសេចក្តីថ្លែងទាមទារ ភាគីឆ្លើយតបអាចត្រូវមានភ្ជាប់មកនូវជាមួយផងដែរនូវសេចក្តីថ្លែងដោះសាដែលអាចជាបណ្តឹងតប ឬការដោះសាតាមការកាត់កង និងទទ្បីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឍត្តកម្ម។ សេចក្តីថ្លែងដោះសា របស់ភាគីឆ្លើយតបត្រូវមានបញ្ជាក់សេចក្តីលម្អិតមួយចំនួនដូចខាងក្រោម៖

ក. អង្គហេតុ និងអំណះអំណាងតាមផ្លូវច្បាប់ក្នុងសេចក្តីថ្លែងទាមទារដែលភាគីឆ្លើយតបបានទទួលស្គាល់

ខ. អង្គហេតុ និងអំណះអំណាងតាមផ្លូវច្បាប់ក្នុងសេចក្តីថ្លែងទាមទារដែលភាគីឆ្លើយតបបដិសេធ និងមូលហេតុនៃការបដិសេធនោះ

គ. អង្គហេតុ និងអំណះអំណាងតាមផ្លូវច្បាប់ផ្សេងទៀតដែលភាគីឆ្លើយតបផ្អែកជាមូលដ្ឋាន។[27]

អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅគូភាគីវិវាទ នៅពេលអគ្គលេខាធិការដ្ឋានបានទទួលសេចក្តីជូនដំណឹងអំពីការឆ្លើយតបពេញលេញ ឬក្នុងករណីដែលមិនបានទទួលសេចក្តីជូនដំណឹងអំពីការឆ្លើយតបពេញលេញទេនោះ អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅគូភាគីវិវាទអំពីកាលបរិច្ឆេទផុតកំណត់នៃអំឡុងពេលសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីការឆ្លើយតបនោះ។

ក្នុងករណីដែលភាគីឆ្លើយតប ធ្វើបណ្តឹងតបរួមបញ្ចូលទាំងការដោះសាតាមការកាត់កងនៅក្នុងសេចក្តីជូនដំណឹងអំពីការឆ្លើយតបរបស់ភាគីនោះ ភាគីឆ្លើយតបត្រូវបង់កម្រៃសេវាចុះបញ្ជីបណ្តឹងតបរបស់ខ្លួនផងដែរ បើមិនដូច្នោះទេបណ្តឹងតបនោះនឹងមិនត្រូវលើកយកមកពិចារណានៅក្នុងដំណើរការមជ្ឍត្តការឡើយ។[28]

[26] វិធានស្តីពីមជ្ឍត្តការ ឆ្នាំ២០២១ ប្រការ ៨.២.

[27] វិធានស្តីពីមជ្ឍត្តការ ឆ្នាំ២០២១ ប្រការ ៣៧.៣.

[28] វិធានស្តីពីមជ្ឍត្តការ ឆ្នាំ២០២១ ប្រការ ៨.៧.

## ២.២. នីតិវិធីជ្រើសរើសមជ្ឈត្តករ

### ២.២.១. មជ្ឈត្តករនៃវេទិកាមជ្ឈត្តកម្ម

មជ្ឈត្តករ គឺជាបុគ្គលឯករាជ្យដែលត្រូវបានតែងតាំងដោយភាគីវិវាទ ដើម្បីធ្វើការសម្រេចសេចក្តីនៅក្នុងវិវាទរបស់គូភាគី។ ជាទូទៅ គូភាគីត្រូវជ្រើសរើសមជ្ឈត្តករចេញពីក្នុងបញ្ជីមជ្ឈត្តករ របស់ស្ថាប័នដែលត្រូវគ្រប់គ្រងដំណើរការមជ្ឈត្តការ។ ផ្អែកតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម រូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬបរទេសដែលជាមជ្ឈត្តករត្រូវចុះបញ្ជីនៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ។[29]

#### ២.២.១.១. ការតែងតាំងមជ្ឈត្តករ

ភាគីវិវាទមានសិទ្ធិកំណត់ចំនួនមជ្ឈត្តករនៃវេទិកាមជ្ឈត្តកម្ម។[30] នៅគ្រប់ករណីទាំងអស់ វេទិកាមជ្ឈត្តកម្ម ត្រូវមានសមាសភាពមជ្ឈត្តករ ជាចំនួនសេស។[31] វេទិកាមជ្ឈត្តកម្ម ត្រូវមានមជ្ឈត្តករចំនួន ៣ (បី) រូប លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ។[32] យើងខ្ញុំសូមបញ្ជាក់ផងដែរថា គ្មានជនណា ត្រូវបានបដិសេធមិនឱ្យធ្វើមជ្ឈត្តករ ដោយសារមូលហេតុ នៃសញ្ជាតិរបស់គេឡើយ លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងក្រៅពីនេះ។[33] ប្រសិនបើវេទិកាមជ្ឈត្តកម្ម មិនត្រូវបានតែងតាំងក្នុងអំឡុងពេលដែលកំណត់ដោយគូភាគី ឬប្រសិនបើគូភាគីមិនបានព្រមព្រៀងលើអំឡុងពេលកំណត់ទេសម្រាប់តែងតាំងទេនោះ វេទិកាមជ្ឈត្តកម្មនឹងត្រូវធ្វើឡើងក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលការជូនដំណឹងអំពីសេចក្តីជូនដំណឹងអំពីការឆ្លើយតប។[34]

##### ក. វេទិកាមជ្ឈត្តកម្មដែលមានការតែងតាំងមជ្ឈត្តករមួយរូប

ចំពោះវេទិកាមជ្ឈត្តកម្មដែលមានមជ្ឈត្តករមួយរូប ប្រសិនបើមជ្ឈត្តករមិនទាន់ត្រូវបានតែងតាំងតាមរយៈសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ឬសេចក្តីជូនដំណឹងអំពីការឆ្លើយតបទេនោះ គូភាគីវិវាទត្រូវរួមគ្នាតែងតាំងមជ្ឈត្តករ ១ (មួយ) រូប ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលការជូនដំណឹងអំពីការឆ្លើយតបពេញលេញ ឬបន្ទាប់ពីផុតរយៈពេល ៣០ (សាបសិប) ថ្ងៃនៃថ្ងៃប្រតិទិន បន្ទាប់ពីថ្ងៃបានទទួល

29 ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា១៨ កថាខណ្ឌទី១
30 ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា១៨ កថាខណ្ឌទី១
31 វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៤. វាក្យខណ្ឌទី១
32 វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៤ .វាក្យខណ្ឌទី២
33 ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា១៩ ចំណុចទី១
34 វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៥.១. វាក្យខណ្ឌទី២

ដំណឹងអំពីការឆ្លើយតបរបស់គូភាគី។[35] ប្រសិនបើភាគីវិវាទទាំងពីរ ខកខានក្នុងការតែងតាំងមជ្ឈត្តករក្នុងអំឡុងពេលដែលវិធានបានកំណត់ គណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវតែងតាំងមជ្ឈត្តករ ១ (មួយ) រូបដើម្បីបង្កើតវេទិកាមជ្ឈត្តកម្ម។[36]

### ខ. វេទិកាមជ្ឈត្តកម្មដែលមានការតែងតាំងមជ្ឈត្តករបីរូប ឬច្រើនរូប

ចំពោះវេទិកាមជ្ឈត្តកម្ម ដែលមានមជ្ឈត្តករ ចំនួន ៣ (បី) រូប ឬច្រើនរូប ប្រសិនបើការតែងតាំង មិនត្រូវបានធ្វើឡើងតាមរយៈសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ឬសេចក្តីជូនដំណឹងអំពីការឆ្លើយតបទេ គូភាគីត្រូវធ្វើការតែងតាំងមជ្ឈត្តករម្នាក់មួយរូប ឬច្រើនរូបស្មើៗគ្នា ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានការជូនដំណឹងអំពីការឆ្លើយតប ចំពោះសេចក្តីជូនដំណឹងអំពីវេទិកាមជ្ឈត្តកម្ម។[37] ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីមានការតែងតាំងមជ្ឈត្តកររូបចុងក្រោយ។ មជ្ឈត្តករ ដែលត្រូវបានតែងតាំងទាំងអស់ត្រូវរួមគ្នាតែងតាំងមជ្ឈត្តករ ១ (មួយ)រូប ផ្សេងទៀតដើម្បីធ្វើជាប្រធាននៃវេទិកាមជ្ឈត្តកម្ម។ [38] ក្នុងករណីដែលភាគីវិវាទខកខានក្នុងការតែងតាំងមជ្ឈត្តករតាមការតម្រូវ ឬមជ្ឈត្តករដែលត្រូវបានតែងតាំងនោះខកខានមិនអាចតែងតាំងប្រធានវេទិកាមជ្ឈត្តកម្មក្នុងអំឡុងពេល ដែលវិធានស្តីអំពីមជ្ឈត្តការ បានកំណត់គណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវតែងតាំងមជ្ឈត្តករ ឬ/និងប្រធានវេទិកាមជ្ឈត្តកម្ម។ [39]

### ២.២.១.២. ការជំទាស់ទៅនឹងមជ្ឈត្តករ

#### ក. មូលដ្ឋានជំទាស់ទៅនឹងមជ្ឈត្តករ

ការជំទាស់ទៅនឹងមជ្ឈត្តករអាចនឹងត្រូវបានធ្វើឡើង ក្នុងករណីដែលមានកាលៈទេសៈណាមួយបង្កឱ្យមានការសង្ស័យសមហេតុផលចំពោះឯករាជ្យភាព ឬអព្យាក្រឹតភាពរបស់មជ្ឈត្តករ។[40] លើសពីនេះទៅទៀតមជ្ឈត្តករអាចត្រូវបានជំទាស់ផងដែរ ប្រសិនបើមជ្ឈត្តកររូបនោះពុំមានលក្ខណៈសម្បត្តិដូចដែលគូភាគីបានព្រមព្រៀងនៅក្នុងកិច្ចព្រមព្រៀងផ្សះផ្សា។ ភាគីវិវាទមួយអាចជំទាស់ទៅនឹងមជ្ឈត្តករ ដែលខ្លួនបានតែងតាំង ឬដែលខ្លួនបានចូលរួមក្នុងការតែងតាំង តែក្នុងករណីដែលវិវាទនោះបានដឹងអំពីមូលហេតុដើម្បីជំទាស់នោះក្រោយការតែងតាំងតែប៉ុណ្ណោះ។

---

[35] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៥.៣ វាក្យខណ្ឌទី១
[36] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៥.៣. វាក្យខណ្ឌទី២
[37] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៥.២. កថាខណ្ឌ១ វាក្យខណ្ឌ១
[38] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៥.២. កថាខណ្ឌ១ វាក្យខណ្ឌ២
[39] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៥.២. កថាខណ្ឌ២
[40] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៨

### ខ. នីតិវិធីជំទាស់ទៅនឹងមជ្ឈត្តករ

ភាគីវិវាទដែលមានបំណងជំទាស់ទៅនឹងមជ្ឈត្តករ ត្រូវបញ្ជូនសេចក្តីជូនដំណឹងអំពីការជំទាស់របស់ខ្លួនដោយមានបញ្ជាក់អំពីមូលហេតុនៃការជំទាស់ទៅនឹងវេទិកាមជ្ឈត្តកម្ម ភាគីម្ខាងទៀត ឬគូភាគីវិវាទ និងអគ្គលេខាធិការដ្ឋាន នៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានដំណឹងអំពីការបង្កើតវេទិកាមជ្ឈត្តកម្ម ឬក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន ដូចគ្នា បន្ទាប់ពីខ្លួនបានដឹងអំពីកាលៈទេសៈនានាដែលអាចជំទាស់ទៅនឹងមជ្ឈត្តករ[41] មជ្ឈត្តករ ដែលត្រូវបានជំទាស់ ភាគីម្ខាងទៀត និងសមាជិកដទៃទៀតរបស់វេទិកាមជ្ឈត្តកម្ម អាចផ្តល់យោបល់របស់ខ្លួន អំពីការជំទាស់ទៅនឹងមជ្ឈត្តករ ទៅវេទិកាមជ្ឈត្តកម្ម ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន ក្រោយពីទទួលបានសេចក្តីជូនដំណឹងអំពីការជំទាស់។[42]

ទោះបីជាភាគីមានសិទ្ធិអាចប្តឹងជំទាស់ទៅនឹងមជ្ឈត្តករ ក៏ពិតមែន ប៉ុន្តែ មជ្ឈត្តករដែលត្រូវបានជំទាស់អាចធ្វើការបដិសេធក្នុងការដកខ្លួនចេញពីវេទិកាមជ្ឈត្តកម្មបានផងដែរ។ នៅក្នុងករណីនេះ ប្រសិនបើវេទិកាមជ្ឈត្តកម្ម មានមជ្ឈត្តករច្រើនរូប វេទិកាមជ្ឈត្តកម្មត្រូវសម្រេចលើការជំទាស់នោះនៅក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃប្រតិទិន បន្ទាប់ពីបានសេចក្តីជូនដំណឹងអំពីការបដិសេធលើការជំទាស់។ ក្រោយពីមជ្ឈត្តករដែលបានជំទាស់ត្រូវបានបដិសេធមិនដកខ្លួនចេញពីវេទិកាមជ្ឈត្តកម្ម ភាគីវិវាទដែលបានជំទាស់អាចធ្វើការដាក់ពាក្យតវ៉ាទៅអគ្គលេខាធិការដ្ឋាន នៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីសម្រេចពីវេទិកាមជ្ឈត្តកម្ម។[43]

### គ. សេចក្តីសម្រេចរបស់ ម.ជ.ម. លើការជំទាស់ទៅនឹងមជ្ឈត្តករ

គណៈកម្មាធិការតែងតាំង និងនីតិវិធី នៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវធ្វើការសម្រេចលើការតវ៉ាចំពោះការជំទាស់ទៅនឹងមជ្ឈត្តករក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីអគ្គលេខាធិការដ្ឋានបានទទួលការតវ៉ាចំពោះការជំទាស់ទៅនឹងមជ្ឈត្តករ។[44] មជ្ឈត្តករ ដែលត្រូវបានជំទាស់នោះ ត្រូវបន្តបំពេញតួនាទីរបស់ខ្លួនជាមជ្ឈត្តករបន្តទៀត ប្រសិនបើគណៈកម្មាធិការបដិសេធចំពោះការជំទាស់ទៅនឹងមជ្ឈត្តករ។[45] ដោយឡែក ប្រសិនបើគណៈកម្មាធិការតែងតាំង និងនីតិវិធី យល់ស្របចំពោះការជំទាស់ អាណត្តិរបស់មជ្ឈត្តករ ដែលត្រូវបានជំទាស់នោះនឹងត្រូវបញ្ចប់ដោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចេញសេចក្តី

[41] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៨.១

[42] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៨.៣

[43] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៨.៤ កថាខណ្ឌទី៣ និងកថាខណ្ឌទី៤

[44] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៨.៥ កថាខណ្ឌ១

[45] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៨.៥. កថាខណ្ឌ២ វាក្យខណ្ឌ១

សម្រេចនោះ។[46] ក្នុងករណីនេះ ដើម្បីបន្តដំណើរការវេទិកាមជ្ឈត្តកម្ម គឺត្រូវដាក់មជ្ឈត្តករជំនួស ដើម្បីដំណើរការវេទិកាមជ្ឈត្តកម្មនេះតែម្តង។ យើងខ្ញុំសូមបញ្ជាក់ផងដែរថា ទោះបីជាគណៈកម្មាធិការតែងតាំង និងនីតិវិធីសម្រេចថាបដិសេធ ឬយល់ស្រប ចំពោះការជំទាស់មជ្ឈត្តកររបស់ភាគី នោះសេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធី មិនចាំបាច់បង្ហាញហេតុផលឡើយ។ ហើយសេចក្តីសម្រេចនោះ គឺជាសេចក្តីសម្រេចជាស្ថាពរ និងបិទផ្លូវតវ៉ា។ អគ្គលេខាធិការដ្ឋាន ត្រូវជូនដំណឹងទៅគូភាគី និងវេទិកាមជ្ឈត្តកម្មអំពីសេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធីនោះ។[47]

## ២.៣. ការប្រជុំបឋម ឬការប្រជុំត្រៀម

កិច្ចប្រជុំត្រៀមរៀបចំសវនាការ មានគោលបំណងស្វែងរកការព្រមព្រៀងលើរាល់នីតិវិធីលម្អិតនានា ដើម្បីឈានទៅដល់សវនាការ។ យោងតាមវិធានស្តីពីមជ្ឈត្តការ ចែងថា ភ្លាមៗតាមដែលអាចធ្វើទៅបាន វេទិកាមជ្ឈត្តកម្មអាចរៀបចំការប្រជុំត្រៀមជាមួយគូភាគីវិវាទដោយផ្ទាល់ ឬដោយមធ្យោបាយផ្សេងទៀត ដើម្បីរៀបចំ និងកំណត់កាលវិភាគ នៃដំណើរការមជ្ឈត្តការបន្ទាន់ ឬ/និងដើម្បីពិភាក្សាអំពីនីតិវិធី ដែលមានភាពសមស្រប និងចំណាយអស់តិចបំផុតសម្រាប់សំណុំរឿង។[48] លើសពីនេះ ភាគីវិវាទអាចព្រមព្រៀង ឬមិនព្រមព្រៀងលើបញ្ហានីតិវិធីដែលវេទិកាមជ្ឈត្តកម្ម ត្រូវអនុវត្តដើម្បីចាត់ចែងដំណើរការមជ្ឈត្តការ។[49] ក្នុងករណីគ្មានការព្រមព្រៀងលើនីតិវិធីនេះ វេទិកាមជ្ឈត្តកម្មចាត់ចែងធ្វើមជ្ឈត្តការទៅតាមបែបបទណា ដែលវេទិកាមជ្ឈត្តកម្មយល់ឃើញថាសមស្របដោយអនុលោមតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[50]

ជាងនេះទៅទៀត វេទិកាមជ្ឈត្តកម្មអាចរៀបចំឱ្យមានការប្រជុំបន្ថែម ដើម្បីពិនិត្យវត្ថុ ឬឯកសារនានា ឬពិនិត្យលើភាពរីកចំរើននៃដំណើរការមជ្ឈត្តការ។[51] នៅមុន ឬក្នុងអំឡុងពេលប្រជុំត្រៀម វេទិកាមជ្ឈត្តកម្មត្រូវពិភាក្សាជាមួយគូភាគីវិវាទ ដើម្បីស្វែងរកដំណោះស្រាយវិវាទដោយស្រុះស្រួលគ្នា និងជួយគូភាគីវិវាទក្នុងលក្ខណៈណាមួយ ដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប។[52] ម៉្យាងវិញទៀត វេទិកាមជ្ឈត្តកម្ម តាមឆន្ទានុសិទ្ធិរបស់ខ្លួនអាចបំបែកដំណើរការមជ្ឈត្តការដាច់ៗពីគ្នា និងកំណត់ឱ្យគូភាគីវិវាទផ្តោតការបង្ហាញនានារបស់ខ្លួនលើបញ្ហានានា ដែលសេចក្តីសម្រេចលើបញ្ហាទាំងនោះអាចបំបែកសំណុំរឿងទាំងមូល ឬជាផ្នែក បន្ទាប់ពីបានពិភាក្សាជាមួយគូភាគីវិវាទ។[53] សូមកត់សម្គាល់ថា នៅគ្រប់ករណីទាំងអស់ វេទិកាមជ្ឈត្តកម្មត្រូវដំណើរការក្នុងលក្ខណៈ ដែល

[46] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៨.៥. កថាខណ្ឌ២ វាក្យខណ្ឌ២

[47] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ២៨.៦.

[48] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៥.២.

[49] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា២៧

[50] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា២៧

[51] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៥.២.

[52] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៥.៣.

[53] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៥.៤.

គូភាគីវិវាទត្រូវបានយកចិត្តទុកដាក់ស្មើៗគ្នា និងភាគីវិវាទនីមួយៗ ត្រូវបានផ្តល់ឱកាសសមរម្យដើម្បីបង្ហាញរឿងរ៉ាវរបស់ខ្លួន។

នៅក្នុងកិច្ចប្រជុំត្រៀមរៀបចំសវនាការវេទិកាមជ្ឈត្តកម្ម និងគូភាគីវិវាទ គួរពិចារណាបញ្ហាមួយចំនួនដូចខាងក្រោម៖

- វិធានស្តីពីមជ្ឈត្តការ
- ច្បាប់គ្រប់គ្រង
- ភាសានៃដំណើរការមជ្ឈត្តការ
- ការបកប្រែឯកសារ
- ទីកន្លែងមជ្ឈត្តការ
- មធ្យោបាយទំនាក់ទំនងរវាងគូភាគី និងមជ្ឈត្តករ
- ការដាក់សេចក្តីថ្លែងជាលាយលក្ខណ៍អក្សរដោយគូភាគីវិវាទ
- កំណត់ចំណុចវិវាទ
- លទ្ធភាពក្នុងការដោះស្រាយវិវាទដោយការចរចា
- ឯកសារភស្តុតាង
- សាក្សី
- អ្នកជំនាញ និងសាក្សីជាអ្នកជំនាញ
- សវនាការ។

## ២.៤. សេចក្តីបង្គាប់នីតិវិធីរបស់វេទិកាមជ្ឈត្តកម្ម

បន្ទាប់ពីពិភាក្សាជាមួយភាគីវិវាទ ដោយផ្អែកលើភាពសាំញ៉ាំ និងតម្លៃនៃវិវាទ ដោយកិច្ចប្រជុំបឋម ឬកិច្ចប្រជុំត្រៀមរួចរាល់ វេទិកាមជ្ឈត្តកម្មត្រូវដំណើរការក្នុងលក្ខណៈមួយដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប ដើម្បីធានាឱ្យបាននូវយុត្តិធម៌មានភាពឆាប់រហ័សមានប្រសិទ្ធភាព ចំណាយតិច និងផ្តល់ដំណោះស្រាយចុងក្រោយនៃវិវាទ។[54] វេទិកាមជ្ឈត្តកម្ម ត្រូវដំណើរការគ្រប់ករណីទាំងអស់ដោយគូភាគីវិវាទត្រូវបានទទួលការយកចិត្តទុកដាក់ស្មើៗគ្នា និងភាគីវិវាទនីមួយៗត្រូវបានផ្តល់ឱកាសសមរម្យក្នុងការបង្ហាញហេតុផល និងទឡ្ហីករណ៍របស់ខ្លួន។ វេទិកាមជ្ឈត្តកម្ម ត្រូវចេញសេចក្តីបង្គាប់ ឬសេចក្តីណែនាំដែលមានលក្ខណៈសមស្រប ដើម្បីធានានូវដំណើរការមជ្ឈត្តការប្រព្រឹត្តទៅដោយរលូន។

[54] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៥.

សេចក្ដីបង្គាប់ ឬសេចក្ដីណែនាំនេះមិនត្រូវផ្ទុយនឹងវិធានស្ដីពីមជ្ឈត្តការ ឬច្បាប់ ដែលគ្រប់គ្រងមជ្ឈត្តការឡើយ។ ការធ្វើសេចក្ដីបង្គាប់ ឬសេចក្ដីណែនាំនេះតម្រូវឱ្យធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែការទាក់ទងដោយផ្ទាល់មាត់នៅពេលសវនាការ និងក្នុងកិច្ចប្រជុំនានាដែលរៀបចំឡើងដោយវេទិកាមជ្ឈត្តកម្ម។[55]

វេទិកាមជ្ឈត្តកម្ម ត្រូវនីតិវិធីផ្សេងៗសម្រាប់ដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលក្នុងនោះនឹងមានការបកស្រាយនៅក្នុងចំណុច **២.៤.១. ការកំណត់ទីកន្លែងនៃដំណើរការមជ្ឈត្តការ ២.៤.២. ការកំណត់លិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្ត ២.៤.៣. ការកំណត់ភាសា ២.៤.៤. ការកំណត់អំពីភស្តុតាង ២.៤.៥. ការកំណត់អំពីសាក្សី ២.៤.៦. ការដាក់សេចក្ដីថ្លែងទាមទារ** និង **២.៤.៧. ការដាក់សេចក្ដីថ្លែងដោះសាចំពោះបណ្ដឹងតប។**

### ២.៤.១. ការកំណត់ទីកន្លែងនៃដំណើរការមជ្ឈត្តការ

ដំណើរការនៃវេទិកាមជ្ឈត្តកម្ម ត្រូវធ្វើឡើងនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីដែលគូភាគីវិវាទបានព្រមព្រៀងគ្នាផ្សេងពីនេះ ឬដោយសារកាលៈទេសៈនានានៃសំណុំរឿងដែលវេទិកាមជ្ឈត្តកម្មសម្រេចថា តើត្រូវធ្វើនៅទីកន្លែងផ្សេងទៀតដែលមានលក្ខណៈសមស្របជាង ត្រូវអនុលោមទៅតាមការព្រមព្រៀង ឬសេចក្ដីសម្រេចនោះ។[56]

### ២.៤.២. ការកំណត់លិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្ត

គូភាគីវិវាទ មានសេរីភាពក្នុងការព្រមព្រៀងយកច្បាប់ ឬបទបញ្ញត្តិគតិយុត្តណាមួយដើម្បីឱ្យវេទិកាមជ្ឈត្តកម្មអនុវត្តចំពោះខ្លឹមសារនៃវិវាទ។ ក្នុងករណីដែលមិនមានការព្រមព្រៀងគ្នា វេទិកាមជ្ឈត្តកម្មជាអ្នកកំណត់ថាតើត្រូវយកច្បាប់ ឬបទបញ្ញត្តិគតិយុត្តណាមួយដែលសមស្របយកមកអនុវត្ត។[57] វេទិកាមជ្ឈត្តកម្មត្រូវធ្វើមជ្ឈត្តវិនិច្ឆ័យតាមសមធម៌ ឬតាមការសម្រុះសម្រួលតែក្នុងករណី និងក្នុងកម្រិតដែលគូវិវាទបានអនុញ្ញាតយ៉ាងច្បាស់លាស់ឱ្យវេទិកាមជ្ឈត្តកម្មធ្វើដូច្នោះតែប៉ុណ្ណោះ។ នៅគ្រប់ករណីទាំងអស់វេទិកាមជ្ឈត្តកម្មត្រូវយកមកពិចារណានូវបញ្ញត្តិនានា ដែលមានចែងក្នុងកិច្ចសន្យា ប្រសិនបើមាន រួមទាំងទម្លាប់ពាណិជ្ជកម្មនានាដែលពាក់ព័ន្ធ។ ជាធម្មតា គូភាគីជ្រើសរើសច្បាប់គ្រប់គ្រងកិច្ចសន្យា ដោយប្រើច្បាប់របស់ភាគីណាមួយ ឬប្រសិនបើកិច្ចសន្យា ជាកិច្ចសន្យាទិញទំនិញអន្តរជាតិ គូភាគីអាចធ្វើការជ្រើសរើសច្បាប់អន្តរជាតិ ដូចជា អនុសញ្ញាអន្តរជាតិ

[55] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៥

[56] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៩.៣.

[57] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣២.១.

ស្តីពី ការលក់ទំនិញអន្តរជាតិ (Convention on Contracts for International Sale of Goods)[58] **ឬហៅកាត់ថា CISG។**

### ២.៤.៣. ការកំណត់ភាសា

ទាក់ទងនឹងការជ្រើសរើសភាសា ភាគីត្រូវបានកំណត់ចំពោះ **២.៤.៣.១. ភាសានៃដំណើរការមជ្ឈត្តការ** និង**២.៤.៣.២. ភាសានៃមជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីបង្គាប់។**

#### ២.៤.៣.១. ភាសានៃដំណើរការមជ្ឈត្តការ

យោងទៅតាមប្រការ៣៣ នៃវិធានស្តីពីមជ្ឈត្តការ ដែលចេញដោយមជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចំពោះភាសានៃដំណើរការមជ្ឈត្តការ គឺគូភាគីវិវាទមានមានសេរីភាពក្នុងការព្រមព្រៀងយកភាសាណាមួយ ឬច្រើនមកប្រើក្នុងដំណើរការមជ្ឈត្តការ។ ក្នុងករណីដែលមិនមានការព្រមព្រៀងគ្នាទេវេទិកាមជ្ឈត្តកម្ម អាចសម្រេចយកភាសាណាមួយសម្រាប់ដំណើរការមជ្ឈត្តការ ដោយគិតពិចារណាទៅលើកាលៈទេសៈនានាដែលពាក់ព័ន្ធទាំងអស់ រួមទាំងភាសានៃកិច្ចសន្យាផងដែរ។[59]

វេទិកាមជ្ឈត្តកម្ម អាចធ្វើការបង្គាប់ឱ្យភាគីវិវាទណាមួយធ្វើការបកប្រែការទំនាក់ទំនងគ្នាជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ណាមួយទៅជាភាសាណាមួយក្នុងទម្រង់ដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប។[60]

#### ២.៤.៣.២. ភាសានៃមជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីបង្គាប់

បន្ទាប់ពីបានពិភាក្សាជាមួយគូវិវាទរួចហើយ វេទិកាមជ្ឈត្តកម្មត្រូវចេញមជ្ឈត្តវិនិច្ឆ័យជាភាសាខ្មែរ ឬជាភាសាអង់គ្លេស ទោះបីជាភាសាដែលត្រូវបានប្រើក្នុងដំណើរការមជ្ឈត្តការត្រូវបានជ្រើសរើសដោយគូភាគីក្តី ឬតាមកំណត់របស់វេទិកាមជ្ឈត្តកម្មក្តីដែលខុសពីភាសាខ្មែរ ឬភាសាអង់គ្លេស។[61]

### ២.៤.៤. កំណត់អំពីភស្តុតាង

នៅក្នុងវិវាទដែលមានភាពស្មុគស្មាញ ភស្តុតាងជាឯកសារ គឺមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយវិវាទ។ ជាទូទៅ ភាគីដែលចាប់ផ្តើមដំណើរការមជ្ឈត្តការ គឺតែងតែមាននូវភស្តុតាង និងឯកសារនានា

[58] សេចក្តីព្រាងមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា ទិដ្ឋភាពច្បាប់ និងការអនុវត្ត រៀបចំដោយ លោក សាន គីរី ឆ្នាំ២០២៤ ទំព័រ២២

[59] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៣.១.

[60] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៣.២.

[61] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៣.៣.

ក្នុងការអះអាងសម្រាប់ការទាមទាររបស់ខ្លួន។ ភាគីវិវាទនីមួយៗត្រូវមានបន្ទុកបង្ហាញអង្គហេតុ វិធានដែលត្រូវអនុវត្ត និងទម្លាប់ពាណិជ្ជកម្មនានាដែលជាមូលដ្ឋាននៃការទាមទារ ឬបណ្តឹងតប ឬការដោះសាបស់ភាគីវិវាទ។ ភស្តុតាងដែលគូភាគីបានដាក់មកក្នុងវេទិកាមជ្ឈត្តកម្ម គឺត្រូវកំណត់អំពីភាពអាចទទួលយកបាន ទំនាក់ទំនងសារៈសំខាន់ និងទម្ងន់នៃភស្តុតាងទាំងអស់។ វេទិកាមជ្ឈត្តកម្ម មិនត្រូវតម្រូវឱ្យអនុវត្តវិធាននៃភស្តុតាងនៃច្បាប់ណាមួយឡើយក្នុងការធ្វើការកំណត់នោះ។

នៅពេលណាមួយក្នុងអំឡុងពេលនៃដំណើរការមជ្ឈត្តការ ភាគីវិវាទមានសិទ្ធិក្នុងការត្រួតពិនិត្យភស្តុតាងដែលបង្ហាញដោយភាគីវិវាទម្ខាងទៀត។ វេទិកាមជ្ឈត្តកម្ម អាចរៀបចំឱ្យមានការសាកសួរ ឬបង្គាប់ភាគីវិវាទណា មួយដើម្បីផ្តល់ការបង្ហាញផ្សេងៗ ដែលវេទិកាមជ្ឈត្តកម្មយល់ថាចាំបាច់ ឬសមស្របដូចជា៖ [62]

- ផ្តល់ឯកសារ វត្ថុតាង ឬភស្តុតាងផ្សេងទៀត
- ផ្តល់តារាងរៀបតាមអក្សរ ឬសេចក្តីសង្ខេបរបស់ឯកសារ ឬភស្តុតាងផ្សេងទៀតដែលភាគីវិវាទនោះបានបង្ហាញ ឬមានបំណងបង្ហាញ
- ផ្តល់ទីកន្លែង វត្ថុ ឬឯកសារនានាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនសម្រាប់ប្រើប្រាស់ក្នុងវេទិកាមជ្ឈត្តកម្ម ភាគីវិវាទម្ខាងទៀត ឬអ្នកជំនាញដែលត្រូវបានតែងតាំងដើម្បីធ្វើការត្រួតពិនិត្យលើភសត្ថុតាងទាំងនោះ
- រៀបចំការយកគំរូដែលត្រូវយកពីទីកន្លែង សម្ភារៈ ឬឯកសារដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គូភាគីវិវាទ ឬរៀបចំឱ្យមានការអង្កេតលើ ឬការពិសោធលើដែលគំរូនោះនឹងត្រូវយកទៅពិនិត្យ ឬសម្រាប់ការពិសោធណាមួយទាំងនោះ។

### ២.៤.៥. កំណត់អំពីសាក្សី

នៅមុនពេលដំណើរការសវនាការ វេទិកាមជ្ឈត្តកម្ម អាចតម្រូវឱ្យភាគីវិវាទនីមួយៗផ្តល់សេចក្តីជូនដំណឹងជាមុនអំពីអត្តសញ្ញាណរបស់សាក្សីដោយរួមបញ្ចូលទាំងសាក្សីជំនាញផងដែរនៅក្នុងប្រការ ៤១ (សាក្សី)ដែលភាគីវិវាទនីមួយៗមានបំណងកោះហៅ ក៏ដូចជាអំពីកម្មវត្ថុ និងទំនាក់ទំនងនៃសក្ខីកម្មរបស់សាក្សីរួមទាំងភាសាដែលសាក្សីនោះនឹងប្រើក្នុងការធ្វើសក្ខីកម្ម។[63]

[62] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៤០.

[63] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៤១.១.

វេទិកាមជ្ឈត្តកម្ម មានឆន្ទានុសិទ្ធិក្នុងការអនុញ្ញាត ការកម្រិត ឬការបដិសេធការបង្ហាញរបស់សាក្សី។ វេទិកាមជ្ឈត្តកម្មអាចធ្វើការកំណត់ឱ្យសាក្សីធ្វើសក្ខីកម្មជាលាយលក្ខណ៍អក្សរ ឬក្នុងទម្រង់ផ្សេងទៀតសម្រាប់ធ្វើកំណត់ត្រា។ ស្របតាមប្រការ ៤១.២ (ការអនុញ្ញាត ការកម្រិត ឬការបដិសេធការបង្ហាញរបស់សាក្សី) គូវិវាទអាចស្នើឱ្យសាក្សីចូលរួមក្នុងការសាកសួរផ្ទាល់មាត់។ ប្រសិនបើសាក្សីខកខានក្នុងការចូលរួមការសាកសួរដោយផ្ទាល់មាត់ វេទិកាមជ្ឈត្តកម្ម អាចដាក់ទម្ងន់នៃការពិចារណារបស់ខ្លួន ទៅលើសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប ឬទាត់ចោល ឬលុបចោល សក្ខីកម្មនោះទាំងស្រុង។[64] សាក្សីណាម្នាក់ដែលផ្តល់សក្ខីកម្មដោយផ្ទាល់មាត់អាចត្រូវបានសាកសួរដោយវេទិកាមជ្ឈត្តកម្ម និងដោយភាគីវិវាទនីមួយៗក្នុងទម្រង់ណាមួយដែលវេទិកាមជ្ឈត្តកម្មបានកំណត់។ សាក្សីណាម្នាក់អាចត្រូវបានវេទិកាមជ្ឈត្តកម្មតម្រូវឱ្យធ្វើសក្ខីកម្មក្រោមសម្បថ ឬធ្វើការអះអាង។

### ២.៤.៦. ការដាក់សេចក្តីថ្លែងទាមទារ

នៅក្នុងរយៈពេលដែលឯកភាពដោយភាគីវិវាទ ឬកំណត់ដោយវេទិកាមជ្ឈត្តកម្ម អ្នកប្តឹងទាមទារត្រូវបញ្ជាក់ពីអង្គហេតុ ដើម្បីគាំទ្រការទាមទាររបស់ខ្លួនព្រមទាំងបញ្ជាក់ពីចំណុចជាក់លាក់នៃបញ្ហា និងសំណងនៃការខូចខាតដែលត្រូវទាមទារ។ ភាគីប្តឹងទាមទារ អាចភ្ជាប់ឯកសារទាំងអស់ដែលយល់ថាទាក់ទងនឹងការទាមទារ ឬអាចបន្ថែមការយោង លើឯកសារ ឬភស្តុតាងដទៃទៀត ដែលភាគីប្តឹងទាមទារត្រូវដាក់ជូនវេទិកាមជ្ឈត្តកម្ម។

តាមការព្រមព្រៀងរបស់គូភាគី វេទិកាមជ្ឈត្តកម្មត្រូវកំណត់កាលវិភាគឱ្យបានច្បាស់លាស់សម្រាប់ឱ្យភាគីប្តឹងទាមទារប្រគល់សេចក្តីថ្លែងទាមទារ មកវេទិកាមជ្ឈត្តកម្ម ដោយភ្ជាប់មកជាមួយផងដែរនឹងសេចក្តីលម្អិតដូចខាងក្រោម៖

ក. អង្គហេតុដែលគាំទ្រការទាមទារនោះ

ខ. មូលដ្ឋានច្បាប់ ឬទឡ្ហីករណ៍តាមផ្លូវច្បាប់ដែលគាំទ្រការទាមទារនោះ

គ. សំណងការខូចខាត ឬការសង្គ្រោះដែលទាមទារ ឬចំនួនទឹកប្រាក់នៃការទាមទារដែលអាចកំណត់បានទាំងអស់។

ប្រសិនបើភាគីប្តឹងទាមទារខកខានក្នុងការដាក់សេចក្តីថ្លែងទាមទារដោយមិនបាន បង្ហាញពីមូលហេតុគ្រប់គ្រាន់នៅក្នុងអំឡុងពេលកំណត់ និងប្រសិនបើសមស្របវេទិកាមជ្ឈត្តកម្មត្រូវចេញសេចក្តីបង្គាប់ឱ្យបញ្ឈប់ដំណើរការមជ្ឈត្តការ បន្ទាប់ពីសម្រេចលើបញ្ហាផ្សេងទៀតដែលនៅសេសសល់ និងដែលត្រូវដោះស្រាយ។[65]

[64] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៤១.៣.

[65] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៧.៧. កថាខណ្ឌទី១

### ២.៤.៧. ការដាក់សេចក្ដីថ្លែងដោះសាចំពោះបណ្ដឹងតប

ប្រសិនបើមានបណ្ដឹងតបត្រូវបានធ្វើឡើង ភាគីប្ដឹងទាមទារត្រូវបញ្ជូនសេចក្ដីថ្លែងដោះសាចំពោះបណ្ដឹងតបនោះក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្ដីថ្លែងដោះសាររបស់ភាគីអ្នកឆ្លើយតប ក្នុងសេចក្ដីថ្លែងដោះសា ចំពោះបណ្ដឹងតបត្រូវបំពេញនូវលក្ខខណ្ឌដូចគ្នាទៅនឹងសេចក្ដីថ្លែងដោះសាររបស់ខាងភាគីអ្នកឆ្លើយតបដែរ។[66]

ប្រសិនបើភាគីប្ដឹងទាមទារខកខានក្នុងការដាក់សេចក្ដីថ្លែងទាមទារ ដោយមិនបានបង្ហាញពីមូលហេតុគ្រប់គ្រាន់នៅក្នុងអំឡុងពេលកំណត់ និងប្រសិនបើសមស្របវេទិកាមជ្ឈត្តកម្មត្រូវចេញសេចក្ដីបង្គាប់ឱ្យបញ្ឈប់ដំណើរការមជ្ឈត្តការ បន្ទាប់ពីសម្រេចលើបញ្ហាផ្សេងទៀតដែលនៅសេសសល់ និងត្រូវដោះស្រាយ។

នៅគ្រប់ករណីទាំងអស់ ដោយមិនបានបង្ហាញពីមូលហេតុគ្រប់គ្រាន់ ប្រសិនបើភាគីវិវាទណាមួយខកខាន ឬបដិសេធក្នុងការដាក់សេចក្ដីថ្លែងនានា ដែលតម្រូវក្នុងការចូលរួមក្នុងវេទិកាមជ្ឈត្តកម្ម ឬក្នុងការគោរពតាមវិធានមជ្ឈត្តការ ឬសេចក្ដីបង្គាប់ សេចក្ដីណែនាំ ឬមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម។ វេទិកាមជ្ឈត្តកម្មយល់ឃើញថាសមស្របអាចដំណើរការមជ្ឈត្តការ និងចេញមជ្ឈត្តវិនិច្ឆ័យដោយផ្អែកតាមសេចក្ដីថ្លែង និងភស្ដុតាងដែលបានដាក់មកវេទិកាមជ្ឈត្តកម្ម។[67]

## ២.៥. សវនាការនៃវេទិកាមជ្ឈត្តកម្ម

ដើម្បីអាចដំណើរការសវនាការមជ្ឈត្តការផ្នែកពាណិជ្ជកម្មបាន ជាចាំបាច់ត្រូវធ្វើឡើងដោយការបើកសវនាការ ដើម្បីឱ្យគូភាគីធ្វើទាញហេតុផល និងធ្វើសេចក្ដីថ្លែងការណ៍អំពីមធ្យោបាយទាមទារ និងធ្វើសេចក្ដីថ្លែងការអំពីមធ្យោបាយដោះសាផងដែរ។ ទៀតសោត វេទិកាមជ្ឈត្តកម្មត្រូវកំណត់កាលបរិច្ឆេទ ពេលវេលា ទីកន្លែង និងរបៀបនៃការធ្វើមជ្ឈត្តការជាមុនសិន ក្នុងករណីនេះយើងតែងតែសង្កេតឃើញថានៅមុនពេលសវនាការវេទិកាមជ្ឈត្តកម្ម ត្រូវធ្វើសេចក្ដីបង្គាប់នីតិវិធីដែលជារបៀបវារៈនៃនីតិវិធីធ្វើសវនាការ។ ជាគោលការណ៍ សវនាការនៃវេទិកាមជ្ឈត្តកម្ម វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថាធ្វើឡើងដោយផ្ទាល់មាត់ ឬធ្វើឡើងដោយផ្អែកលើឯកសារ និងលិខិតស្នាម។ ប៉ុន្តែ ប្រសិនបើគូភាគីព្រមព្រៀងជ្រើសរើសយកសវនាការដោយផ្ទាល់មាត់ ឬជ្រើសរើសយកសវនាការដោយផ្អែកលើឯកសារ ហេតុនេះ សវនាការ ត្រូវធ្វើឡើងតាមឆន្ទៈរបស់គូភាគីតែប៉ុណ្ណោះ។[68] ហេតុដូច្នេះ ដំណើរការសវនាការនៃវេទិកាមជ្ឈត្តកម្ម អាចធ្វើឡើងតាមរយៈ **២.៥.១. សវនាការដោយផ្ទាល់មាត់ ឬ២.៥.២. សវនាការដោយផ្អែកលើឯកសារ និងលិខិតស្នាម។**

---

[66] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៧.៤.

[67] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៧.៧.

[68] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៩.១

### ២.៥.១. សវនាការដោយផ្ទាល់មាត់

ក្នុងករណី គូភាគីព្រមព្រៀងគ្នាដោយជ្រើសរើសយកដំណើរការនៃសវនាការដោយផ្ទាល់មាត់ វេទិកាមជ្ឈត្តកម្ម ត្រូវកំណត់កាលបរិច្ឆេទ ពេលវេលា ទីកន្លែង និងរបៀបវារៈនៃការធ្វើមជ្ឈត្តការ ហើយវេទិកាមជ្ឈត្តកម្មត្រូវធ្វើការជូនដំណឹងជាមុនទៅគូភាគីវិវាទអំពីបញ្ហាទាំងនេះ យ៉ាងហោចណាស់ ១៥ (ដប់ប្រាំ) ថ្ងៃមុនកាលបរិច្ឆេទធ្វើសវនាការ។ ជាមួយគ្នានេះដែរ យ៉ាងហោចណាស់ ១៥ (ដប់ប្រាំ) ថ្ងៃមុនពេលធ្វើសវនាការ វេទិកាមជ្ឈត្តកម្មអាចផ្តល់នូវបញ្ជីនៃចំណុចវិវាទ ឬសំណួរផ្សេងៗដែលវេទិកាមជ្ឈត្តកម្មមានបំណងផ្តល់ឱ្យគូភាគីវិវាទទាំងអស់ដើម្បីពិចារណាជាពិសេស។[69] ប្រសិនបើភាគីវិវាទនៃដំណើរការមជ្ឈត្តការខកខានក្នុងការបង្ហាញខ្លួននៅក្នុងសវនាការដោយផ្ទាល់មាត់ដោយមិនបានបង្ហាញមូលហេតុគ្រប់គ្រាន់នៃការខកខាននេះ វេទិកាមជ្ឈត្តកម្មអាចបន្តនីតិវិធី និងអាចចេញមជ្ឈត្តវិនិច្ឆ័យដោយផ្អែកលើសេចក្តីថ្លែង និងភស្តុតាងដែលបានដាក់មកវេទិកាមជ្ឈត្តកម្ម។

ប្រសិនការធ្វើសវនាការផ្ទាល់មាត់ត្រូវបានធ្វើឡើង វេទិកាមជ្ឈត្តកម្ម អាចសម្រេចថាតើសវនាការនឹងត្រូវធ្វើឡើងដោយមានការចូលរួមដោយផ្ទាល់ ឬពីចម្ងាយតាមរយៈសន្និសីទ វីដេអូ ទូរស័ព្ទ ឬដោយមធ្យោបាយអេឡិចត្រូនិចផ្សេងទៀតជាមួយអ្នកចូលរួមដែលស្ថិតនៅទីកន្លែងមួយ ឬច្រើនបន្ទាប់ពីបានពិភាក្សាជាមួយគូភាគីវិវាទ ដោយផ្អែកលើអង្គហេតុពាក់ព័ន្ធ និងកាលៈទេសៈនៃសំណុំរឿង ដោយផ្អែកលើកាលៈទេសៈនៃមជ្ឈត្តការតម្រូវក្នុងដំណាក់កាលណាមួយនៃដំណើរការមជ្ឈត្តការនឹងមុនពេលចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ វេទិកាមជ្ឈត្តកម្មអាចសម្រេចឱ្យមានមជ្ឈត្តការបន្ថែមបាន។[70]

ក្នុងដំណើរការមជ្ឈត្តការ វេទិកាមជ្ឈត្តកម្ម ត្រូវទទួលបន្ទុកគ្រប់គ្រងទាំងស្រុងលើសវនាការដែលគូភាគីនៃ វិវាទទាំងអស់មានសិទ្ធិចូលរួម។ លើកលែងតែមានការឯកភាពពីវេទិកាមជ្ឈត្តកម្ម និងគូភាគីវិវាទ អ្នកដែលមិនពាក់ព័ន្ធនឹងដំណើរការនៃនីតិវិធី មិនត្រូវបានអនុញ្ញាតឱ្យចូលរួមឡើយ។[71]

### ២.៥.២. សវនាការដោយផ្អែកលើឯកសារ និងលិខិតស្នាម

យើងសង្កេតឃើញថា ប្រសិនបើគូភាគីវិវាទមានការព្រមព្រៀងជ្រើសរើសយកមធ្យោបាយសវនាការដោយផ្អែកលើឯកសារ និងលិខិតស្នាម ហេតុនេះការធ្វើសវនាការផ្ទាល់មាត់មិនចាំបាច់ប្រព្រឹត្តឡើងឡើយ ពោលគឺគូភាគីវិវាទអាចកំណត់អំពីដំណើរការសវនាការដោយគ្រាន់តែធ្វើការបង្ហាញនូវភស្តុតាងជាឯកសារ និងធ្វើសេចក្តីថ្លែងទាមទារ ឬសេចក្តីថ្លែងដោះសា ជាលាយលក្ខណ៍អក្សរដាក់ជូនវេទិកាមជ្ឈត្តកម្មដើម្បីធ្វើការ

[69] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៩.៥.

[70] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៩.២

[71] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៣៩.៦

ពិចារណាតែប៉ុណ្ណោះ។ ត្រង់ចំណុចនេះបង្ហាញឱ្យឃើញថា ដំណើរការនៃនីតិវិធីមជ្ឈត្តការមានលក្ខណៈបត់បែន និងទន់ភ្លន់ ជាងនីតិវិធីនៅក្នុងតុលាការពីព្រោះថានីតិវិធីនៅតុលាការ ចៅក្រមជាអ្នកដឹកនាំនីតិវិធីទាំងស្រុង ផ្ទុយទៅវិញ ការដោះស្រាយវិវាទតាមរយៈយន្តការមជ្ឈត្តការ គូភាគីជាអ្នកកំណត់កាលវិភាគ និងរបៀបនៃការធ្វើសវនាការ ទាំងនេះគឺជាចំណុចពិសេស និងគួរឱ្យកត់សម្គាល់ នៃនីតិវិធីរបស់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

## ២.៦. នីតិវិធីចេញមជ្ឈត្តវិនិច្ឆ័យ

បន្ទាប់ពីកម្មវត្ថុវិវាទត្រូវបានដោះស្រាយចប់ហើយ ជាចុងក្រោយនោះគឺការចេញនូវមជ្ឈត្តវិនិច្ឆ័យ។ ការចេញនូវសេចក្តីសម្រេចនេះ ជាសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្មដែលពិចារណាទៅលើចំណុចមួយចំនួន ដូចជាអង្គហេតុ មូលដ្ឋានច្បាប់ វិធាន លក្ខខណ្ឌផ្សេងៗក្នុងកិច្ចសន្យា និងទម្លាប់ផ្នែកពាណិជ្ជកម្មដោយស្របតាមគោលការណ៍សមធម៌។[72]

ប៉ុន្តែ មុននឹងចេញសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យជាផ្លូវការនោះ វេទិកាមជ្ឈត្តកម្មត្រូវធ្វើសេចក្តីព្រាងមួយ ហើយបញ្ជូនសេចក្តីព្រាងសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យនោះទៅកាន់អគ្គលេខាធិការដ្ឋានក្នុងគោលបំណងធ្វើការត្រួតពិនិត្យលើទម្រង់ផ្សេងៗ ចំពោះសេចក្តីសម្រេចនោះមុនធ្វើការចេញសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ។ នៅក្នុងការចេញនូវមជ្ឈត្តវិនិច្ឆ័យនោះដែរ ត្រូវធ្វើឡើងជាទម្រង់លាយលក្ខណ៍អក្សរដែលបានព្រមព្រៀង បញ្ជាក់មូលហេតុ កាលបរិច្ឆេទ ទីកន្លែង និងចុះហត្ថលេខាដោយមជ្ឈត្តករភាគច្រើន។ ហេតុដូច្នេះ ក្នុងចំណុច **២.៦. នីតិវិធីចេញមជ្ឈត្តវិនិច្ឆ័យ** ត្រូវមានទម្រង់ច្បាស់លាស់ ហើយយើងនឹងធ្វើការបកស្រាយនៅក្នុង **២.៦.១. ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ ២.៦.២. ការត្រួតពិនិត្យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ ២.៦.៣. ប្រភេទនៃមជ្ឈត្តវិនិច្ឆ័យ ២.៦.៤. ការចេញមជ្ឈត្តវិនិច្ឆ័យ និង២.៦.៥. អានុភាព និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ។**

### ២.៦.១. ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ

មជ្ឈត្តវិនិច្ឆ័យត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែគូភាគីវិវាទបានព្រមព្រៀងគ្នាផ្សេងពីនេះ និងស្របតាមវិធានស្តីពីមជ្ឈត្តការដែលចែងអំពី ការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត។ មជ្ឈត្តវិនិច្ឆ័យត្រូវមានសំអាងហេតុ ដែលជាមូលដ្ឋាននៃការសម្រេចចិត្ត។[73]

មជ្ឈត្តវិនិច្ឆ័យត្រូវមានការចុះកាលបរិច្ឆេទ និងទីកន្លែងដែលចេញមជ្ឈត្តវិនិច្ឆ័យនោះ និងត្រូវចុះហត្ថលេខា ដោយមជ្ឈត្តករទាំងអស់ ដោយឡែកចំពោះវេទិកាមជ្ឈត្តកម្មដែលមានមជ្ឈត្តករច្រើនរូបហត្ថលេខា

[72] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា៣៦

[73] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៤៩.

របស់សមាជិកភាគច្រើននៃវេទិកាមជ្ឈត្តកម្ម ត្រូវចាត់ទុកថាគ្រប់គ្រាន់។ ប៉ុន្តែ មជ្ឈត្តករដទៃទៀតដែលមិនបានចុះហត្ថលេខាតម្រូវឱ្យធ្វើការបញ្ជាក់ពីមូលហេតុដែលខ្លួនអវត្តមានមិនបានចុះហត្ថលេខាលើមជ្ឈត្តវិនិច្ឆ័យនោះ។[74]

មជ្ឈត្តករ ឬវេទិកាមជ្ឈត្តកម្ម អាចធ្វើការចេញមជ្ឈត្តវិនិច្ឆ័យរបស់ខ្លួនបានបន្ទាប់ពីអគ្គលេខាធិការដ្ឋានបានពិនិត្យ និងឯកភាពចំពោះទម្រង់របស់មជ្ឈត្តវិនិច្ឆ័យនោះ។

### ២.៦.២. ការត្រួតពិនិត្យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ

តាមវិធានមជ្ឈត្តការបានកំណត់ថា មុនពេលចេញមជ្ឈត្តវិនិច្ឆ័យ វេទិកាមជ្ឈត្តកម្មត្រូវបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យទៅអគ្គលេខាធិការដ្ឋាន ដើម្បីធ្វើការពិនិត្យពិច័យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ។ សេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យនឹងត្រូវបានបញ្ជូនទៅអគ្គលេខាធិការដ្ឋានក្នុងអំឡុងពេល ៤៥(សែសិបប្រាំ) ថ្ងៃប្រតិទិនគិតចាប់ពីថ្ងៃដែលវេទិកាមជ្ឈត្តកម្មប្រកាសបិទដំណើរការមជ្ឈត្តកម្ម ប្រសិនបើអគ្គលេខាធិការពន្យារពេលកំណត់ស្របតាមសំណើរបស់វេទិកាមជ្ឈត្តកម្ម ឬការព្រមព្រៀងរបស់គូភាគីវិវាទ។ ស្របតាមប្រការ ៥០.១ នៃវិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ក្នុងអំឡុងពេល ៣០(សាមសិប) ថ្ងៃប្រតិទិន គិតចាប់ពីថ្ងៃទទួលបានសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យ អគ្គលេខាធិការដ្ឋានអាចធ្វើការស្នើកែប្រែលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ និងមិនធ្វើឱ្យប៉ះពាល់ដល់សេរីភាពក្នុងការសម្រេចរបស់វេទិកាមជ្ឈត្តកម្មឡើយ។ ការស្នើសុំឱ្យមានការកែប្រែលើមជ្ឈត្តវិនិច្ឆ័យក៏អាចជាកម្មវត្ថុក្នុងការឱ្យមានការកែតម្រូវ ការបំភ្លឺលំអិត និងការបកស្រាយនូវមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែមផងដែរ។ ការកែតម្រូវទៅលើមជ្ឈត្តវិនិច្ឆ័យ វេទិកាមជ្ឈត្តកម្មត្រូវធ្វើឡើងក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃប្រតិទិនបន្ទាប់ពីទទួលបានមជ្ឈត្តវិនិច្ឆ័យ។[75]

### ២.៦.៣. ប្រភេទនៃមជ្ឈត្តវិនិច្ឆ័យ

#### ២.៦.៣.១. មជ្ឈត្តវិនិច្ឆ័យចុងក្រោយ

**មជ្ឈត្តវិនិច្ឆ័យចុងក្រោយ** គឺសំដៅលើមជ្ឈត្តវិនិច្ឆ័យស្ថាពរដែលធ្វើឡើងដោយមជ្ឈត្តករដែលសម្រេចលើបញ្ហាទាំងអស់ របស់គូភាគីវិវាទ។ នៅក្រោយការចេញមជ្ឈត្តវិនិច្ឆ័យ ភាគីដែលចាញ់អាចធ្វើការប្តឹងជំទាស់ទៅតុលាការ ដើម្បីស្នើសុំមោឃភាពមជ្ឈត្តវិនិច្ឆ័យ ស្របតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ដោយឡែក ភាគីដែលឈ្នះ អាចធ្វើការដាក់ពាក្យសុំទទួលស្គាល់ និងដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យនៅតុលាការក្នុងប្រទេសដែលជាសមាជិកនៃអនុសញ្ញាទីក្រុងញ៉ូវយ៉ក។ លើសពីនេះទៀត ការចេញមជ្ឈត្តវិនិច្ឆ័យចុងក្រោយ នាំឱ្យបញ្ចប់កាតព្វកិច្ចរបស់មជ្ឈត្តករ ដែលមានន័យថា មជ្ឈត្តករលែងមានយុត្តាធិការក្នុងការដោះស្រាយវិវាទនោះបន្តទៀត។

---

[74] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៤៩.៣.

[75] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៥៣

**២.៦.៣.២. មជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន**

**មជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន** ពេលខ្លះត្រូវបានប្រើន័យដូចទៅនឹង **មជ្ឈត្តវិនិច្ឆ័យដោយផ្នែក។** អ្នកវិភាគខ្លះធ្វើការបែងចែកដោយនិយាយថា មជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន គឺសេចក្តីសម្រេចដោះស្រាយទៅលើបញ្ហាយុត្តាធិការ ឬច្បាប់គ្រប់គ្រង និងមជ្ឈត្តវិនិច្ឆ័យដោយផ្នែក គឺសេចក្តីសម្រេចទៅលើការទាមទារ ជាសារធាតុរវាងគូភាគី។ មជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន ឬ ដោយផ្នែក មិនធ្វើការសម្រេច ទៅលើបញ្ហាទាំងអស់រវាងគូភាគីវិវាទឡើយ។ បើទោះបីជា មជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន មិនសម្រេចលើបញ្ហាទាំងអស់ ក៏ប៉ុន្តែ មជ្ឈត្តវិនិច្ឆ័យនោះ គឺជាមជ្ឈត្តវិនិច្ឆ័យស្ថាពរ មានអានុភាពកាតព្វកិច្ចចំពោះគូភាគីវិវាទ។ ភាគីដែលចាញ់អាចធ្វើការ ប្តឹងជំទាស់ទៅតុលាការ ដើម្បីស្នើសុំមោឃភាពមជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន ស្របតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

**២.៦.៣.៣. មជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀង**

នៅក្នុងអំឡុងពេលដំណើរការមជ្ឈត្តការ គូភាគីអាចធ្វើការដោះស្រាយបញ្ចប់វិវាទរបស់ពួកគេតាមការព្រមព្រៀង ដោយមិនចាំបាច់រង់ចាំការសម្រេចរបស់មជ្ឈត្តករឡើយ។ វិធានស្តីពីមជ្ឈត្តការ អនុញ្ញាតឱ្យគូភាគីស្នើសុំមជ្ឈត្តករដើម្បីចេញមជ្ឈត្តវិនិច្ឆ័យផ្អែកតាមការព្រមព្រៀងរវាងគូភាគីវិវាទ។ ប្រសិនបើ គូភាគីវិវាទបានធ្វើការទូទាត់សំណងនៃការខូចខាតសព្វគ្រប់នៅពេលធ្វើការព្រមព្រៀងបញ្ចប់វិវាទ គូភាគីអាចនឹងមិនចាំបាច់ស្នើសុំឱ្យមជ្ឈត្តករ ចេញមជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀងនោះទេ។ ក៏ប៉ុន្តែ ប្រសិនបើគូភាគីវិវាទមិនទាន់បានទូទាត់សំណងនៃការខូចខាត ដែលបានព្រមព្រៀងដើម្បីបញ្ចប់វិវាទនៅឡើយ គូភាគីគួរតែស្នើសុំឱ្យមជ្ឈត្តករ បញ្ចូលការព្រមព្រៀងទៅក្នុងមជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀង ដើម្បីធានាថាគូភាគីដែលត្រូវទទួលបានសំណងនៃការខូចខាត អាចប្តឹងទៅតុលាការ ដើម្បីទទួលស្គាល់និងអនុវត្តមជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀង ប្រសិនបើភាគីម្ខាងទៀតមិនព្រមអនុវត្តតាមខសន្យា។

**២.៦.៣.៤. មជ្ឈត្តវិនិច្ឆ័យដោយការបំពាន**

**មជ្ឈត្តវិនិច្ឆ័យដោយការបំពាន** គឺជាមជ្ឈត្តវិនិច្ឆ័យដែលធ្វើឡើងដោយភាគីឆ្លើយតបខកខានក្នុងការចូលរួមក្នុងដំណើរការនីតិវិធីមជ្ឈត្តការ។ ប្រសិនបើភាគីឆ្លើយតបខកខានក្នុងការចូលរួមក្នុងដំណើរការនីតិវិធីមជ្ឈត្តការ មជ្ឈត្តករមិនអាចសម្រេចដោយផ្តល់ជាប្រយោជន៍ដល់ភាគីទាមទារដោយស្វ័យប្រវត្តិនោះទេ។ មជ្ឈត្តករត្រូវពិនិត្យ មើលភស្តុតាងដែលបានដាក់មកមុននឹងធ្វើការសម្រេចទៅលើអង្គសេចក្តី។ នៅក្នុងការចេញមជ្ឈត្តវិនិច្ឆ័យដោយការបំពាននេះ មជ្ឈត្តករត្រូវតែធានាថាគ្រប់ដំណើរការនីតិវិធី ភាគីឆ្លើយតបទទួលបានការជូនដំណឹង និងមានឱកាសគ្រប់គ្រាន់ក្នុងការចូលរួមនៅក្នុងដំណើរការនីតិវិធីមជ្ឈត្តការ។ មជ្ឈត្តករត្រូវបង្ហាញថា ខ្លួនបានផ្តល់ឱកាសសមរម្យឱ្យភាគីឆ្លើយតប បង្ហាញពីករណីរបស់ខ្លួនដោយប្រសិទ្ធភាព។

### ២.៦.៤. ការចេញមជ្ឈត្តវិនិច្ឆ័យ

នៅពេលដែលវេទិកាមជ្ឈត្តកម្ម បានចេញមជ្ឈត្តវិនិច្ឆ័យសមស្របត្រឹមត្រូវទៅតាមទម្រង់ហើយនោះ អគ្គលេខាធិការដ្ឋាន ត្រូវបោះត្រារបស់ ម.ជ.ម. លើមជ្ឈត្តវិនិច្ឆ័យដោយមិនបង្អង់ និងបញ្ជូនមជ្ឈត្តវិនិច្ឆ័យនោះទៅភាគីវិវាទទាំងអស់ប្រសិនបើការបង់ប្រាក់ជាមុនដែលតម្រូវត្រូវបានបង់ទៅ ម.ជ.ម. ឬក្នុងករណីបើកម្រៃសេវាទាំងអស់លើមជ្ឈត្តការត្រូវបានបង់គ្រប់ចំនួនទៅ ម.ជ.ម. សម្រាប់មជ្ឈត្តវិនិច្ឆ័យស្ថាពរ។[76] គូភាគីវិវាទត្រូវបង់ទៅ ម.ជ.ម. នូវប្រាក់បង់ជាមុនសម្រាប់កម្រៃសេវាមជ្ឈត្តកម្មក្នុងតម្លៃប៉ាន់ស្មានណាមួយ លើកលែងតែកម្រៃសេវាចុះបញ្ជីដែលត្រូវបង់ទាំងស្រុង។[77]

### ២.៦.៥. អានុភាព និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ

ក្រោយពេលវេទិកាមជ្ឈត្តកម្មបានចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរហើយ មជ្ឈត្តវិនិច្ឆ័យនោះនឹងមានអានុភាពអនុវត្តចំពោះគូភាគីវិវាទចាប់ពីកាលបរិច្ឆេទដែលមជ្ឈត្តវិនិច្ឆ័យនោះត្រូវបានចេញ។ មជ្ឈត្តវិនិច្ឆ័យទោះជាបានធ្វើឡើងក្នុងប្រទេសណាក៏ដោយ គឺត្រូវបានគេទទួលស្គាល់ថាជាកាតព្វកិច្ច។[78] គូភាគីវិវាទត្រូវអនុវត្តមជ្ឈត្តវិនិច្ឆ័យដោយមិនបង្អង់។ គូភាគីវិវាទទួលស្គាល់ថាខ្លួនមិនមានសិទ្ធិក្នុងការប្ដឹងជំទាស់ផ្សេងក្រៅពីស្របតាមបញ្ញត្តិច្បាប់ដែលមានអានុភាពបង្ខំ ហើយដោយមិនអាចដកហូតវិញបាន គូភាគីវិវាទធ្វើការបោះបង់សិទ្ធិក្នុងការប្ដឹងជំទាស់របស់ខ្លួន ដរាបណាសិទ្ធិក្នុងការប្ដឹងជំទាស់នោះអាចបោះបង់បានដោយមានសុពលភាព។[79]

## ២.៧. ការទទួលស្គាល់ និងការប្ដឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ

រាល់មជ្ឈត្តវិនិច្ឆ័យទាំងអស់អាចអនុវត្តទៅបានលុះត្រាតែមានការទទួលស្គាល់ពីសាលាឧទ្ធរណ៍។ ផ្ទុយទៅវិញ ក្នុងករណីដែលភាគីណាមួយយល់ឃើញថាមជ្ឈត្តវិនិច្ឆ័យនោះធ្វើឡើងខុសទម្រង់ ភាគីអាចប្ដឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមទម្រង់ជាបណ្ដឹងបដិសេធ តាមបែបបទដែលកំណត់ក្នុងច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ការទទួលស្គាល់ និងការប្ដឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យអាចធ្វើទៅបានដោយអនុលោមតាមកម្មវត្ថុចំនួន៣ ដូចជា មជ្ឈត្តវិនិច្ឆ័យចុងក្រោយ មជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀងនិងមជ្ឈត្តវិនិច្ឆ័យដោយការបំពាន។ អាស្រ័យហេតុនេះ ដើម្បីឱ្យកាន់តែងាយយល់ទៅលើចំណុចនេះ យើងនឹងសិក្សាអំពី **២.៧.១. ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យ** និង**២.៧.២. ការប្ដឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ។**

[76] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៥១.

[77] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៥២

[78] ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា៤៥

[79] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៥២

### ២.៧.១. ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យ

មជ្ឈត្តវិនិច្ឆ័យ ទោះជាបានធ្វើនៅប្រទេសណាក៏ដោយត្រូវបានគេទទួលស្គាល់ថាជាកាតព្វកិច្ច ដោយធ្វើការដាក់ពាក្យសុំទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យជាលាយលក្ខណ៍អក្សរទៅសាលាឧទ្ធរណ៍។[80] ដោយហេតុថានៅក្នុងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មិនត្រឹមតែមានបញ្ញត្តិអំពីការទទួលមជ្ឈត្តវិនិច្ឆ័យក្នុងប្រទេសប៉ុណ្ណោះទេ ប៉ុន្តែ មជ្ឈត្តវិនិច្ឆ័យបរទេសក៏អាចយកមកអនុវត្តក្នុងប្រទេសកម្ពុជាបានតាមរយៈការដាក់ពាក្យសុំផងដែរ។ ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យបរទេស អាចសុំទទួលស្គាល់បានលុះត្រាតែជាប្រទេសដែលជាភាគីនៃអនុសញ្ញាទីក្រុងញូវយ៉ក។ អាស្រ័យហេតុនេះ ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យត្រូវបានចែកជា២ (ពីរ) គឺ **២.៧.១.១. ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យក្នុងប្រទេស** និង**២.៧.១.២. ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យបរទេស**។

#### ២.៧.១.១. ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យក្នុងប្រទេស

មជ្ឈត្តវិនិច្ឆ័យក្នុងប្រទេសជាមជ្ឈត្តវិនិច្ឆ័យដែលចេញដោយមជ្ឈត្តករ នៃមជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលមានអានុភាពអនុវត្តបាននៅក្នុងប្រទេសតាមរយៈការដាក់ពាក្យសុំទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យទៅកាន់សាលាឧទ្ធរណ៍។ ភាគីដែលសំអាងលើមជ្ឈត្តវិនិច្ឆ័យ ឬដែលដាក់ពាក្យសុំឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យត្រូវផ្តល់ច្បាប់ដើមត្រឹមត្រូវពិតប្រាកដនៃមជ្ឈត្តវិនិច្ឆ័យ និងច្បាប់ដើមនៃកិច្ចព្រមព្រៀងផ្សះផ្សា ឬអត្ថបទថតចម្លងដែលបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម។ ប្រសិនបើមជ្ឈត្តវិនិច្ឆ័យ ឬកិច្ចព្រមព្រៀងនោះមិនបានធ្វើជាភាសាខ្មែរទេ ភាគីនោះត្រូវផ្តល់សេចក្តីបកប្រែជាភាសាខ្មែរ ដែលមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម។ បន្ទាប់ពីទទួលបានសេចក្តីសម្រេចទទួលស្គាល់ និងដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យពីតុលាការរួចមក ភាគីត្រូវដាក់ពាក្យសុំអនុវត្តដោយបង្ខំទៅតាមនីតិវិធីអនុវត្តដោយបង្ខំដោយយកដីកាសម្រេចទទួលស្គាល់នេះ ជាលិខិតអនុវត្ត ដូចមានកំណត់យ៉ាងជាក់លាក់នៅក្នុងមាត្រា ៣៥០ កថាខណ្ឌទី២ ចំណុច ជ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ម្យ៉ាងវិញទៀតពាក្យសុំចេញដីកាសម្រេចអនុវត្តមជ្ឈត្តវិនិច្ឆ័យក្នុងប្រទេសត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើកន្លែងរបស់កូនបំណុលនៃការអនុវត្ត ហើយក្នុងករណីដែលមិនអាចកំណត់តុលាការដែលមានសមត្ថកិច្ចបានទេនោះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬទ្រព្យរបស់កូនបំណុលនៃការអនុវត្តដែលអាចរឹបអូសបានស្ថិតនៅ។ បន្ទាប់ពីតុលាការបានពិនិត្យចប់សព្វគ្រប់ តុលាការត្រូវប្រកាសឱ្យអនុវត្តដោយបង្ខំតាមមជ្ឈត្តវិនិច្ឆ័យ ហើយដីកាសម្រេចនោះអាចប្តឹងជំទាស់បាន។[81]

[80] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា៤៥

[81] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៥៣

**២.៧.១.២. ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យបរទេស**

មជ្ឈត្តវិនិច្ឆ័យបរទេស ជាមជ្ឈត្តវិនិច្ឆ័យដែលចេញដោយមជ្ឈត្តករបរទេស។ មជ្ឈត្តវិនិច្ឆ័យបរទេស ក៏ដូចជាមជ្ឈត្តវិនិច្ឆ័យក្នុងស្រុកផងដែរគឺត្រូវមានការទទួលស្គាល់ តាមរយៈការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ទៅសាលាឧទ្ធរណ៍។ នៅក្នុងប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស ដែលរដ្ឋសភាអនុម័ត នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ ដោយបានបញ្ញត្តិអំពីសមត្ថកិច្ចរបស់តុលាការក្នុងការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យក្នុងប្រទេស។ ក្នុងនោះតុលាការកម្ពុជាត្រូវបានប្រគល់សមត្ថកិច្ចវិនិច្ឆ័យលើសំណើសុំការទទួលស្គាល់ និងការប្រតិបត្តិនូវសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេស ទោះបីជាអ្នកសុំមានសញ្ជាតិអ្វីក៏ដោយ។ តុលាការកម្ពុជាត្រូវតែសម្រេចឱ្យស្របតាមអនុសញ្ញាទីក្រុងញូវយ៉ក ក្នុងការវិនិច្ឆ័យលើការទទួលស្គាល់ និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស។ នីតិវិធីនៃការដាក់ពាក្យសុំទទួលស្គាល់អនុវត្តតាមការស្នើសុំទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យក្នុងស្រុកដែរ។ បន្ទាប់ពីសាលាឧទ្ធរណ៍ទទួលពាក្យសុំហើយត្រូវធ្វើលិខិតជូនដំណឹងអំពីបណ្តឹងនេះទៅភាគីដែលសេចក្តីសម្រេចត្រូវអនុវត្តចំពោះខ្លួនក្នុងរយៈពេល ១០ (ដប់) ថ្ងៃប្រតិទិន។[82]

**២.៧.២. ការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ**

មជ្ឈត្តវិនិច្ឆ័យ ជាសេចក្តីសម្រេចចុងក្រោយដែលភាគីមិនអាចធ្វើការតវ៉ាបាន។ តែទោះបីជាយ៉ាងនេះក្តី បញ្ញត្តិនៃច្បាប់បានកំណត់នូវលក្ខខណ្ឌមួយចំនួនដែលភាគីវិវាទអាចធ្វើការប្តឹងតវ៉ានឹងមជ្ឈត្តវិនិច្ឆ័យនោះ។ តួយ៉ាង ការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យនេះ យើងខ្ញុំនឹងលើកចំណុចសំខាន់ៗចំនួន ២ (ពីរ) ដែលនឹងធ្វើការបកស្រាយក្នុង **២.៧.២.១. ការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យក្នុងប្រទេស** និង**២.៧.២.២. ការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យបរទេស។**

**២.៧.២.១. ការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យក្នុងប្រទេស**

ការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ មិនមែនអាចធ្វើឡើងដោយគ្រាន់តែមានការមិនពេញចិត្តនឹងមជ្ឈត្តវិនិច្ឆ័យនោះទេ ភាគីវិវាទអាចប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យបានតែចំពោះដំណើរការ នៃវិវាទមជ្ឈត្តការបានធ្វើខុសទៅនឹងនីតិវិធីដែលភាគីបានកំណត់ក្នុងកិច្ចព្រមព្រៀង ឬក៏ផ្ទុយនឹងបញ្ញត្តិនៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[83]ការប្តឹងជំទាស់នឹងនីតិវិធីក្នុងដំណើរការមជ្ឈត្តការអាចត្រូវធ្វើឡើង បើភាគីណាមួយនៃវិវាទបានបាត់បង់សិទ្ធិមួយចំនួនដូចជាការតែងតាំងមជ្ឈត្តករ ឬមិនបានទទួលដំណឹងពីដំណើរការមជ្ឈត្តការ ឬកិច្ចព្រមព្រៀង

[82] ច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស ឆ្នាំ២០០១ មាត្រា៨

[83] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា៤៤

មជ្ឈត្តការនោះពុំអាចយកជាការបាន ឬកម្មវត្ថុនៃវិវាទពុំអាចដោះស្រាយតាមរយៈមជ្ឈត្តការបាន ឬដំណើរការនៃមជ្ឈត្តការមិនស្របតាមកិច្ចព្រមព្រៀងរបស់ភាគី ឬមជ្ឈត្តវិនិច្ឆ័យផ្ទុយនឹងនយោបាយសាធារណៈជាដើម។[84]

ជាទូទៅ ភាគីវិវាទប្រសិនបើបានបញ្ចប់នីតិវិធីត្រឹមវេទិកាមជ្ឈត្តកម្មនោះ គឺពុំអាចធ្វើការប្ដឹងបានទេ នៅក្នុងកម្រិតមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដោយសារតែមជ្ឈត្តវិនិច្ឆ័យ គឺជាសេចក្ដីសម្រេចចុងក្រោយដែលបិទផ្លូវតវ៉ា។ ក៏ប៉ុន្តែ ដោយសារយន្តការនេះត្រូវបានចូលជាធរមាន នៅក្នុងព្រះរាជាណាចក្រកម្ពុជាផ្ដល់សិទ្ធិដល់គូភាគីវិវាទក្នុងការធ្វើបណ្ដឹងជំទាស់ដើម្បីបដិសេធមជ្ឈត្តវិនិច្ឆ័យទៅកាន់ស្ថាប័នតុលាការ ទើបសេចក្ដីសម្រេចរបស់វេទិកាមជ្ឈត្តកម្មអាចត្រូវបានយកមកពិនិត្យ និងវិនិច្ឆ័យឡើងវិញដោយតុលាការមានសមត្ថកិច្ច។ ជាការបញ្ជាក់ផងដែរថា ការធ្វើបណ្ដឹងជំទាស់នេះ គឺមិនមែនជាការធ្វើបណ្ដឹងមួយដោយស្រេចតែបំណងរបស់ភាគីវិវាទ ដោយគ្មានមូលហេតុ ឬភស្តុតាងត្រឹមត្រូវ ឬដើម្បីពន្យារពេលនៃការអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះ។ ការពិនិត្យមើលទៅលើបណ្ដឹងជំទាស់នេះ ភាគីត្រូវមានភស្តុតាងដាក់បន្ទុកដូចមានចែងក្នុងមាត្រា៤៤ នៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ លើសពីនេះទៅទៀត ការពិនិត្យមើលមជ្ឈត្តវិនិច្ឆ័យនេះផងដែរ តុលាការពុំមានសិទ្ធិធ្វើការពិនិត្យទៅលើសេចក្ដីសម្រេចរបស់វេទិកាមជ្ឈត្តកម្មបានទាំងស្រុងទេ គឺពិនិត្យមើលបានត្រឹមក្របខណ្ឌ ឬត្រឹមមូលដ្ឋានដែលបានផ្ដល់ជូនដល់ភាគីវិវាទក្នុងការធ្វើបណ្ដឹងជំទាស់តែប៉ុណ្ណោះ។ មូលហេតុដែលតុលាការពុំអាចពិនិត្យមើលមជ្ឈត្តវិនិច្ឆ័យទាំងស្រុងបាននេះគឺដោយសារតែវេទិកាមជ្ឈត្តកម្ម គឺជាវេទិកានៃការដោះស្រាយវិវាទដែលមានចរិកលក្ខណៈឯកជន ការពារការសម្ងាត់ទាំងឡាយរបស់គូភាគីវិវាទ ពោលគឺគូភាគីវិវាទបើពុំមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរនោះទេ គឺមានកាតព្វកិច្ចរក្សាការសម្ងាត់ និងមិនត្រូវបង្ហាញនូវអង្គហេតុដែលពាក់ព័ន្ធទៅតតិយជន ឬបុគ្គលដទៃដោយគ្មានការអនុញ្ញាត ឬការព្រមព្រៀងពីភាគីម្ខាងទៀតបានឡើយ។[85] ប៉ុន្តែ មានអញ្ញត្រកម្មចំពោះវិធានស្ដីពីមជ្ឈត្តការឆ្នាំ២០២១ បានអនុញ្ញាតឱ្យភាគីនៃវិវាទបង្ហាញអង្គហេតុ ឬព័ត៌មានដែលដែលពាក់ព័ន្ធទៅកាន់តុលាការដែលមានសមត្ថកិច្ចបាន ក្នុងករណីដែលភាគីបានដាក់ពាក្យបណ្ដឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីធ្វើបណ្ដឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ។[86] លើសពីនេះទៅទៀត ក្នុងករណីដែលមានដីកាបង្គាប់ ឬដីកាកោះរបស់តុលាការមានសមត្ថកិច្ច ភាគីវិវាទចាំបាច់ត្រូវបង្ហាញនូវអង្គហេតុ ឬព័ត៌មានទាំងឡាយណាដែលពាក់ព័ន្ធតបតាមដីការបស់តុលាការមានសមត្ថកិច្ច។

[84] ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា៤៤

[85] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៦៦

[86] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៦៦.៣ (ក)

ក្នុងការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទណាមួយដែលមានបំណងចង់ប្តឹងអាចធ្វើការដាក់ពាក្យប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ជាលាយលក្ខណ៍អក្សរ និងភស្តុតាងផ្សេងៗដែលបង្ហាញពីកំហុសឆ្គងនៃនីតិវិធីរបស់វេទិកាមជ្ឈត្តកម្មដើម្បីឱ្យសាលាឧទ្ធរណ៍ធ្វើការពិនិត្យ និងសម្រេចលើបណ្តឹងទាស់នោះក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃដោយគិតចាប់ពីថ្ងៃដែលភាគីនោះបានទទួលមជ្ឈត្តវិនិច្ឆ័យ[87]ក្រោយពីសាលាឧទ្ធរណ៍បានចេញសេចក្តីសម្រេចលើបណ្តឹងទាស់នោះហើយ ប្រសិនបើភាគីមិនពេញចិត្តសេចក្តីសម្រេចនោះ ភាគីវិវាទអាចធ្វើការប្តឹងបន្តទៅតុលាការកំពូលក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ហើយសេចក្តីសម្រេចរបស់តុលាការកំពូលលើបណ្តឹងជំទាស់នេះគឺជា សេចក្តីសម្រេចចុងក្រោយបង្អស់។

ដូច្នេះហើយចំពោះភាគីដែលស្វែងរកការលុបចោល ឬស្នើសុំការកែប្រែមជ្ឈត្តវិនិច្ឆ័យ អាចសំអាងលើច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលបានកំណត់ថា សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា មានសមត្ថកិច្ចក្នុងការចេញសេចក្តីសម្រេចលើការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ ដោយមានវត្តមានផងដែរចំពោះតុលាការកំពូលជាសាលាជំនុំជម្រះក្តីចុងក្រោយ ចំពោះករណីដែលភាគីវិវាទមានបំណងក្នុងការធ្វើបណ្តឹងជំទាស់ជាមួយ នឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍។[88] សរុបមក តុលាការពិចារណា និងសម្រេចលើបណ្តឹងជំទាស់ ឬបណ្តឹងសុំបដិសេធមជ្ឈត្តវិនិច្ឆ័យ មិនផ្អែកលើអង្គសេចក្តីនៃរឿងទេ ប៉ុន្តែ ផ្អែកជាសំខាន់លើមូលហេតុកំហុសបច្ចេកទេស និងនីតិវិធីនៃដំណើរការមជ្ឈត្តការជាចម្បង។

### ២.៧.២.២. ការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យបរទេស

ក្នុងករណីដែលភាគីដែលមជ្ឈត្តវិនិច្ឆ័យបរទេសត្រូវអនុវត្តចំពោះខ្លួននោះ ភាគីនោះមានសិទ្ធិប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍កុំឱ្យទទួលស្គាល់ និងប្រតិបត្តិមជ្ឈត្តវិនិច្ឆ័យបរទេស ដោយផ្តល់ភស្តុតាង និងមានមូលដ្ឋានស្របច្បាប់ ដែលការប្តឹងជំទាស់នេះត្រូវធ្វើឡើងនៅក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិនក្រោយពីសាលាឧទ្ធរណ៍បានទទួលពាក្យសុំទទួលស្គាល់ និងប្រតិបត្តិមជ្ឈត្តវិនិច្ឆ័យបរទេស។ ក្នុងករណីនេះ សាលាឧទ្ធរណ៍អាចតម្រូវឱ្យអ្នកដាក់ពាក្យជំទាស់ដាក់ប្រាក់ធានា ក្នុងទឹកប្រាក់ដែលមិនឱ្យលើសពីចំនួនទឹកប្រាក់នៃមជ្ឈត្តវិនិច្ឆ័យបរទេស បូកនឹងការប៉ាន់ស្មានកម្រៃសេវាមេធាវី និងសោហ៊ុយផ្សេងទៀតលើការវិនិច្ឆ័យ។ ប្រសិនបើ អ្នកដាក់ពាក្យសុំជំទាស់ពុំមានលទ្ធភាពដាក់ប្រាក់ធានាទេនោះ សាលាឧទ្ធរណ៍ត្រូវចេញបញ្ជាឃាត់ទុកជាបណ្តោះអាសន្ន ឬបើពុំនោះទេ កាន់កាប់ជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិដទៃទៀតដែលជាកម្មសិទ្ធិ

[87] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា ៤២ និងមាត្រា ៤៤

[88] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា៤៤

របស់អ្នកប្ដឹងជំទាស់។ [89] ការបដិសេធលើការទទួលស្គាល់ និងការប្រតិបត្តិនូវមជ្ឈត្តវិនិច្ឆ័យបរទេសអាចធ្វើទៅបានដោយផ្អែកលើមូលដ្ឋានចំនួន ២ (ពីរ) គឺតាមសំណើសុំរបស់ភាគី និងតាមមូលហេតុដែលតុលាការយល់ឃើញថាមិនស្របច្បាប់។ តួយ៉ាង ភាគីដែលដាក់ពាក្យសុំជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យបរទេសត្រូវដាក់ពាក្យសុំដោយអាស្រ័យទៅលើមូលហេតុដែល ខ្លួនបានចុះកិច្ចព្រមព្រៀងមជ្ឈត្តការក្នុងករណីអសមត្ថភាព ឬកិច្ចព្រមព្រៀងនេះគ្មានសុពលភាព ឬកិច្ចព្រមព្រៀងមិនបានបង្ហាញនូវចំណុចណាមួយច្បាស់លាស់ក្រោមច្បាប់នៃប្រទេសណាមួយដែលការសម្រេចមជ្ឈត្តករបរទេសបានធ្វើឡើង។ ភាគីដែលប្ដឹងជំទាស់ពុំបានទទួលនូវសេចក្ដីជូនដំណឹងត្រឹមត្រូវស្ដីពីការតែងតាំងមជ្ឈត្តករ ឬនីតិវិធីនៃមជ្ឈត្តការ ឬមជ្ឈត្តវិនិច្ឆ័យបរទេសស្ដីពីជម្លោះដែលមិនស្រប ឬមិនចូលក្នុងន័យនៃការដាក់ស្នើសុំមជ្ឈត្តវិនិច្ឆ័យ ឬមជ្ឈត្តវិនិច្ឆ័យដែលមានខ្លឹមសារហួសពីវិសាលភាពនៃការដាក់ស្នើសុំ ឬនីតិវិធីនៃមជ្ឈត្តវិនិច្ឆ័យមានលក្ខណៈពុំស្របតាមកិច្ចព្រមព្រៀងរបស់គូភាគី។ ក្រៅពីការប្ដឹងជំទាស់របស់ភាគី តុលាការក៏អាចធ្វើការបដិសធមិនទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យបរទេសបានផងដែរ ក្នុងករណីដែលតុលាការយល់ឃើញថារឿងក្ដីនោះ មិនអាចនឹងធ្វើការដោះស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបាន ឬការទទួលស្គាល់ និងប្រតិបត្តិមជ្ឈត្តវិនិច្ឆ័យបរទេសផ្ទុយនឹងគោលនយោបាយសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។[90] ការសម្រេចសេចក្ដីរបស់សាលាឧទ្ធរណ៍បានទុកសិទ្ធិឱ្យភាគីម្ខាងទៀតធ្វើការប្ដឹងជំទាស់នឹងសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ទៅតុលាការកំពូលក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិនគិតពីថ្ងៃចេញសេចក្ដីសម្រេច។ ហើយតុលាការកំពូលត្រូវជំនុំជម្រះ និងចេញសាលដីកាក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិនចាប់ពីថ្ងៃដែលភាគីបានដាក់ពាក្យបណ្ដឹង ដោយពុំចាំបាច់ឡើងវិញទេ ហើយសាលដីការបស់តុលាការកំពូលជាសេចក្ដីសម្រេចចុងក្រោយហើយមិនត្រូវជាកម្មវត្ថុប្ដឹងជំទាស់ បញ្ជូនសំណុំរឿងត្រឡប់មកសាលាឧទ្ធរណ៍ពិនិត្យ ឬប្ដឹងតវ៉ាឡើយ។

[89] ច្បាប់ស្ដីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្ដីសម្រេចមជ្ឈត្តករបរទេស ឆ្នាំ២០០១ មាត្រា១១

[90] ច្បាប់ស្ដីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្ដីសម្រេចមជ្ឈត្តករបរទេស ឆ្នាំ២០០១ មាត្រា១៥

# ជំពូកទី៣

# បញ្ហាប្រឈមក្នុងការអនុវត្តនីតិវិធី

# នៃមជ្ឈត្តការផ្ដែកពាណិជ្ជកម្ម

# ជំពូកទី៣
# បញ្ហាប្រឈមក្នុងការអនុវត្តនីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

## ៣.១. បញ្ហាប្រឈមពាក់ព័ន្ធទៅនឹងកង្វះខាតព័ត៌មាន

### ៣.១.១. កម្រៃសេវា

ទោះបីជាការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការ ជាទូទៅមានតម្លៃទាបជាងការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការក៏ដោយ ក៏នៅតែត្រូវការមានការចំណាយទៅលើសេវាមជ្ឈត្តការ និងសេវាផ្សេងៗផងដែរ។ ភាគីត្រូវបង់ថ្លៃពេលវេលារបស់មជ្ឈត្តករ ថ្លៃវេទិកាមជ្ឈត្តកម្ម ក៏ដូចជាថ្លៃវិវាទធម្មតាទាំងអស់ ក៏ដូចជាថ្លៃអ្នកតំណាង។ ដោយហេតុថា មជ្ឈត្តវិនិច្ឆ័យមិនមែនបានមកពីការចរចា និងការសម្រុះសម្រួលគ្នានោះទេ ហេតុនេះ គឺអាចមានលទ្ធភាពច្រើននៃការមិនអនុវត្តតាមមជ្ឈត្តវិនិច្ឆ័យ។ ហេតុដូច្នេះ គូភាគីអាចត្រូវចំណាយបន្ថែមកាន់តែច្រើនលើសេវាមេធាវី ដែលចាំបាច់ដើម្បីបន្តសុំការអនុវត្តតាមប្រព័ន្ធតុលាការ។ ម្យ៉ាងវិញទៀត រាល់ពាក្យសុំនានា ដែលធ្វើឡើងក្រោមវិធានស្តីពីមជ្ឈត្តការនៃព្រះរាជាណាចក្រកម្ពុជា ត្រូវភ្ជាប់មកជាមួយនូវកម្រៃសេវាលើពាក្យសុំដូចមានកំណត់ក្នុងតារាងកម្រៃសេវា ម.ជ.ម.។ ការខកខានក្នុងការបង់កម្រៃសេវាលើពាក្យសុំឱ្យបានគ្រប់ចំនួនទាន់ពេលវេលា ពាក្យសុំទាំងនោះមិនត្រូវបានលើកយកមកពិចារណាក្នុងដំណើរការមជ្ឈត្តការឡើយ ដែលកម្រៃសេវាត្រូវបង់គឺ៥០០ (ប្រាំរយ) ដុល្លារសហរដ្ឋអាមេរិកសម្រាប់ការដាក់ឯកសារម្តងៗ។ ហើយរាល់កម្រៃសេវាចុះបញ្ជី គឺជាកម្រៃដែលមិនត្រូវសងវិញនោះ។[91] ជាងនេះទៅទៀត នៅក្នុងវិធានស្តីពីមជ្ឈត្តការ នៃព្រះរាជាណាចក្រកម្ពុជាក៏បានកំណត់អំពីការបង់កម្រៃសេវាឱ្យទាន់ពេលវេលាផងដែរ ដោយក្នុងនោះ ភាគីប្តឹងទាមទារត្រូវបង់កម្រៃចុះបញ្ជីនៅពេលដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម។ ភាគីប្តឹងទាមទារនៃបណ្តឹងតបត្រូវបង់កម្រៃសេវាបន្ថែមចំនួន ៥០០ (ប្រាំរយ) ដុល្លារសហរដ្ឋអាមេរិក សម្រាប់ការចុះបញ្ជីនៅពេលដាក់បណ្តឹងតបផងដែរ។ ហើយការខកខានក្នុងការបង់កម្រៃសេវាចុះបញ្ជីឱ្យបានគ្រប់ចំនួនទាន់ពេលវេលា ត្រូវចាត់ទុកថាការខកខានក្នុងការដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មដូចមានកំណត់ក្នុងប្រការ ៧.៥ (ភាពមិនពេញលេញនៃសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម) ឬអាចប្រឈមនឹងហានិភ័យដែលបណ្តឹងតបរបស់ភាគីវិវាទមិនត្រូវបានលើកយកមកពិចារណាក្នុងដំណើរការមជ្ឈត្តការឡើយ។[92] ហេតុដូច្នេះ រាល់ការបង់ថ្លៃសេវានានាគឺសុទ្ធតែកំណត់ពេលវេលា ប្រសិនភាគីមានការខកខានក្នុងការបង់នោះនឹងត្រូវប្រឈមនឹងការមិនត្រូវបានលើកយកមកពិចារណា ក្នុងដំណើរការមជ្ឈត្តការឡើយ។ បន្ថែមពីនេះ វិធានស្តីពីមជ្ឈត្តការនៃព្រះរាជាណាចក្រកម្ពុជាក៏បានចែងអំពីការបង់ប្រាក់មុនផងដែរ ហើយក្នុង

---

[91] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៥៧.៣.

[92] វិធានស្តីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៥៧.២.

ករណីដែលប្រាក់បង់ជាមុនមិនត្រូវបានបង់ទាំងស្រុងតាមកាលកំណត់ដែលត្រូវបង់ទេនោះ អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងដល់គូភាគីវិវាទដើម្បីឱ្យភាគីវិវាទណាមួយបង់នូវទឹកប្រាក់ដែលត្រូវបង់។ ប្រសិនបើភាគីមិនបង់ប្រាក់ក្នុងរយៈពេលដែលបានកំណត់ដោយអគ្គលេខាធិការដ្ឋាន នាំឱ្យអគ្គលេខាធិការដ្ឋានក្រោយពីបានពិភាក្សាជាមួយវេទិកាមជ្ឈត្តកម្ម អាចឱ្យវេទិកាមជ្ឈត្តកម្មផ្អាកការងារ និងកំណត់អំឡុងពេលមួយដែលការទាមទារ ឬបណ្ដឹងតប ដែលពាក់ព័ន្ធនោះត្រូវចាត់ទុកថាបានដកនៅពេលផុតកំណត់អំឡុងពេលនោះ។ វេទិកាមជ្ឈត្តកម្ម ឬអគ្គលេខាធិការដ្ឋានអាចផ្អាកការងារខ្លួនមួយផ្នែក ឬទាំងស្រុង ឬបញ្ឈប់ដំណើរការមជ្ឈត្តការតែម្ដងប្រសិនបើប្រាក់បង់ជាមុនដែលតម្រូវក្រោមវិធាននេះមួយចំណែក ឬទាំងស្រុងមិនត្រូវបានបង់ទេនោះ។[93] អាស្រ័យហេតុរាល់ដំណើរការមជ្ឈត្តការទាំងអស់គឺតម្រូវឱ្យមានការបង់ប្រាក់ជាមុន ហើយប្រសិនបើភាគីខកខានក្នុងការបង់នោះនឹងត្រូវបានវេទិកាមជ្ឈត្តកម្ម ឬអគ្គលេខាធិការដ្ឋានផ្អាក ឬបញ្ឈប់ដំណើរការមជ្ឈត្តការ ដែលនេះក៏អាចជាបញ្ហាប្រឈមសម្រាប់ភាគីដែលពុំមានប្រាក់គ្រប់គ្រាន់ក្នុងការបង់ថ្លៃសេវា ហើយបណ្ដាលឱ្យមានការអូសបន្លាយពេលវេលាក្នុងការដោះស្រាយវិវាទរបស់ខ្លួនផងដែរ។

### ៣.១.២. កង្វះភាពផ្សព្វផ្សាយការប្រើប្រាស់យន្តការ ម.ជ.ម.

បើទោះបីជាច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងវិធានស្ដីពីមជ្ឈត្តការ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តដទៃទៀតពាក់ព័ន្ធនឹងកាដោះស្រាយវិវាទ តាមមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវបានដាក់ចេញឱ្យមានការប្រើប្រាស់ទូទាំងប្រទេសកម្ពុជាក៏ពិតមែន ប៉ុន្តែ ការអនុវត្តជាក់ស្ដែងនៃយន្តការនេះនៅពុំទាន់មានការផ្សព្វផ្សាយជាសាធារណៈ ដែលមានលក្ខណៈទូលំទូលាយដូចប្រព័ន្ធតុលាការឡើយ។ វិនិយោគិនដែលជាជនជាតិខ្មែរមួយចំនួននៅប្រើប្រាស់ប្រព័ន្ធតុលាការសម្រាប់ដោះស្រាយវិវាទនៅឡើយ ដោយហេតុថា ភាគីពុំទាន់យល់ដឹងច្បាស់អំពីយន្តការមួយនេះនៅឡើយ។ ម៉្យាងវិញទៀត ការបណ្ដុះបណ្ដាលអំពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជាក៏នៅពុំសូវមាននៅឡើយ ជាពិសេសវគ្គបណ្ដុះបណ្ដាលដែលធ្វើឡើងនៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មតម្រូវឱ្យមានការបង់ថ្លៃសិក្សា និងធ្វើឡើងក្នុងលក្ខណៈផ្ទៃក្នុង ពុំមានការចាក់ផ្សាយជាសាធារណៈ ដូចនីតិវិធីនៅតុលាការនោះ។ ម៉្យាងវិញទៀត បើទោះបីជាមានការផ្សព្វផ្សាយខ្លះក៏ដោយ ក៏ការផ្សព្វផ្សាយទាំងនោះពុំសូវមានប្រសិទ្ធភាពនោះឡើយ ពោលគឺជាការផ្សព្វផ្សាយដែលធ្វើឡើងដោយបុគ្គលដែលមិនមែនជាអ្នកមានវិជ្ជាជីវៈមួយនេះឡើយ ហើយការផ្សព្វផ្សាយទាំងនោះគឺនៅមានភាពខ្វះខាត ពុំមានលក្ខណៈក្បោះក្បាយដែលអាចឱ្យប្រជាពលរដ្ឋយល់ដឹងអំពីយន្តការនេះឱ្យបានច្បាស់លាស់ឡើយ។ កង្វះខាតនៃការផ្សព្វផ្សាយអំពីយន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ គឺជាបញ្ហាមួយដែលបង្កឱ្យមានផលប៉ះពាល់ខ្លាំងទាំងស្ថាប័ននៃមជ្ឈត្តការ

[93] វិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ ប្រការ ៦៥.៣.

ផ្នែកពាណិជ្ជកម្ម និងការបាត់បង់ទំនុកចិត្តពីវិនិយោគិន ដោយហេតុថាប្រជាពលរដ្ឋពុំសូវមានការយល់ដឹងបែបនេះ ហើយទើបធ្វើឱ្យប្រជាពលរដ្ឋជ្រើសរើសយកការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ ជាជាងការប្រើប្រាស់តាមរយៈយន្តការនៃមជ្ឈត្តកាផ្នែកពាណិជ្ជកម្ម។

## ៣.២. បញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្ត

ជាទូទៅ ដំណើរការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះ មានលិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រការអនុវត្ត និងដើម្បីធានានូវប្រសិទ្ធភាពក្នុងការអនុវត្តតាមរយៈយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក៏ពិតមែន ក៏ប៉ុន្តែ ការអនុវត្តជាក់ស្តែងនៅតែចៀសមិនបំផុតអំពីបញ្ហាប្រឈមនោះទេ។ ហេតុដូច្នេះ នៅក្នុងចំណុច **៣.២. បញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្ត** នេះយើងខ្ញុំនឹងធ្វើការបកស្រាយទៅលើកត្តា ៤ (បួន) យ៉ាងគឺ៖ **៣.២.១. បញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងផ្សះផ្សា ៣.២.២. បញ្ហាប្រឈមពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងតប** និង**៣.២.៣. បញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តវិធានការបណ្តោះអាសន្ន** និង **៣.២.៤. បញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ**។

### ៣.២.១. បញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងផ្សះផ្សា

ជាទូទៅ ដំណើរការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គូភាគីត្រូវមានការព្រមព្រៀងគ្នាជាមុនតាមរយៈកិច្ចព្រមព្រៀងផ្សះផ្សា ដើម្បីកំណត់ថាយកវិវាទរបស់ខ្លួនមកដោះស្រាយតាមរយៈយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ កិច្ចព្រមព្រៀងផ្សះផ្សា បានដើរតួរយ៉ាងសំខាន់នៅក្នុងយុត្តាធិការនៃការដោះស្រាយវិវាទរបស់គូភាគី ហេតុនេះ អ្នកតាក់តែងកិច្ចព្រមព្រៀងផ្សះផ្សា ត្រូវមានការប្រុងប្រយ័ត្នបំផុតដើម្បីធានាថាកិច្ចព្រមព្រៀងផ្សះផ្សានេះនឹងមិនត្រូវមោឃៈ ឬមិនអាចអនុវត្តបាន។ បន្ថែមពីនេះ អ្នកតាក់តែងកិច្ចព្រមព្រៀងត្រូវដឹងឱ្យបានច្បាស់អំពីគោលបំណងក្នុងការធ្វើកិច្ចព្រមព្រៀងផ្សះផ្សានេះឡើង។ ក្នុងករណី អ្នកតាក់តែងកិច្ចព្រមព្រៀងផ្សះផ្សា ធ្វើឡើងដោយមិនមានភាពត្រឹមត្រូវទៅតាមបច្ចេកស័ព្ទ ដែលបានកំណត់នៅក្នុងវិធានស្តីពីមជ្ឈត្តការ និងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា នោះទេ ធ្វើឱ្យមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មានភាពលំបាកដើម្បីដោះស្រាយអំពីយុត្តាធិការជាមុនសិន ទើបអាចសម្រេចបង្កើតវេទិកាមជ្ឈត្តកម្ម។ ហេតុដូច្នេះ នៅក្នុងចំណុច **៣.២.១. បញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងផ្សះផ្សា** នេះយើងនឹងធ្វើការបកស្រាយទៅលើកត្តា ៣ (បី) យ៉ាងគឺ**៣.២.១.១. បញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងផ្សះផ្សាដោយការយល់ច្រឡំ** និង**៣.២.១.២. បញ្ហាប្រឈមពាក់ព័ន្ធនឹងការបកប្រែភាសា** និង**៣.២.១.៣. បញ្ហាប្រឈមពាក់ព័ន្ធនឹងជម្រើសយុត្តាធិការរបស់គូភាគី**។

**៣.២.១.១. បញ្ហាពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងផ្សះផ្សាដោយការយល់ច្រឡំ**

កិច្ចព្រមព្រៀងផ្សះផ្សា ធ្វើឡើងដើម្បីបញ្ជាក់អំពីការព្រមព្រៀងរបស់គូភាគីវិវាទថាយកវិវាទរបស់ពួកគេមកដោះស្រាយតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង អ្នកតាក់តែងកិច្ចព្រមព្រៀងផ្សះផ្សាមួយចំនួន មិនបានពន្យល់ឱ្យបានច្បាស់អំពីគោលបំណងនៃការធ្វើកិច្ចព្រមព្រៀងផ្សះផ្សានោះទេ ដោយគ្រាន់តែសរសេរអំពីកិច្ចព្រមព្រៀងផ្សះផ្សា ឬខចែងស្តីពីមជ្ឈត្តការ បញ្ចូលទៅក្នុងកិច្ចសន្យាពាណិជ្ជកម្មដែលគូភាគីបានធ្វើនោះថា ប្រសិនបើមានវិវាទកើតឡើង គូភាគីព្រមព្រៀងគ្នានឹងយកវិវាទនោះមកដោះស្រាយតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម តែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ប្រសិនបើកិច្ចសន្យាពាណិជ្ជកម្ម ដែលគូភាគីធ្លាប់បានធ្វើកន្លងមក មិនបានចែងអំពីកិច្ចព្រមព្រៀងផ្សះផ្សា ឬខចែងស្តីពីមជ្ឈត្តការ ហើយក្នុងករណីគូភាគីកំពុងតែមានវិវាទកើតឡើង និងបានចរចាគ្នា គូភាគីសម្រេចធ្វើកិច្ចព្រមព្រៀងផ្សះផ្សាដោយឡែកមួយ និងយោងកិច្ចសន្យាពាណិជ្ជកម្មដែលគូភាគីធ្លាប់បានធ្វើកន្លងនោះ។ ដោយសារតែចំណងជើងរបស់លិខិតមានឈ្មោះ **កិច្ចព្រមព្រៀងផ្សះផ្សា** ជាហេតុធ្វើឱ្យគូភាគីមានការយល់ច្រឡំថា វិវាទរបស់ពួកគេត្រូវបានផ្សះផ្សាតាមការព្រៀមព្រៀង ឬមិនមានវិវាទជាមួយគ្នាបន្តទៀត។

**៣.២.១.២. បញ្ហាពាក់ព័ន្ធនឹងការបកប្រែភាសា**

ជាគោលការណ៍ កិច្ចព្រមព្រៀងផ្សះផ្សាតម្រូវឱ្យមានការធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលស្ថិតនៅក្នុងឯកសារចុះហត្ថលេខាដោយភាគីវិវាទ។ ហេតុដូច្នេះ ក្នុងការតាក់តែងកិច្ចព្រមព្រៀងផ្សះផ្សានេះត្រូវមានភាពហ្មត់ចត់ក្នុងការប្រើប្រាស់ពាក្យពេចន៍ ដើម្បីឱ្យមានភាពត្រឹមត្រូវតាមគតិច្បាប់ និងបច្ចេកស័ព្ទច្បាប់។ ត្ួយ៉ាង នៅក្នុងទិដ្ឋភាពទូទៅនៃការដោះស្រាយវិវាទតាមមជ្ឈត្តការផ្នែកពាណិជ្ជកម្មមានលក្ខណៈផ្ទុយគ្នាទៅនឹងការអនុវត្តនៅក្នុងប្រព័ន្ធតុលាការជាខ្លាំង ដោយក្នុងនោះបញ្ហានៃកង្វះខាតទម្រង់នៃការតាក់តែងកិច្ចព្រមព្រៀងផ្សះផ្សាក៏ជាផ្នែកមួយដែលផ្តល់ផលលំបាកសម្រាប់គូភាគីផងដែរ។ ម៉្យាងវិញទៀត ក្នុងការតាក់តែងកិច្ចព្រមព្រៀងរបស់ភាគីមួយចំនួនធ្វើឡើងដោយផ្អែកតាមទម្រង់ នៃការតាក់តែងរបស់មជ្ឈត្តករបរទេស។ ការតាក់តែងតាមគំរូបរទេសនេះទៀតសោធ ភាគីត្រូវធ្វើការបកប្រែនូវខ្លឹមសារនៃកិច្ចព្រមព្រៀងនេះពីភាសាបរទេសមកភាសាខ្មែរដើម្បីអាចយកជាគោលគំនិតក្នុងការតាក់តែងកិច្ចព្រមព្រៀងផ្សះផ្សា។ ប៉ុន្តែ ការបកប្រែមួយចំនួនពុំមានភាពត្រឹមត្រូវទៅតាមបច្ចេកស័ព្ទច្បាប់ដែលអនុវត្តឡើយ ពោលគឺភាគីមួយចំនួនធ្វើការបកប្រែដោយប្រើប្រាស់នូវពាក្យសាមញ្ញដែលពុំស៊ីសង្វាក់គ្នាជាមួយបច្ចេកស័ព្ទច្បាប់ ដែលប្រើប្រាស់ក្នុងវិធានស្តីពីមជ្ឈត្តការ របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក៏ដូចជា ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជាឡើយ ឬកំណត់ឈ្មោះស្ថាប័នមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងសេចក្តីសម្រេចរបស់មជ្ឈត្តករមិនមានភាពត្រឹមត្រូវដែលជាហេតុធ្វើឱ្យកិច្ចព្រមព្រៀងផ្សះផ្សានេះមានភាពលំបាកក្នុងការអនុវត្តដោយសារកំហុសពាក្យពេចន៍។

### ៣.២.១.៣. បញ្ហាពាក់ព័ន្ធនឹងជម្រើសយុត្តាធិការរបស់គូភាគី

ចំពោះបញ្ហាប្រឈមពាក់ព័ន្ធនឹងជម្រើសរបស់គូភាគី នេះយើងខ្ញុំឃើញថា កើតមានភាគច្រើននៅពេលដែលគូភាគីបង្កើតកិច្ចសន្យាពាណិជ្ជកម្ម គូភាគីជ្រើសរើសការដោះស្រាយវិវាទតាមរយៈយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងជ្រើសរើសការដោះស្រាយវិវាទតាមរយៈប្រព័ន្ធតុលាការ នៅក្នុងកិច្ចសន្យាតែមួយ។ ចំពោះបញ្ហាមួយនេះ តែងតែកើតមានជាញឹកញាប់នៅក្នុងការអនុវត្តជាក់ស្តែង។ ការបញ្ចូលជម្រើសការដោះស្រាយវិវាទដែលនឹងកើតមាននាពេលអនាគត តាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មផង និងតាមរយៈតុលាការផង បែបនេះបង្ហាញថាគូភាគី មិនបានផ្តោតទៅលើការដោះស្រាយតាមមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឬមិនបានយកចិត្តទុកដាក់ក្នុងការតាក់តែងកិច្ចព្រមព្រៀងផ្សះផ្សានោះឡើយ។ បន្ថែមពីនេះ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ក៏បានធ្វើគំរូខចែងស្តីពីមជ្ឈត្តការផងដែរ ដើម្បីឱ្យគូភាគីអាចយកគំរូខចែងស្តីពីមជ្ឈត្តការនេះមកប្រើប្រាស់ ប្រសិនបើគូភាគីព្រមព្រៀងយកវិវាទនោះមកដោះស្រាយតាមរយៈ មជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៅប្រទេសកម្ពុជា។

ប៉ុន្តែ ការអនុវត្តជាក់ស្តែង ជាពិសេសអ្នកតាក់តែងកិច្ចព្រមព្រៀងផ្សះផ្សា ពុំបានយកគំរូខចែងស្តីពីមជ្ឈត្តការ ដែលខាងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ធ្វើឡើងសម្រាប់បុគ្គលដែលមានបំណងដោះស្រាយវិវាទតាមរយៈយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះមកប្រើប្រាស់នោះទេ។ ទោះបីជា ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បានចែងថា **ទោះបីជាមានបណ្តឹងទាមទារទៅតុលាការ ក៏ដោយ ក៏ដំណើរការរបស់វេទិកាមជ្ឈត្តកម្ម អាចចាប់ផ្តើម ឬបន្តដំណើរការបានបន្តទៅទៀត ហើយតុលាការត្រូវបង្វែរសមត្ថកិច្ច ជូនទៅវេទិកាមជ្ឈត្តកម្មវិញ ដោយរង់ចាំការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម**[94]ក៏ដោយ ប៉ុន្តែ តាមរយៈការអះអាងរបស់អ្នកមានបទពិសោធន៍ដោះស្រាយវិវាទតាមរយៈយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បានបញ្ជាក់ថា **ក្នុងករណីមានភាគីម្ខាងបានប្តឹងទៅតុលាការឱ្យដោះស្រាយវិវាទបែបនេះ ខាងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មិនទទួលយកវិវាទនេះយកមិនដោះស្រាយនោះទេ។** ហេតុដូច្នេះ គូភាគី ត្រូវកំណត់ឱ្យបានច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀងផ្សះផ្សា ឬខចែងស្តីពីមជ្ឈត្តការ ថាវិវាទនេះនឹងត្រូវដោះស្រាយតាមរយៈយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដើម្បីធានាថាមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺជាស្ថាប័នតែមួយគត់ដែលមានយុត្តាធិការ សម្រាប់ដោះស្រាយវិវាទមួយនេះ។

### ៣.២.២. បញ្ហាប្រឈមពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងតប

បន្ទាប់ពីគូភាគីព្រមព្រៀងគ្នា ក្នុងកិច្ចព្រមព្រៀងផ្សះផ្សាថានឹងដាក់វិវាទមកដោះស្រាយតាមមជ្ឈត្តការផ្នែកពាណិជ្ជកម្មរួចមក ភាគីដែលទទួលរងការបំពានដែលហៅថា ភាគីប្តឹងទាមទារនោះត្រូវបញ្ជូនសេចក្តីជូនដំណឹង

[94] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មាត្រា៨ កថាខណ្ឌទី១

របស់ខ្លួនទៅអគ្គលេខាធិការដ្ឋាននៃ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នូវសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម។ ហើយអគ្គលេខាធិការដ្ឋាននៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវបញ្ជូនសេចក្តីជូនដំណឹងទៅភាគីឆ្លើយតប ដើម្បីឱ្យភាគីឆ្លយតបដាក់បណ្តឹងតបរបស់ខ្លួន។ ក៏ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង ប្រសិនបើអគ្គលេខាធិការដ្ឋាននៃ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មិនអាចស្វែងរកឃើញអាសយដ្ឋានរបស់ភាគីឆ្លើយតបបានទេនោះ គឺអាចផ្ញើសារអេឡិចត្រូនិចទៅកាន់ភាគីឆ្លើយតប ដោយការផ្ញើសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មតាមសារអេឡិចត្រូនិចបែបនេះ ត្រូវបានចាត់ទុកថាភាគីបានទទួលសេចក្តីជូនដំណឹង បើទោះបីជាភាគីពុំបានទទួលសេចក្តីជូនដំណឹងអំពីមជ្ឈត្តការក៏ដោយ។ ហេតុដូច្នេះ វាជាបញ្ហាសម្រាប់ភាគីឆ្លើយតប អាចនឹងផ្លោះសិទ្ធិដាក់សេចក្តីជូនដំណឹងតប ហើយម៉្យាងវិញទៀត ភាគីឆ្លើយតបក៏អាចនឹងផ្លោះសិទ្ធិក្នុងការចូលរួមនីតិវិធីក្នុងវេទិកាមជ្ឈត្តកម្ម ដោយសារពុំបានដឹងអំពីវេទិកាមជ្ឈត្តកម្មដែលនឹងត្រូវធ្វើឡើង។

### ៣.២.៣. បញ្ហាប្រឈមពាក់ព័ន្ធនឹងវិធានការបណ្តោះអាសន្ន

ការស្នើសុំវិធានការបណ្តោះអាសន្ន គឺតម្រូវឱ្យភាគីអ្នកស្នើសុំ ត្រូវបញ្ជូនសំណៅថតចម្លងនៃសំណើសុំវិធានការបណ្តោះអាសន្នមួយច្បាប់ជូនភាគីម្ខាងទៀត។ សកម្មភាពនេះ អាចធ្វើឱ្យភាគីម្ខាងទៀតបានដឹងអំពីឆន្ទៈរបស់ភាគីអ្នកស្នើសុំ ហើយដើម្បីជៀសវាងការខូចខាត ឬរិតត្បិតលើសិទ្ធិណាមួយក្រោមសេចក្តីសម្រេចនៃវិធានការបណ្តោះអាសន្ន ដែលនឹងអាចកើតឡើងនាពេលអនាគត ភាគីម្ខាងទៀត មានលទ្ធភាពគ្រប់គ្រាន់ក្នុងការចាត់ចែងទ្រព្យសម្បត្តិណាមួយ ដែលគេគិតថាអាចជាកម្មវត្ថុ នៃវិធានការបណ្តោះអាសន្ន ទៅតតិយជនបាន បន្ទាប់ពីទទួលបានសំណៅថតចម្លងខាងលើ។

ទោះបីជាមានវិធានការបណ្តោះអាសន្នកើតឡើងមែន ប៉ុន្តែការអនុវត្តវិធានការបណ្តោះអាសន្នហាក់ដូចជា នៅតែមានឧបសគ្គ ដោយហេតុថា រាល់ការអនុវត្តផ្អែកតាមវិធានការណ្តោះអាសន្ន គឺជាការស្ម័គ្រចិត្តរបស់ភាគីសុទ្ធសាធ ដោយពុំទាន់មានវិធាន ឬច្បាប់ណាមួយ ចង្អុលបង្ហាញពីការអនុត្តដោយបង្ខំនៅពេលភាគីបដិសេធមិនព្រមអនុវត្តតាមនោះឡើយ។ ផ្ទុយពីតុលាការ ដែលមាននីតិវិធីរក្សាការពារ ក្រោយពេលតុលាការចេញដីកាសម្រេចរក្សាការពារតាមពាក្យសុំរបស់ម្ចាស់បំណុលហើយក្រឡាបញ្ជីនឹងចេញលិខិតផ្ទុកផ្តាក់ទៅរដ្ឋបាលសុរិយោដីដើម្បីចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ននូវទ្រព្យសសម្បត្តិរបស់កូនបំណុល ដែលហេតុនាំឱ្យនីតិវិធីរក្សាការពាររបស់តុលាការមានភាពច្បាស់លាស់ និងមានប្រសិទ្ធភាពជាងវិធានការបណ្តោះអាសន្នរបស់ ម.ជ.ម.។

ម្យ៉ាងវិញទៀត ក្នុងករណីភាគីនៃវិធានការបណ្តោះអាសន្នពុំអនុវត្តដោយស្ម័គ្រចិត្តទេ វិធានការបណ្តោះអាសន្ននេះ គ្មានប្រយោជន៍ចំពោះភាគីប្តឹងទាមទារឡើយ។ លើសពីនេះ ភាគីប្តឹងទាមទារសុំវិធានការបណ្តោះអាសន្ន មិនអាចធ្វើការស្នើសុំឱ្យតុលាការទទួលស្គាល់ និងអនុវត្តដោយបង្ខំ ដូចមជ្ឈត្តវិនិច្ឆ័យបាន

ឡើយ ដោយសារតែពុំមានច្បាប់ ឬបទដ្ឋានគតិយុត្តណាមួយចង្អុលបង្ហាញថាវិធានការបណ្តោះអាសន្នរបស់ ម.ជ.ម. អាចអនុវត្តដោយបង្ខំបានឡើយ។

### ៣.២.៤. បញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ

#### ៣.២.៤.១. ការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ

ទោះបីជា មជ្ឈត្តវិនិច្ឆ័យចងជាកាតព្វកិច្ចឱ្យគូភាគីត្រូវតែអនុវត្តទៅតាមខ្លឹមសារក៏ពិតមែន ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង ភាគីដែលចាញ់នៅតែប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ ទៅសាលាឧទ្ធរណ៍ដដែល។ យើងខ្ញុំសូមបញ្ជាក់ថា មិនមែនគ្រប់ករណី ភាគីអាចប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យបាននោះទេ។ មូលហេតុនៃការប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ មានភាពតឹងរឹង និងរិតត្បិតជាខ្លាំង មានន័យថា ក្រៅពីចំណុចដែលច្បាប់បានកំណត់ទុកជាមុន ដូចមានចែងក្នុងមាត្រា ៤៤ និងមាត្រា ៤៦ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ភាគីមិនអាចប្តឹងជំទាស់បានឡើយ។ មិនតែប៉ុណ្ណោះ ប្រសិនបើមានមូលហេតុនៃការប្តឹងជំទាស់ក៏ដោយ ចៅក្រមជំនុំជម្រះដោយពិនិត្យទៅលើទម្រង់នៃនីតិវិធីសុទសាធ ច្បាប់មិនអនុញ្ញាតឱ្យចៅក្រមជំនុំជម្រះទៅលើផ្នែកសារធាតុនៃសិទ្ធិនោះទេ។ មជ្ឈត្តវិនិច្ឆ័យ ដែលបានសម្រេចអំពីលក្ខណៈសារធាតុនៃសិទ្ធិរួចនោះ តុលាការមិនមានសិទ្ធិសើរើនោះទេ ទោះបីជាមជ្ឈត្តវិនិច្ឆ័យនោះ សម្រេចឱ្យភាគីឈ្នះ ឬចាញ់មួយផ្នែកក៏ដោយ។ ប៉ុន្តែ ការអនុវត្តជាក់ស្តែង ទោះបីជាគ្មានមូលហេតុនៃប្តឹងជំទាស់ ក៏ចៅក្រមទទួលស្គាល់ពាក្យបណ្តឹងជំទាស់របស់ភាគីយកមកជំនុំជម្រះដែរ ពីព្រោះនីតិវិធីក្នុងការអនុវត្តជាក់ស្តែង គឺពាក្យបណ្តឹងជំទាស់ត្រូវដាក់ទៅរដ្ឋបាលតុលាការ ហើយរដ្ឋបាលតុលាការត្រូវបញ្ជូនពាក្យបណ្តឹងជំទាស់នោះទៅចៅក្រមទទួលបន្ទុកសំណុំរឿង ទើបចៅក្រមអាចសម្រេចពីការទទួលស្គាល់ ឬបដិសេធ មជ្ឈត្តវិនិច្ឆ័យតាមរយៈការជំនុំជម្រះ។ ជាងនេះទៅទៀត ចៅក្រមត្រូវជំនុំជម្រះទៅលើសំណុំរឿងដែលមជ្ឈមណ្ឌលមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បានចេញមជ្ឈត្តវិនិច្ឆ័យនេះដោយផ្អែកទៅលើទម្រង់នៃនីតិវិធីមជ្ឈត្តការប៉ុណ្ណោះ ប៉ុន្តែចៅក្រមបែរជាជំនុំជម្រះឡើងវិញនូវសារធាតុនៃសិទ្ធិទៅវិញ។

#### ៣.២.៤.២. ការជួយអន្តរាគមន៍ពីតុលាការ

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជាស្ថាប័នឯករាជ្យ ហេតុដូច្នេះសេចក្តីសម្រេចរបស់មជ្ឈត្តករ ឬហៅថាមជ្ឈត្តវិនិច្ឆ័យ នោះជាមជ្ឈត្តវិនិច្ឆ័យចងកាតព្វកិច្ចភាគីក៏ពិតមែន ប៉ុន្តែ ក្នុងករណីថាភាគីចាញ់ក្តីមិនយល់ព្រមអនុវត្តមជ្ឈត្តវិនិច្ឆ័យដោយស្ម័គ្រចិត្តទេ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ពុំមានអំណាចចាប់បង្ខំដូចស្ថាប័នតុលាការនោះទេ។ ម្ល៉េះហើយ ដើម្បីអាចអនុវត្តតាមខ្លឹមសារនៃមជ្ឈត្តវិនិច្ឆ័យបាន ភាគីឈ្នះក្តី ត្រូវតែស្នើសុំការអន្តរាគមន៍ពីស្ថាប័ន ដោយដាក់ពាក្យសុំទៅតុលាការ ឱ្យទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យ និងដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះ។ ក្រោយពីតុលាការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យ និងដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

ហេតុនេះ មជ្ឈត្តវិនិច្ឆ័យក្លាយទៅជាលិខិតអនុវត្ត ស្របតាមមាត្រា៣៥០ កថាខណ្ឌទី២ **ចំណុច ជ** នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលអាចអនុវត្តដោយបង្ខំបាន។ ភាគីឈ្នះក្តីត្រូវដាក់ពាក្យសុំទៅសាលាដំបូងរាជធានី-ខេត្ត ដែលជាតុលាការមានសមត្ថកិច្ចអនុវត្តដោយបង្ខំទៅលើទ្រព្យសម្បត្តិរបស់ភាគីចាញ់ក្តី ទៅតាមនីតិវិធីអនុវត្តដោយបង្ខំតាមប្រព័ន្ធក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

ទោះបីជា ភាគីឈ្នះក្តីអាចដាក់ពាក្យសុំអនុវត្តដោយបង្ខំតាមផ្លូវតុលាការ ក៏ពិតមែន ក៏ប៉ុន្តែ ហានិភ័យត្រង់ថាភាគីឈ្នះក្តីនឹងបង្វែរ ឬចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនមុនពេលដែលនីតិវិធីអនុវត្តដោយបង្ខំទៅទៀត។ ពីព្រោះថា ការដោះស្រាយវិវាទតាមរយៈយន្តមជ្ឈត្តការនេះ ប្រសិនបើមិនមានដាក់ស្នើសុំដាក់រក្សាការពារទៅលើទ្រព្យសម្បត្តិរបស់ភាគីទេ ភាគីចាញ់ក្តីមានលទ្ធភាពពេញលេញក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនបានដោយសេរី។ មិនតែប៉ុណ្ណោះ ភាគីឈ្នះក្តីត្រូវចំណាយប្រាក់អស់ជាច្រើនទៅលើនីតិវិធីតុលាការ និងអូសបន្លាយពេលវេលាបន្ថែមផងដែរ។

**៣.២.៤.៣. គ្មានទិន្នន័យចំពោះការទទួលស្គាល់ បដិសេធ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យ**

ជាទូទៅ រាល់សំណុំរឿងទាំងឡាយនៅក្នុងប្រព័ន្ធតុលាការតែងមានធ្វើជាទិន្នន័យនៃការគ្រប់គ្រងសំណុំរឿងឱ្យបានច្បាស់លាស់ និងដាក់ជូនទៅក្រសួងយុត្តិធម៌ដើម្បីគ្រប់គ្រងទិន្នន័យនៃសំណុំរឿងទាំងអស់ដែលដំណើរការតាមតុលាការគ្រប់ជាន់ថ្នាក់ និងគ្រប់រាជធានី ខេត្ត។ ផ្ទុយទៅវិញ សម្រាប់សំណុំរឿងដែលដោះស្រាយតាមយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលមានភាគីណាម្ខាងដាក់បណ្តឹងជំទាស់ទៅកាន់សាលាឧទ្ធរណ៍វិញ គឺក្រសួងយុត្តិធម៌ពុំមានទិន្ន័យច្បាស់លាស់ ដែលអាចឱ្យមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មអាចដឹងអំពីដំណើរការ ក៏ដូចជាការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍នោះឡើយ។ បញ្ហាកង្វះទិន្ន័យបែបនេះនាំឱ្យមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជកម្មមានភាពលំបាកក្នុងការគ្រប់គ្រង និងតាមដានទិន្ន័យនៃសំណុំរឿងនីមួយៗ

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី **"ដំណើរការប្រព្រឹត្តទៅនៃមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា និងបញ្ហាប្រឈម"** រួចមកយើងខ្ញុំយល់ឃើញថាការដោះស្រាយវិវាទតាមយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺជាវិធីដោះស្រាយជម្លោះមួយដែលមានសារៈសំខាន់ ដោយផ្តល់ជម្រើសដល់ពាណិជ្ជករទាំងក្នុង និងក្រៅប្រទេសនូវវិធីនៃការដោះស្រាយវិវាទពាណិជ្ជកម្មដែលមានភាពងាយស្រួល និងឆាប់រហ័ស។ ជាក់ស្តែងការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈយន្តការមជ្ឈត្តការ គឺជាយន្តការទំនើបថ្មីមួយ ដែលទើបបានបង្កើតឡើងដើម្បីដោះស្រាយវិវាទទាក់ទងនឹងពាណិជ្ជកម្ម ដោយមានភាពរហ័ស អព្យាក្រឹត ច្បាស់លាស់ និងជាការសម្ងាត់។

នៅក្នុងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម យើងសង្កេតឃើញថាមុននឹងចាប់ផ្តើមនីតិវិធីនៃការដោះស្រាយវិវាទត្រូវមានការធ្វើសន្និសីទ អំពីការគ្រប់គ្រងចាត់ចែងសំណុំរឿងដោយតម្រូវឱ្យមានការជួបជុំរវាងវេទិកាមជ្ឈត្តកម្ម និងភាគីវិវាទដើម្បីពិភាក្សាអំពីនីតិវិធីនានា បន្ទាប់មកការជូនដំណឹងអំពីមជ្ឈត្តកម្មដែលត្រូវបានចាត់ទុកថាជាការចាប់ផ្តើមកាលបរិច្ឆេទនៃការដាក់សំណុំឯកសារ និងការជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញដោយភាគីប្តឹងទាមទារ រួមទាំងការដាក់សេចក្តីជូនដំណឹងតបរបស់ភាគីឆ្លើយតប។ បន្ទាប់ពីដាក់សេចក្តីជូនដំណឹងរួចមក ភាគីត្រូវធ្វើការជ្រើសរើសមជ្ឈត្តករក្នុងចំនួនសេសតាមការព្រមព្រៀង។ ក្រោយពីបានជ្រើសរើសមជ្ឈត្តកររួចមក ភាគីត្រូវធ្វើការប្រជុំបឋម ឬប្រជុំត្រៀមដើម្បីកំណត់ អំពីទីកន្លែងនៃដំណើរការមជ្ឈត្តការ លិខិតបទដ្ឋានគតិយុត្តិសម្រាប់អនុវត្ត កំណត់អំពីភាសា ភស្តុតាង និងសាក្សី ព្រមទាំងអំឡុងពេលដាក់លាក់សម្រាប់ដាក់សេចក្តីថ្លែងទាមទារ សេចក្តីថ្លែងដោះសា។ បន្ទាប់ពីគូភាគីបានព្រមព្រៀងគ្នាទៅលើនីតិវិធីនៃមជ្ឈត្តការរួចវេទិកាមជ្ឈត្តកម្មនឹងចេញសេចក្តីបង្គាប់នីតិវិធី ដែលមានភ្ជាប់ជាមួយនឹងរបៀបវារៈសម្រាប់ឱ្យគូភាគីវិវាទបានដឹងអំពីអំឡុងពេលជាក់លាក់នីមួយៗ ដូចទៅនឹងអ្វីដែលគូភាគីវិវាទព្រមព្រៀងនៅពេលដែលគូភាគីបានធ្វើការប្រជុំបឋមកន្លងមក។ ដំណើរការសវនាការនៃវេទិកាមជ្ឈត្តកម្ម អាចធ្វើឡើងដោយសវនាការផ្ទាល់មាត់ ឬអាចធ្វើឡើងដោយសវនាការជាឯកសារ និងលិខិតស្នាម អាស្រ័យទៅលើការព្រមព្រៀងរបស់គូភាគី។ ក្រោយពីបានបញ្ចប់សវនាការរួចរាល់ មជ្ឈត្តករនឹងចេញសេចក្តីសម្រេចដែលហៅថា មជ្ឈត្តវិនិច្ឆ័យ ដោយមជ្ឈត្តវិនិច្ឆ័យនោះនឹងមានអានុភាពអនុវត្ត និងមានលក្ខណៈជាកាតព្វកិច្ចចំពោះគូភាគីវិវាទចាប់ពីកាលបរិច្ឆេទ ដែលមជ្ឈត្តវិនិច្ឆ័យនោះត្រូវបានចេញ។ ប្រសិនបើភាគីអនុវត្តមជ្ឈត្តវិនិច្ឆ័យដោយស្ម័គ្រចិត្ត នឹងមិនមានការប្តឹងជំទាស់ ឬប្តឹងសុំឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះទេ ផ្ទុយទៅវិញប្រសិនបើភាគីមិនអនុវត្តដោយស្ម័គ្រចិត្ត ដាច់ខាតត្រូវតែសុំការអន្តរាគមន៍ពីតុលាការ។ ក្នុងករណីនេះ ភាគីដែលមានផលប្រយោជន៍ គឺជាភាគីដែលឈ្នះក្តី ត្រូវដាក់ពាក្យប្តឹងទៅតុលាការដើម្បីឱ្យតុលាការទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យ។ ដោយឡែក ភាគីចាញ់ក្តីនឹងដាក់ពាក្យប្តឹងជំទាស់ទៅនឹងការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះទៅតុលាការដូចគ្នា។

ថ្វីត្បិតតែយន្តការមួយនេះមានភាពងាយស្រួល និងឆាប់រហ័សក៏ដោយ ក៏មានបញ្ហាប្រឈមមួយចំនួនដែលជាផលវិបាកមួយក្នុងការអនុវត្តផងដែរ។ ក្នុងនោះការអនុវត្តកិច្ចព្រមព្រៀងផ្សះផ្សា ស្ថាប័ន ម.ជ.ម. ខិតខំធ្វើគំរូខចែងស្តីពីមជ្ឈត្តការ ដើម្បីឱ្យភាគីយកទៅប្រាស់ប្រាស់ ដើម្បីធានាថា ម.ជ.ម. គឺជាស្ថាប័នដែលមានយុត្តាធិការក្នុងការដោះស្រាយវិវាទ ប៉ុន្តែ ភាគីមិនបានយកចិត្តទុកដាក់សរសេរខចែងស្តីពីមជ្ឈត្តការ ឬកិច្ចព្រមព្រៀងផ្សះផ្សា ធ្វើឱ្យមានបញ្ហាប្រឈមពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងផ្សះផ្សានេះជាច្រើន។ ចំណែកបញ្ហាប្រឈមពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងតបវិញ គឺទាក់ទងនឹងការចាត់ទុកថាបានទទួលសេចក្តីជូនដំណឹងរបស់ភាគីប្តឹងទាមទារ ដោយបញ្ហានេះច្រើនកើតឡើងលើភាគីឆ្លើយតបនៅពេលដែលខ្លួនមិនទទួលបានសេចក្តីជូនដំណឹងទាល់តែសោះ ប៉ុន្តែ បែរជាវេទិកាមជ្ឈត្តកម្មត្រូវបានចាប់ផ្តើមទៅវិញ។ រីឯបញ្ហាប្រឈមទាក់ទងនឹងវិធានការបណ្តោះអាសន្ន គឺពុំមានអានុភាពចាប់បង្ខំនោះឡើយ។ ចំណែកបញ្ហាប្រឈមផ្សេងទៀតគឺពាក់ព័ន្ធនឹងកម្រៃសេវា និងកង្វះការផ្សព្វផ្សាយការប្រើប្រាស់យន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា។ ទោះបីជាវេទិកាមជ្ឈត្តកម្មកំណត់នូវកម្រៃសេវាច្បាស់លាស់ក៏ពិតមែន ប៉ុន្តែ យើងខ្ញុំឃើញថាគូភាគីនៅតែត្រូវបង់ថ្លៃសេវាផ្សេងៗទៀតដែលជាការចំណាយក្នុងចំនួនខ្ពស់ផងដែរ។ កង្វះការផ្សព្វផ្សាយអំពីការប្រើប្រាស់យន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជាក៏បង្កើតបានជាបញ្ហាប្រឈមផងដែរ ដោយសារតែកង្វះការផ្សព្វផ្សាយយ៉ាងនេះ ធ្វើដែលជាហេតុធ្វើឱ្យការប្រើប្រាស់យន្តការមួយនេះនៅមានកម្រិតទាបនៅឡើយ។

# អនុសាសន៍

# អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវ និងចងក្រងនូវអត្ថបទសារណាលើប្រធានបទ "**ដំណើរការប្រព្រឹត្តទៅនៃមជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា និងបញ្ហាប្រឈម**" យើងខ្ញុំអាចសង្កេតបានថាការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជាពិតជាមានសារៈប្រយោជន៍ និងគុណប្រយោជន៍ជាច្រើន ប៉ុន្តែ ទន្ទឹមនឹងសារៈប្រយោជន៍នេះក៏ឃើញមានលេចឡើងនូវចំណុចខ្វះខាតមួយចំនួនដែលបង្កើតបានជាបញ្ហាប្រឈមក្នុងការអនុវត្តយន្តការនេះនៅក្នុងប្រទេសកម្ពុជាផងដែរ។ តាមរយៈបញ្ហាប្រឈមដែលយើងខ្ញុំបានសិក្សាស្វែងរក និងទទួលបានការផ្តល់យោបល់ពីអ្នកវិជ្ជាជីវៈដែលជាមជ្ឈត្តករផ្ទាល់ យើងខ្ញុំយល់ឃើញថា នៅក្នុងបញ្ហាប្រឈមនីមួយៗគប្បីមាននូវដំណោះស្រាយ និងការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋ ដែលជាផ្នែកមួយនៃការអភិវឌ្ឍន៍វិស័យយុត្តធម៌ក្នុងប្រទេសជាតិផងដែរ។ ដូច្នេះហើយ យើងខ្ញុំយល់ឃើញថា រាជរដ្ឋាភិបាល នីតិនិពន្ធ និងអ្នកច្បាប់ វិនិយោគិន គប្បីមានការកំណែទម្រង់ និងយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម៖

- គប្បីធ្វើវិសោធនកម្មច្បាប់ដែលពាក់ព័ន្ធនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្មឡើងវិញ ពីព្រោះថាពាក្យពេចន៍ និងនិយមន័យពាក្យបច្ចេកទេសមួយចំនួននៅក្នុងច្បាប់ដែលពាក់ព័ន្ធនឹងមជ្ឈត្តការមិនទាន់ផ្តល់និយមន័យច្បាស់លាស់នៅឡើយទេ ដោយសារតែច្បាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្មមិនទាន់មានភាពទំនើបកម្មនៅឡើយ។ ជាពិសេស គោលការណ៍មួយចំនួនដែលមានចែងក្នុងក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងមជ្ឈត្តការ និងវិធានស្តីពីមជ្ឈត្តការ ដែល ម.ជ.ម. បង្កើតឡើងដែលជានីតិវិធីដោះស្រាយវិវាទតាមរយៈមជ្ឈត្តការ មិនមានសង្គតិភាពនោះទេ។ យើងខ្ញុំផ្តល់ជាយោបល់ថា គួរតែធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងមជ្ឈត្តការឱ្យសមស្របទៅនឹងវិធានស្តីពីមជ្ឈត្តការ ទើបជាការប្រសើរ ពីព្រោះថាវិធានស្តីពីមជ្ឈត្តការមានភាពទំនើប និងមានយន្តការច្បាស់លាស់ចំពោះនីតិវិធីនីមួយៗ។
- ចំពោះអ្នកច្បាប់ វិនិយោគិន ដែលជាអ្នកតាក់តែងកិច្ចព្រមព្រៀងផ្សះផ្សា ឬខចែងស្តីពីមជ្ឈត្តការគប្បីយកគំរូខចែងស្តីពីមជ្ឈត្តការ ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធ នៃវិធានស្តីពីមជ្ឈត្តការឆ្នាំ ២០២១ របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មកប្រើប្រាស់ទាំងស្រុង ពោលគឺមិនគួរតាក់តែងកិច្ចព្រមព្រៀងផ្សះផ្សា ឬខចែងស្តីពីមជ្ឈត្តការ ដែលមានខ្លឹមសារមិនច្បាស់លាស់នោះទេ ដែលជាហេតុធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់ភាគី និងមានបញ្ហាពាក់ព័ន្ធនឹង ម.ជ.ម. មិនមានយុត្តាធិការក្នុងការដោះស្រាយវិវាទ ព្រមទាំងធ្វើឱ្យអូសបន្លាយពេលវេលា និងថវិការឥតប្រយោជន៍ដោយសារកត្តា ខ្លឹមសារ និងទម្រង់នៃកិច្ចព្រមពៀងផ្សះផ្សា ខចែងស្តីពី

មជ្ឈត្តការ ពុំមានភាពច្បាស់លាស់។ ក្រៅពីខ្លឹមសារមិនមានភាពច្បាស់លាស់ អ្នកតាក់តែងកិច្ចព្រមព្រៀងផ្សះផ្សា ឬខចែងស្តីពីមជ្ឈត្តការ គប្បីប្រើប្រាស់ពាក្យពេចន៍ឱ្យបានត្រឹមត្រូវទៅតាមច្បាប់ និងវិធានស្តីពីមជ្ឈត្តការ បានកំណត់ផងដែរ។

- ខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ក្នុងការពង្រឹង និងពង្រីកចំណេះដឹងពាក់ព័ន្ធនឹងយន្តការនេះ ជាពិសេស បុគ្គលដែលពាក់ព័ន្ធដែលមានដូចជាមជ្ឈត្តករផ្ទាល់ ឬបុគ្គលដែលមានវិជ្ជាជីវៈពាក់ព័ន្ធមួយនឹងយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះ ឬបុគ្គលដែលមកពីស្ថាប័នមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បង្កើនការចែករំលែកចំណេះដឹង និងនីតិវិធីនៃដំណើរការដោះស្រាយវិវាទតាមយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះឱ្យមានភាពស៊ីជម្រៅជាងពេលបច្ចុប្បន្ន។
- បើកវគ្គបណ្តុះបណ្តាលដោយឥតគិតថ្លៃជូនដល់ជាពិសេសនិស្សិតច្បាប់ និងអ្នកពាក់ព័ន្ធផ្សេងទៀតដូចជាអ្នកច្បាប់ មេធាវី ឬវិនិយោគិន ជាអាទិ៍ ដើម្បីឱ្យមានការយល់ដឹងឱ្យកាន់តែច្បាស់អំពីការប្រើប្រាស់យន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្មកាន់តែច្រើនឡើង។ ជាពិសេស ទាក់ទងនឹងការប្រើប្រាស់ពាក្យពេចន៍ជាភាសាអង់គ្លេស និងបច្ចេកស័ព្ទដែលត្រូវប្រើប្រាស់ក្នុងភាសាដើម្បីពង្រីកសមត្ថភាពនៃការយល់ដឹងបន្ថែម ពាក់ព័ន្ធនឹងយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ហើយក៏ជាឱកាសមួយផងដែរសម្រាប់ពង្រឹងការវិនិយោគពីវិនិយោគិនទាំងក្នុង និងក្រៅប្រទេស។
- អ្វីដែលសំខាន់ជាងគេនោះគឺការដាក់បញ្ចូលនូវមេរៀនទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលទាក់ទងនឹងការដោះស្រាយវិវាទ តាមរយៈយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្មឱ្យមានភាពស៊ីជម្រៅ និងក្បោះក្បាយបន្ថែមទៀត ទៅក្នុងកម្មវិធីសិក្សាផ្សេងៗ ដែលអាចធ្វើឱ្យអ្នកសិក្សាទាំងឡាយទទួលបានពុទ្ធិដែលទាក់ទងនឹងយន្តការនេះ ក៏ដូចជាបញ្ជ្រាបទៅគ្រប់មូលដ្ឋាន និងពង្រីកនូវវិសាលភាពនៃយន្តការនេះឱ្យកាន់តែមានភាពរីកដុះដាលទូទាំងប្រទេស។
- ក្រសួងយុត្តិធម៌គប្បីបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យឱ្យបានច្បាស់លាស់ ដែលពាក់ព័ន្ធទៅនឹងមជ្ឈត្តវិនិច្ឆ័យ ដែលភាគីបានប្តឹងទៅសាលាឧទ្ធរណ៍ទៅលើការប្តឹងជំទាស់ ការទទួលស្គាល់ការបដិសេធ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ។ ការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យបែបនេះគឺមានភាពងាយស្រួល និងក្តោបក្តាប់ព័ត៌មាន ដែលពាក់ព័ន្ធនឹងមជ្ឈត្តវិនិច្ឆ័យឱ្យបានច្បាស់លាស់ថាសំណុំរឿងដែលពាក់ព័ន្ធនឹងមជ្ឈត្តវិនិច្ឆ័យភាគីបានប្តឹងមកតុលាការក្នុង ១ (មួយ) ឆ្នាំ

មានចំនួនប៉ុន្មានសំណុំរឿង តុលាការទទួលស្គាល់មានចំនួនសំណុំរឿង តុលាការបដិសេធមានចំនួនប៉ុន្មានសំណុំរឿង និងដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យមានប៉ុន្មានសំណុំរឿង។ ទន្ទឹមនឹងនេះ ក្រោយពេលក្រសួងយុត្តធម៌ បានបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យរួចរាល់ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវតែធ្វើបច្ចុប្បន្នភាពជាប្រចាំទៅលើគេហទំព័ររបស់ ម.ជ.ម. ផងដែរ ដើម្បីឱ្យសាធារណជនបានដឹងអំពីវឌ្ឍនភាពនៃសំណុំរឿង និងជាការបង្ហាញឱ្យឃើញថាយន្តការនៃការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មានភាពទំនើបកម្ម និងពេញនិយមសម្រាប់វិនិយោគិនក្នុងការប្រើប្រាស់ប្រព័ន្ធមួយនេះ។

ជាចុងក្រោយ ក្នុងនាមជាបញ្ញាវ័ន្តជំនាន់ថ្មី និងជាទំពាំងស្នងឫស្សី យើងខ្ញុំសង្ឃឹម និងមានជំនឿយ៉ាងមុតមាំថា រាជរដ្ឋាភិបាល មន្ត្រីមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ មិត្តនិស្សិតដែលមានជំនាញខាងនីតិសាស្ត្រ និងប្រជាពលរដ្ឋគ្រប់រូបនឹងព្យាយាមពង្រីកការយល់ដឹង និងពង្រឹងសមត្ថភាពលើវិស័យច្បាប់ទាំងឯកជន និងសាធារណៈ ជាពិសេសប្រជាពលរដ្ឋគប្បីមានការយល់ដឹងបន្ថែមពាក់ព័ន្ធនឹងការដោះស្រាយវិវាទតាមរយៈប្រព័ន្ធតុលាការ និងការដោះស្រាយវិវាទតាមរយៈយន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីធានាឱ្យបាននូវវិសាលភាពពេញលេញក្នុងការអនុវត្តដែលអាចជាប្រយោជន៍រួមសម្រាប់សង្គមជាតិ និងចៀសវាងការចំណាយពេលវេលា និងថវិកាក្នុងចំនួនច្រើនផងដែរ។

# ឯកសារយោង

## ឯកសារយោង

### ១. លិខិតបទដ្ឋានគតិយុត្ត

- ❖ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣
- ❖ ច្បាប់ស្ដីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ថែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្ដីសម្រេចមជ្ឈត្តករបរទេស, លេខ នស/រកម/០៧០១/១០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១។
- ❖ ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦។
- ❖ ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦។
- ❖ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។
- ❖ អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩។
- ❖ វិធានស្ដីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។
- ❖ ក្រមសីលធម៌សម្រាប់មជ្ឈត្តករ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។
- ❖ បទបញ្ជាផ្ទៃក្នុង របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។

### ២. ឯកសារជំនួយស្មារតី

- ❖ សៀវភៅ កម្រងវិធីសាស្ត្រគន្លឹះ នីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និពន្ធដោយមជ្ឈត្តករ ហួន សុខនីម ចុះផ្សាយក្នុងឆ្នាំ២០២១។
- ❖ សេចក្ដីព្រាង មជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា ទិដ្ឋភាពច្បាប់ និងការអនុវត្ត រៀបរៀងដោយមជ្ឈត្តករ សាន គីរី ចុះក្នុងឆ្នាំ២០២៤។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១** ៖ គំរូខចែងស្តីពីមជ្ឈត្តការ

**ឧបសម្ព័ន្ធទី២** ៖ សេចក្តីបង្គាប់នីតិវិធី

## ២. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១** ៖ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦។

**ឧបសម្ព័ន្ធទី២** ៖ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ។

**ឧបសម្ព័ន្ធទី៣** ៖ វិធានស្តីពីមជ្ឈត្តការ, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១ ។

# ឧបសម្ព័ន្ធរូបភាព

# ឧបសម្ព័ន្ធទី១៖ គំរូខចែងស្តីពីមជ្ឈត្តការ របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

## គំរូខចែងរបស់ ម.ជ.ម.

### ខចែងស្តីពីមជ្ឈត្តការ

រាល់វិវាទទាំងអស់ដែលកើតចេញពី ឬដែលទាក់ទងនឹងកិច្ចសន្យានេះ រួមបញ្ចូលវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត ឬការបញ្ចប់កិច្ចសន្យានេះ ត្រូវបញ្ជូនទៅដោះស្រាយជាស្ថាពរតាមរយៈមជ្ឈត្តការចាត់ចែងដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (វិធានស្តីពីមជ្ឈត្តការ ម.ជ.ម.) ដែលមានសុពលភាពអនុវត្តនៅពេលចាប់ផ្តើមដំណើរការមជ្ឈត្តការ ហើយតាមរយៈការយោងក្នុងប្រការនេះ វិធានស្តីពីមជ្ឈត្តការ ម.ជ.ម. ត្រូវចាត់ទុកថាបានរួមបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។

ទីកន្លែងធ្វើមជ្ឈត្តការគឺ [រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]។*

វេទិកាមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករចំនួន__________**រូប។

ភាសានៃមជ្ឈត្តការគឺ ________________ ។

### ខចែងស្តីពីច្បាប់គ្រប់គ្រងកិច្ចសន្យា

ច្បាប់ដែលត្រូវយកមកអនុវត្តលើកិច្ចសន្យានេះគឺច្បាប់នៃ________________***។

* គូភាគីវិវាទគួរបញ្ជាក់អំពីជម្រើស នៃទីកន្លែងធ្វើមជ្ឈត្តការរបស់ខ្លួន។ ប្រសិនបើគូភាគីវិវាទមានបំណងចង់ជ្រើសរើសទីកន្លែងធ្វើមជ្ឈត្តការផ្សេងពីរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា គូភាគីវិវាទត្រូវជំនួស "[រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]" ដោយឈ្មោះទីក្រុង និងប្រទេសនៃជម្រើសរបស់ខ្លួន (ឧទាហរណ៍ "[ទីក្រុង ប្រទេស]")។

** ចំនួនមជ្ឈត្តករត្រូវកំណត់ជាចំនួនសេស។

*** បញ្ជាក់ឈ្មោះប្រទេស ឬយុត្តាធិការ។

## ឧបសម្ព័ន្ធទី២៖ សេចក្តីបង្គាប់នីតិវិធី របស់វេទិកាមជ្ឈត្តកម្ម

### កាលវិភាគនីតិវិធី

| ល.រ | ព្រឹត្តិការណ៍ | គូភាគី / វេទិកាមជ្ឈត្តកម្ម | កាលបរិច្ឆេទកំណត់ |
|---|---|---|---|
| ១ | ការដាក់សេចក្តីថ្លែងទាមទារដោយភាគីប្តឹងទាមទារ រួមជាមួយនឹងឯកសារយោងទាំងអស់ ជាអាទិ៍ ឯកសារភស្តុតាង សក្ខីកម្មជាលាយលក្ខណ៍អក្សរ របស់សាក្សី ឬអ្នកជំនាញ (ប្រសិនបើមាន) | ភាគីប្តឹងទាមទារ | ថ្ងៃទី[x] ខែ[x] ឆ្នាំ ២០២[x] |
| ២ | ការដាក់សេចក្តីថ្លែងដោះសា និងបណ្តឹងតបដោយភាគីឆ្លើយតប រួមជាមួយនឹងឯកសារយោងទាំងអស់ ជាអាទិ៍ ឯកសារភស្តុតាង សក្ខីកម្មជាលាយលក្ខណ៍អក្សររបស់សាក្សី ឬអ្នកជំនាញ (ប្រសិនបើមាន) | ភាគីឆ្លើយតប | ថ្ងៃទី[x] ខែ[x] ឆ្នាំ ២០២[x] |
| ៣ | ការដាក់សេចក្តីថ្លែងដោះសាចំពោះបណ្តឹងតប ដោយភាគីប្តឹងទាមទារ រួមជាមួយនឹងឯកសារយោងទាំងអស់ ជាអាទិ៍ ឯកសារភស្តុតាង សក្ខីកម្ម ជាលាយលក្ខណ៍អក្សររបស់សាក្សី ឬអ្នកជំនាញ (ប្រសិនបើមាន) | ភាគីប្តឹងទាមទារ | ថ្ងៃទី[x] ខែ[x] ឆ្នាំ ២០២[x] |
| ៤ | ផ្តល់ឯកសារភស្តុតាងទាំងអស់ ដែលពឹងផ្អែកសម្រាប់ការទាមទារ ការដោះសា និងបណ្តឹងតប ជាអាទិ៍ ឯកសារភស្តុតាង សក្ខីកម្មជាលាយលក្ខណ៍អក្សររបស់សាក្សី ឬអ្នកជំនាញ (ប្រសិនបើមាន) | គូភាគី | ថ្ងៃទី[x] ខែ[x] ឆ្នាំ ២០២[x] |
| ៥ | សេចក្តីជូនដំណឹងជាមុនអំពីអត្តសញ្ញាណរបស់សាក្សី ឬអ្នកជំនាញ ដែលគូភាគីមានបំណងកោះហៅចូលរួមក្នុងសវនាការ ដើម្បីផ្តល់សក្ខីកម្មផ្ទាល់មាត់ | គូភាគី | ថ្ងៃទី[x] ខែ[x] ឆ្នាំ ២០២[x] |

| | | | |
|---|---|---|---|
| ៦ | កិច្ចប្រជុំត្រៀមរៀបចំសវនាការ | គូភាគី និង វេទិកាមជ្ឈត្តកម្ម | ថ្ងៃទី[x] ខែ[x] ឆ្នាំ ២០២[x] |
| ៧ | បណ្ដុំឯកសារសម្រាប់សវនាការ (hearing bundle) | គូភាគី | ថ្ងៃទី[x] ខែ[x] ឆ្នាំ ២០២[x] |
| ៨ | សេចក្តីជូនដំណឹងអំពីសវនាការ | វេទិកាមជ្ឈត្តកម្ម | ថ្ងៃទី[x] ខែ[x] ឆ្នាំ ២០២[x] |
| ៩ | បញ្ជីបឋមនៃចំណុចវិវាទ និងសំណួរមុនពេលសវនាការ | វេទិកាមជ្ឈត្តកម្ម | ថ្ងៃទី[x] ខែ[x] ឆ្នាំ ២០២[x] |
| ១០ | សេចក្តីថ្លែងបើកជាលាយលក្ខណ៍អក្សរ | គូភាគី | ថ្ងៃទី[x] ខែ[x] ឆ្នាំ ២០២[x] |
| ១១ | សវនាការ | គូភាគី និង វេទិកាមជ្ឈត្តកម្ម | ថ្ងៃទី[x] ខែ[x] ឆ្នាំ ២០២[x] |
| ១២ | សេចក្តីថ្លែងបិទជាលាយលក្ខណ៍អក្សរ | គូភាគី | ថ្ងៃទី[x] ខែ[x] ឆ្នាំ ២០២[x] |

# ឧបសម្ព័ន្ធគតិយុត្ត

# ព្រះរាជក្រម

នស/រកម/០៥០៦/០១០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦ ក្នុងសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បី ពិនិត្យច្បាប់នេះឱ្យទាន់តាមកាលកំណត់របស់មាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ និងដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសម្រេចលេខ ០៧៥/០០២/២០០៦ កបធ.ច ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងសម្រួលដល់ការដោះស្រាយជាបន្ទាន់ តាមការផ្សះផ្សានូវវិវាទពាណិជ្ជកម្មដែលកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមការស្ម័គ្រចិត្តរបស់ភាគីវិវាទដើម្បីការពារសិទ្ធិនិងផលប្រយោជន៍នៃភាគីវិវាទទាំងនេះ និងដើម្បីលើកស្ទួយការអភិវឌ្ឍន៍សេដ្ឋកិច្ច ។

ច្បាប់នេះមិនប៉ះពាល់ដល់អានុភាពគតិយុត្តិនៃច្បាប់នានាឯទៀតរបស់ព្រះរាជាណាចក្រកម្ពុជាដែលនៅក្នុងនោះ ករណីវិវាទខ្លះផ្សះផ្សាបាន ឬ ដោះស្រាយបានតាមនីតិវិធីផ្សេងៗទៀត និងវិវាទខ្លះទៀតផ្សះផ្សាមិនបាន ។

**មាត្រា ២.-**

និយមន័យ និងវិធាននៃការបកស្រាយពាក្យដែលប្រើក្នុងច្បាប់នេះ :

ក- "មជ្ឈត្តការ" គឺជាការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្ម ហើយអាចស្ថិតនៅក្នុង ឬ នៅក្រៅក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍ ។

ខ- "វេទិកាមជ្ឈត្តកម្ម" គឺជាមជ្ឈត្តករមួយនាក់ ឬ មួយក្រុម ។

គ- "តុលាការ" គឺជាស្ថាប័ន ឬ អង្គការនៃប្រព័ន្ធតុលាការរបស់ប្រទេសមួយ ។

ឃ- "កិច្ចព្រមព្រៀងផ្សះផ្សា" ជាកិច្ចព្រមព្រៀងរវាងភាគីវិវាទក្នុងការធ្វើមជ្ឈត្តការវិវាទទាំងអស់ ឬ វិវាទបែបណាមួយដែលកើតឡើង ឬ ដែលអាចកើតឡើងរវាងភាគីវិវាទនានា ដោយគោរពតាមទំនាក់ទំនងកំណត់ដោយច្បាប់ ទោះបីជាមានកិច្ចសន្យា ឬ គ្មានក៏ដោយ ។

ង-ក្រៅពីមាត្រា ៣៦ កាលណាបទប្បញ្ញត្តិនានានៃច្បាប់នេះទុកសេរីភាពឱ្យភាគីវិវាទកំណត់ពីបញ្ហាណាមួយ សេរីភាពនេះគឺរាប់បញ្ចូលទាំងសិទ្ធិរបស់ភាគីវិវាទក្នុងការអនុញ្ញាតឱ្យមានភាគីទី ៣ រួមបញ្ចូលទាំងស្ថាប័នមួយ ដើម្បីធ្វើការសម្រេចលើបញ្ហានោះ ។

4/28

ច-ក្នុងករណីដែលបទប្បញ្ញត្តិនៃច្បាប់នេះ យោងតាមអ្វីដែលភាគីវិវាទបានព្រមព្រៀង ឬ អាចនឹងព្រមព្រៀងគ្នា ឬ យោងតាមមធ្យោបាយផ្សេងទៀតនៃកិច្ចព្រមព្រៀងរបស់ភាគីវិវាទ កិច្ចព្រមព្រៀងនោះ ។

ឆ-ក្រៅពីមាត្រា ៣៣ (១) និងមាត្រា ៤០ (១) នៃច្បាប់នេះ កាលណាបទប្បញ្ញត្តិនៃច្បាប់នេះយោងតាមការប្តឹងទាមទារ បទប្បញ្ញត្តិនោះក៏ត្រូវអនុវត្តចំពោះការប្តឹងទាមទារបកវិញដែរ ហើយនៅពេលដែលយោងតាមការដោះសាពីការប្តឹងទាមទារ ក៏ត្រូវអនុវត្តចំពោះការដោះសាពីការប្តឹងទាមទារបកវិញដែរ ។

ជ-មជ្ឈត្តការមានលក្ខណៈជា "អន្តរជាតិ" ក្នុងករណី :

ជ.១-ភាគីវិវាទ និងកិច្ចព្រមព្រៀងផ្សះផ្សាមានទីកន្លែងធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសផ្សេងពីគ្នា ក្នុងពេលសម្រេចកិច្ចព្រមព្រៀងនោះ ឬ

ជ.២-ទីកន្លែងមួយក្នុងចំណោមទីកន្លែងខាងក្រោមនោះ ស្ថិតនៅក្រៅប្រទេសធ្វើពាណិជ្ជកម្មរបស់ភាគីវិវាទ :

-ទីកន្លែងធ្វើមជ្ឈត្តការ : ប្រសិនបើបានកំណត់ ឬ បានយោងក្នុងកិច្ចព្រមព្រៀងផ្សះផ្សា ។

-ទីកន្លែងដែលភាគច្រើនកិច្ចសំខាន់នៃទំនាក់ទំនងពាណិជ្ជកម្មបានប្រព្រឹត្តទៅ ឬ ទីកន្លែងជិតជាងគេនៃរឿងពាក់ព័ន្ធនឹងវិវាទ ។

ជ.៣-ភាគីវិវាទបានព្រមព្រៀងជាក់លាក់ថា រឿងនៃកិច្ចព្រមព្រៀងផ្សះផ្សាទាក់ទងទៅនឹងប្រទេសលើសពីមួយ ។

ជ.៤-តាមគោលបំណងក្នុងកថាខណ្ឌ (ជ) នេះ :

-ប្រសិនបើភាគីវិវាទមួយមានទីកន្លែងប្រកបពាណិជ្ជកម្មលើសពីមួយកន្លែង ទីកន្លែងដែលមានទាក់ទងជិតស្និទ្ធជាងគេបំផុតទៅនឹងកិច្ចព្រមព្រៀងផ្សះផ្សាគឺជាទីកន្លែងពាណិជ្ជកម្ម ។

-ប្រសិនបើភាគីវិវាទមួយមិនមានទីកន្លែងប្រកបពាណិជ្ជកម្មទេ ការយោងក្នុងច្បាប់នេះគឺទីលំនៅអចិន្ត្រៃយ៍របស់ភាគីនោះ ។

ឈ-ពាក្យថា "ពាណិជ្ជកម្ម" ត្រូវបកស្រាយឱ្យបានទូលំទូលាយ ដើម្បីគ្របដណ្តប់លើធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្ម ទោះបីជាមានកិច្ចសន្យា ឬ គ្មានកិច្ច

សន្យាក៏ដោយ ។ ធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្មមានជាអាទិ៍ : កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬ ការផ្លាស់ប្តូរទំនិញ ឬ សេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬ ទីភ្នាក់ងារពាណិជ្ជកម្ម ការទិញ-លក់គណនីក្រុមហ៊ុន ការជួលទីតាំង ឬ សម្ភារៈវត្ថុ ការងារស្ថាបនា ការពិគ្រោះយោបល់វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬ សម្បទាន ក្រុមហ៊ុនចំរុះ និងប្រភេទផ្សេងៗទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬ ពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ ឬ អ្នកដំណើរតាមផ្លូវអាកាស ផ្លូវទឹក ផ្លូវគោក ។

**មាត្រា ៣.-**

លើកលែងតែភាគីទាំងអស់បានព្រមព្រៀងផ្សេងពីនេះ :

១-លិខិតឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាបានទទួល ក្នុងករណីដែលបានប្រគល់ឱ្យអ្នកទទួលដោយផ្ទាល់ដៃ ឬ ប្រគល់ដល់កន្លែងប្រកបពាណិជ្ជកម្ម ឬ ទីលំនៅអចិន្ត្រៃយ៍ ឬ អាសយដ្ឋានប្រៃសណីយ៍របស់អ្នកទទួល ។ ប្រសិនបើរកកន្លែងទាំងនោះមិនឃើញទេ ក្រោយពីការស្វះស្វែងរកយ៉ាងល្អិតល្អន់រួចមក លិខិតឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាបានទទួលក្នុងករណីបានធ្វើតាមរយៈលិខិតអនុសិដ្ឋ ឬ តាមមធ្យោបាយផ្សេងៗដែលផ្តល់ហេតុផលថា ពិតជាបានខំប្រឹងប្រែងប្រគល់លិខិតទៅដល់កន្លែងប្រកបពាណិជ្ជកម្ម ឬ ទីលំនៅអចិន្ត្រៃយ៍ ឬ អាសយដ្ឋានរបស់អ្នកទទួលដែលស្គាល់ចុងក្រោយបំផុត ។

២-បទប្បញ្ញត្តិនានាក្នុងមាត្រា ៣ នៃច្បាប់នេះ មិនយកទៅអនុវត្តលើលិខិតឆ្លើយឆ្លងក្នុងពេលដំណើរការកាត់ក្តីរបស់តុលាការទេ ។

**មាត្រា ៤.-**

ត្រូវបានចាត់ទុកថាបានបោះបង់សិទ្ធិជំទាស់របស់ខ្លួន ប្រសិនបើភាគីវិវាទមួយបានដឹងថាភាគីវិវាទផ្សេងទៀត អាចប្រព្រឹត្តខុសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ពុំគោរពតាមការតម្រូវរបស់កិច្ចព្រមព្រៀងផ្សះផ្សា ប៉ុន្តែភាគីវិវាទនោះនៅតែបន្តដំណើរការមជ្ឈត្តការដោយមិនបានជំទាស់ទៅនឹងការមិនគោរពនោះ ហើយក្នុងករណីដែលមានចែងពីរយៈពេលកំណត់សម្រាប់ការជំទាស់ ភាគីវិវាទនោះពុំបានធ្វើការពន្យារពេលជាចាំបាច់ ។

មាត្រា ៥.–

នៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ តុលាការធ្វើអន្តរាគមន៍បានតែក្នុងករណីទាំងឡាយណាដែលច្បាប់នេះបានចែង ។

មាត្រា ៦.–

មុខងារផ្សេងៗដែលមានចែងក្នុងមាត្រា ១៩ កថាខណ្ឌទី ៣, ៤ និង ៥ មាត្រា ២១ កថាខណ្ឌទី ៣ មាត្រា ២២ មាត្រា ២៤ កថាខណ្ឌទី ៣ នៃច្បាប់នេះ ត្រូវបំពេញដោយតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ។

## ជំពូកទី ២

## កិច្ចព្រមព្រៀងផ្សះផ្សា

មាត្រា ៧.–

កិច្ចព្រមព្រៀងផ្សះផ្សារួមមានខចែងស្តីពីមជ្ឈត្តការដែលបានចែងនៅក្នុងកិច្ចសន្យា ឬ ក្នុងកិច្ចព្រមព្រៀងដោយឡែក ។

កិច្ចព្រមព្រៀងផ្សះផ្សាត្រូវសរសេរជាលាយលក្ខណ៍អក្សរ ។ ដែលហៅថាកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ គឺជាកិច្ចព្រមព្រៀងដែលស្ថិតនៅក្នុងឯកសារចុះហត្ថលេខាដោយភាគីវិវាទ ឬ ដែលស្ថិតនៅក្នុងការផ្ញើរលិខិតឆ្លាម ឬ មធ្យោបាយទូរគមនាគមន៍តាមប្រព័ន្ធអេឡិចត្រូនិច ដែលផ្តល់កំណត់ត្រាបញ្ជាក់ពីការព្រមព្រៀងគ្នា ឬ ដែលស្ថិតនៅក្នុងការប្តូរគ្នាទៅវិញទៅមកនូវពាក្យទាមទារ ឬ ពាក្យដោះសាដែលក្នុងនោះ ភាគីវិវាទមួយបានទាមទារ ហើយមិនត្រូវបានបដិសេធដោយភាគីវិវាទម្ខាងទៀត ។ សេចក្តីយោងក្នុងកិច្ចសន្យា និង ឯកសារមួយដែលមានប្រការស្តីពីមជ្ឈត្តការអាចក្លាយជាកិច្ចព្រមព្រៀងផ្សះផ្សាបានលុះត្រាណាកិច្ចសន្យានោះសរសេរជាលាយលក្ខណ៍អក្សរ ហើយសេចក្តីយោងនោះគឺជាប្រការដែលក្លាយជាផ្នែកមួយនៃកិច្ចសន្យា ។

**មាត្រា ៨.-**

នៅពេលដោះស្រាយបណ្ដឹងវិវាទ តុលាការដែលទទួលដោះស្រាយវិវាទដែលជាកម្មវត្ថុកិច្ចព្រមព្រៀងផ្សះផ្សា ត្រូវបញ្ជូនភាគីវិវាទទៅធ្វើមជ្ឈត្តការ ប្រសិនបើមានសំណើពីភាគីវិវាទមួយ លើកលែងតែតុលាការនោះរកឃើញថាកិច្ចព្រមព្រៀងផ្សះផ្សានោះត្រូវចាត់ទុកជាមោឃៈ ឬ មិនអាចអនុវត្តបាន ។

ទោះបីជាមានបណ្ដឹងទាមទារទៅតុលាការដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះក៏ដោយ ក៏ដំណើរការរបស់វេទិកាមជ្ឈត្តកម្មអាចចាប់ផ្ដើម ឬ បន្តដំណើរការបានតទៅទៀត ហើយតុលាការត្រូវបង្វែរសមត្ថកិច្ចជូនទៅវេទិកាមជ្ឈត្តកម្មវិញ ដោយរង់ចាំការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ។

**មាត្រា ៩.-**

នៅមុនពេល ឬ ក្នុងពេលកំពុងដំណើរការមជ្ឈត្តការ ការធ្វើសំណូមពររបស់ភាគីវិវាទមួយទៅតុលាការឱ្យផ្ដល់វិធានការបណ្ដោះអាសន្ន ដើម្បីការពារ និងការផ្ដល់នូវវិធានការទាំងនោះដោយតុលាការពុំមានវិសមិតភាពជាមួយកិច្ចព្រមព្រៀងផ្សះផ្សាឡើយ ។

## ជំពូកទី ៣
## មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

**មាត្រា ១០.-**

ត្រូវបានបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការមួយឯករាជ្យ នៅក្រោមការឧបត្ថម្ភរបស់ក្រសួងពាណិជ្ជកម្ម ។ គោលបំណងនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការគឺ :

១-ជម្រុញការដោះស្រាយវិវាទពាណិជ្ជកម្ម តាមរយៈការផ្សះផ្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា

២-បង្កើតរចនាសម្ព័ន្ធ និងវិធានចាំបាច់សម្រាប់គ្រប់គ្រងរឿងមជ្ឈត្តការនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដែលកិច្ចព្រមព្រៀងជាក់ច្បាស់មួយនៃភាគីវិវាទ ដាក់វិវាទទៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

៣-ធានាឱ្យមជ្ឈត្តការនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានគុណភាពខ្ពស់ ។ គោល

9/28k

បំណងនេះរួមបញ្ចូលការកំណត់ស្តង់ដាសម្រាប់លក្ខណៈសម្បត្តិរបស់មជ្ឈត្តករ ។

**មាត្រា ១១.-**

រូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬ បរទេសដែលជាមជ្ឈត្តករត្រូវចុះបញ្ជីនៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការមានភារកិច្ចកំណត់ពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករ ហើយត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈនូវបញ្ជីឈ្មោះមជ្ឈត្តករជារៀងរាល់ឆ្នាំ ។ បញ្ជីនេះមិនមានលក្ខណៈដាច់ណាត់ទេ ភាគីវិវាទអាចជ្រើសរើសមជ្ឈត្តករក្រៅពីបញ្ជីក៏បាន ។

**មាត្រា ១២.-**

អាចសុំចូលជាសមាជិកមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការបាន រូបវន្តបុគ្គល និងនីតិបុគ្គលដូចខាងក្រោម :

-រូបវន្តបុគ្គលជាមជ្ឈត្តករដែលបានចុះឈ្មោះក្នុងបញ្ជីរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

-សភាពាណិជ្ជកម្ម

-គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-រាល់សមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និង សេវាករ ។

សំណើសុំចូលជាសមាជិកមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ត្រូវបានពិនិត្យដោយក្រុមប្រឹក្សាប្រតិបត្តិនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការដែលមានចំនួនមិនលើសពីប្រាំពីរ (៧) នាក់ ។ សមាជិកក្រុមប្រឹក្សាប្រតិបត្តិមានអាណត្តិរយៈពេលបី (៣) ឆ្នាំ ហើយអាចឈរឈ្មោះបន្តមួយអាណត្តិទៀតបាន ។

**មាត្រា ១៣.-**

សភាពាណិជ្ជកម្មអាចរៀបចំមជ្ឈមណ្ឌលមជ្ឈត្តកម្មមួយនៅភ្នំពេញ ។ រាល់សមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និងសេវាករ អាចបង្កើតមជ្ឈមណ្ឌលមជ្ឈត្តកម្មរបស់ខ្លួនដោយឡែកសម្រាប់ដោះស្រាយវិវាទរវាងសមាជិក និងរវាងសមាជិកជាមួយអ្នកដទៃ ។

7/28

**មាត្រា ១៤.-**

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ត្រូវគ្រប់គ្រងដោយ :

-មហាសន្និបាត

-ក្រុមប្រឹក្សាប្រតិបត្តិ ។

ភារកិច្ចសំខាន់ៗរបស់មហាសន្និបាតមាន :

-ប្រជុំមួយដង ឬ ពីរដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ឬ តាមសំណើរបស់សមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ ។

-ជ្រើសតាំងក្រុមប្រឹក្សាប្រតិបត្តិ

-ពិនិត្យរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាប្រតិបត្តិ

-សម្រេចលើស្ថានភាពហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

-កំណត់សោហ៊ុយ ដែលជាតម្លៃនៃការធ្វើមជ្ឈត្តការ

-ពិនិត្យសម្រេចលើរាល់សំណើកែប្រែលិខិតបទដ្ឋានដែលទាក់ទងដល់ដំណើរការមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ និងដំណើរការមជ្ឈត្តការ ។

-បំពេញភារកិច្ចផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។

**មាត្រា ១៥.-**

មហាសន្និបាតរួមប្រជុំដោយសមាជិកជារូបវន្តបុគ្គល និងតំណាងមួយរូបរបស់សមាជិកជានីតិបុគ្គលនិមួយៗ ។

**មាត្រា ១៦.-**

សមាសភាពក្រុមប្រឹក្សាប្រតិបត្តិដែលគ្រប់គ្រងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការត្រូវបានបោះឆ្នោតជ្រើសតាំងក្នុងចំណោមសមាជិកដោយមហាសន្និបាត ។ ប្រធានក្រុមប្រឹក្សាប្រតិបត្តិ គឺជាប្រធានរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។

4

10/28K

**មាត្រា ១៧.-**

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## សមាសភាពនៃវេទិកាមជ្ឈត្តកម្ម

**មាត្រា ១៨.-**

ភាគីវិវាទមានសិទ្ធិកំណត់ចំនួនមជ្ឈត្តករនៃវេទិកាមជ្ឈត្តកម្ម ។ មជ្ឈត្តករត្រូវមានចំនួនសេស ។

បើគ្មានការកំណត់ពីភាគីវិវាទទេ មជ្ឈត្តករត្រូវមានចំនួនបី (៣) នាក់ ។

**មាត្រា ១៩.-**

ការជ្រើសតាំងមជ្ឈត្តករត្រូវអនុវត្តតាមបែបបទដូចខាងក្រោម :

១-មិនត្រូវបដិសេធជនណាម្នាក់មិនឱ្យធ្វើមជ្ឈត្តករ ដោយសារមូលហេតុនៃសញ្ជាតិរបស់គេឡើយ លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ។

២-ភាគីវិវាទអាចព្រមព្រៀងលើនីតិវិធីនៃការតែងតាំងមជ្ឈត្តករមួយ (១) នាក់ ឬ ច្រើននាក់ យោងតាមបទប្បញ្ញត្តិក្នុងកថាខណ្ឌទី ៤ និងកថាខណ្ឌទី ៥ នៃមាត្រានេះ ។

៣-ករណីមិនបានព្រមព្រៀងពីនីតិវិធីនេះ :

ក-ក្នុងការធ្វើមជ្ឈត្តការដែលមានមជ្ឈត្តករបី (៣) នាក់ ភាគីវិវាទនីមួយៗត្រូវជ្រើសតាំងមជ្ឈត្តករមួយ (១) នាក់ ហើយមជ្ឈត្តករទាំងពីរនាក់នេះ ត្រូវជ្រើសតាំងមជ្ឈត្តករទីបី ។ ប្រសិនបើភាគីវិវាទណាមួយពុំបានជ្រើសតាំងមជ្ឈត្តករក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពេលទទួលសំណើជ្រើសតាំងពីភាគីវិវាទម្ខាងទៀត ឬ ប្រសិនបើមជ្ឈត្តករទាំងពីរ (២) នាក់ ពុំបានព្រមព្រៀងលើការតែងតាំងមជ្ឈត្តករទីបីក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពីត្រូវបានគេជ្រើសតាំងរួចមក តុលាការ ( តុលាការពាណិជ្ជ-កម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជ-

កម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវជ្រើសតាំងមជ្ឈត្តករទី ៣ តាមការស្នើសុំនៃភាគីវិវាទណាមួយ ។

ខ-ក្នុងការធ្វើមជ្ឈត្តការដែលមានមជ្ឈត្តករតែមួយនាក់ ប្រសិនបើភាគីវិវាទមិនអាចព្រមព្រៀងលើការជ្រើសតាំងមជ្ឈត្តករទេនោះ តុលាការ (តុលាការ ពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះត្រូវជ្រើសតាំងមជ្ឈត្តករតាមសំណូមពររបស់ភាគីវិវាទណាមួយ ។

៤-តាមនីតិវិធីជ្រើសតាំងមជ្ឈត្តករ ដែលបានព្រមព្រៀងដោយភាគីវិវាទភាគីវិវាទណាក៏ដោយ អាចធ្វើសំណូមពរទៅតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះឱ្យចាត់វិធានការចាំបាច់ ក្នុងករណីណាមួយដូចខាងក្រោម :

ក-ភាគីវិវាទមួយមិនបានប្រតិបត្តិតាមការតម្រូវក្នុងនីតិវិធី ឬ

ខ-ភាគីវិវាទ ឬ មជ្ឈត្តករពីរ (២) នាក់ មិនអាចឈានដល់ការព្រមព្រៀងដូចដែលគេរំពឹងទុកតាមនីតិវិធីនេះ ឬ

គ-ភាគីទីបី ដោយរាប់បញ្ចូលទាំងស្ថាប័នមួយផង មិនបានអនុវត្តតួនាទីណាមួយដូចដែលបានប្រគល់ឱ្យក្នុងនីតិវិធីនោះ ។ មាត្រានេះ មិនត្រូវបានយកមកអនុវត្តទេ ប្រសិនបើការព្រមព្រៀងស្តីពីនីតិវិធីជ្រើសតាំងមជ្ឈត្តករមានចែងពីវិធីផ្សេងទៀតសម្រាប់ធានាដល់ការជ្រើសតាំងនោះ ។

៥-ការជ្រើសតាំងរបស់តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ លើបញ្ហាណាមួយតាមកថាខណ្ឌទី ៣ ឬ កថាខណ្ឌទី ៤ នៃមាត្រានេះ គឺជាការសម្រេចដែលមិនអាចតវ៉ាបានឡើយ ។ នៅក្នុងការជ្រើសតាំងមជ្ឈត្តករម្នាក់ តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវពិចារណាពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករដែលបានចែងក្នុងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ដើម្បីធានាដល់ការជ្រើសតាំងមជ្ឈត្តករដែលឯករាជ្យ និងមិនលម្អៀង ។ ក្នុងករណីមានមជ្ឈត្តករតែមួយនាក់

12/28

ឬ មានមជ្ឈត្តករទីបី នៅក្នុងការធ្វើមជ្ឈត្តការដែលមានលក្ខណៈអន្តរជាតិ តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវពិនិត្យលទ្ធភាពជ្រើសតាំងមជ្ឈត្តករដែលមានសញ្ជាតិផ្សេងពីសញ្ជាតិរបស់ភាគីវិវាទ ដូចមានចែងក្នុងចំណុច ១ នៃមាត្រា ១៩ នៃច្បាប់នេះ ។

**មាត្រា ២០.-**

បុគ្គលម្នាក់ដែលត្រូវគេជ្រើសតាំងជាមជ្ឈត្តករ ត្រូវបង្ហាញពីលក្ខណៈពិសេសដែលអាចបង្កឱ្យមានការសង្ស័យពីភាពមិនលម្អៀង ឬ ពីភាពឯករាជ្យរបស់ខ្លួន ចាប់ពីពេលដែលត្រូវគេជ្រើសតាំងមក រហូតដល់ពេលបញ្ចប់ដំណើរការមជ្ឈត្តការ ។ មជ្ឈត្តករត្រូវបង្ហាញពីលក្ខណៈពិសេសទាំងនោះឱ្យភាគីវិវាទបានដឹង ដោយគ្មានពន្យារពេល លើកលែងតែភាគីវិវាទបានដឹងពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករនោះរួចហើយ ។

មជ្ឈត្តករម្នាក់អាចត្រូវជំទាស់តែក្នុងករណីដែលកើតមានការសង្ស័យពីលក្ខណៈពិសេសដែលប៉ះពាល់ដល់ភាពមិនលម្អៀង ឬ ភាពឯករាជ្យរបស់ខ្លួន ឬ នៅពេលដែលខ្លួនមិនមានលក្ខណៈសម្បត្តិដូចដែលភាគីវិវាទបានព្រមព្រៀង ។ ភាគីវិវាទមួយអាចជំទាស់នឹងមជ្ឈត្តករដែលខ្លួនបានជ្រើសតាំង ឬ បានចូលរួមជ្រើសតាំងតែក្នុងករណីដែលមូលហេតុនៃការជំទាស់នោះត្រូវបានដឹងក្រោយពេលជ្រើសតាំងរួចប៉ុណ្ណោះ ។

**មាត្រា ២១.-**

ភាគីវិវាទដែលមានបំណងជំទាស់ទៅនឹងមជ្ឈត្តករ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម :

១-ភាគីវិវាទ អាចព្រមព្រៀងលើនីតិវិធីនៃការជំទាស់នឹងមជ្ឈត្តករដោយអនុលោមតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី ៣ ក្នុងមាត្រានេះ ។

២-ក្នុងករណីគ្មានការព្រមព្រៀងលើនីតិវិធីនៃការជំទាស់នេះ ភាគីវិវាទមួយដែលមានបំណងជំទាស់នឹងមជ្ឈត្តករ ត្រូវធ្វើលិខិតតវ៉ាបញ្ជាក់មូលហេតុពីការជំទាស់នោះជាលាយលក្ខណ៍អក្សរទៅកាន់វេទិកាមជ្ឈត្តកម្ម ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ក្រោយពេលបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ក្រោយពេលបានដឹងពីលក្ខណៈពិសេស ដូចចែងក្នុងមាត្រា ២០ នៃកថាខណ្ឌទី ២ ។ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចលើការជំទាស់ លើកលែងតែមជ្ឈត្តករដែល

13/28

គេជំទាស់នោះ ដកខ្លួនចេញពីមុខតំណែង ឬ លើកលែងតែភាគីវិវាទមួយទៀតបានឯកភាព នឹងការជំទាស់នោះ ។

៣-ប្រសិនបើការជំទាស់ដែលត្រូវធ្វើតាមនីតិវិធីដែលព្រមព្រៀងដោយភាគីវិវាទ ឬ តាមនីតិវិធីក្នុងកថាខណ្ឌទី ២ នៃមាត្រានេះពុំបានសម្រេចទេនោះ ភាគីជំទាស់អាចស្នើសុំឱ្យតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះធ្វើការសម្រេចចុងក្រោយលើការជំទាស់ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងបដិសេធការជំទាស់ ។ ក្នុងពេលរង់ចាំការសម្រេចរបស់តុលាការលើសំណើជំទាស់នេះ វេទិកាមជ្ឈត្តកម្មក្នុងនោះមានទាំងមជ្ឈត្តករដែលត្រូវគេជំទាស់ផងអាចបន្តដំណើរការមជ្ឈត្តការ ហើយអាចធ្វើសេចក្តីសម្រេចបាន ។

**មាត្រា ២២.-**

ប្រសិនបើមជ្ឈត្តករម្នាក់ពុំអាចបំពេញមុខងាររបស់ខ្លួនបានដោយមូលហេតុខាងច្បាប់ ឬ មូលហេតុជាក់ស្តែងណាមួយ ឬ មូលហេតុដទៃទៀតក្នុងរយៈពេលមួយសមស្របនោះ អាណត្តិរបស់មជ្ឈត្តករនោះត្រូវបានបញ្ចប់ដោយមជ្ឈត្តករនោះដកខ្លួនចេញពីមុខតំណែង ឬ ដោយភាគីវិវាទឯកភាពបញ្ចប់អាណត្តិនោះ ។ ផ្ទុយពីនេះ បើនៅតែមានភាពខ្វែងគ្នាស្តីពីមូលហេតុណាមួយ ក្នុងចំណោមមូលហេតុទាំងនេះ ភាគីណាក៏ដោយអាចស្នើសុំឱ្យតុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាកាកំពូល) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះធ្វើការសម្រេចចុងក្រោយពីការបញ្ចប់អាណត្តិនោះ ។

តាមមាត្រានេះ ឬ មាត្រា ២១ កថាខណ្ឌទី ២ នៃច្បាប់នេះ ប្រសិនបើមជ្ឈត្តករម្នាក់ដកខ្លួនចេញពីមុខតំណែង ឬ ប្រសិនបើភាគីមួយឯកភាពចំពោះការបញ្ចប់អាណត្តិរបស់មជ្ឈត្តករនោះ ហេតុការណ៍នេះមិនបណ្តាលឱ្យមានការទទួលយកជាការបាននូវមូលហេតុណាមួយដែលចែងក្នុងមាត្រានេះ ឬ មាត្រា ២០ កថាខណ្ឌទី ២ នៃច្បាប់នេះឡើយ ។

14/28

**មាត្រា ២៣.-**

ក្នុងករណីដែលអាណត្តិរបស់មជ្ឈត្តករម្នាក់ត្រូវបញ្ចប់តាមបញ្ញត្តិនៃមាត្រា ២១ ឬ មាត្រា ២២ នៃច្បាប់នេះ មជ្ឈត្តករជំនួសនឹងត្រូវជ្រើសតាំងស្របតាម វិធាននៃមាត្រា ១៩ នៃច្បាប់នេះ ។

## ជំពូកទី ៥
## សមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្ម

**មាត្រា ២៤.-**

សមត្ថកិច្ចរបស់វេទិការមជ្ឈត្តកម្មត្រូវកំណត់ដូចខាងក្រោម :

១-វេទិកាមជ្ឈត្តកម្មអាចសម្រេចទៅតាមសមត្ថកិច្ចរបស់ខ្លួន ក្នុងនោះមានការជំទាស់នានាដែលទាក់ទងនឹងអត្ថិភាព ឬ សុពលភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ សម្រាប់គោលដៅនេះ ខចែងស្តីពីការផ្សះផ្សាដែលបង្កើតបានជាផ្នែកមួយនៃកិច្ចសន្យា ត្រូវចាត់ទុកថាជាកិច្ចព្រមព្រៀងដោយឡែក ដែលមិនទាក់ទិនទៅនឹងល័ក្ខខ័ណ្ឌដទៃទៀតក្នុងកិច្ចសន្យាឡើយ ។ ការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ដែលចាត់ទុកកិច្ចសន្យាថាមោឃៈ និងអសារឥតការមិននាំអោយខចែងស្តីពីការផ្សះផ្សានោះបាត់សុពលភាពឡើយ ។

២-ទឡ្ហីករណីដែលបញ្ជាក់ថា វេទិកាមជ្ឈត្តកម្មពុំមានអំណាចធ្វើមជ្ឈត្តការនោះត្រូវបង្ហាញឱ្យឃើញមុនការដាក់ជូនពាក្យដោះសា ។ មិនត្រូវហាមឃាត់ភាគីវិវាទមួយមិនឱ្យលើកឡើងពីទឡ្ហីករណីបែបនេះ ដោយសារតែភាគីនោះបានតែងតាំង ឬ បានចូលរួមតែងតាំងមជ្ឈត្តករឡើយ ។ ទឡ្ហីករណីដែលបញ្ជាក់ថា ក្របខ័ណ្ឌជំលោះដែលមានកើតហួសពីក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់វេទិការមជ្ឈត្តកម្មត្រូវបង្ហាញភ្លាមៗនៅពេលដែលបញ្ហាហួសក្របខ័ណ្ឌសមត្ថកិច្ចនេះ ត្រូវបានគេលើកឡើងក្នុងពេលធ្វើមជ្ឈត្តការ ។ ក្នុងចំណោមករណីទាំងពីរ វេទិកាមជ្ឈត្តកម្មអាចទទួលយកទឡ្ហីករណី ដែលលើកឡើងក្រោយរយៈពេលកំណត់ប្រសិនបើពិចារណាឃើញថា ការយឺតយ៉ាវនេះមានភាពត្រឹមត្រូវ ។

៣-វេទិកាមជ្ឈត្តកម្មអាចធ្វើសេចក្តីសម្រេចលើទឡ្ហីករណីដូចចែងក្នុងកថាខណ្ឌ

ទី ២ នៃមាត្រានេះ ដោយចាត់ទុកថាជាបញ្ហាដំបូង ឬ ថាជាការសម្រេចតាមជាក់ស្តែង ។ ប្រសិនបើវេទិកាមជ្ឈត្តកម្មចាត់ទុកថាជាបញ្ហាដំបូងដែលខ្លួនមានអំណាចសម្រេចនោះ ភាគីណាក៏ដោយ ក៏អាចធ្វើសំណើទៅតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ឱ្យសម្រេចចុងក្រោយលើបញ្ហានេះក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពីបានទទួលសេចក្តីជូនដំណឹងពីការសម្រេចនោះរបស់វេទិកា ។ ការសម្រេចរបស់តុលាការក្នុងរឿងនេះគឺជាការសម្រេចដែលមិនអាចតវ៉ាបាន ។ ក្នុងពេលរង់ចាំការសម្រេចពីតុលាការនោះ វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការមជ្ឈត្តការ និងអាចធ្វើមជ្ឈត្តវិនិច្ឆ័យបាន ។

**មាត្រា ២៥.-**

តាមការស្នើសុំរបស់ភាគីវិវាទមួយ វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យភាគីណាមួយចាត់វិធានការបណ្តោះអាសន្នទៅតាមការចាំបាច់ទាក់ទិននឹងកម្មវត្ថុវិវាទ វៀរលែងតែភាគីវិវាទបានព្រមព្រៀងគ្នាផ្សេងពីនេះ ។ វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យភាគីវិវាទណាមួយបង់ប្រាក់ធានាសមស្របសម្រាប់វិធានការនេះ ។

## ជំពូកទី ៦
## ដំណើរការនៃនីតិវិធីមជ្ឈត្តការ

**មាត្រា ២៦.-**

ភាគីវិវាទត្រូវបានទទួលការយកចិត្តទុកដាក់ស្មើៗគ្នា និងត្រូវបានផ្តល់ឱកាសពេញលេញ ដើម្បីបង្ហាញពីរឿងរ៉ាវរបស់ខ្លួនរួមទាំងសិទ្ធិតែងតាំងជនណាម្នាក់ឱ្យធ្វើជាតំណាងរបស់ខ្លួនបាន ។

**មាត្រា ២៧.-**

ភាគីវិវាទអាចព្រមព្រៀង ឬ មិនព្រមព្រៀងលើនីតិវិធីដែលវេទិកាមជ្ឈត្តកម្ម ត្រូវអនុវត្តដើម្បីចាត់ចែងដំណើរការមជ្ឈត្តការ ។

16/2874

ក្នុងករណីគ្មានការព្រមព្រៀងពីនីតិវិធីនេះទេ វេទិកាមជ្ឈត្តកម្មអាចចាត់ចែងការធ្វើមជ្ឈត្តការទៅតាមបែបបទណាដែលវេទិកាយល់ឃើញថាសមស្រប ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ អំណាចដែលត្រូវបានប្រគល់ឱ្យទៅវេទិកាមជ្ឈត្តកម្មរួមមានអំណាចក្នុងការកំណត់ពីភាពយកជាការបាននៃភស្តុតាងណាមួយ ។

**មាត្រា ២៨.-**

ភាគីវិវាទអាចព្រមព្រៀងពីទីកន្លែងមជ្ឈត្តការ ។ ក្នុងករណីមិនបានព្រមព្រៀងពីទីកន្លែងទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ទីតាំងដោយគិតគូរពីលក្ខណៈពិសេសនៃវិវាទ ក្នុងនោះត្រូវមានការឯកភាពពីភាគីវិវាទផង ។

ថ្វីបើមានបទប្បញ្ញត្តិក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះក៏ដោយ ក៏វេទិកាមជ្ឈត្តកម្មអាចប្រជុំនៅកន្លែងណាមួយដែលសមស្របក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ក្នុងបំណងពិគ្រោះយោបល់ក្នុងចំណោមសមាជិករបស់វេទិកា ស្តាប់សាក្សី ស្តាប់អ្នកជំនាញការ ស្តាប់ភាគីវិវាទ ឬ ធ្វើអធិការកិច្ចលើសម្ភារៈ កម្មសិទ្ធិ ឬ ឯកសារដទៃទៀត ។

**មាត្រា ២៩.-**

ដំណើរការមជ្ឈត្តការដែលទាក់ទងនឹងវិវាទណាមួយ ចាប់ផ្តើមឡើងនៅថ្ងៃនៃកាលបរិច្ឆេទ ដែលភាគីឆ្លើយតបបានទទួលសំណើសុំឱ្យធ្វើមជ្ឈត្តការ វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ។

**មាត្រា ៣០.-**

ភាគីវិវាទអាចព្រមព្រៀងលើភាសាណាមួយ ឬ លើសពីមួយ ដែលត្រូវប្រើប្រាស់ក្នុងដំណើរការធ្វើមជ្ឈត្តការ ។ ក្នុងករណីគ្មានការឯកភាពលើភាសាទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ភាសាណាមួយ ឬ លើសពីមួយសម្រាប់ប្រើប្រាស់ក្នុងដំណើរការមជ្ឈត្តការ ។

វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យមានការបកប្រែភ្ជាប់ជាមួយនឹងឯកសារ ភស្តុតាង ដោយប្រើប្រាស់ភាសាណាមួយ ឬ លើសពីមួយ ដែលបានឯកភាពដោយភាគីវិវាទ ឬ ដែលបានកំណត់ដោយវេទិកាមជ្ឈត្តកម្ម ។

17/28

**មាត្រា ៣១.-**

នៅក្នុងរយៈពេលដែលឯកភាពដោយភាគីវិវាទ ឬ កំណត់ដោយវេទិកាមជ្ឈត្តកម្ម អ្នកប្តឹងទាមទារត្រូវបញ្ជាក់ពីអង្គហេតុ ដើម្បីគាំទ្រការទាមទាររបស់ខ្លួនព្រមទាំងបញ្ជាក់ពីចំណុចជាក់លាក់នៃបញ្ហា និងសំណងការខូចខាតដែលត្រូវទាមទារ ហើយភាគីឆ្លើយតបត្រូវឆ្លើយបញ្ជាក់ពីការដោះសាលើចំណុចទាំងនេះ វៀរលែងតែភាគីវិវាទបានព្រមព្រៀងថា ក្នុងបណ្តឹងទាមទារ ឬ ការដោះសា ត្រូវបញ្ជាក់ផ្សេងពីនេះ ។ ភាគីវិវាទអាចភ្ជាប់ឯកសារទាំងអស់ដែលយល់ថាទាក់ទងនឹងពាក្យបណ្តឹងទាមទារ ឬ ពាក្យដោះសា ឬ អាចបន្ថែមការយោងលើឯកសារ ឬ ភស្តុតាងដទៃទៀត ដែលភាគីទាំងនោះត្រូវដាក់ជូនវេទិកាមជ្ឈត្តកម្ម ។

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ភាគីវិវាទមួយអាចសុំកែសម្រួល ឬ បំពេញបន្ថែមលើពាក្យបណ្តឹងទាមទារ ឬ ពាក្យដោះសារបស់ខ្លួនបាន ក្នុងពេលកំពុងដំណើរការធ្វើមជ្ឈត្តការ លើកលែងតែវេទិកាមជ្ឈត្តកម្មយល់ថា ការសុំពន្យារពេលដើម្បីកែសម្រួលនេះពុំមានលក្ខណៈសមស្រប ។

**មាត្រា ៣២.-**

លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថា តើត្រូវធ្វើសវនាការដោយផ្ទាល់មាត់ដើម្បីបង្ហាញពីភស្តុតាង ឬ ទឡ្ហីករណ៍ផ្ទាល់មាត់ ឬ ក៏ត្រូវដំណើរការមជ្ឈត្តការដោយផ្អែកលើមូលដ្ឋាននៃឯកសារ ឬ លិខិតស្នាមដទៃទៀត ។ ក៏ប៉ុន្តែបើមានសំណើពីភាគីវិវាទមួយ វេទិកាមជ្ឈត្តកម្មត្រូវរៀបចំសវនាការបែបនេះ ក្នុងដំណាក់កាលសមស្របណាមួយនៃមជ្ឈត្តការ វៀរលែងតែភាគីវិវាទបានឯកភាពថា មិនត្រូវធ្វើសវនាការ ។

ត្រូវជូនដំណឹងឱ្យបានគ្រប់គ្រាន់ជាមុនដល់ភាគីវិវាទស្តីពីសវនាការ ឬ ក៏ការប្រជុំណាមួយរបស់វេទិកាមជ្ឈត្តកម្ម ដែលមានគោលបំណងធ្វើអធិការកិច្ចលើសម្ភារៈ ទំនិញ ទ្រព្យសម្បត្តិ និងឯកសារដទៃទៀត ។

រាល់សេចក្តីថ្លែង ឯកសារ ឬ ព័ត៌មានដទៃទៀត ដែលភាគីវិវាទមួយផ្តល់ជូនវេទិកាមជ្ឈត្តកម្ម ក៏ត្រូវបញ្ជូនទៅឱ្យភាគីវិវាទម្ខាងទៀតដែរ ។ របាយការណ៍របស់អ្នកជំនាញការ ឬ

18/2 84

ឯកសារភស្តុតាងណាមួយ ដែលវេទិកាមជ្ឈត្តកម្មអាចយកជាសំអាង ដើម្បីធ្វើការសម្រេច ក៏ត្រូវបញ្ជូនជាដំណឹងឱ្យភាគីវិវាទដែរ ។

មាត្រា ៣៣.-

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ហើយបើគ្មានការបង្ហាញមូលហេតុគ្រប់គ្រាន់ :

១-វេទិកាមជ្ឈត្តកម្មត្រូវបញ្ចប់ដំណើរការមជ្ឈត្តការ ក្នុងករណីដែលអ្នកប្តឹងពុំមានបញ្ជាក់លើពាក្យបណ្តឹងទាមទាររបស់ខ្លួនតាមមាត្រា ៣១ នៃ កថាខណ្ឌទី ១ នៃច្បាប់នេះ ។

២-បើភាគីឆ្លើយតបពុំអាចផ្តល់សេចក្តីដោះសាររបស់ខ្លួនដូចចែងក្នុងមាត្រា ៣១ នៃកថាខណ្ឌទី ១ នៃច្បាប់នេះ វេទិកាមជ្ឈត្តកម្មត្រូវបន្តដំណើរការមជ្ឈត្តការដោយពុំចាត់ទុកការខកខាននេះថា ជាការទទួលស្គាល់ពាក្យចោទប្រកាន់របស់ភាគីប្តឹងទាមទារឡើយ ។

៣-បើភាគីវិវាទណាមួយពុំបានបង្ហាញមុខនៅសវនាការ ឬ ពុំបានផ្តល់ឯកសារភស្តុតាង វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការ ហើយធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុ-តាងដែលមាននៅចំពោះមុខ ។

មាត្រា ៣៤.-

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មអាច :

១-តែងតាំងអ្នកជំនាញការម្នាក់ ឬ ច្រើននាក់ ដើម្បីរាយការណ៍ឱ្យខ្លួនស្តីពីបញ្ហាជាក់លាក់នានា ដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម ។

២-តម្រូវឱ្យភាគីវិវាទមួយផ្តល់ព័ត៌មាន ឬ ឯកសារ ឬ អនុញ្ញាតឱ្យអ្នកជំនាញការពិនិត្យលើឯកសារ សម្ភារៈដែលសមស្របផ្សេងៗដែលទាក់ទងដល់ការធ្វើអធិការកិច្ចរបស់អ្នកជំនាញការ ។

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ប្រសិនបើមានភាគីវិវាទមួយស្នើសុំ ឬ វេទិកាមជ្ឈត្តកម្មយល់ថាចាំបាច់ អ្នកជំនាញការបន្ទាប់ពីបានបង្ហាញរបាយការណ៍ផ្ទាល់មាត់ ឬ លាយលក្ខណ៍អក្សររួចហើយ ត្រូវចូលរួមក្នុងសវនាការដែលក្នុងឱកាសនោះ ភាគីវិវាទអាចលើកសំណួរ និងអញ្ជើញជំនាញការផ្សេងទៀត ក្នុងនាមជាសាក្សី ដើម្បីបញ្ជាក់ពីចំណុចជាក់លាក់នៃជម្លោះ ។

7/284

មាត្រា ៣៥.-

វេទិកាមជ្ឈត្តកម្ម ឬ ភាគីវិវាទមួយដោយបានការឯកភាពពីវេទិកាមជ្ឈត្តកម្ម អាចស្នើសុំជំនួយពីតុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល) ក្នុងការត្រួតពិនិត្យភស្តុតាង ។ តុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬតុលាការកំពូល) អាចអនុវត្តតាមសំណើនេះនៅក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន និងដោយអនុលោមតាមវិធានស្តីពីការត្រួតពិនិត្យភស្តុតាង ។

## ជំពូកទី ៧
## ការធ្វើមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម និងការបញ្ចប់ដំណើរការមជ្ឈត្តការ

មាត្រា ៣៦.-

ក្នុងការធ្វើមជ្ឈត្តវិនិច្ឆ័យវេទិកាមជ្ឈត្តកម្មត្រូវ :

១-សម្រេចពីវិវាទមួយទៅតាមវិធាននៃច្បាប់ ដែលជ្រើសរើសដោយភាគីវិវាទ និងដែលអនុវត្តបានចំពោះកម្មវត្ថុនៃវិវាទនេះ ។ ការកំណត់យកច្បាប់ ឬ ប្រព័ន្ធច្បាប់នៃប្រទេសណាមួយដែលត្រូវយកទៅបកស្រាយ គឺមិនត្រូវបកស្រាយដោយសំអាងលើភាពផ្ទុយគ្នានៃច្បាប់ ឬវិធាននៃច្បាប់នោះឡើយ វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ ។

២-ប្រើប្រាស់ច្បាប់ណាដែលយល់ថាអាចអនុវត្តបាន ក្នុងករណីដែលភាគីវិវាទមិនបានធ្វើការកំណត់លើប្រព័ន្ធច្បាប់ទេនោះ ។

៣-ធ្វើមជ្ឈត្តវិនិច្ឆ័យស្របតាមសមធម៌ ឬ តាមការស្រុះស្រួលតែក្នុងករណីដែលភាគីវិវាទអនុញ្ញាតច្បាស់លាស់ឱ្យធ្វើដូច្នោះ ។

៤-ធ្វើមជ្ឈត្តវិនិច្ឆ័យឱ្យស្របតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា និងត្រូវយកចិត្តទុកដាក់ផងដែរដល់ទម្លាប់ផ្នែកពាណិជ្ជកម្ម ដែលអនុវត្តបានចំពោះមុខជំនួញនោះ ។

20/28h/

**មាត្រា ៣៧.-**

ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ មជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ត្រូវធ្វើឡើងតាមមតិភាគច្រើនដោយប្រៀបនៃមជ្ឈត្តករ ដែលជាសមាជិកនៃវេទិកាមជ្ឈត្តកម្ម ។

**មាត្រា ៣៨.-**

មុនពេលចាប់ផ្តើមដំណើរការមជ្ឈត្តការផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវពិភាក្សាជាមួយភាគីវិវាទ ដើម្បីស្វែងរកលទ្ធភាពនៃការដោះស្រាយវិវាទដោយស្ម័គ្រចិត្តរបស់ភាគី :

១-ប្រសិនបើភាគីវិវាទព្រមដោះស្រាយវិវាទដោយស្ម័គ្រចិត្ត វេទិកាមជ្ឈត្តកម្មត្រូវជួយភាគីវិវាទទៅតាមបែបបទដែលសមស្រប ។

២-ប្រសិនបើភាគីវិវាទបានស្រុះស្រួលគ្នាមុនពេលចាប់ផ្តើម ឬ ក្នុងពេលកំពុងធ្វើមជ្ឈត្តការជាផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវបញ្ចប់ដំណើរការ ។ ប្រសិនបើមានការស្នើសុំពីភាគីវិវាទ វេទិកាមជ្ឈត្តកម្មអាចកត់ត្រាទុកការដោះស្រាយនោះ ក្នុងមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ។

៣-មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួល ត្រូវធ្វើឡើងតាមបទប្បញ្ញត្តិក្នុងមាត្រា ៣៩ នៃច្បាប់នេះ ហើយត្រូវបញ្ជាក់ថាជាមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ។ មជ្ឈត្តវិនិច្ឆ័យនេះមានលក្ខណៈ និង ឥទ្ធិពលដូចមជ្ឈត្តវិនិច្ឆ័យដទៃទៀតដែលវេទិកាមជ្ឈត្តកម្មធ្វើដោយផ្អែកលើភាពជាក់ស្តែងនៃវិវាទដែរ ។

**មាត្រា ៣៩.-**

មជ្ឈត្តវិនិច្ឆ័យត្រូវមានទម្រង់ទ្រាយ និងខ្លឹមសារដូចខាងក្រោម :

១-មជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្មត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះហត្ថលេខាដោយមជ្ឈត្តករ ។ ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ ហត្ថលេខារបស់សមាជិកភាគច្រើនក្នុងវេទិកាមជ្ឈត្តកម្មត្រូវចាត់ទុកថាគ្រប់គ្រាន់ ល្គឹកណាមានការបញ្ជាក់ពីមូលហេតុដែលមជ្ឈត្តករដទៃទៀតមិនបានចុះហត្ថលេខា ។

២-មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់ពីមូលហេតុនានាដែលបានយកមកធ្វើជាគោលបង្អែក វៀរលែងតែភាគីវិវាទបានព្រមព្រៀងគ្នាថាមិនចាំបាច់បញ្ជាក់ពីមូលហេតុទេ ឬ វៀរលែងតែ

21/284

មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួលរបស់ភាគី ដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

៣-មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់ពីសោហ៊ុយចំណាយក្នុងការធ្វើមជ្ឈត្តការ ដែលភាគីវិវាទមានចំណែកត្រូវចេញ ក្នុងនោះមានប្រាក់កម្រៃសម្រាប់មជ្ឈត្តករនិងការចំណាយផ្សេងៗ ដែលបានបម្រុងទុកជាមុន ដោយអនុលោមតាមបែបបទដែលព្រមព្រៀងដោយភាគីវិវាទ ឬ អនុលោមតាមការយល់សមស្របរបស់មជ្ឈត្តករ ប្រសិនបើគ្មានការព្រមព្រៀងដោយភាគីទេ ។ មជ្ឈត្តវិនិច្ឆ័យអាចចែងផងដែរពីសោហ៊ុយចំណាយសមស្របសម្រាប់ការពិគ្រោះច្បាប់ដែលត្រូវសងទៅឱ្យភាគីឈ្នះ ប្រសិនបើភាគីវិវាទបានព្រមព្រៀងដូច្នោះ ឬ មជ្ឈត្តករយល់ថាសមស្រប ។

៤-មជ្ឈត្តវិនិច្ឆ័យត្រូវចែងពីកាលបរិច្ឆេទ និងទីកន្លែងផ្ទះផ្សាដូចកំណត់ក្នុងមាត្រា ២៨ កថាខណ្ឌទី ១ នៃច្បាប់នេះ ។ ត្រូវចាត់ទុកទីកន្លែងធ្វើមជ្ឈត្តការជាទីកន្លែងធ្វើមជ្ឈត្ត-វិនិច្ឆ័យ ។

៥-បន្ទាប់ពីធ្វើមជ្ឈត្តវិនិច្ឆ័យរួចហើយ អត្ថបទចម្លងនៃមជ្ឈត្តវិនិច្ឆ័យនោះ ដែលចុះហត្ថលេខាដោយមជ្ឈត្តករតាមបែបបទក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវបញ្ជូនទៅឱ្យភាគីវិវាទនីមួយៗ ។

**មាត្រា ៤០.-**

ដំណើរការមជ្ឈត្តការត្រូវបញ្ចប់ដោយធ្វើមជ្ឈត្តវិនិច្ឆ័យជាស្ថាពរ ឬ ដោយដីកាបង្គាប់របស់វេទិកាមជ្ឈត្តកម្មស្របតាមកថាខណ្ឌទី ២ នៃមាត្រានេះ ។

វេទិកាមជ្ឈត្តកម្មចេញដីកាបង្គាប់ដើម្បីបញ្ចប់ដំណើរការមជ្ឈត្តការ នៅក្នុងករណីដែល :

១-ភាគីប្តឹងទាមទារដកពាក្យទាមទាររបស់ខ្លួន វៀរលែងតែភាគីឆ្លើយតបធ្វើការជំទាស់នឹងការដកពាក្យនោះ ហើយវេទិកាមជ្ឈត្តកម្មទទួលស្គាល់ពីអត្ថប្រយោជន៍ស្របច្បាប់របស់ភាគីឆ្លើយតបក្នុងការទទួលដំណោះស្រាយវិវាទជាស្ថាពរ ។

២-ភាគីវិវាទឯកភាពឱ្យបញ្ចប់ដំណើរការមជ្ឈត្តការ ។

៣-វេទិកាមជ្ឈត្តកម្មរកឃើញមូលហេតុដទៃទៀត ដែលបញ្ជាក់ពីភាពមិនចាំបាច់សម្រាប់បន្តដំណើរការ ឬ ការធ្វើមជ្ឈត្តការនោះពុំអាចបន្តទៅទៀតកើត ។



22/28 W

អាណត្តិរបស់វេទិកាមជ្ឈត្តកម្មបញ្ចប់ជាមួយនឹងការបញ្ចប់ដំណើរការមជ្ឈត្តការតាមបទប្បញ្ញត្តិនៃមាត្រា ៤១ និងមាត្រា ៤២ កថាខណ្ឌទី ៤ នៃច្បាប់នេះ ។

**មាត្រា ៤១.–**

ការកែតម្រូវនិងការបកស្រាយមជ្ឈត្តវិនិច្ឆ័យត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

១-ក្នុងកំឡុងពេលសាមសិប (៣០) ថ្ងៃ យ៉ាងយូរបន្ទាប់ពីទទួលមជ្ឈត្តវិនិច្ឆ័យ វៀរលែងតែភាគីវិវាទបានព្រមព្រៀងលើរយៈពេលបន្តទៀត :

ក-ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀតអាចស្នើសុំឱ្យវេទិកាមជ្ឈត្តកម្មកែតម្រូវកំហុសផ្នែកគណនា កំហុសផ្នែកការងារលេខាធិការ និងកំហុសនៃការបោះពុម្ព ឬ កំហុសដទៃទៀត ដែលមានលក្ខណៈស្រដៀងគ្នា ។

ខ-ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀត អាចស្នើសុំឱ្យវេទិកាមជ្ឈត្តកម្មផ្តល់ការបកស្រាយ ឬ ការបំភ្លឺលម្អិតពីចំណុច ឬ ផ្នែកណាមួយនៃមជ្ឈត្តវិនិច្ឆ័យ ប្រសិនបើភាគីវិវាទបានព្រមព្រៀងដូច្នេះ ។ ប្រសិនបើយល់ថាសំណើនោះសមស្របវេទិកាមជ្ឈត្តកម្មត្រូវបកស្រាយ ឬ បំភ្លឺលម្អិតក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ បន្ទាប់ពីទទួលសំណើ ។ ការបកស្រាយ ឬ ការបំភ្លឺលម្អិតនោះ ត្រូវបញ្ចូលជាផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ ។

២-ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ ក្រោយកាលបរិច្ឆេទចេញមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្មអាចកែតម្រូវកំហុសដូចដែលចែងក្នុងកថាខណ្ឌទី ១ក នៃមាត្រានេះ ទៅតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ។

៣-វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ ក្រោយពីទទួលបានមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀត អាចស្នើសុំឱ្យវេទិកាមជ្ឈត្តការធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែម ដូចជាដោយសារការទាមទារនានា ដែលលើកឡើងក្នុងដំណើរការមជ្ឈត្តការនោះ មិនបានដាក់ចូលទៅក្នុងមជ្ឈត្តវិនិច្ឆ័យ ។ ប្រសិនបើយល់ឃើញថាសំណើនោះសមស្របវេទិកាមជ្ឈត្តកម្ម ត្រូវធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែមក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ ។

23/28 h

៤-ប្រសិនបើចាំបាច់ និងដោយបានជូនដំណឹងដល់ភាគីវិវាទ វេទិកាមជ្ឈត្តកម្ម អាចពន្យាររយៈពេលដែលកំណត់សម្រាប់ការកែតម្រូវការបកស្រាយ ការបំភ្លឺលម្អិត ឬ ការធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែមតាមកថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ នៃមាត្រានេះ ។

៥-បទប្បញ្ញត្តិនានានៃមាត្រា ៣៩ នៃច្បាប់នេះ ត្រូវយកទៅអនុវត្តសម្រាប់កែតម្រូវការបកស្រាយ ឬ ការបំភ្លឺលម្អិតលើមជ្ឈត្តវិនិច្ឆ័យ ឬ ការចេញមជ្ឈត្តវិនិច្ឆ័យបន្ថែម ។

## ជំពូកទី ៨
## ការប្តឹងជំទាស់ ការទទួលស្គាល់
## និង ការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

### ផ្នែកទី១
### ស្ថាប័នមានសមត្ថកិច្ចក្នុងការប្តឹងជំទាស់
### ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

**មាត្រា ៤២.-**

សេចក្តីសម្រេចលើការប្តឹងជំទាស់ ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤៣.-**

តុលាការកំពូលជាសាលាជំនុំជម្រះក្តីចុងក្រោយ ដែលមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងជំទាស់របស់ភាគីវិវាទ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥) ថ្ងៃ ។

### ផ្នែកទី ២
### បណ្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ

**មាត្រា ៤៤.-**

ភាគីវិវាទអាចប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមទម្រង់ទ្រាយជាបណ្តឹងបដិសេធ និងតាមបែបបទដូចខាងក្រោម :

29/28

១-បណ្ដឹងបដិសេធទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមផ្លូវតុលាការ អាចធ្វើទៅបានលុះត្រាតែស្របតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ និងវាក្យខ័ណ្ឌទី ៣ នៃមាត្រានេះ ។

២-សាលាឧទ្ធរណ៍ និង តុលាការកំពូលអាចបដិសេធមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តករ បានក្នុងករណី ៖

ក-ភាគីដែលដាក់ពាក្យសុំបដិសេធបានផ្ដល់ភស្តុតាងគ្រប់គ្រាន់ថា ៖

ក.១-ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចមានយោងក្នុងមាត្រា ៧ នៃច្បាប់នេះ បានបាត់បង់សិទ្ធិមួយចំនួនខាងផ្លូវច្បាប់ ឬ កិច្ចព្រមព្រៀងផ្សះផ្សានោះ ពុំអាចយកជាការបាន បើយោងតាមច្បាប់ដែលភាគីវិវាទបានសំអាង ឬ កិច្ចព្រមព្រៀងផ្សះផ្សាពុំបានគោរពតាមបញ្ញត្តិណាមួយនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ក.២-ភាគីដែលដាក់ពាក្យសុំបដិសេធនោះ មិនបានទទួលដំណឹងត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬ ពីដំណើរការមជ្ឈត្តការ ឬ ភាគីនេះពុំអាចបង្ហាញពីអង្គហេតុរបស់ខ្លួនបានដោយប្រសិទ្ធភាព ។

ក.៣-មជ្ឈត្តវិនិច្ឆ័យដែលទាក់ទិននឹងវិវាទនោះពុំឆ្លើយតប ឬ ពុំគោរពល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ ប្រសិនបើបញ្ហាដែលដាក់ឱ្យធ្វើមជ្ឈត្តការនោះ អាចផ្ដាច់ចេញពីបញ្ហាដែលមិនបានដាក់ឱ្យធ្វើមជ្ឈត្តការ ការបដិសេធអាចធ្វើទៅបានតែត្រង់ផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ លើបញ្ហាដែលបានដាក់ឱ្យធ្វើមជ្ឈត្តការពីមុនប៉ុណ្ណោះ ។

ក.៤-ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការ ពុំស្របនឹងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ក្នុងករណីដែលកិច្ចព្រមព្រៀងនោះស្របតាមបទបញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងផ្សះផ្សាទេ ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការខាងលើមិនសមស្របតាមច្បាប់នេះ ។

ខ-សាលាឧទ្ធរណ៍ និង តុលាការកំពូលរកឃើញថា ៖

ខ.១- កម្មវត្ថុនៃវិវាទនោះ ពុំអាចដោះស្រាយបានតាមរយៈការធ្វើមជ្ឈត្តការឡើយ បើយោងទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ខ.២-មជ្ឈត្តវិនិច្ឆ័យនោះផ្ទុយនឹងនយោបាយសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ។

25/2

៣-ការដាក់ពាក្យសុំបដិសេធមិនអាចធ្វើបានឡើយ បើរយៈពេលបានកន្លងផុតសាមសិប (៣០) ថ្ងៃ គិតពីថ្ងៃដែលភាគីសុំបដិសេធនោះទទួលបានមជ្ឈត្តវិនិច្ឆ័យ ឬ ប្រសិនបើសំណើនោះធ្វើឡើងតាមមាត្រា ៤១ នៃច្បាប់នេះ រយៈពេលសាមសិប (៣០) ថ្ងៃ គិតពីកាលបរិច្ឆេទដែលវេទិកាមជ្ឈត្តកម្មបានដោះស្រាយលើសំណើនោះ ។

៤-នៅពេលទទួលដំណឹងបដិសេធមជ្ឈត្តវិនិច្ឆ័យ បើមានលក្ខណៈសមស្របហើយមានសំណើពីភាគីមួយ សាលាឧទ្ធរណ៍ និង តុលាការកំពូលអាចផ្អាកដំណើរការបដិសេធនេះ នៅក្នុងរយៈពេលមួយដែលកំណត់ដោយសាលាឧទ្ធរណ៍ និង តុលាការកំពូល ដើម្បីផ្តល់ឱកាសដល់វេទិកាមជ្ឈត្តកម្មធ្វើដំណើរការមជ្ឈត្តការឡើងវិញ ឬ ចាត់វិធានការមួយតាមការយល់ឃើញរបស់វេទិកាថា អាចនឹងលុបបំបាត់មូលហេតុនៃការសុំបដិសេធនោះបាន ។

## ជំពូកទី ៣
## ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

**មាត្រា ៤៥.-**

មជ្ឈត្តវិនិច្ឆ័យ ទោះជាបានធ្វើនៅប្រទេសណាក៏ដោយត្រូវបានគេទទួលស្គាល់ថាជាកាតព្វកិច្ច ហើយបន្ទាប់ពីបានដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅសាលាឧទ្ធរណ៍រួចមកត្រូវបានអនុវត្តដោយយោងតាមបទប្បញ្ញត្តិក្នុងមាត្រានេះ និងមាត្រា ៤៤ ។

ភាគីដែលសំអាងលើមជ្ឈត្តវិនិច្ឆ័យ ឬ ដែលដាក់ពាក្យសុំឱ្យមានការអនុវត្តមជ្ឈត្តវិនិច្ឆ័យត្រូវផ្តល់ច្បាប់ដើមត្រឹមត្រូវពិតប្រាកដនៃមជ្ឈត្តវិនិច្ឆ័យ និងច្បាប់ដើមនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ឬ អត្ថបទថតចម្លងដែលបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។ ប្រសិនបើមជ្ឈត្តវិនិច្ឆ័យ ឬ កិច្ចព្រមព្រៀងនោះមិនបានធ្វើជាភាសាខ្មែរទេ ភាគីនោះត្រូវផ្តល់សេចក្តីបកប្រែជាភាសាខ្មែរ ដែលមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម ។

**មាត្រា ៤៦.-**

ទោះបីជាមជ្ឈត្តវិនិច្ឆ័យធ្វើនៅប្រទេសណាក៏ដោយ ការជំទាស់ទៅនឹងការទទួលស្គាល់ ឬ ជំទាស់ទៅនឹងការដាក់ឱ្យអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យ អាចធ្វើបានតែក្នុងករណី :

26/28A/

១-អនុវត្តន៍តាមសំណើរបស់ភាគីជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ ដោយភាគីនោះផ្តល់ភស្តុតាងដល់សាលាឧទ្ធរណ៍ថា ៖

ក-ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចបានយោងក្នុងមាត្រា ៧ បានបាត់បង់សិទ្ធិមួយចំនួនខាងផ្លូវច្បាប់ ឬ កិច្ចព្រមព្រៀងនោះពុំអាចយកជាការបាន បើយោងតាមច្បាប់ដែលភាគីវិវាទបានសំអាង ឬ កិច្ចព្រមព្រៀងផ្សះផ្សាពុំបានគោរពតាមការកំណត់ណាមួយនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ឬ

ខ-ភាគីដែលជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យនោះ ពុំទទួលបានព័ត៌មានត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬ ពីដំណើរការមជ្ឈត្តការពុំអាចបង្ហាញពីករណីរបស់ខ្លួនបានដោយប្រសិទ្ធភាព ឬ

គ-មជ្ឈត្តវិនិច្ឆ័យដែលទាក់ទងនឹងវិវាទនោះពុំឆ្លើយតប ឬ ពុំគោរពលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ឬ ក៏បញ្ហាដែលបានសម្រេចនោះហួសពីក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ ប្រសិនបើការសម្រេចលើបញ្ហាដែលបានដាក់ជូនឱ្យផ្សះផ្សា អាចផ្តាច់ចេញពីបញ្ហាដែលពុំបានដាក់ឱ្យផ្សះផ្សានោះ ផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យលើបញ្ហាដែលបានដាក់ជូនអាចត្រូវគេទទួលស្គាល់ និងដាក់អោយអនុវត្ត ឬ

ឃ-ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការពុំសមស្របជាមួយនឹងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ឬ ប្រសិនបើគ្មានកិច្ចព្រមព្រៀងផ្សះផ្សានោះទេ ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការ គឺពុំសមស្របទៅនឹងច្បាប់នៃប្រទេសដែលការផ្សះផ្សាបានប្រព្រឹត្តទៅ ឬ

ង-មជ្ឈត្តវិនិច្ឆ័យនោះពុំទាន់បានក្លាយទៅជាកាតព្វកិច្ចនៅឡើយសម្រាប់ភាគីវិវាទ បើយោងតាមច្បាប់នៃប្រទេសដែលធ្វើសេចក្តីសម្រេចនោះ ឬ ម្យ៉ាងទៀតមជ្ឈត្តវិនិច្ឆ័យត្រូវបានបដិសេធ ឬ ល្បែងទុក ដោយតុលាការនៃប្រទេសដែលធ្វើមជ្ឈត្តវិនិច្ឆ័យ ឬ

២-ប្រសិនបើសាលាឧទ្ធរណ៍រកឃើញថា ៖

ក-កម្មវត្ថុនៃវិវាទនោះ ពុំអាចដោះស្រាយបានតាមការធ្វើមជ្ឈត្តការឡើយ បើយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ

27/28

ខ-ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យនោះ អាចផ្ទុយនឹងនយោបាយសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ។

បើមានការសុំឱ្យសាលាឧទ្ធរណ៍បដិសេធ ឬ ព្យួរទុកមជ្ឈត្តវិនិច្ឆ័យ ដូចមានចែងក្នុងកថាខណ្ឌទី ១ (ង) នៃមាត្រានេះ ហើយប្រសិនបើសាលាឧទ្ធរណ៍យល់ថាត្រឹមត្រូវ សាលាឧទ្ធរណ៍ដែលភាគីវិវាទស្នើសុំការទទួលស្គាល់ ឬ ការអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះ អាចបញ្ឈប់ការសម្រេចរបស់ខ្លួន ហើយអាចបញ្ជាឱ្យភាគីវិវាទម្ខាងទៀតផ្តល់ការធានាសមស្របទៅតាមសំណូមពររបស់ភាគីដែលសុំឱ្យមានការទទួលស្គាល់ ឬ ការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ៤៧.-**

បទប្បញ្ញត្តិទាំងឡាយណាក្នុងវិស័យមជ្ឈត្តការពាណិជ្ជកម្មដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០០៦

ពរ/ល.០៦០៥/០១៨ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ហត្ថលេខា**

**ចម ប្រសិទ្ធ**

លេខៈ ២០៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារី គាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៤ អនក្រ.បក

4334
14 08 9

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ថតចម្លង
នាយកដ្ឋាន.រដ្ឋបាល.

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ។

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលសរសេរកាត់ថា **ម.ជ.ម.** ជាអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងមានទីស្នាក់ការនៅរាជធានីភ្នំពេញ ។

## ជំពូកទី២

## តួនាទីនិងភារកិច្ច

**មាត្រា២.-**

**ម.ជ.ម.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម ÷

- ជំរុញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ផ្តល់ការបណ្តុះបណ្តាលនិងហ្វឹកហ្វឺនបុគ្គលដែលកំពុងអនុវត្តនិងបុគ្គលដែលមានបំណងអនុវត្តវិជ្ជាជីវៈ ជាមជ្ឈត្តករ ដើម្បីធានាឱ្យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានគុណភាពខ្ពស់
- កំណត់ពីលក្ខណសម្បត្តិនៃបុគ្គល ដែលមានបំណងចូលជាសមាជិក **ម.ជ.ម.**
- ផ្តល់សេវាដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ
- រៀបចំសន្និសីទថ្នាក់ជាតិនិងអន្តរជាតិ ក្នុងគោលដៅជំរុញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- រៀបចំ ចូលរួមសិក្ខាសាលានិងវគ្គសិក្សា លើប្រធានបទទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ប្រមូល បោះពុម្ព និងផ្សព្វផ្សាយព័ត៌មាន អត្ថបទនិពន្ធ សៀវភៅនិងឯកសារ សោតទស្សន៍ឬហ្វូណូក្រាម ដែលទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- គ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិ **ម.ជ.ម.**
- រៀបចំបណ្ណាល័យនិងបន្ទប់ផ្សេងៗ សម្រាប់បម្រើសេវាទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ចុះកិច្ចព្រមព្រៀងនានាដែលចាំបាច់ក្នុងការបំពេញមុខងាររបស់ខ្លួន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់មហាសន្និបាត **ម.ជ.ម.** ។

# ជំពូកទី៣
# រចនាសម្ព័ន្ធ
## ផ្នែកទី១
## មហាសន្និបាត

**មាត្រា៣.–**

សិទ្ធិអំណាចកំពូលរបស់ **ម.ជ.ម.** គឺមហាសន្និបាត។

មហាសន្និបាតប្រចាំឆ្នាំត្រូវធ្វើឡើងតាមកាលបរិច្ឆេទ ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។ ក្នុងករណីចាំបាច់ ប្រធានក្រុមប្រឹក្សាប្រតិបត្តិ ឬសមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ អាចស្នើសុំបើកមហាសន្និបាតវិសាមញ្ញបានដោយមានភ្ជាប់មកជាមួយ នូវរបៀបវារៈក្នុងរយៈពេលយ៉ាងតិច១៥ (ដប់ប្រាំ)ថ្ងៃ មុនថ្ងៃប្រជុំ។ មហាសន្និបាតវិសាមញ្ញនេះត្រូវពិចារណាតែបញ្ហាណាដែលមិនបានលើកឡើង ឬដោះស្រាយនៅក្នុងមហាសន្និបាតប្រចាំឆ្នាំ ដែលបានធ្វើឡើងរួចហើយតែប៉ុណ្ណោះ។

**មាត្រា៤.–**

មហាសន្និបាតប្រចាំឆ្នាំពិនិត្យនិងអនុម័តលើបញ្ហាជាអាទិ៍÷

- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាប្រតិបត្តិ
- គម្រោងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.ម.**
- ការបោះឆ្នោតជ្រើសតាំងនិងដកហូតសមាជិកក្រុមប្រឹក្សាប្រតិបត្តិ
- បទបញ្ជាផ្ទៃក្នុងនិងវិធាន ដែលទាក់ទងនឹងការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម
- ការកែប្រែនូវបទប្បញ្ញត្តិនានា ដែលទាក់ទងដល់ដំណើរការរបស់ **ម.ជ.ម.**
- បែបបទហិរញ្ញវត្ថុនិងរដ្ឋបាល សម្រាប់ការគ្រប់គ្រងដំណើរការរបស់ **ម.ជ.ម.**
- នីតិវិធីសម្រាប់ការចុះបញ្ជីមជ្ឈត្តករ
- លក្ខណសម្បត្តិបន្ថែមសម្រាប់ឱ្យធ្វើជាមជ្ឈត្តករនៅ **ម.ជ.ម.**
- ក្រមសីលធមិសម្រាប់មជ្ឈត្តករ។

**មាត្រា៥.–**

ការជូនដំណឹងពីមហាសន្និបាតប្រចាំឆ្នាំ ត្រូវធ្វើឡើងយ៉ាងតិច ៣០ (សាមសិប)ថ្ងៃ មុនថ្ងៃប្រជុំ។ លិខិតជូនដំណឹងនេះត្រូវបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែងប្រជុំ និងរបៀបវារៈ។

**មាត្រា៦.–**

មហាសន្និបាតអាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមាន២/៣ (ពីរភាគបី) នៃសមាជិកទាំងអស់គិតទាំងសមាជិកផ្ទេរសិទ្ធិ ហើយបញ្ហានានាដែលលើកមកពិភាក្សា ត្រូវសម្រេចដោយសំឡេងភាគច្រើនដាច់ខាត។

ក្នុងករណីមិនមានកូរ៉ុមដើម្បីដំណើរការមហាសន្និបាត កិច្ចប្រជុំនេះត្រូវពន្យាររយៈពេលចំនួន១៤ (ដប់បួន) ថ្ងៃ ហើយកូរ៉ុមសម្រាប់កិច្ចប្រជុំលើកទីពីរនេះគឺ ១/២ (មួយភាគពីរ) នៃសមាជិកទាំងអស់ គិតទាំងសមាជិកផ្ទេរសិទ្ធិ។

ក្នុងករណីដែលកិច្ចប្រជុំលើកទីពីរពុំមានកូរ៉ុម មហាសន្និបាតនេះត្រូវពន្យាររយៈពេលចំនួន១៤ (ដប់បួន) ថ្ងៃទៀត ហើយប្រសិនបើនៅតែគ្មានកូរ៉ុមនៅក្នុងកិច្ចប្រជុំនេះទៀត ចំនួនអ្នកចូលរួមក្នុងកិច្ចប្រជុំដែលត្រូវពន្យាពេលជាលើកទីពីរនោះត្រូវចាត់ទុកថាជាកូរ៉ុមដើម្បីចាប់ផ្តើមមហាសន្និបាត។

ការបោះឆ្នោតតាមរយៈសិទ្ធិប្រទានត្រូវបានអនុញ្ញាតប៉ុន្តែសមាជិកម្នាក់អាចទទួលបានសិទ្ធិប្រទានតែមួយប៉ុណ្ណោះ។ សិទ្ធិប្រទានត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះក្នុងកំណត់ហេតុប្រជុំ។

**មាត្រា៧.–**

មហាសន្និបាតវិសាមញ្ញ ត្រូវបានកោះប្រជុំដោយប្រធានក្រុមប្រឹក្សាប្រតិបត្តិ និងតាមពេលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

ប្រសិនបើប្រធានក្រុមប្រឹក្សាប្រតិបត្តិ មិនបានកោះប្រជុំមហាសន្និបាតវិសាមញ្ញ ក្នុងរយៈពេល៣ (បី) ខែ បន្ទាប់ពីបានទទួលសំណើជាលាយលក្ខណ៍អក្សរទេនោះ សមាជិកដែលស្នើសុំឱ្យមានមហាសន្និបាតវិសាមញ្ញ អាចបើកមហាសន្និបាតវិសាមញ្ញតាមរយៈការជូនដំណឹងទៅសមាជិកទាំងអស់ ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃជាមុន ដោយរៀបរាប់អំពីបញ្ហាដែលត្រូវពិភាក្សា ហើយត្រូវបិទផ្សាយរបៀបវារៈរបស់ខ្លួន នៅលើក្តារព័ត៌មានក្នុងបរិវេណ **ម.ជ.ម.**។

## ផ្នែកទី២
## ក្រុមប្រឹក្សាប្រតិបត្តិ

**មាត្រា៨.–**

**ម.ជ.ម.** គ្រប់គ្រងដោយក្រុមប្រឹក្សាប្រតិបត្តិ ដែលត្រូវជួបប្រជុំរៀងរាល់ខែ។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវមានសមាជិកមិនលើសពី ៧ (ប្រាំពីរ) រូបឡើយ។

សមាសភាពក្រុមប្រឹក្សាប្រតិបត្តិរួមមាន ÷

- ប្រធានមួយរូប
- អនុប្រធានមួយរូប

- ហេរញ្ញិកមួយរូប
- សមាជិកមួយចំនួន។

**មាត្រា៩.–**

ក្រុមប្រឹក្សាប្រតិបត្តិគ្រប់គ្រងនិងសម្រេចការងារប្រចាំថ្ងៃ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រតិបត្តិមានអានុភាពអនុវត្ត លើកលែងតែសេចក្តីសម្រេចនោះ ត្រូវបានបដិសេធដោយមហាសន្និបាត។

**មាត្រា១០.–**

ក្រុមប្រឹក្សាប្រតិបត្តិបំពេញតួនាទីផ្សេងៗទៀតមានជាអាទិ៍÷

- ជ្រើសរើសបុគ្គលិកឱ្យបម្រើការងារជាអគ្គលេខាធិការរបស់ **ម.ជ.ម.**
- កំណត់ចំនួនបុគ្គលិក និយោជិត លក្ខខណ្ឌការងារ ប្រាក់បៀវត្ស កម្រៃសេវា ឬលក្ខខណ្ឌដទៃទៀត
- បញ្ឈប់ការងារនិងដាក់វិន័យលើបុគ្គលិក ដោយផ្អែកតាមកិច្ចសន្យាការងារ។

**មាត្រា១១.–**

ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ គម្រោងថវិកាប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ **ម.ជ.ម.** ជូនមហាសន្និបាតប្រចាំឆ្នាំ។

**មាត្រា១២.–**

សមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវបានបោះឆ្នោតជ្រើសតាំងនៅក្នុងមហាសន្និបាតនៃ **ម.ជ.ម.**។

សមាជិកក្រុមប្រឹក្សាប្រតិបត្តិមានអាណត្តិ ៣ (បី)ឆ្នាំ ហើយសមាជិកទាំងអស់អាចធ្វើជាសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិមិនលើសពី ២(ពីរ) អាណត្តិឡើយ។ សមាជិកក្រុមប្រឹក្សាប្រតិបត្តិទាំងអស់អាចត្រូវបានបោះឆ្នោតសម្រាប់ ២ (ពីរ) អាណត្តិជាប់គ្នា លើកលែងតែមុខតំណែងជាហេរញ្ញិកដែលមិនអាចត្រូវបានជ្រើសរើស ២(ពីរ) អាណត្តិជាប់គ្នា។

**មាត្រា១៣.–**

ប្រធាន អនុប្រធាន និងហេរញ្ញិក ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយឡែកពីគ្នាក្នុងចំណោមសមាជិកក្រុមប្រឹក្សាប្រតិបត្តិដោយក្រុមប្រឹក្សាប្រតិបត្តិ។

**មាត្រា១៤.–**

ប្រធានក្រុមប្រឹក្សាប្រតិបត្តិត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ខ្លួន។

ការបោះឆ្នោតជ្រើសរើសប្រធានត្រូវធ្វើជា ២ (ពីរ)ជុំ ប្រសិនបើជុំទី១ គ្មានបេក្ខជនណាទទួលសំឡេងគាំទ្រភាគច្រើនដាច់ខាតទេ។ ការបោះឆ្នោតនៃជុំទីពីរ គឺយកតែបេក្ខជនពីររូបដែលមានសំឡេងឆ្នោតច្រើនជាងគេ [illegible] ឈ្មោះមកឱ្យឈរឈ្មោះ។

ដោយឡែកអនុប្រធាននិងហេរញ្ញិក ត្រូវបោះឆ្នោតជ្រើសរើសដោយយកតាមសំឡេងភាគច្រើនធម្មតា ក្នុងករណីមានសំឡេងស្មើគ្នា ត្រូវយកអ្នកមានអាយុច្រើនជាងគេ។

សមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ ត្រូវមានសញ្ជាតិខ្មែរ។ ដោយឡែក ប្រធាន និង ហេរញ្ញិក ត្រូវមានសញ្ជាតិខ្មែរ។

ប្រធានរបស់ក្រុមប្រឹក្សាប្រតិបត្តិ គឺជាប្រធានរបស់ **ម.ជ.ម.**។

អនុប្រធាន ត្រូវជួយការងាររបស់ប្រធាន ហើយជំនួសប្រធាននៅពេលដែលប្រធានអវត្តមាន។

ហេរញ្ញិក ត្រូវគ្រប់គ្រងមូលនិធិ ប្រមូលចំណូលនិងចាត់ចែងចំណាយក្នុងនាម **ម.ជ.ម.** ហើយត្រូវមានគណនីចរន្ត និងត្រូវទទួលខុសត្រូវពីភាពត្រឹមត្រូវនៃគណនីទាំងនោះ។

សមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវជួយការងារ **ម.ជ.ម.**និងបំពេញភារកិច្ច ដែលក្រុមប្រឹក្សាប្រតិបត្តិប្រគល់ជូន។

**មាត្រា១៥.-**

ក្នុងករណីតំណែងប្រធាន អនុប្រធាន ឬហេរញ្ញិក របស់ក្រុមប្រឹក្សាប្រតិបត្តិនៃ **ម.ជ.ម.** នៅទំនេរដោយសារការលាលែងពីមុខតំណែង ក្រុមប្រឹក្សាប្រតិបត្តិត្រូវបោះឆ្នោតជ្រើសរើសសមាជិករបស់ខ្លួនម្នាក់ទៀតឱ្យចូលកាន់មុខតំណែងដែលនៅទំនេរនោះនៅក្នុងកិច្ចប្រជុំបន្ទាប់ ឬនៅឯកិច្ចប្រជុំណាមួយដ៏ខ្លី បន្ទាប់ពីការលាលែងនោះ។

**មាត្រា១៦.-**

សមាជិកគ្រប់រូបរបស់ **ម.ជ.ម.** ទោះរូបវន្តបុគ្គលក្តី អ្នកតំណាងផ្ទេរសិទ្ធិដែលទទួលបានការចាត់តាំងពីសភាពាណិជ្ជកម្មរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា សភាមុខរបរនិងមីក្រូសហគ្រាស គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និងសេវាករក្តី មានសិទ្ធិឈរឈ្មោះឱ្យមហាសន្និបាតបោះឆ្នោតជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ លុះត្រាតែបានចុះឈ្មោះ ជាមជ្ឈត្តករក្នុងបញ្ជីនៃ **ម.ជ.ម.**។

**មាត្រា១៧.-**

ក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលត្រូវបានកំណត់ សម្រាប់មហាសន្និបាតប្រចាំឆ្នាំ ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើការកំណត់ និងផ្សព្វផ្សាយនូវ÷

- កាលបរិច្ឆេទនៃការជ្រើសរើសបេក្ខជន
- កាលបរិច្ឆេទបោះឆ្នោត ដែលមិនត្រូវតិចជាង៣ (បី) សប្តាហ៍ បន្ទាប់ពីកាលបរិច្ឆេទនៃការជ្រើសរើសបេក្ខជន
- ទីកន្លែងដែលមានភាពងាយស្រួលក្នុងបរិវេណ **ម.ជ.ម.** ឬកន្លែងផ្សេងទៀតសម្រាប់រៀបចំការបោះឆ្នោតជាសម្ងាត់។

**មាត្រា១៨.-**

ការបោះឆ្នោតជ្រើសរើសសមាជិកទាំងអស់ ឬសមាជិកណាម្នាក់របស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវធ្វើឡើងតាមរយៈការបោះឆ្នោតជាសម្ងាត់ ដោយសមាជិកមួយរូបមានសំឡេងឆ្នោតមួយសំឡេង ក្នុងមហាសន្និបាតប្រចាំឆ្នាំ ឬមហាសន្និបាតវិសាមញ្ញ ដោយអនុលោមតាមវិធានកំណត់ដោយមហាសន្និបាត។

ក្រុមប្រឹក្សាប្រតិបត្តិថ្មីដែលទើបកើតឡើងក្រោយពីមានការបោះឆ្នោតត្រូវចូលកាន់មុខតំណែងនៅក្រោយពេលមហាសន្និបាតប្រចាំឆ្នាំ។

**មាត្រា១៩.-**

មជ្ឈត្តករដែលឈរឈ្មោះបោះឆ្នោត ជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម ÷

- សមាជិក **ម.ជ.ម.** ពីររូបអាចស្នើតែងតាំងសមាជិក **ម.ជ.ម.** បានតែម្នាក់ប៉ុណ្ណោះធ្វើជាបេក្ខជន
- សំណើតែងតាំងបេក្ខជនត្រូវមានការយល់ព្រមពីសាមីខ្លួនផ្ទាល់
- សំណើតែងតាំងត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខា។

**មាត្រា២០.-**

បើសិនបេក្ខជនឈរឈ្មោះមានចំនួនតិចជាង ឬស្មើនឹងតំណែងដែលត្រូវបោះឆ្នោតរើស សម្រាប់ធ្វើជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ការជ្រើសរើសត្រូវពន្យាររយៈពេល១៥(ដប់ប្រាំ)ថ្ងៃទៀត។ ក្រោយរយៈពេលពន្យារ ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើបេក្ខជននៅតែមានចំនួនតិចជាង ឬស្មើនឹងតំណែងដែលត្រូវបោះឆ្នោតជ្រើសរើស បេក្ខជនទាំងនោះត្រូវចាត់ទុកថាជាប់ឆ្នោតដោយស្វ័យប្រវត្តិ។ ក្នុងករណីដែលបេក្ខជនឈរឈ្មោះមិនគ្រប់ចំនួន មហាសន្និបាតអាចតែងតាំងបេក្ខជនបន្ថែមតាមនីតិវិធីដដែល។ ក្នុងករណីដែលបេក្ខជនមានចំនួនលើសពីចំនួនតំណែង ដែលត្រូវជ្រើសរើស មហាសន្និបាតត្រូវធ្វើការបោះឆ្នោត។

**មាត្រា២១.-**

សមាជិកក្រុមប្រឹក្សាប្រតិបត្តិត្រូវបាត់បង់មុខតំណែងក្នុងករណីដូចខាងក្រោម ÷

- ក្លាយជាអសមត្ថជនផ្នែករូបរាងកាយ និងសតិស្មារតី មិនអាចបំពេញមុខងាររបស់ខ្លួនបាន
- ត្រូវបានផ្តន្ទាទោសពីបទល្មើសមជ្ឈិម ឬឧក្រិដ្ឋណាមួយ
- អវត្តមានពីកិច្ចប្រជុំ ៣ (បី)ដង ជាប់ៗគ្នាដោយគ្មានមូលហេតុ
- ត្រូវបានវិនិច្ឆ័យថា ក្ស័យធនដោយតុលាការ
- សុំលាលែងជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាប្រតិបត្តិ
- លែងជាសមាជិករបស់ **ម.ជ.ម.**
- លែងជាតំណាងចាត់តាំងរបស់អង្គការសមាជិក

- ទទួលមរណភាព។

**មាត្រា២២.–**

ក្រៅពីការប្រជុំប្រចាំខែ ប្រធានក្រុមប្រឹក្សាប្រតិបត្តិ អាចកោះប្រជុំក្រុមប្រឹក្សាប្រតិបត្តិពេលណាក៏បាន ដោយជូនដំណឹងទៅកាន់សមាជិកក្រុមប្រឹក្សាប្រតិបត្តិ រយៈពេល ៧ (ប្រាំពីរ) ថ្ងៃជាមុន។ យ៉ាងហោចណាស់ត្រូវមានសមាជិក ២/៣ (ពីរភាគបី) វត្តមាន ដើម្បីឱ្យដំណើរការប្រជុំមានសុពលភាព។

បញ្ហានានាដែលត្រូវបានលើកឡើងមកពិភាក្សា នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ ត្រូវសម្រេចដោយសំឡេងភាគច្រើន ហើយក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមានុភាព។

**មាត្រា២៣.–**

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាប្រតិបត្តិបាត់បង់សមាជិកភាពរបស់ខ្លួន ប្រធាន **ម.ខ.ម.** ត្រូវកោះប្រជុំសន្និបាតវិសាមញ្ញ ដើម្បីធ្វើការជ្រើសរើសសមាជិកបង្គ្រប់។ អាណត្តិរបស់សមាជិកជំនួសនេះជាអាណត្តិរបស់សមាជិក ដែលបានបាត់បង់សមាជិកភាព។

**មាត្រា២៤.–**

ក្រុមប្រឹក្សាប្រតិបត្តិ អាចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការនានា ដែលមានសមាសភាពសមាជិកក្រុមប្រឹក្សាប្រតិបត្តិមួយរូប ឬច្រើនរូបដឹកនាំការងារ។ ការរៀបចំគណៈកម្មាធិការ ឬអនុគណៈកម្មាធិការនានាត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **ម.ខ.ម.**។

## ផ្នែកទី៣

## អគ្គលេខាធិការដ្ឋាន

**មាត្រា២៥.–**

អគ្គលេខាធិការដ្ឋាននៃ **ម.ខ.ម.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ដែលត្រូវជ្រើសរើសដោយក្រុមប្រឹក្សាប្រតិបត្តិ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **ម.ខ.ម.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា២៦.–**

អគ្គលេខាធិការដ្ឋាននៃ **ម.ខ.ម.** មានតួនាទីជាសេនាធិការឱ្យក្រុមប្រឹក្សាប្រតិបត្តិ និងមានភារកិច្ចដូចខាងក្រោម÷

- គ្រប់គ្រងលើការងារនិងសកម្មភាពប្រចាំថ្ងៃរបស់ **ម.ខ.ម.**
- អនុវត្តគោលនយោបាយដែលក្រុមប្រឹក្សាប្រតិបត្តិដាក់ចេញ
- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិ មហាសន្និបាត និងកិច្ចប្រជុំផ្សេងទៀត

- រក្សាឯកសារ
- ប្រមូលព័ត៌មានដែលពាក់ព័ន្ធនិងសកម្មភាពមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលអាចមានប្រយោជន៍ដល់សមាជិក របស់ **ម.ជ.ម.**
- ផ្តួចផ្តើមគំនិតលើកិច្ចការថ្មីៗ និងរៀបចំសកម្មភាព និងគម្រោងនានាដែលជួយទ្រទ្រង់តួនាទីរបស់ **ម.ជ.ម.**
- ផ្តល់សេវាផ្នែកលេខាធិការដល់សមាជិក ដោយយកកម្រៃសេវាស្របតាមលក្ខខណ្ឌ ដែលអនុម័តដោយក្រុមប្រឹក្សាប្រតិបត្តិ
- ទ្រទ្រង់ផ្នែកបោះពុម្ពនានារបស់ **ម.ជ.ម.** រួមទាំងកាន់កាប់គេហទំព័ររបស់ **ម.ជ.ម.**
- រៀបចំការបណ្តុះបណ្តាល
- បំពេញភារកិច្ចផ្សេងៗដែលក្រុមប្រឹក្សាប្រតិបត្តិប្រគល់ជូន។

**មាត្រា២៧.–**

**ម.ជ.ម.** មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួន។

## ផ្នែកទី៤
## សមាជិកនៃ ម.ជ.ម.

**មាត្រា២៨.–**

បុគ្គលទាំងឡាយដែលចង់ក្លាយជាសមាជិកនៃ **ម.ជ.ម.** ត្រូវចុះបញ្ជីជាមជ្ឈត្តករនៅ **ម.ជ.ម.**។

រាល់ពាក្យសុំចុះឈ្មោះទាំងអស់ ត្រូវដាក់ជូនទៅក្រុមប្រឹក្សាប្រតិបត្តិរបស់ **ម.ជ.ម.** ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារផ្សេងៗ តាមការតម្រូវរបស់ក្រុមប្រឹក្សាប្រតិបត្តិ និងបង់ភាគទានតាមការកំណត់របស់ **ម.ជ.ម.**។

**មាត្រា២៩.–**

រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេស អាចដាក់ពាក្យសុំធ្វើជាមជ្ឈត្តករជាមួយ **ម.ជ.ម.** បាន បើសិនជារូបវន្តបុគ្គលនោះ មានលក្ខណសម្បត្តិដូចខាងក្រោម ÷

- មានអាយុចាប់ពី ៣០ (សាមសិប) ឆ្នាំឡើង
- មានសញ្ញាបត្របរិញ្ញាបត្រជំនាញណាមួយ ក្រោយពីបានបញ្ចប់ការសិក្សានៅតាមសកលវិទ្យាល័យក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស និង
- បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកមជ្ឈត្តការផ្នែកពាណិជ្ជកម្មជាមួយ **ម.ជ.ម.** ឬ[illegible]ជាមួយ៖

- មជ្ឈមណ្ឌលនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិនានា ដែលទទួលស្គាល់ដោយ **ម.ជ.ម.**។

ប្រសិនបើពុំមានលក្ខណសម្បត្តិដូចខាងលើទេ រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេសនោះត្រូវជាបុគ្គលដែលធ្លាប់ធ្វើជា÷

- សមាជិកនៃស្ថាប័នវិជ្ជាជីវៈផ្នែកមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលទទួលស្គាល់ដោយ **ម.ជ.ម.** ឬ
- មជ្ឈត្តករ ឬអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្មចាប់ពី៣ (បី) ដង ឡើងទៅ ឬបានសរសេរសេចក្តីបង្គាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចំនួនយ៉ាងតិច៣ (បី) ក្នុងពេលដែលបុគ្គលនោះធ្វើជាមជ្ឈត្តករ។

ទោះបីដូចមានចែងខាងលើក៏ដោយ និងក្រោយពីមានការយល់ព្រមពីមហាសន្និបាត ក្រុមប្រឹក្សាប្រតិបត្តិអាចកំណត់នូវលក្ខណវិនិច្ឆ័យបន្ថែមផ្សេងទៀត ដែលខ្លួនគិតថា សមស្រប និងមានប្រយោជន៍ដល់ **ម.ជ.ម.**។

**មាត្រា៣០.-**

មជ្ឈត្តករ÷

- មិនត្រូវស្ថិតនៅក្នុងឋានានុក្រមជាមន្ត្រីនៃស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិប្បញ្ញត្តិ និងតុលាការ
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋណាមួយ។

**មាត្រា៣១.-**

**ម.ជ.ម.** ត្រូវរៀបចំបញ្ជីឈ្មោះសមាជិករបស់ខ្លួន ដែលមានចុះព័ត៌មានដូចខាងក្រោម÷

- ឈ្មោះនិងអាសយដ្ឋាន
- កាលបរិច្ឆេទនៃការចុះបញ្ជី
- លក្ខណសម្បត្តិនិង
- ព័ត៌មានចាំបាច់ដទៃទៀត ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។

**មាត្រា៣២.-**

ក្រុមប្រឹក្សាប្រតិបត្តិត្រូវបដិសេធការចុះបញ្ជីឱ្យបេក្ខជនណាមួយ ដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមមាត្រា២៩ និង៣០ នៃអនុក្រឹត្យនេះ។

**មាត្រា៣៣.-**

វិញ្ញាបនបត្រចុះបញ្ជី ត្រូវសុំបន្តជារៀងរាល់ឆ្នាំតាមរយៈការបង់ភាគទានប្រចាំឆ្នាំ។

រៀងរាល់ឆ្នាំ **ម.ជ.ម.** ត្រូវប្រកាសជាសាធារណៈ នូវឈ្មោះរបស់មជ្ឈត្តករដែលបានចុះបញ្ជី។

សមាជិក **ម.ជ.ម.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ នូវរាល់ការផ្លាស់ប្តូរអាសយដ្ឋានវិជ្ជាជីវៈ ឬ អាសយដ្ឋានផ្ទាល់ខ្លួន ក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃផ្លាស់ប្តូរនោះ។

**មាត្រា៣៤.-**

សភាពាណិជ្ជកម្មរាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា សភាមុខរបរនិងមីក្រូសហគ្រាស គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងសមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និងសេវាករ អាចតែងតាំងបុគ្គលមួយរូបធ្វើជាតំណាង និងបោះឆ្នោតក្នុងមហាសន្និបាតនានារបស់ **ម.ជ.ម.**។ ក្នុងករណីលាលែង ឬឈប់ធ្វើការជាមួយអង្គការដែលខ្លួនជាតំណាង បុគ្គលរូបនោះលែងមានសិទ្ធិជាអ្នកតំណាងរបស់អង្គការសមាជិកនោះដោយស្វ័យប្រវត្តិ។ ក្រុមប្រឹក្សាប្រតិបត្តិមានសិទ្ធិបដិសេធអ្នកតំណាង ដែលតែងតាំងដោយអង្គការសមាជិកណាមួយ ប្រសិនបើពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់។

**មាត្រា៣៥.-**

សមាជិក **ម.ជ.ម.** ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោមនេះ ៖

- មិនបានបន្តចុះបញ្ជីជាមជ្ឈត្តករជាមួយ **ម.ជ.ម.** តាមការកំណត់
- ក្លាយជាអសមត្ថជនផ្នែករូបរាងកាយនិងសតិស្មារតី ដែលមិនអាចបំពេញមុខងាររបស់ខ្លួនបាន
- ត្រូវបានវិនិច្ឆ័យថា ក្ស័យធន ឬត្រូវដាក់ឱ្យជម្រះបញ្ជី
- សុំលាលែងជាលាយលក្ខណ៍អក្សរទៅកាន់ **ម.ជ.ម.**
- ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ
- បានរំលោភលើក្រមសីលធម៌របស់មជ្ឈត្តករនិងបទបញ្ជាផ្ទៃក្នុង
- ទទួលមរណភាព
- ខកខានមិនបានបង់ភាគទានតាមការកំណត់

ការបាត់បង់សមាជិកភាពនេះត្រូវសម្រេចដោយក្រុមប្រឹក្សាប្រតិបត្តិ។

**មាត្រា៣៦.-**

ការដកហូតសមាជិកភាពរបស់សមាជិកណាម្នាក់ អាចធ្វើទៅបាន លុះត្រាតែសមាជិកនោះ ត្រូវបានផ្តល់ឱកាសដើម្បីធ្វើការដោះសារជាលាយលក្ខណ៍អក្សរតែមិនបានដោះសារតាមពេលវេលាកំណត់។ ក្នុងករណីដែលក្រុមប្រឹក្សាប្រតិបត្តិសម្រេចដកហូតសមាជិកភាពពី **ម.ជ.ម.** ក្រុមប្រឹក្សាត្រូវផ្តល់ហេតុផលជាលាយលក្ខណ៍អក្សរ។ ក្នុងករណីដែលសាមីខ្លួនមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ សមាជិកនោះមានសិទ្ធិប្តឹងទៅ[illegible]

**មាត្រា៣៧.–**

សមាជិក **ម.ជ.ម.** ត្រូវទទួលក្នុងរយៈពេល ២ (ពីរ) ឆ្នាំម្តងយ៉ាងតិចនូវការបណ្តុះបណ្តាលបន្ត ដែលរៀបចំដោយ **ម.ជ.ម.** ឬរៀបចំដោយស្ថាប័នជាតិ និងអន្តរជាតិដែលទទួលស្គាល់ដោយ **ម.ជ.ម.** ។

នៅក្នុងការចុះបញ្ជីបន្តជាមជ្ឈត្តករនៅ **ម.ជ.ម.** ក្រុមប្រឹក្សាប្រតិបត្តិអាចបដិសេធការចុះបញ្ជីរបស់សមាជិកណាម្នាក់បាន ក្នុងករណីដែលសមាជិកនោះខកខានមិនបានធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត។

**មាត្រា៣៨.–**

នៅក្នុងកាលៈទេសៈពិសេសដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ក្រុមប្រឹក្សាប្រតិបត្តិ អាចចុះបញ្ជីបន្តសម្រាប់មជ្ឈត្តករណាម្នាក់បាន ទោះបីមជ្ឈត្តករនោះខកខានមិនបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ៣៧ ខាងលើ។

## ផ្នែកទី៥

## សវនកម្ម

**មាត្រា៣៩.–**

ក្រុមហ៊ុនសវនកម្មដែលទទួលបានការអនុម័តយល់ព្រមពីមហាសន្និបាត ត្រូវបានជ្រើសតាំងជាសវនកររបស់ **ម.ជ.ម.** សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ ហើយអាចត្រូវបានជ្រើសតាំងសារជាថ្មីទៀតបាន។

**មាត្រា៤០.–**

សវនករមានតួនាទីនិងភារកិច្ច ដូចខាងក្រោម ÷

- ធ្វើសវនកម្មប្រចាំឆ្នាំ និងបង្ហាញរបាយការណ៍សវនកម្មរបស់ខ្លួន ក្នុងមហាសន្និបាតប្រចាំឆ្នាំ
- ធ្វើសវនកម្មតាមការស្នើសុំរបស់ប្រធាន **ម.ជ.ម.** សម្រាប់រយៈពេលណាមួយក៏បាន និងនៅគ្រប់ពេលវេលានៅក្នុងអំឡុងពេលនៃកិច្ចសន្យា ហើយត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាប្រតិបត្តិ។

សមាជិកនិងបុគ្គលិកគ្រប់រូបរបស់ **ម.ជ.ម.** មានកាតព្វកិច្ចផ្តល់ព័ត៌មាន និងសេចក្តីពន្យល់នានាដែលតម្រូវដោយសវនករ។

## ផ្នែកទី៦

## សាខារបស់ម.ជ.ម.

**មាត្រា៤១.–**

**ម.ជ.ម.** អាចបង្កើតសាខារបស់ខ្លួនបាននៅតាមខេត្តនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ [illegible]ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាខានីមួយៗត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **ម.ជ.ម.** ។

## ជំពូកទី៤

## ប្រភពធនធាន

**មាត្រា៤២.–**

ប្រភពធនធានរបស់ **ម.ជ.ម.** បានមកពី ÷

- ភាគទានរបស់សមាជិក
- អំណោយនិងវិភាគទានពីប្រភពផ្សេងៗ
- កម្រៃសេវាផ្នែករដ្ឋបាលរបស់ **ម.ជ.ម.** ។

**មាត្រា៤៣.–**

សមាជិកត្រូវបង់ភាគទានប្រចាំឆ្នាំ តាមការកំណត់របស់មហាសន្និបាតដែលស្នើដោយក្រុមប្រឹក្សាប្រតិបត្តិ ។

ភាគទានប្រចាំឆ្នាំត្រូវបង់ជាមុន ក្នុងអំលុងខែទីមួយរៀងរាល់ឆ្នាំ។ ប្រសិនបើសមាជិកណាម្នាក់ មានភាពយឺតយ៉ាវក្នុងការបង់ភាគទានប្រចាំឆ្នាំ ឬវិភាគទានដទៃទៀត ហើយហេរញ្ញិកត្រូវក្រើនរំលឹកជាបន្ទាន់ដល់សមាជិកនោះ ។

ប្រសិនបើសមាជិកណាម្នាក់ មានការយឺតយ៉ាវក្នុងការបង់ភាគទានប្រចាំឆ្នាំ លើសពី ៣ (បី)ខែ ចាប់ពីខែទីពីរ សមាជិកនោះត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ដោយស្វ័យប្រវត្តិ។

រាល់មូលនិធិបន្ថែមនានាដែលតម្រូវដោយ **ម.ជ.ម.** សម្រាប់គោលបំណងពិសេសណាមួយអាចប្រមូលពីបណ្ដាសមាជិកបាន លុះត្រាតែមានសំឡេងយល់ព្រមពីមហាសន្និបាតរបស់សមាជិកលើសពី៥០ (ហាសិប) ភាគរយ នៃសមាជិកដែលមានវត្តមានក្នុងមហាសន្និបាត ។

**មាត្រា៤៤.–**

បុគ្គលិករបស់ **ម.ជ.ម.** និងសមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ទទួលបានការធានារ៉ាប់រងពី **ម.ជ.ម.** ចំពោះរាល់ការបង់ថ្លៃចំណាយ និងការខាតបង់នានាក្នុងការបំពេញដ៏ត្រឹមត្រូវនូវភារកិច្ចរបស់ខ្លួន ។

## ជំពូកទី៥

## ការជ្រើសរើសមជ្ឈត្តករដំបូង

**មាត្រា៤៥.–**

ក្រសួងពាណិជ្ជកម្មត្រូវបង្កើតគណៈកម្មការរៀបចំ និងជ្រើសរើសមជ្ឈត្តករដំបូងមួយ ដែលមានសមាជិកមិនលើសពី ១២ (ដប់ពីរ)រូប ។

គណៈកម្មការនេះត្រូវដឹកនាំដោយតំណាងក្រសួងពាណិជ្ជកម្ម ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន ដូចខាងក្រោម ÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- សហព័ន្ធនិយោជក
- សភាពាណិជ្ជកម្មកម្ពុជា
- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- សភាពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជា
- សមាគមរោងចក្រកាត់ដេរកម្ពុជា
- សភាមុខរបរនិងមីក្រូសហគ្រាស
- បុគ្គលដទៃទៀតដែលក្រសួងពាណិជ្ជកម្ម និងក្រសួងយុត្តិធម៌យល់ថា សមស្រប ។

**មាត្រា៤៦.-**

ក្រសួងពាណិជ្ជកម្មត្រូវចេញប្រកាសតែងតាំងសមាសភាពគណៈកម្មការរៀបចំនិងជ្រើសរើសមជ្ឈត្តករដំបូង ។ សមាជិកម្នាក់ៗត្រូវចូលរួមដោយផ្ទាល់ ក្នុងរាល់ការប្រជុំរបស់គណៈកម្មការតាមការអញ្ជើញរបស់ប្រធាន ។

**មាត្រា៤៧.-**

គណៈកម្មការរៀបចំ និងជ្រើសរើសនោះត្រូវរៀបចំធ្វើការជ្រើសរើសចេញពីពាក្យស្នើសុំរបស់បេក្ខជនដំបូង ដែលមានចំនួនមិនលើសពី ៦០ ( ហុកសិប)រូប ដើម្បីឱ្យចុះឈ្មោះជាមជ្ឈត្តករដំបូងនៃ **ម.ជ.ម.** ។

**មាត្រា៤៨.-**

សេចក្តីជូនដំណឹងផ្សេងៗរបស់គណៈកម្មការត្រូវធ្វើឡើងតាមរយៈបណ្តាញសារព័ត៌មាន និងផ្ញើជូន អង្គការ ក្រសួង ស្ថាប័នទាំងអស់ និងបុគ្គលពាក់ព័ន្ធនានាដោយផ្ទាល់ ។

**មាត្រា៤៩.-**

អ្នកដាក់ពាក្យទាំងអស់ត្រូវផ្តល់ព័ត៌មានលម្អិតផ្ទាល់ខ្លួន និងព័ត៌មានអំពីលក្ខណសម្បត្តិរបស់ខ្លួនដូចបានកំណត់នៅក្នុងអនុក្រឹត្យនេះ និងតាមការកំណត់របស់គណៈកម្មការរៀបចំ និងជ្រើសរើសមជ្ឈត្តករដំបូង ។

គណៈកម្មការត្រូវធ្វើការប្រជុំតាមការចាំបាច់ ដើម្បីធ្វើការពិនិត្យលើពាក្យសុំ និងកំណត់ពីបេក្ខជន ដែលត្រូវជ្រើសរើសមិនតិចជាង ៥០ ( ហាសិប)រូប ។

**មាត្រា៥០._**

ការប្រជុំរបស់គណៈកម្មការអាចប្រព្រឹត្តទៅបាន លុះត្រាតែមានកូរ៉ុមលើសពី ៥០ (ហាសិប) ភាគរយ នៃចំនួនសមាជិក។ សេចក្តីសម្រេចរបស់គណៈកម្មការរៀបចំ និងជ្រើសរើសត្រូវធ្វើឡើងដោយសំឡេងភាគច្រើន នៃសមាជិកដែលមានវត្តមាន និងបោះឆ្នោតនៅក្នុងកិច្ចប្រជុំ។ ក្នុងករណីសំឡេងស្មើគ្នា សំឡេងខាងប្រធានមានឧត្តមានុភាព។

**មាត្រា៥១._**

ឈ្មោះរបស់បុគ្គលដែលត្រូវបានជ្រើសរើសជាសមាជិកដំបូង ត្រូវបិទផ្សាយក្នុងរយៈពេល១៤ (ដប់បួន)ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចចុងក្រោយ ហើយបុគ្គលដែលជាប់ឈ្មោះទាំងនោះត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលរៀបចំដោយក្រសួងពាណិជ្ជកម្ម។

**មាត្រា៥២._**

បុគ្គលដែលត្រូវបានជ្រើសរើសដំបូង មិនតិចជាង៥០ (ហាសិប) រូប ត្រូវដាក់ពាក្យសុំធ្វើជាមជ្ឈត្តករនៅ **ម.ជ.ម.** ក្រោយពីបានបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

**មាត្រា៥៣._**

ក្រសួងពាណិជ្ជកម្មត្រូវទទួលខុសត្រូវ ក្នុងការរៀបចំបង្កើតការិយាល័យចុះបញ្ជីមជ្ឈត្តករជាលើកដំបូង និងត្រូវគ្រប់គ្រងការិយាល័យនេះរហូតដល់ពេលដែល **ម.ជ.ម.** ដំណើរការងារដំបូងរបស់ខ្លួន ហើយមានការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាប្រតិបត្តិ។

## ជំពូកទី៦

## អន្តរប្បញ្ញត្តិ

**មាត្រា៥៤._**

ក្រោយពីសមាជិក **ម.ជ.ម.** ត្រូវបានជ្រើសរើសនិងក្រុមប្រឹក្សាប្រតិបត្តិ ត្រូវបានបោះឆ្នោតរួចមក ក្រសួងពាណិជ្ជកម្មត្រូវសហការជាមួយ **ម.ជ.ម.** ក្នុងការផ្ទេរបញ្ជីឈ្មោះមជ្ឈត្តករទៅឱ្យអ្នកកាន់បញ្ជីរបស់ **ម.ជ.ម.** រួមទាំងមូលនិធិ និងទ្រព្យនានា ដែលជាកម្មសិទ្ធិ ឬក្លាយជាកម្មសិទ្ធិរបស់ **ម.ជ.ម.**។

ភារកិច្ចគណៈកម្មការត្រូវបញ្ចប់ នៅពេលក្រុមប្រឹក្សាប្រតិបត្តិ **ម.ជ.ម.** ចូលកាន់ការងារ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា៥៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

NCAC
មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
NATIONAL COMMERCIAL ARBITRATION CENTRE

# វិធាន
# ស្តីពីមជ្ឈត្តការ

២៨ មីនា ២០២១

# បុព្វកថា

មជ្ឈត្តការពាណិជ្ជកម្មបានក្លាយជាជម្រើសដ៏សមស្របមួយ សម្រាប់គូភាគីវិវាទដែលមានបំណងដោះស្រាយវិវាទរបស់ខ្លួនក្រៅប្រព័ន្ធតុលាការ ហើយនិន្នាការនេះត្រូវបានគេរំពឹងនឹងបន្តកើនឡើងខ្លាំងនៅពេលអនាគត។ ជាក់ស្តែង គិតត្រឹមខែធ្នូ ឆ្នាំ២០២០ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) បានទទួលចាត់ចែងធ្វើមជ្ឈត្តការលើសំណុំរឿងក្រោមវិធានស្តីពីមជ្ឈត្តការឆ្នាំ២០១៤ ចំនួន ២៥ សំណុំរឿង ដោយរួមបញ្ចូលទាំងសំណុំរឿងអន្តរជាតិ ដែលមានតម្លៃកម្មវត្ថុនៃវិវាទសរុបលើសពី ៧២ លានដុល្លារអាមេរិក។

ក្នុងឆ្នាំ២០២១ នេះ ម.ជ.ម. បានធ្វើវិសោធនកម្មលើវិធានស្តីពីមជ្ឈត្តការឆ្នាំ២០១៤ របស់ខ្លួនក្នុងគោលបំណងធ្វើបច្ចុប្បន្នភាពជាមួយនឹងការអភិវឌ្ឍនានាក្នុងវិស័យមជ្ឈត្តការពាណិជ្ជកម្ម និងដើម្បីផ្តល់សេវារបស់ខ្លួនទៅកាន់អ្នកប្រើប្រាស់ឱ្យកាន់តែប្រសើរថែមទៀត។ វិធានស្តីពីមជ្ឈត្តការថ្មីនេះ ត្រូវបានអនុម័តនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១ និងត្រូវបានកំណត់ឱ្យចូលជាធរមានចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១។ វិធានស្តីពីមជ្ឈត្តការថ្មីនេះ គឺជាលទ្ធផលនៃការចំណាយពេលជាច្រើនរបស់ ម.ជ.ម. លើការស្រាវជ្រាវ ការវិភាគ ការកែតម្រូវ និងការពិគ្រោះយោបល់ជាមួយអ្នកអនុវត្តច្បាប់ ក៏ដូចជាមជ្ឈត្តករជាតិ និងអន្តរជាតិ ដែលមានបទពិសោធន៍ខ្ពស់ផងដែរ។

ចំនុចសំខាន់ៗនៃវិសោធនកម្មរួមមាន ការអនុញ្ញាតឱ្យ ម.ជ.ម. អាចចាត់ចែងសំណុំរឿងមជ្ឈត្តការ និងផ្តល់សេវាកម្មផ្សេងៗ ក្រោមវិធានមជ្ឈត្តការក្រៅពីវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. និងការអនុញ្ញាតឱ្យគូភាគីវិវាទអាចបន្ថយពេលវេលាកំណត់ដែលមានចែងនៅក្នុងវិធានស្តីពីមជ្ឈត្តការ ប្រសិនបើមានការព្រមព្រៀងពីគូភាគីវិវាទ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហានានាដែលអាចកើតមានទាក់ទងនឹងឯករាជភាព និងអព្យាក្រឹតភាពរបស់មជ្ឈត្តករ ដែលកើតចេញពីការផ្លាស់ប្តូរអ្នកតំណាងរបស់ភាគីវិវាទ បន្ទាប់ពីវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើតរួច វិសោធនកម្មថ្មីបានអនុញ្ញាតឱ្យវេទិកាមជ្ឈត្តកម្មមានសិទ្ធិអំណាចក្នុងការចាត់វិធានការ

ចាំបាច់នានា ដើម្បីជៀសវាងការកើតមានទំនាស់ផលប្រយោជន៍ ចេញពីការផ្លាស់ប្តូរនោះ។ វិធានថ្មីនេះ ក៏បានកំណត់វិធីសាស្ត្រថ្មីក្នុងការកំណត់កាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការមជ្ឈត្តការដែលមានសារៈសំខាន់ជាពិសេសសម្រាប់វិវាទដែលមានភាគីឆ្លើយតបច្រើន។ បន្ថែមពីនេះទៀត វិធានថ្មីនេះ បានចែងអំពីការប្រើប្រាស់មធ្យោបាយទំនាក់ទំនងតាមរយៈប្រព័ន្ធអេឡិចត្រូនិច ក្នុងដំណើរការមជ្ឈត្តការឱ្យកាន់តែមានលក្ខណៈច្បាស់ជាងមុន ដើម្បីឆ្លើយតបទៅនឹងទម្លាប់ថ្មីនាសម័យបច្ចុប្បន្ននេះ។ វិធានថ្មីនេះ ក៏មានកំណត់អំពីពេលវេលាជាក់លាក់សម្រាប់វេទិកាមជ្ឈត្តកម្ម ក្នុងការប្រកាសបិទដំណើរការមជ្ឈត្តការ ដើម្បីអនុញ្ញាតឱ្យគូភាគីវិវាទអាចស្មានទុកជាមុននូវកាលបរិច្ឆេទចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ។

លើសពីនេះ វិធានស្តីពីមជ្ឈត្តការថ្មី ក៏បានបន្ថែមនីតិវិធីពន្លឿន និងមជ្ឈត្តករបន្ទាន់ជាលើកដំបូងផងដែរ។ ភាគីវិវាទអាចដាក់សំណើសុំនីតិវិធីពន្លឿនបាន ប្រសិនបើតម្លៃកម្មវត្ថុនៃវិវាទ មានតម្លៃមិនលើសពី ៣ លាន ដុល្លារអាមេរិក មានការព្រមព្រៀងពីគូភាគីវិវាទ ឬក្នុងករណីពិសេសបន្ទាន់ខ្លាំង។ ក្រោមដំណើរការនីតិវិធីពន្លឿននេះ មជ្ឈត្តវិនិច្ឆ័យស្ថាពរនឹងត្រូវចេញក្នុងអំឡុងពេល ២៧០ ថ្ងៃប្រតិទិន គិតចាប់ពីថ្ងៃដែលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត។ មុនពេលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើតឡើង ភាគីវិវាទក៏អាចដាក់សំណើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ ដែលសេចក្តីសម្រេចលើសំណើនោះនឹងត្រូវចេញក្នុងអំឡុងពេល ១៥ ថ្ងៃប្រតិទិន បន្ទាប់ពីថ្ងៃដែលមជ្ឈត្តករបន្ទាន់ត្រូវបានតែងតាំង។

តាមរយៈវិធានថ្មីនេះ អ្នកប្រើប្រាស់អាចដោះស្រាយវិវាទរបស់ខ្លួននៅ ម.ជ.ម. ជាមួយនឹងភាពបត់បែន ប្រសិទ្ធភាព និងតម្លាភាពកាន់តែខ្ពស់ជាងមុនថែមទៀត។

**ម៉ុន យូឌី**
**ប្រធាន**
**មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**

# មាតិកា

ជំពូកទី ១

## វិធានទូទៅ ៨

ប្រការ ១. និយមន័យ ៨

ប្រការ ២. វិសាលភាពអនុវត្ត ៩

ប្រការ ៣. ការតំណាង ១០

ប្រការ ៤. ការទាក់ទង និងសំណៅចម្លងក្នុងពេលដំណាលគ្នា ១០

ប្រការ ៥. ការកំណត់ពេលវេលា ១២

ប្រការ ៦. ដំណើរការមជ្ឈត្តការដោយយុត្តិធម៌ ឆាប់រហ័ស មានប្រសិទ្ធភាព និងដោយមិនបង្អង់ ១៣

ជំពូកទី ២

## ការចាប់ផ្តើមមជ្ឈត្តកម្ម ១៤

ប្រការ ៧. ការចាប់ផ្តើមមជ្ឈត្តកម្ម ១៤

ប្រការ ៨. ការឆ្លើយតបរបស់ភាគីឆ្លើយតប ១៧

ប្រការ ៩. ដំណើរការនីតិវិធីពន្លឿន ១៩

ជំពូកទី ៣

## មជ្ឈត្តករបន្ទាន់ ២២

ប្រការ ១០. សំណើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ ២២

ប្រការ ១១. កម្រៃសេវានៃការស្នើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ ២៣

ប្រការ ១២. ការទទួលយកដោយគណៈកម្មាធិការតែងតាំង និងនីតិវិធី ២៣

ប្រការ ១៣. ទីកន្លែងធ្វើមជ្ឈត្តការ ២៣

ប្រការ ១៤. ការបង្ហាញព័ត៌មាន ២៣

ប្រការ ១៥. មជ្ឈត្តករបន្ទាន់និងដំណើរការមជ្ឈត្តការបន្ទាប់មកទៀត ២៤
ប្រការ ១៦. កាលវិភាគសម្រាប់វិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ ២៤
ប្រការ ១៧. អំណាចរបស់មជ្ឈត្តករបន្ទាន់ ២៤
ប្រការ ១៨. ការចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យ ដោយមជ្ឈត្តករបន្ទាន់ ២៤
ប្រការ ១៩. អំណាចរបស់វេទិកាមជ្ឈត្តកម្ម ក្នុងការពិនិត្យដើម្បីកែប្រែ ផ្អាក ឬបញ្ឈប់សេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យចេញដោយមជ្ឈត្តករបន្ទាន់ ២៥
ប្រការ ២០. លក្ខខណ្ឌនៃការចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យ ២៥
ប្រការ ២១. អានុភាព និងការអនុវត្ត សេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យចេញដោយមជ្ឈត្តករបន្ទាន់ ២៥
ប្រការ ២២. ការកំណត់បែងចែកកម្រៃសេវា នៃការស្នើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ ២៦
ប្រការ ២៣. បទប្បញ្ញត្តិផ្សេងៗ ពាក់ព័ន្ធនឹងមជ្ឈត្តករបន្ទាន់ ២៦

ជំពូកទី ៤

## ការបង្កើតវេទិកាមជ្ឈត្តកម្ម ២៧

ប្រការ ២៤. ចំនួនមជ្ឈត្តករ ២៧
ប្រការ ២៥. ការតែងតាំងមជ្ឈត្តករ ២៧
ប្រការ ២៦. បុគ្គលដែលអាចត្រូវបានតែងតាំងជាមជ្ឈត្តករ ៣០
ប្រការ ២៧. ឯករាជភាព និងអព្យាក្រឹតភាពរបស់មជ្ឈត្តករ និងការប្រកាសបង្ហាញ ៣១
ប្រការ ២៨. ការជំទាស់ទៅនឹងមជ្ឈត្តករ ៣២
ប្រការ ២៩. ការខកខាន ឬអលទ្ធភាពក្នុងការបំពេញតួនាទី ៣៤
ប្រការ ៣០. ការដាក់មជ្ឈត្តករជំនួស ៣៥

ជំពូកទី ៥

## ដំណើរការមជ្ឈត្តការ ៣៧

ប្រការ ៣១. ទីកន្លែងធ្វើមជ្ឈត្តការ ៣៧
ប្រការ ៣២. ច្បាប់អនុវត្ត និងសមធម៌ ៣៧

ប្រការ ៣៣. ភាសា ៣៨
ប្រការ ៣៤. ទឡ្ហីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម ៣៨
ប្រការ ៣៥. បញ្ញត្តិទូទៅអំពីដំណើរការមជ្ឈត្តការ ៤០
ប្រការ ៣៦. ការរួមបញ្ចូលមជ្ឈត្តការ ៤១
ប្រការ ៣៧. ការដាក់សេចក្តីថ្លែងដោយគូភាគីវិវាទ ៤២
ប្រការ ៣៨. ការដកពាក្យបណ្តឹង ការកែប្រែ និងការដោះសា ៤៤
ប្រការ ៣៩. សវនាការ និងការប្រជុំ ៤៥
ប្រការ ៤០. បញ្ញត្តិទូទៅអំពីភស្តុតាង ៤៦
ប្រការ ៤១. សាក្សី ៤៧
ប្រការ ៤២. អ្នកជំនាញដែលតែងតាំងដោយវេទិកាមជ្ឈត្តកម្ម ៤៨
ប្រការ ៤៣. វិធានការបណ្តោះអាសន្ន ៤៩
ប្រការ ៤៤. ការបញ្ចប់ និងការបើកដំណើរការមជ្ឈត្តការជាថ្មី ៥១
ប្រការ ៤៥. ការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត ៥២
ប្រការ ៤៦. មូលហេតុផ្សេងទៀតសម្រាប់បញ្ចប់ដំណើរការមជ្ឈត្តការ ៥២

ជំពូកទី ៦

## ការសម្រេច និងមជ្ឈត្តវិនិច្ឆ័យ ៥៣

ប្រការ ៤៧. ការសម្រេច ៥៣
ប្រការ ៤៨. មជ្ឈត្តវិនិច្ឆ័យស្ថាពរ មជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន និង មជ្ឈត្តវិនិច្ឆ័យដោយផ្នែក ៥៣
ប្រការ ៤៩. ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ ៥៤
ប្រការ ៥០. ការពិនិត្យពិច័យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ ៥៤
ប្រការ ៥១. ការចេញមជ្ឈត្តវិនិច្ឆ័យ ៥៥
ប្រការ ៥២. អានុភាព និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ៥៥
ប្រការ ៥៣. ការកែតម្រូវ ការបំភ្លឺលម្អិត និងការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម ៥៦
ប្រការ ៥៤. ការរក្សាឯកសាររបស់សំណុំរឿងដោយអគ្គលេខាធិការដ្ឋាន ៥៧
ប្រការ ៥៥. អំណាចរបស់វេទិកាមជ្ឈត្តកម្ម ៥៧

ជំពូកទី ៧

## កម្រៃសេវា ៥៩


ប្រការ ៥៦. កម្រៃសេវាមជ្ឈត្តកម្ម ៥៩

ប្រការ ៥៧. កម្រៃសេវាចុះបញ្ជីសំណុំរឿង និងកម្រៃសេវាលើពាក្យសុំនានា ៦០

ប្រការ ៥៨. កម្រៃសេវារដ្ឋបាល ៦១

ប្រការ ៥៩. កម្រៃសេវាតែងតាំងមជ្ឈត្តករ ៦២

ប្រការ ៦០. កម្រៃសេវាវេទិកាមជ្ឈត្តកម្ម ៦២

ប្រការ ៦១. កម្រៃសេវានានា សម្រាប់នីតិវិធីមជ្ឈត្តករបន្ទាន់ ៦៤

ប្រការ ៦២. ការចំណាយផ្សេងៗ របស់មជ្ឈត្តករបន្ទាន់ វេទិកាមជ្ឈត្តកម្ម និង ម.ជ.ម. ៦៤

ប្រការ ៦៣. សោហ៊ុយចំណាយលើសេវាផ្នែកច្បាប់ និងការចំណាយផ្សេងៗ របស់ភាគីវិវាទ ៦៥

ប្រការ ៦៤. ប្រាក់បង់ជាមុន ៦៥

ប្រការ ៦៥. កម្រៃសេវាមជ្ឈត្តកម្មដំណើរការក្រោមវិធានផ្សេង ក្រៅពីវិធានស្តីពីមជ្ឈត្តការ ម.ជ.ម. ៦៧


ជំពូកទី ៨

## បទប្បញ្ញត្តិផ្សេងៗ ៦៨


ប្រការ ៦៦. ការសម្ងាត់ ៦៨

ប្រការ ៦៧. ការផ្សព្វផ្សាយមជ្ឈត្តវិនិច្ឆ័យ ៦៩

ប្រការ ៦៨. ការបោះបង់សិទ្ធិ ៦៩

ប្រការ ៦៩. ជម្រើសរវាងតុលាការ និង ម.ជ.ម. ៧០

ប្រការ ៧០. ករណីដែលមិនមានចែងច្បាស់លាស់ក្នុងវិធាន ៧០

ប្រការ ៧១. ការមិនទទួលខុសត្រូវ ៧០

ប្រការ ៧២. វិសោធនកម្មទៅលើវិធាន ៧១

ប្រការ ៧៣. សេចក្តីណែនាំសម្រាប់អនុវត្ត ៧១

ជំពូកទី ៩
**អវសានប្បញ្ញត្តិ** ៧២

ប្រការ ៧៤. អវសានប្បញ្ញត្តិ ៧២

ឧបសម្ព័ន្ធ ១
**តារាងកម្រៃសេវារបស់ ម.ជ.ម.** ៧៣

ឧបសម្ព័ន្ធ ២
**គំរូខចែងរបស់ ម.ជ.ម.** ៧៩

ជំពូកទី ១

# វិធានទូទៅ

## ប្រការ ១. និយមន័យ

វាក្យស័ព្ទខាងក្រោម ដែលប្រើក្នុងវិធានស្តីពីមជ្ឈត្តការនេះ ត្រូវមានអត្ថន័យដូចបានកំណត់ខាងក្រោម៖

**គណៈកម្មាធិការតែងតាំង និងនីតិវិធី** គឺគណៈកម្មាធិការមួយរបស់ ម.ជ.ម. ដែលមានអំណាចក្នុងការតែងតាំងមជ្ឈត្តករ និងបំពេញកិច្ចការផ្សេងទៀតស្របតាមវិធាននេះ។

**មជ្ឈត្តករបន្ទាន់** គឺមជ្ឈត្តករដែលតែងតាំងស្របតាមប្រការ ១២ នៃវិធាននេះ (*ការទទួលយកដោយគណៈកម្មាធិការតែងតាំង និងនីតិវិធី*)។

**អគ្គលេខាធិការដ្ឋាន** គឺអគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម.។

**ម.ជ.ម.** គឺមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

**វិធាន** គឺវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលត្រូវបានអនុម័តនាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។

**វេទិកាមជ្ឈត្តកម្ម** គឺវេទិកាមជ្ឈត្តកម្ម ដែលត្រូវបានបង្កើតឡើងដោយមានមជ្ឈត្តករមួយរូប ឬច្រើនរូប។

## ប្រការ ២. វិសាលភាពអនុវត្ត

### ២.១. ការអនុវត្តវិធាននេះ ការអនុវត្តវិធានដទៃ និងសេវាផ្សេងៗ

(ក) វិធាននេះត្រូវអនុវត្ត ប្រសិនបើភាគីវិវាទបានព្រមព្រៀងដាក់វិវាទរបស់ខ្លួនឱ្យដោះស្រាយតាមរយៈមជ្ឈត្តកម្មចាត់ចែងដោយ ម.ជ.ម. ឬតាមរយៈមជ្ឈត្តកម្មក្រោមវិធានរបស់ ម.ជ.ម. ឬប្រសិនបើពាក្យពេចន៍ក្នុងការព្រមព្រៀងនោះមានអត្ថន័យដូចគ្នា។

(ខ) ប្រការ ២.១(ក) មិនត្រូវបានយកមកអនុវត្ត ប្រសិនបើ៖

(i) គណៈកម្មាធិការតែងតាំង និងនីតិវិធី សម្រេចទទួលចាត់ចែងធ្វើមជ្ឈត្តការលើសំណុំរឿងក្រោមវិធានផ្សេងក្រៅពីវិធាននេះ ក្នុងករណីដែលមានការព្រមព្រៀងរបស់គូភាគីវិវាទ ឬ

(ii) គូភាគីវិវាទនៃកិច្ចសន្យាមជ្ឈត្តកម្មជ្រើសរើសយក ម.ជ.ម. ជាស្ថាប័នមានសមត្ថកិច្ចតែងតាំងមជ្ឈត្តករ ឬធ្វើការស្នើសុំសេវាផ្សេងៗពី ម.ជ.ម. ដោយមិនតម្រូវឱ្យមជ្ឈត្តការនោះអនុវត្តតាមបញ្ញត្តិដែលមានចែងក្រោមវិធាននេះឡើយ។

(គ) ប្រសិនបើប្រការ ២.១(ខ) ត្រូវបានអនុវត្ត គូភាគីវិវាទត្រូវបានចាត់ទុកថាបានព្រមព្រៀងទៅលើវិធានការចាំបាច់ទាំងអស់ ដែលអាចនឹងត្រូវធ្វើឡើងដោយ ម.ជ.ម. ដើម្បីធានាភាពត្រូវគ្នារវាងវិធានដែលគូភាគីវិវាទបានព្រមព្រៀងទៅនឹងរចនាសម្ព័ន្ធរបស់ ម.ជ.ម.។

### ២.២. កាលបរិច្ឆេទចូលជាធរមាន

វិធាននេះត្រូវមានសុពលភាពចូលជាធរមាននៅកាលបរិច្ឆេទដូចមានកំណត់ក្នុងប្រការ ៧៤.២។ លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វិធាននេះត្រូវយកមកអនុវត្តចំពោះមជ្ឈត្តកម្មទាំងឡាយណា ដែលស្ថិតក្រោមប្រការ ២.១(ក) ដែលអគ្គលេខាធិការដ្ឋានបានទទួលសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មនៅកាលបរិច្ឆេទចូលជាធរមាននេះ ឬនៅថ្ងៃបន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននេះ។

### ២.៣. ភាពផ្ទុយគ្នានៃវិធានស្ដីពីមជ្ឈត្តការនឹងច្បាប់គ្រប់គ្រងមជ្ឈត្តកម្ម

ប្រសិនបើប្រការណាមួយនៃវិធាននេះផ្ទុយនឹងបទប្បញ្ញត្តិដែលមានអានុភាពចាប់បង្ខំណាមួយរបស់ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា (ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាគឺជាទីកន្លែងធ្វើមជ្ឈត្តការ) ឬបទប្បញ្ញត្តិដែលមានអានុភាពចាប់បង្ខំណាមួយរបស់ច្បាប់ផ្សេងទៀតដែលគ្រប់គ្រងមជ្ឈត្តកម្ម (ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាមិនមែនជាទីកន្លែងធ្វើមជ្ឈត្តការ) បទប្បញ្ញត្តិនោះត្រូវមានឧត្តមានុភាព។

### ២.៤. បដិប្បញ្ញត្តិនឹងវិធាននេះ

ប្រសិនបើគូភាគីវិវាទបានព្រមព្រៀងគ្នា គូភាគីវិវាទអាចធ្វើបដិប្បញ្ញត្តិលើបទប្បញ្ញត្តិទាំងឡាយនៃវិធាននេះ ដែលត្រូវបានអនុញ្ញាតឱ្យធ្វើបានក្រោមវិធាននេះ។

## ប្រការ ៣. ការតំណាង

នៅក្នុងដំណើរការមជ្ឈត្តការនានាក្រោមវិធាននេះ ភាគីវិវាទនីមួយៗអាចត្រូវបានតំណាងដោយបុគ្គលណាម្នាក់តាមការជ្រើសរើសរបស់ខ្លួន ដោយមានភស្តុតាងបង្ហាញអំពីសិទ្ធិតំណាងនេះ ដែលអាចតម្រូវដោយអគ្គលេខាធិការដ្ឋាន ឬវេទិកាមជ្ឈត្តកម្ម។

ក្រោយពីវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើតឡើង និងបន្ទាប់ពីបានផ្តល់ឱកាសឱ្យគូភាគីវិវាទផ្តល់យោបល់ជាលាយលក្ខណ៍អក្សរក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន វេទិកាមជ្ឈត្តកម្មអាចចាត់វិធានការដែលចាំបាច់នានា រួមបញ្ចូលទាំងការបដិសេធអ្នកតំណាងថ្មីរបស់ភាគីវិវាទក្នុងការចូលរួមក្នុងដំណើរការមជ្ឈត្តការទាំងស្រុង ឬដោយផ្នែក ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍របស់មជ្ឈត្តករ ដែលកើតមានឡើងពីការប្តូរ ឬបន្ថែមអ្នកតំណាងថ្មី។

## ប្រការ ៤. ការទាក់ទង និងសំណៅចម្លងក្នុងពេលដំណាលគ្នា

### ៤.១. ការទាក់ទងជាលាយលក្ខណ៍អក្សរ

សម្រាប់គោលបំណងនៃវិធាននេះ ការទាក់ទងណាមួយ (រួមបញ្ចូលទាំងសេចក្តីជូនដំណឹង ការផ្តល់ដំណឹង សេចក្តីថ្លែង សំណូមពរ សំណើ ការដាក់ឯកសារ សេចក្តីបង្គាប់ ឬសេចក្តីណែនាំ) ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ លើកលែងតែការទាក់ទងដោយផ្ទាល់មាត់នៅពេលសវនាការ និងនៅក្នុងកិច្ចប្រជុំនានាដែលរៀបចំឡើងដោយវេទិកាមជ្ឈត្តកម្ម។

### ៤.២. មធ្យោបាយនៃការទាក់ទង

ការទាក់ទងជាលាយលក្ខណ៍អក្សរ អាចត្រូវបានធ្វើឡើងតាមរយៈការប្រគល់ដោយផ្ទាល់ដៃ ប្រៃសណីយ៍អនុសិដ្ឋិ ការបញ្ជូន ទូរសារ សារអេឡិចត្រូនិច ឬមធ្យោបាយទាក់ទងផ្សេងទៀត ដែលមានកំណត់ត្រានៃការប្រគល់ទាំងនោះ។

### ៤.៣. ការបញ្ជូន និងការទទួល

ការទាក់ទងនឹងត្រូវចាត់ទុកថាបានទទួល ប្រសិនបើការទាក់ទងនោះត្រូវបានប្រគល់ទៅអ្នកទទួល ឬទៅអ្នកតំណាងរបស់អ្នកទទួល៖

(ក) ដោយផ្ទាល់ដៃ ឬនៅអាសយដ្ឋានដែលបានកំណត់

(ខ) នៅលំនៅឋាន ឬទីកន្លែងអាជីវកម្មបច្ចុប្បន្ន ឬអាសយដ្ឋានប្រៃសណីយ៍របស់អ្នកទទួលក្នុងករណីមិនអាចប្រគល់បានតាមចំណុច (ក) ខាងលើ

(គ) ប្រសិនបើតាមមធ្យោបាយអេឡិចត្រូនិច តាមរយៈអាសយដ្ឋានសារអេឡិចត្រូនិច ឬលេខទូរសារ ឬអាសយដ្ឋាននៃមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀត ដែលត្រូវបានកំណត់ ឬ

(ឃ) នៅលំនៅឋាន ឬទីកន្លែងអាជីវកម្ម ឬអាសយដ្ឋានប្រៃសណីយ៍ ឬអាសយដ្ឋាននៃមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀត ដែលបានស្គាល់ចុងក្រោយ ប្រសិនបើមិនអាចធ្វើបានតាមចំណុច (ក) ដល់ចំណុច (គ) បន្ទាប់ពីមានការស៊ើបសួរសមហេតុផលរួចហើយ។

ការទាក់ទងត្រូវចាត់ទុកថាបានទទួលនៅកាលបរិច្ឆេទដែលការទាក់ទងនោះត្រូវបានប្រគល់។ សម្រាប់គោលបំណងនេះ កាលបរិច្ឆេទត្រូវកំណត់ស្របតាមពេលវេលាក្នុងតំបន់នៃទីកន្លែងដែលទទួលបានការទាក់ទង។

## ៤.៤. *សំណៅចម្លងក្នុងពេលដំណាលគ្នា*

នៅពេលភាគីវិវាទណាមួយបញ្ជូនការទាក់ទង (ដែលរួមមានជាអាទិ៍ សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម សេចក្តីជូនដំណឹងអំពីការឆ្លើយតប សំណើសុំមជ្ឈត្តករបន្ទាន់ សំណើសុំនីតិវិធីពន្លឿន និងរាល់សំណើសុំ ការដាក់ឯកសារ សេចក្តីថ្លែងសំណូមពរ ការបដិសេធគ្រប់ប្រភេទ) ទៅ៖

(ក) អគ្គលេខាធិការដ្ឋាន៖ ភាគីវិវាទនោះត្រូវ ក្នុងពេលដំណាលគ្នា បញ្ជូនសំណៅចម្លងនោះមួយច្បាប់ទៅភាគីវិវាទម្ខាងទៀត និងទៅវេទិកាមជ្ឈត្តកម្ម ប្រសិនបើវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើតរួចហើយ។

(ខ) វេទិកាមជ្ឈត្តកម្ម៖ ភាគីវិវាទនោះត្រូវ ក្នុងពេលដំណាលគ្នា បញ្ជូនសំណៅចម្លងនោះមួយច្បាប់ទៅភាគីវិវាទម្ខាងទៀត និងទៅអគ្គលេខាធិការដ្ឋាន។

ប្រសិនបើមានសំណើរបស់អគ្គលេខាធិការដ្ឋាន ឬវេទិកាមជ្ឈត្តកម្ម ភាគីវិវាទត្រូវបង្ហាញថាខ្លួនបានគោរពតាមការតម្រូវនៃកថាខណ្ឌទី១ នៃប្រការ ៤.៤ *(សំណៅចម្លងក្នុងពេលដំណាលគ្នា)* នេះ។

ក្នុងករណីដែលវេទិកាមជ្ឈត្តកម្មមានមជ្ឈត្តករច្រើនរូប ការទាក់ទងដែលបញ្ជូនទៅវេទិកាមជ្ឈត្តកម្ម ត្រូវបញ្ជូនទៅមជ្ឈត្តករនីមួយៗ។

នៅពេលដែលវេទិកាមជ្ឈត្តកម្មបញ្ជូនការទាក់ទងទៅភាគីវិវាទណាមួយ វេទិកាមជ្ឈត្តកម្មក្នុងពេលដំណាលគ្នា ត្រូវបញ្ជូនការទាក់ទងនោះមួយច្បាប់ទៅភាគីវិវាទម្ខាងទៀត និងទៅអគ្គលេខាធិការដ្ឋាន។

## ៤.៥. *ហាមមិនឱ្យមានការទាក់ទងដោយគ្មានភាគីវិវាទម្ខាងទៀត*

គ្មានភាគីវិវាទណាមួយ ឬបុគ្គលណាម្នាក់ក្នុងនាមភាគីវិវាទនោះ អាចធ្វើការទាក់ទងដោយគ្មានភាគីវិវាទម្ខាងទៀតពាក់ព័ន្ធនឹងសំណុំរឿងជាមួយនឹងមជ្ឈត្តករ ឬបេក្ខជនណាម្នាក់សម្រាប់តែងតាំងជាមជ្ឈត្តករដោយភាគីវិវាទឡើយ លើកលែងតែការទាក់ទងនោះជា៖

(ក) ការផ្ដល់ព័ត៌មានដល់មជ្ឈត្តករ ឬបេក្ខជន អំពីលក្ខណៈទូទៅនៃវិវាទ និងអំពីដំណើរការមជ្ឈត្តការដែលអាចកើតមាន

(ខ) ការពិភាក្សាអំពីលក្ខណសម្បត្តិ កាលវិភាគ ឬឯករាជភាព របស់មជ្ឈត្តករ ឬបេក្ខជន ឬ

(គ) ការពិភាក្សាអំពីភាពសមស្របនៃមជ្ឈត្តករ ឬបេក្ខជនសម្រាប់ការជ្រើសរើសជាប្រធានវេទិកាមជ្ឈត្តកម្ម ដែលគូភាគីវិវាទ ឬមជ្ឈត្តករដែលតែងតាំងដោយភាគីវិវាទ ត្រូវចូលរួមក្នុងការជ្រើសរើសនោះ។

គ្មានភាគីវិវាទណាមួយ ឬបុគ្គលណាម្នាក់ក្នុងនាមភាគីវិវាទ អាចធ្វើការទាក់ទងដោយគ្មានភាគីវិវាទម្ខាងទៀតពាក់ព័ន្ធនឹងសំណុំរឿងជាមួយនឹងបេក្ខជនណាម្នាក់ដែលជាបេក្ខជនសម្រាប់ការជ្រើសរើសជាប្រធានវេទិកាមជ្ឈត្តកម្មឡើយ។

## ប្រការ ៥. ការកំណត់ពេលវេលា

### *៥.១. ការគណនាអំឡុងពេល*

សម្រាប់គោលបំណងនៃការគណនាអំឡុងពេលក្រោមវិធាននេះ អំឡុងពេលត្រូវចាប់ផ្ដើមគិតពីថ្ងៃបន្ទាប់ ដែលការទាក់ទងណាមួយត្រូវបានទទួលស្របតាមប្រការ ៤ *(ការទាក់ទង និងសំណៅចម្លងក្នុងពេលដំណាលគ្នា)* ឬថ្ងៃបន្ទាប់ដែលសកម្មភាព ឬព្រឹត្តិការណ៍នោះចាប់ផ្ដើមអំឡុងពេលនោះ និងត្រូវរាប់បញ្ចូលរយៈពេលពេញនៃថ្ងៃចុងក្រោយនៃអំឡុងពេលនោះ។

លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គលេខាធិការដ្ឋាន ឬវេទិកាមជ្ឈត្តកម្ម ពាក្យ "ថ្ងៃ" ឬ "កាលបរិច្ឆេទ" សំដៅលើអំឡុងពេលដែលស្ថិតក្នុងចន្លោះម៉ោង ០៨:០០ ព្រឹក និងម៉ោង ០៥:០០ ល្ងាច នៃល្វែងម៉ោងប្រទេសកម្ពុជា (GMT+7)។ ពេលវេលាក្រោយពីម៉ោង ៥:០០ ល្ងាច ត្រូវចាត់ទុកជាពេលវេលានៃថ្ងៃបន្ទាប់ ឬកាលបរិច្ឆេទបន្ទាប់។

ប្រសិនបើថ្ងៃចុងក្រោយនៃអំឡុងពេលនោះមិនមែនជាថ្ងៃធ្វើការសម្រាប់ទីកន្លែងដែលទទួលការទាក់ទងទេ អំឡុងពេលនោះនឹងត្រូវពន្យារហូតដល់ថ្ងៃធ្វើការទីមួយបន្ទាប់ពីថ្ងៃមិនធ្វើការនោះ។ ដើម្បីជៀសវាងការភ័ន្តច្រឡំ ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាករបស់ស្ថាប័នសាធារណៈ តាមការកំណត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកជាថ្ងៃមិនធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ៥.២. *ការកែប្រែពេលវេលាកំណត់*

(ក) ប្រសិនបើកាលៈទេសៈតម្រូវ និងតាមរយៈការជូនដំណឹងដល់គូភាគីវិវាទ អគ្គលេខាធិការដ្ឋានអាចកែប្រែ៖

(i) ពេលវេលាកំណត់ ដូចមានចែងក្នុងជំពូកទី ២ *(ការចាប់ផ្តើមមជ្ឈត្តកម្ម)* ជំពូកទី ៤ *(ការបង្កើតវេទិកាមជ្ឈត្តកម្ម)* ជំពូកទី ៧ *(កម្រៃសេវា)* និង ជំពូកទី ៨ *(បទប្បញ្ញត្តិផ្សេងៗ)* បាន និង

(ii) ពេលវេលាកំណត់ណាមួយ ដែលអគ្គលេខាធិការដ្ឋានមានអំណាច ឬ ត្រូវបានផ្តល់អំណាចក្នុងការកំណត់។

(ខ) ប្រសិនបើកាលៈទេសៈតម្រូវ និងតាមរយៈការជូនដំណឹងដល់គូភាគីវិវាទ វេទិកាមជ្ឈត្តកម្មអាចកែប្រែ៖

(i) ពេលវេលាកំណត់ ដូចមានចែងក្នុងជំពូកទី ៥ *(ដំណើរការមជ្ឈត្តការ)*

(ii) ពេលវេលាកំណត់ក្នុងប្រការ ៥៣.២ *(សេចក្តីសម្រេចលើការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ មជ្ឈត្តវិនិច្ឆ័យបន្ថែម)* និង

(iii) ពេលវេលាកំណត់ណាមួយ ដែលវេទិកាមជ្ឈត្តកម្មបានកំណត់។

(គ) គូភាគីវិវាទអាចព្រមព្រៀងបន្ថយពេលវេលាកំណត់ណាមួយ ដែលមានចែងក្នុងវិធាននេះបាន។ រាល់ការព្រមព្រៀងដែលធ្វើឡើងក្រោយពេលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើតឡើងត្រូវចាត់ទុកថាមានអានុភាពបាន លុះត្រាតែមានការឯកភាពពីវេទិកាមជ្ឈត្តកម្ម។

## ប្រការ ៦. ដំណើរការមជ្ឈត្តការដោយយុត្តិធម៌ ឆាប់រហ័ស មានប្រសិទ្ធភាព និងដោយមិនបង្អង់

វេទិកាមជ្ឈត្តកម្ម និងគូភាគីវិវាទ ត្រូវខិតខំប្រឹងប្រែងក្នុងការធ្វើឱ្យដំណើរការមជ្ឈត្តការប្រព្រឹត្តទៅដោយយុត្តិធម៌ ឆាប់រហ័ស មានប្រសិទ្ធភាព ចំណាយអស់តិច និងមិនត្រូវបង្កឱ្យមានការពន្យារពេលដែលមិនចាំបាច់ណាមួយឡើយ។

ជំពូកទី ២

# ការចាប់ផ្ដើមមជ្ឈត្តកម្ម

## ប្រការ ៧. ការចាប់ផ្ដើមមជ្ឈត្តកម្ម

### *៧.១. សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម*

ភាគីវិវាទ ដែលមានបំណងដាក់វិវាទរបស់ខ្លួនឱ្យដោះស្រាយតាមរយៈមជ្ឈត្តកម្ម ("**ភាគីប្ដឹងទាមទារ**") ទាមទារចំពោះគូភាគីវិវាទម្ខាងទៀត ("**ភាគីឆ្លើយតប**") ត្រូវបញ្ជូនទៅអគ្គលេខាធិការដ្ឋាន នូវសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម ដែលត្រូវមានព័ត៌មានដូចខាងក្រោម៖

(ក) សេចក្ដីថ្លែងដែលបញ្ជាក់ថា វិវាទត្រូវបានដាក់ឱ្យដោះស្រាយតាមមជ្ឈត្តកម្ម

(ខ) ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ លេខទូរសារ អាសយដ្ឋានសារអេឡិចត្រូនិច និងអាសយដ្ឋាននៃមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀត ប្រសិនបើមានព័ត៌មានទាំងនេះរបស់គូភាគីវិវាទ និងរបស់អ្នកតំណាងរបស់គូភាគីវិវាទ ប្រសិនបើមាន

(គ) សញ្ជាតិ ឬប្រសិនបើតម្រូវ ព័ត៌មានអំពីអត្តសញ្ញាណក្រុមហ៊ុនរបស់គូភាគីវិវាទ ប្រសិនបើស្គាល់

(ឃ) សេចក្ដីយោងនៃខចែងស្ដីពីមជ្ឈត្តកម្ម ឬកិច្ចសន្យាមជ្ឈត្តកម្មដោយឡែកដែលយកមកប្រើ និងភ្ជាប់សំណៅចម្លងនៃខចែងស្ដីពីមជ្ឈត្តកម្ម ឬកិច្ចសន្យាមជ្ឈត្តកម្មដោយឡែកនោះ

(ង) សេចក្ដីយោងនៃកិច្ចសន្យា ឬទំនាក់ទំនងផ្សេងៗដែលកើតចេញពី ឬដែលទាក់ទងនឹងវិវាទ និងភ្ជាប់សំណៅចម្លងនៃកិច្ចសន្យាទាំងនោះ ប្រសិនបើអាច

(ច) សេចក្តីថ្លែងសង្ខេប ដែលពិពណ៌នាអំពីលក្ខណៈ និងកាលៈទេសៈនៃវិវាទ ការទាមទារ ឬការសង្គ្រោះដែលទាមទារ និងប្រសិនបើអាច ភ្ជាប់តម្លៃបឋម នៃការទាមទារ ដែលភាគីប្តឹងទាមទារមានបំណងដាក់ស្នើ

(ឆ) ចំនួនមជ្ឈត្តករដែលបានព្រមព្រៀង ឬនៅក្នុងករណីដែលមិនមានការព្រមព្រៀងទេនោះ ចំនួនមជ្ឈត្តករដែលស្នើសុំដែលត្រូវមានចំនួន ១ (មួយ) រូប ឬ ៣ (បី) រូប និង

(ជ) សេចក្តីថ្លែង ឬសំណើបន្ថែមផ្សេងៗ ពាក់ព័ន្ធនឹងដំណើរការមជ្ឈត្តការ រួមបញ្ចូលទាំងច្បាប់ដែលត្រូវអនុវត្ត ភាសាសម្រាប់ដំណើរការមជ្ឈត្តការ និងលក្ខណសម្បត្តិនិងសញ្ជាតិរបស់មជ្ឈត្តករដែលបានព្រមព្រៀង ឬដែលចង់បាន ប្រសិនបើមាន។

ដោយមិនគិតអំពីភាសាដែលត្រូវប្រើក្នុងដំណើរការមជ្ឈត្តការ ស្របតាមប្រការ ៣៣.១ *(ភាសានៃដំណើរការមជ្ឈត្តការ)* សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មត្រូវធ្វើជាភាសាសម្រាប់មជ្ឈត្តកម្ម និងបកប្រែជាភាសាខ្មែរ ឬភាសាអង់គ្លេស។

សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មត្រូវមានភ្ជាប់មកជាមួយនូវការបង់ប្រាក់សម្រាប់កម្រៃសេវាចុះបញ្ជីសំណុំរឿងដែលអាចជា មូលប្បទានបត្រ ឬការផ្ទេរចូលគណនីធនាគារកំណត់ណាមួយរបស់ ម.ជ.ម.។

## *៧.២. ការភ្ជាប់សំណើសុំដំណើរការនីតិវិធីពន្លឿន*

សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម អាចត្រូវបានភ្ជាប់មកជាមួយនូវសំណើសុំដំណើរការនីតិវិធីពន្លឿនដូចមានកំណត់ក្នុងប្រការ ៩ *(ដំណើរការនីតិវិធីពន្លឿន)*។

## *៧.៣. ការរួមបញ្ចូលការតែងតាំងមជ្ឈត្តករក្នុងសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម*

សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម អាចត្រូវរួមបញ្ចូលផងដែរនូវ៖

(ក) សម្រាប់ករណីវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ៣ (បី) រូប ឬច្រើនរូប៖ ការតែងតាំងមជ្ឈត្តករត្រូវធ្វើឡើងស្របតាមប្រការ ២៥ *(ការតែងតាំងមជ្ឈត្តករ)* និងប្រការ ២៦ *(បុគ្គលដែលអាចត្រូវបានតែងតាំងជាមជ្ឈត្តករ)*

(ខ) សម្រាប់ករណីវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករមួយរូប៖ ការតែងតាំងមជ្ឈត្តកររួមគ្នា ប្រសិនបើគូភាគីវិវាទបានព្រមព្រៀងគ្នារួចហើយ ឬប្រសិនបើគូភាគីវិវាទមិនទាន់បានព្រមព្រៀងគ្នានៅឡើយ សំណើតែងតាំងមជ្ឈត្តកររបស់ភាគីប្តឹងទាមទារស្របតាមប្រការ ២៥ *(ការតែងតាំងមជ្ឈត្តករ)* និងប្រការ ២៦ *(បុគ្គលដែលអាចត្រូវបានតែងតាំងជាមជ្ឈត្តករ)* ឬ

(គ) សេចក្តីថ្លែងដែលបញ្ជាក់ថាភាគីប្តឹងទាមទារផ្តល់សមត្ថកិច្ចឱ្យ ម.ជ.ម. ក្នុងការតែងតាំងមជ្ឈត្តករមួយរូប។

### ៧.៤. *ការភ្ជាប់សេចក្ដីថ្លែងទាមទារ*

សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម អាចត្រូវបានភ្ជាប់មកជាមួយនូវសេចក្ដីថ្លែងទាមទារដូចមានកំណត់ក្នុងប្រការ ៣៧.២ *(សេចក្ដីថ្លែងទាមទារ)* និងឯកសារគាំទ្រផ្សេងៗទៀត។

### ៧.៥. *ភាពមិនពេញលេញនៃសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម*

ប្រសិនបើសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មមានលក្ខណៈមិនពេញលេញ អគ្គលេខាធិការដ្ឋានអាចស្នើសុំភាគីប្ដឹងទាមទារឱ្យបំពេញបន្ថែមចំណុចខ្វះខាតទាំងនោះក្នុងអំឡុងពេលសមស្របណាមួយដែលកំណត់ដោយអគ្គលេខាធិការដ្ឋាន។ ដើម្បីជៀសវាងការភ័ន្តច្រឡំ សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មត្រូវចាត់ទុកថាពេញលេញនៅពេលដែលចំណុចទាំងអស់ដែលតម្រូវក្នុងប្រការ ៧.១ *(សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម)* ត្រូវបានបំពេញ រួមបញ្ចូលទាំងការបង់កម្រៃសេវាចុះបញ្ជី។

ប្រសិនបើភាគីប្ដឹងទាមទារបានគោរពតាមការស្នើសុំខាងលើតាមពេលវេលា ដែលត្រូវអនុវត្ត ឬដែលត្រូវបានកំណត់ សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មនោះនឹងត្រូវបានចាត់ទុកថាបានដាក់នៅក្នុងថ្ងៃដែលអគ្គលេខាធិការដ្ឋានបានទទួលសំណៅដំបូងនៃសេចក្ដីជូនដំណឹងនោះ។

### ៧.៦. *ការខកខានមិនបានដាក់សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញ*

ប្រសិនបើភាគីប្ដឹងទាមទារខកខានមិនបានដាក់សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញ អគ្គលេខាធិការដ្ឋានត្រូវបិទសំណុំរឿងនោះ ដោយមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីប្ដឹងទាមទារក្នុងការដាក់ពាក្យបណ្ដឹងទាមទារដដែលនាថ្ងៃក្រោយ តាមរយៈសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មផ្សេងឡើយ។

### ៧.៧. *ការជូនដំណឹងអំពីការទទួលបានសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម*

អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅគូភាគីវិវាទនៅពេលដែលអគ្គលេខាធិការដ្ឋានបានទទួលសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញ។

### ៧.៨. *ការចាប់ផ្ដើមដំណើរការមជ្ឈត្តការ*

លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ដំណើរការមជ្ឈត្តការដែលទាក់ទងនឹងវិវាទណាមួយត្រូវបានចាត់ទុកថាចាប់ផ្ដើមនៅកាលបរិច្ឆេទបន្ទាប់ពីសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញ ត្រូវបានទទួលដោយអគ្គលេខាធិការដ្ឋាន។ ដើម្បីជៀសវាងការភ័ន្តច្រឡំ សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម ត្រូវបានចាត់ទុកថាពេញលេញ នៅពេលការតម្រូវទាំងអស់ដូចមានចែងក្នុងប្រការ ៧.១ *(សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម)* ត្រូវបានបំពេញ ឬនៅពេលដែលអគ្គលេខាធិការដ្ឋានកំណត់ថាការតម្រូវសំខាន់ៗ នៃបញ្ញត្តិនេះត្រូវបានបំពេញ។

## ប្រការ ៨. ការឆ្លើយតបរបស់ភាគីឆ្លើយតប

### *៨.១. សេចក្តីជូនដំណឹងអំពីការឆ្លើយតប*

ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹង ដូចមានកំណត់ក្នុងប្រការ ៧.៧ *(ការជូនដំណឹងអំពីការទទួលបានសេចក្តីជូនដំណឹងអំពីមជ្ឍត្តកម្ម)* ភាគីឆ្លើយតប ត្រូវបញ្ជូនទៅអគ្គលេខាធិការដ្ឋាននូវសេចក្តីជូនដំណឹងអំពីការឆ្លើយតប ដែលត្រូវមានព័ត៌មានដូចខាងក្រោម៖

(ក) ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ លេខទូរសារ អាសយដ្ឋានសារអេឡិចត្រូនិច និងអាសយដ្ឋាននៃមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀតរបស់ភាគីឆ្លើយតប និងអ្នកតំណាងរបស់ខ្លួន ប្រសិនបើមាន និងប្រសិនបើព័ត៌មានទាំងនេះខុសពីព័ត៌មាន ដែលមានក្នុងសេចក្តីជូនដំណឹងអំពីមជ្ឍត្តកម្ម

(ខ) សញ្ជាតិ ឬប្រសិនបើតម្រូវ អត្តសញ្ញាណក្រុមហ៊ុនរបស់គូភាគីវិវាទ ប្រសិនបើមាន និងប្រសិនបើព័ត៌មានទាំងនេះខុសពីព័ត៌មានដែលមានក្នុងសេចក្តីជូនដំណឹងអំពីមជ្ឍត្តកម្ម

(គ) ការបញ្ជាក់សង្ខេបអំពីការទទួលយក ឬការបដិសេធចំពោះការទាមទារទាំងស្រុង ឬដោយផ្នែក

(ឃ) សេចក្តីថ្លែងសង្ខេប ដែលពិពណ៌នាអំពីលក្ខណៈ និងកាលៈទេសៈនៃបណ្តឹងតប ឬការដោះសាតាមការកាត់កង ដែលភាគីឆ្លើយតបមានបំណងបញ្ជូន និងប្រសិនបើអាច ត្រូវភ្ជាប់តម្លៃបឋមនៃបណ្តឹងតប ឬការដោះសាតាមការកាត់កងនោះ

(ង) ចំនួនមជ្ឍត្តករដែលបានព្រមព្រៀង ឬនៅក្នុងករណីដែលមិនមានការព្រមព្រៀងទេនោះ ចំនួនមជ្ឍត្តករដែលបានស្នើដែលត្រូវមានចំនួន ១ (មួយ) រូប ឬ ៣ (បី) រូប និង

(ច) ប្រសិនបើមាន សេចក្តីថ្លែងការណ៍ ឬសំណើបន្ថែមផ្សេងៗ ដែលពាក់ព័ន្ធនឹងដំណើរការមជ្ឍត្តការ រួមបញ្ចូលទាំងច្បាប់ដែលត្រូវអនុវត្ត ភាសាសម្រាប់ដំណើរការមជ្ឍត្តការ និងលក្ខណសម្បត្តិនិងសញ្ជាតិរបស់មជ្ឍត្តករ ដែលបានតម្រូវ ឬដែលជាការឆ្លើយតបចំពោះសេចក្តីថ្លែង ឬសំណើនានា ដែលមានក្នុងសេចក្តីជូនដំណឹងអំពីមជ្ឍត្តកម្ម។

ដោយមិនគិតអំពីភាសាដែលត្រូវប្រើក្នុងដំណើរការមជ្ឍត្តការ ស្របតាមប្រការ ៣៣.១ *(ភាសានៃដំណើរការមជ្ឍត្តការ)* សេចក្តីជូនដំណឹងអំពីការឆ្លើយតបត្រូវធ្វើជាភាសានៃមជ្ឍត្តកម្ម និងត្រូវបកប្រែជាភាសាខ្មែរ ឬភាសាអង់គ្លេស។

## ៨.២. *ការភ្ជាប់សំណើសុំដំណើរការនីតិវិធីពន្លឿន*

ប្រសិនបើភាគីប្ដឹងទាមទារមិនទាន់បានដាក់សំណើសុំដំណើរការនីតិវិធីពន្លឿន ស្របតាមប្រការ ៧.២ *(ការភ្ជាប់សំណើសុំដំណើរការនីតិវិធីពន្លឿន)* ទេ ភាគីឆ្លើយតបអាចដាក់សំណើសុំដំណើរការនីតិវិធីពន្លឿន ដូចមានចែងក្នុងប្រការ ៩ *(ដំណើរការនីតិវិធីពន្លឿន)* ដោយភ្ជាប់សំណើនោះ មកជាមួយសេចក្ដីជូនដំណឹងអំពីការឆ្លើយតប។

ប្រសិនបើភាគីប្ដឹងទាមទារបានដាក់សំណើសុំដំណើរការនីតិវិធីពន្លឿន ភាគីឆ្លើយតបអាចធ្វើការផ្ដល់យោបល់លើសំណើនោះ ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិនបន្ទាប់ពីបានទទួលសំណើសុំនេះ។

## ៨.៣. *ការបញ្ចូលការតែងតាំងមជ្ឈត្តករក្នុងសេចក្ដីជូនដំណឹងអំពីការឆ្លើយតប*

សេចក្ដីជូនដំណឹងអំពីការឆ្លើយតបអាចត្រូវរួមបញ្ចូលផងដែរនូវ៖

(ក) សម្រាប់ករណីវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ៣ (បី) រូប ឬច្រើនរូប៖ ការតែងតាំងមជ្ឈត្តករ ត្រូវធ្វើឡើងស្របតាមប្រការ ២៥ *(ការតែងតាំងមជ្ឈត្តករ)* និងប្រការ ២៦ *(បុគ្គលដែលអាចត្រូវបានតែងតាំងជាមជ្ឈត្តករ)*

(ខ) សម្រាប់ករណីវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករមួយរូប៖ ការតែងតាំងមជ្ឈត្តករត្រូវធ្វើឡើងរួមគ្នា ប្រសិនបើភាគីបានព្រមព្រៀងគ្នារួចហើយ ឬប្រសិនបើភាគីមិនទាន់បានព្រមព្រៀងគ្នានៅឡើយ ការឆ្លើយតបចំពោះសំណើតែងតាំងមជ្ឈត្តករ ដែលភាគីប្ដឹងទាមទារស្នើឡើងស្របតាមប្រការ ២៥ *(ការតែងតាំងមជ្ឈត្តករ)* និងប្រការ ២៦ *(បុគ្គលដែលអាចត្រូវបានតែងតាំងជាមជ្ឈត្តករ)* ឬ

(គ) សេចក្ដីថ្លែងដែលបញ្ជាក់ថា ភាគីឆ្លើយតបផ្ដល់សមត្ថកិច្ចឱ្យ ម.ជ.ម. ក្នុងការតែងតាំងមជ្ឈត្តករ។

## ៨.៤. *ការភ្ជាប់សេចក្ដីថ្លែងដោះសា និងទឡ្ហីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម*

ប្រសិនបើសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មត្រូវបានភ្ជាប់មកជាមួយនូវសេចក្ដីថ្លែងទាមទារ សេចក្ដីជូនដំណឹងអំពីការឆ្លើយតបអាចត្រូវមានភ្ជាប់មកជាមួយនូវសេចក្ដីថ្លែងដោះសា ដែលអាចមានបណ្ដឹងតប ឬការដោះសាតាមការកាត់កង ដូចមានកំណត់ក្នុងប្រការ ៣៧.៣ *(សេចក្ដីថ្លែងដោះសា និងបណ្ដឹងតប)* និងឯកសារយោងនានា។

សេចក្ដីជូនដំណឹងអំពីការឆ្លើយតបអាចត្រូវភ្ជាប់មកជាមួយនូវទឡ្ហីករណ៍ដូចមានកំណត់ក្នុងប្រការ ៣៤ *(ទឡ្ហីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម)*។

### *៨.៥. ភាពមិនពេញលេញនៃសេចក្តីជូនដំណឹងអំពីការឆ្លើយតប*

ប្រសិនបើសេចក្តីជូនដំណឹងអំពីការឆ្លើយតបមានលក្ខណៈមិនពេញលេញ អគ្គលេខាធិការដ្ឋានអាចស្នើសុំភាគីឆ្លើយតបឱ្យបំពេញបន្ថែមចំណុចខ្វះខាតនោះក្នុងអំឡុងពេលសមស្របណាមួយ ដែលកំណត់ដោយអគ្គលេខាធិការដ្ឋាន។ ដើម្បីជៀសវាងការភ័ន្តច្រឡំ សេចក្តីជូនដំណឹងអំពីការឆ្លើយតបត្រូវចាត់ទុកថាពេញលេញ នៅពេលដែលចំណុចនានាដែលតម្រូវក្នុងប្រការ ៨.១ *(សេចក្តីជូនដំណឹងអំពីការឆ្លើយតប)* ត្រូវបានបំពេញ រួមបញ្ចូលទាំងការបង់កម្រៃសេវាចុះបញ្ជីសំណុំរឿង។

### *៨.៦. ការខកខានក្នុងការដាក់សេចក្តីជូនដំណឹងអំពីការឆ្លើយតបពេញលេញ*

ការបង្កើតវេទិកាមជ្ឈត្តកម្មស្របតាមជំពូកទី ៤ *(ការបង្កើតវេទិកាមជ្ឈត្តកម្ម)* មិនត្រូវបង្អាក់ដោយសារការខកខានរបស់ភាគីឆ្លើយតបក្នុងការដាក់សេចក្តីជូនដំណឹងអំពីការឆ្លើយតបពេញលេញឱ្យបានទាន់ពេលវេលាឡើយ។ ការខកខាននេះមិនរារាំងភាគីឆ្លើយតបក្នុងការបដិសេធការទាមទារ ឬការដាក់បណ្តឹងតប ឬការដោះសាតាមការកាត់កង នៅក្នុងដំណើរការមជ្ឈត្តការឡើយ។

### *៨.៧. ការជូនដំណឹងអំពីការទទួលបានសេចក្តីជូនដំណឹងអំពីការឆ្លើយតប*

អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅគូភាគីវិវាទ នៅពេលអគ្គលេខាធិការដ្ឋានបានទទួលសេចក្តីជូនដំណឹងអំពីការឆ្លើយតបពេញលេញ ឬក្នុងករណីដែលមិនបានទទួលសេចក្តីជូនដំណឹងអំពីការឆ្លើយតបពេញលេញទេនោះ អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅគូភាគីវិវាទអំពីកាលបរិច្ឆេទផុតកំណត់នៃអំឡុងពេលសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីការឆ្លើយតបនោះ។

ក្នុងករណីដែលភាគីឆ្លើយតបធ្វើបណ្តឹងតប រួមបញ្ចូលទាំងការដោះសាតាមការកាត់កង នៅក្នុងសេចក្តីជូនដំណឹងអំពីការឆ្លើយតបរបស់ភាគីនោះ ភាគីឆ្លើយតបត្រូវបង់កម្រៃសេវាចុះបញ្ជីបណ្តឹងតបរបស់ខ្លួនផងដែរ បើមិនដូច្នោះទេបណ្តឹងតបនោះនឹងមិនត្រូវលើកយកមកពិចារណានៅក្នុងដំណើរការមជ្ឈត្តការឡើយ។

## ប្រការ ៩. ដំណើរការនីតិវិធីពន្លឿន

### *៩.១. សំណើសុំដំណើរការនីតិវិធីពន្លឿន*

មុនពេលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត ភាគីវិវាទអាចដាក់សំណើសុំទៅអគ្គលេខាធិការដ្ឋាន ឱ្យអនុវត្តដំណើរការមជ្ឈត្តការតាមដំណើរការនីតិវិធីពន្លឿនក្រោមប្រការ ៩ *(ដំណើរការនីតិវិធីពន្លឿន)* ដោយត្រូវបំពេញលក្ខខណ្ឌណាមួយខាងក្រោម៖

(ក) តម្លៃកម្មវត្ថុនៃវិវាទមានតម្លៃមិនលើស ៣.០០០.០០០ (បីលាន) ដុល្លារអាមេរិក ដោយរាប់បញ្ចូលសរុបទាំងអស់តម្លៃកម្មវត្ថុនៃការទាមទារ បណ្តឹងតប និងការដោះសាតាមការកាត់កងនានា

(ខ) គូភាគីវិវាទបានព្រមព្រៀងយកនីតិវិធីពន្លឿន ឬ

(គ) ក្នុងករណីពិសេសបន្ទាន់ខ្លាំង។

## *៩.២. ការទទួលយកដោយគណៈកម្មាធិការតែងតាំង និងនីតិវិធី*

ប្រសិនបើមានភាគីវិវាទណាមួយបានដាក់សំណើក្រោមប្រការ ៩.១ *(សំណើសុំដំណើរការនីតិវិធីពន្លឿន)* គណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវសម្រេចលើសំណើនោះបន្ទាប់ពីបានពិចារណាលើយោបល់របស់គូភាគីវិវាទ និងបានពិនិត្យលើកាលៈទេសៈរបស់សំណុំរឿងថា តើត្រូវអនុវត្តដំណើរការមជ្ឈត្តការស្របតាមដំណើរការនីតិវិធីពន្លឿនដែរឬទេ។

ប្រសិនបើគណៈកម្មាធិការតែងតាំង និងនីតិវិធី ទទួលយកសំណើសុំឱ្យអនុវត្តដំណើរការនីតិវិធីពន្លឿននោះ នីតិវិធីខាងក្រោមត្រូវយកមកអនុវត្តៈ

(ក) អគ្គលេខាធិការដ្ឋាន អាចកែប្រែពេលវេលាកំណត់ណាមួយក្រោមវិធាននេះ

(ខ) សំណុំរឿងត្រូវបញ្ជូនទៅវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ១ (មួយ) រូប លើកលែងតែកិច្ចសន្យាមជ្ឈត្តកម្មកំណត់យកវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ៣ (បី) រូប។ ប្រសិនបើកិច្ចសន្យាមជ្ឈត្តកម្មកំណត់យកវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ៣ (បី) រូប អគ្គលេខាធិការដ្ឋានត្រូវស្នើឱ្យគូភាគីវិវាទព្រមព្រៀងបញ្ជូនសំណុំ-រឿងទៅវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ១ (មួយ) រូប។ ក្នុងករណីមិនមានការព្រមព្រៀងពីគូភាគីវិវាទ សំណុំរឿងនេះត្រូវបញ្ជូនទៅវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ៣ (បី) រូប វិញ

(គ) បន្ទាប់ពីបានពិភាក្សាជាមួយគូភាគីវិវាទ វេទិកាមជ្ឈត្តកម្មអាចសម្រេចថាតើវិវាទនោះត្រូវសម្រេចដោយផ្អែកលើតែឯកសារ ឬទាមទារឱ្យមានសវនាការសម្រាប់ការសាកសួរសាក្សី និងអ្នកជំនាញក៏ដូចជាការទាញហេតុផលផ្ទាល់មាត់ណាមួយ និង

(ឃ) មជ្ឈត្តវិនិច្ឆ័យស្ថាពរត្រូវចេញក្នុងអំឡុងពេល ២៧០ (ពីររយចិតសិប) ថ្ងៃប្រតិទិន គិតចាប់ពីថ្ងៃដែលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត លើកលែងតែមានកាលៈទេសៈពិសេស គណៈកម្មាធិការតែងតាំង និងនីតិវិធី អាចពន្យារពេលវេលាកំណត់សម្រាប់ការចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរនោះ។

## *៩.៣. ភាពផ្ទុយគ្នាក្នុងកិច្ចសន្យាមជ្ឈត្តកម្ម*

តាមការព្រមព្រៀងធ្វើមជ្ឈត្តកម្មក្រោមវិធាននេះ គូភាគីវិវាទព្រមព្រៀងថា ប្រសិនបើត្រូវអនុវត្តដំណើរការមជ្ឈត្តការស្របតាមដំណើរការនីតិវិធីពន្លឿនក្រោមប្រការ ៩ *(ដំណើរការនីតិវិធីពន្លឿន)* នេះ វិធាននិងនីតិវិធីដែលមានចែងក្នុងប្រការ ៩.២ *(ការទទួលយកដោយគណៈកម្មាធិការតែងតាំង និងនីតិវិធី)* ត្រូវយកមកអនុវត្ត ទោះកិច្ចសន្យាមជ្ឈត្តកម្មមានខ្លឹមសារផ្ទុយពីនោះក៏ដោយ។

### *៩.៤. ការបញ្ឈប់នីតិវិធីពន្លឿន*

ក្រោយពីមានសំណើណាមួយពីភាគីវិវាទ និងបន្ទាប់ពីបានផ្តល់ឱកាសឱ្យគូភាគីវិវាទបញ្ចេញមតិរបស់ខ្លួន ព្រមទាំងបានពិនិត្យលើព័ត៌មានបន្ថែមដែលអាចមាននៅពេលបន្ទាប់ និងបានពិភាក្សាជាមួយគណៈកម្មាធិការតែងតាំង និងនីតិវិធីវេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យដំណើរការមជ្ឈត្តការលែងប្រព្រឹត្តទៅស្របទៅតាមនីតិវិធីពន្លឿន។ ប្រសិនបើវេទិកាមជ្ឈត្តកម្មឯកភាពលើសំណើក្រោមប្រការ ៩.៤ *(ការបញ្ឈប់ដំណើរការនីតិវិធីពន្លឿន)* មជ្ឈត្តកម្មត្រូវបន្តដំណើរការនីតិវិធី ដោយវេទិកាមជ្ឈត្តកម្មដែលបានបង្កើតឡើងដើម្បីអនុវត្តដំណើរការនីតិវិធីពន្លឿនដដែលនោះ។

ជំពូកទី ៣

# មជ្ឈត្តករបន្ទាន់

## ប្រការ ១០. សំណើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់

មុនពេលការបង្កើតវេទិកាមជ្ឈត្តកម្ម ភាគីវិវាទដែលមានបំណងស្នើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់អាចដាក់សំណើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់នោះទៅអគ្គលេខាធិការដ្ឋាន នៅពេលដាក់ ឬក្រោយពេលដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម។ ភាគីវិវាទត្រូវបញ្ជូនសំណៅចម្លងនៃសំណើនោះមួយច្បាប់ទៅភាគីផ្សេងទៀតទាំងអស់ ក្នុងពេលដំណាលគ្នាពេលដែលដាក់សំណើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់។ សំណើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ត្រូវមានព័ត៌មានដូចខាងក្រោម៖

(ក) លក្ខណៈនៃវិធានការដែលបានស្នើសុំ

(ខ) មូលហេតុដែលភាគីវិវាទដែលស្នើសុំ មានសិទ្ធិទទួលបានវិធានការនោះ និង

(គ) សេចក្តីថ្លែងដែលបញ្ជាក់ថា ភាគីផ្សេងទៀតទាំងអស់បានទទួលសំណៅចម្លងនៃសំណើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ ឬ បើគ្មានទេ សេចក្តីថ្លែងពិពណ៌នាអំពីចំណាត់ការដែលបានធ្វើរួចដោយសុចរិត និងស្មោះត្រង់ដើម្បីប្រគល់សំណៅចម្លងនៃសំណើ ឬសេចក្តីជូនដំណឹងទៅភាគីវិវាទផ្សេងទៀតទាំងអស់។

## ប្រការ ១១. កម្រៃសេវានៃការស្នើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់

រាល់សំណើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវការបង់កម្រៃសេវានៃការស្នើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់រួមមាន៖ កម្រៃសេវាស្នើសុំ និងកម្រៃសេវាមជ្ឈត្តករបន្ទាន់ និងការចំណាយផ្សេងៗ សម្រាប់ដំណើរការនីតិវិធីដោយយោងតាមតារាងកម្រៃសេវារបស់ ម.ជ.ម. ។ ក្នុងកាលៈទេសៈពិសេស អគ្គលេខាធិការដ្ឋានអាចបង្កើនកម្រៃសេវានៃការស្នើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ពីភាគីវិវាទដែលធ្វើការដាក់សំណើ។ ប្រសិនបើកម្រៃសេវាបន្ថែមមិនត្រូវបានបង់តាមកាលកំណត់ដោយអគ្គលេខាធិការដ្ឋានទេ សំណើនោះត្រូវចាត់ទុកថាបានដក។

## ប្រការ ១២. ការទទួលយកដោយគណៈកម្មាធិការតែងតាំង និងនីតិវិធី

ប្រសិនបើគណៈកម្មាធិការតែងតាំង និងនីតិវិធី ទទួលយកសំណើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ គណៈកម្មាធិការតែងតាំង និងនីតិវិធីត្រូវតែងតាំងមជ្ឈត្តករបន្ទាន់ម្នាក់ ក្នុងអំឡុងពេល ៣ (បី) ថ្ងៃប្រតិទិន បន្ទាប់ពីអគ្គលេខាធិការដ្ឋានទទួលបានសំណើនោះ និងការទូទាត់កម្រៃសេវាវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់។

## ប្រការ ១៣. ទីកន្លែងធ្វើមជ្ឈត្តការ

ប្រសិនបើគូភាគីវិវាទបានព្រមព្រៀងលើទីកន្លែងធ្វើមជ្ឈត្តការ ទីកន្លែងធ្វើមជ្ឈត្តការនោះត្រូវតែជាទីកន្លែងធ្វើមជ្ឈត្តការសម្រាប់ដំណើរការនីតិវិធីមជ្ឈត្តការលើវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់។ ក្នុងករណីមិនមានការព្រមព្រៀងរវាងគូភាគីវិវាទ ទីកន្លែងធ្វើមជ្ឈត្តការសម្រាប់ដំណើរការមជ្ឈត្តការវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ គឺរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដោយមិនប៉ះពាល់ដល់ការធ្វើសេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តកម្ម អំពីទីកន្លែងធ្វើមជ្ឈត្តការ ដោយអនុលោមតាមប្រការ ៣១ *(ទីកន្លែងធ្វើមជ្ឈត្តការ)*។

## ប្រការ ១៤. ការបង្ហាញព័ត៌មាន

មុនពេលទទួលយកការតែងតាំង មជ្ឈត្តករបន្ទាន់ដែលអាចត្រូវតែងតាំង ត្រូវធ្វើការបង្ហាញទៅអគ្គលេខាធិការដ្ឋានអំពីកាលៈទេសៈទាំងឡាយណាដែលអាចបង្កឱ្យមានការសង្ស័យសមហេតុសមផលណាមួយពាក់ព័ន្ធនឹងឯករាជភាព និងអព្យាក្រឹតភាពរបស់ខ្លួន។ រាល់ការជំទាស់ទៅនឹងការតែងតាំងមជ្ឈត្តករបន្ទាន់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) ថ្ងៃប្រតិទិន បន្ទាប់ពីអគ្គលេខាធិការដ្ឋានជូនដំណឹងអំពីការតែងតាំងមជ្ឈត្តករបន្ទាន់ និងកាលៈទេសៈដែលបានបង្ហាញទៅគូភាគីវិវាទ។

## ប្រការ ១៥. មជ្ឈត្តករបន្ទាន់និងដំណើរការមជ្ឈត្តការបន្ទាប់មកទៀត

មជ្ឈត្តករបន្ទាន់មិនអាចធ្វើជាមជ្ឈត្តករនៅក្នុងដំណើរការមជ្ឈត្តការណាមួយ ដែលពាក់ព័ន្ធនឹងវិវាទនោះនាពេលអនាគតឡើយ លើកលែងតែគូភាគីវិវាទបាន ព្រមព្រៀងផ្សេងពីនេះ។

## ប្រការ ១៦. កាលវិភាគសម្រាប់វិធានការបណ្តោះអាសន្នចេញដោយ មជ្ឈត្តករបន្ទាន់

ភ្លាមៗតាមដែលធ្វើទៅបាន ដោយមិនលើសពីអំឡុងពេល ២ (ពីរ) ថ្ងៃប្រតិទិន បន្ទាប់ពីការតែងតាំង មជ្ឈត្តករបន្ទាន់ត្រូវបង្កើតកាលវិភាគដើម្បីពិចារណាលើសំណើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់នោះ។ កាលវិភាគនោះត្រូវផ្តល់ឱកាសសមរម្យឱ្យភាគីវិវាទក្នុងការបង្ហាញរឿងរ៉ាវរបស់ខ្លួន។ មជ្ឈត្តករបន្ទាន់អាចអនុវត្តដំណើរការនីតិវិធីបានតាមរយៈសន្និសីទវីដេអូ ទូរស័ព្ទ ឬមធ្យោបាយទាក់ទងអេឡិចត្រូនិចផ្សេងទៀតជាមួយអ្នកចូលរួមដែលស្ថិតនៅទីកន្លែងមួយ ឬច្រើន ឬក្នុងទម្រង់រួមបញ្ចូលគ្នា ឬដោយផ្អែកលើឯកសារ និងលិខិតស្នាមផ្សេងៗ សម្រាប់ជាមធ្យោបាយជំនួសការចូលរួមសវនាការដោយផ្ទាល់។ មជ្ឈត្តករបន្ទាន់មានអំណាចដូចវេទិកាមជ្ឈត្តកម្មដូចមានចែងក្នុងវិធាននេះ រួមបញ្ចូលទាំង និងមិនកំណត់ចំពោះសមត្ថកិច្ចក្នុងការសម្រេចអំពីយុត្តាធិការរបស់ខ្លួន ដោយមិនប៉ះពាល់ដល់ការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម។

## ប្រការ ១៧. អំណាចរបស់មជ្ឈត្តករបន្ទាន់

មជ្ឈត្តករបន្ទាន់មានអំណាចក្នុងការចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យលើវិធានការបណ្តោះអាសន្ន ដែលខ្លួនយល់ថាចាំបាច់ រួមបញ្ចូលទាំងការចេញសេចក្តីបង្គាប់បឋមក្នុងអំឡុងពេលរង់ចាំសវនាការ ឬដំណើរការនីតិវិធីតាមរយៈ សន្និសីទវីដេអូ ទូរស័ព្ទ ឬ ឯកសារនិងលិខិតស្នាមផ្សេងៗ ដោយភាគីវិវាទ។ មជ្ឈត្តករបន្ទាន់ត្រូវផ្តល់សំអាងហេតុក្នុងសេចក្តីសម្រេចជាទម្រង់សង្ខេបជាលាយលក្ខណ៍អក្សរ។ មជ្ឈត្តករបន្ទាន់អាចកែប្រែ ឬបញ្ចប់សេចក្តីបង្គាប់បឋម សេចក្តីបង្គាប់ ឬមជ្ឈត្ត-វិនិច្ឆ័យវិធានការបណ្តោះអាសន្នបន្ទាន់បានដោយមូលហេតុត្រឹមត្រូវណាមួយ។

## ប្រការ ១៨. ការចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យ ដោយមជ្ឈត្តករបន្ទាន់

មជ្ឈត្តករបន្ទាន់ត្រូវចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យ លើលើវិធានការបណ្តោះអាសន្នរបស់ខ្លួន ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិនចាប់ពីថ្ងៃដែលត្រូវបានតែងតាំង លើកលែងតែក្នុងកាលៈទេសៈពិសេស អគ្គលេខាធិការដ្ឋានអាចពន្យារពេលនេះ។ មជ្ឈត្តករបន្ទាន់ មិនត្រូវចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យលើវិធានការបណ្តោះអាសន្នឡើយ ប្រសិនបើទម្រង់របស់សេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យ លើវិធានការបណ្តោះអាសន្ននោះមិនទាន់ត្រូវបានពិនិត្យពិច័យ និងឯកភាពដោយអគ្គលេខាធិការដ្ឋាន។

ដើម្បីជៀសវាងការភ័ន្តច្រឡំ អំឡុងពេលខាងលើនេះ ត្រូវរាប់បញ្ចូលទាំងអំឡុងពេលយ៉ាងតិច ២ (ពីរ) ថ្ងៃប្រតិទិន សម្រាប់អគ្គលេខាធិការដ្ឋានធ្វើការពិនិត្យពិច័យលើសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យចេញដោយមជ្ឈត្តករបន្ទាន់។

## ប្រការ ១៩. អំណាចរបស់វេទិកាមជ្ឈត្តកម្ម ក្នុងការពិនិត្យដើម្បីកែប្រែ ផ្អាក ឬបញ្ឈប់សេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យចេញដោយមជ្ឈត្តករបន្ទាន់

មជ្ឈត្តករបន្ទាន់មិនមានអំណាចទៀតឡើយ បន្ទាប់ពីវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត។ វេទិកាមជ្ឈត្តកម្មអាចពិនិត្យ កែប្រែ ផ្អាក ឬបញ្ឈប់ សេចក្តីបង្គាប់ ឬមជ្ឈត្ត-វិនិច្ឆ័យលើវិធានការបណ្តោះអាសន្ន ដែលបានចេញដោយមជ្ឈត្តករបន្ទាន់ រួមបញ្ចូលទាំងការសម្រេចអំពីយុត្តាធិការរបស់ខ្លួន។ វេទិកាមជ្ឈត្តកម្មមិនជាប់កាតព្វកិច្ចទៅនឹងមូលហេតុផ្តល់ដោយមជ្ឈត្តករបន្ទាន់ឡើយ។ រាល់ការចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យ ដោយមជ្ឈត្តករបន្ទាន់ ទោះក្នុងកាលៈទេសៈណាក៏ដោយ ត្រូវចាត់ទុកថាឈប់មានអានុភាពអនុវត្ត ប្រសិនបើវេទិកាមជ្ឈត្តកម្មមិនត្រូវបានបង្កើតឡើងក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃប្រតិទិន បន្ទាប់ពីការចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យ ឬពេលវេទិកាមជ្ឈត្តកម្មចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ ឬប្រសិនបើការទាមទារត្រូវបានដក។

## ប្រការ ២០. លក្ខខណ្ឌនៃការចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យ

សេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យដោយមជ្ឈត្តករបន្ទាន់ អាចត្រូវចេញក្រោមលក្ខខណ្ឌដែលមានការផ្តល់ការធានាសមស្របដោយភាគីវិវាទ ដែលបានស្នើសុំវិធានការបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់នោះ។

## ប្រការ ២១. អានុភាព និងការអនុវត្ត សេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យចេញដោយមជ្ឈត្តករបន្ទាន់

គូភាគីវិវាទយល់ព្រមថាសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យចេញដោយមជ្ឈត្តករបន្ទាន់អនុលោមតាមជំពូកទី ៣ *(មជ្ឈត្តករបន្ទាន់)* នេះ ត្រូវមានអានុភាពអនុវត្តចំពោះគូភាគីវិវាទចាប់ពីថ្ងៃដែលបានចេញ ហើយគូភាគីវិវាទត្រូវគោរពតាមសេចក្តីបង្គាប់ ឬមជ្ឈត្ត-វិនិច្ឆ័យដោយមិនបង្អង់។ គូភាគីវិវាទក៏បោះបង់សិទ្ធិក្នុងការតវ៉ា ការស្នើសុំការពិនិត្យឡើងវិញ ឬការប្តឹងជំទាស់ក្នុងទម្រង់ណាមួយ ទៅតុលាការដែលមានសមត្ថកិច្ច ឬសមត្ថកិច្ចតុលាការផ្សេងទៀត ពាក់ព័ន្ធនឹងសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យនោះ ដោយការបោះបង់សិទ្ធិនេះ គឺត្រូវបានធ្វើឡើងដោយមានសុពលភាព។

## ប្រការ ២២. ការកំណត់បែងចែកកម្រៃសេវា នៃការស្នើសុំវិធានការបណ្ដោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់

មជ្ឈត្តករបន្ទាន់អាចធ្វើការបែងចែករាល់កាតព្វកិច្ចបង់កម្រៃសេវាពាក់ព័ន្ធនឹងសំណើសុំក្រោមជំពូកទី ៣ *(មជ្ឈត្តករបន្ទាន់)* នេះ ក្រោមលក្ខខណ្ឌដែលវេទិកាមជ្ឈត្តកម្មមានអំណាចកំណត់ចុងក្រោយនូវការបែងចែកកាតព្វកិច្ចបង់កម្រៃសេវានេះ។

## ប្រការ ២៣. បទប្បញ្ញត្តិផ្សេងៗ ពាក់ព័ន្ធនឹងមជ្ឈត្តករបន្ទាន់

វិធាននេះត្រូវអនុវត្តដោយសមស្របទៅលើរាល់ដំណើរការនីតិវិធីដែលអនុលោមតាមជំពូកទី ៣ *(មជ្ឈត្តករបន្ទាន់)* នេះ ដោយពិចារណាទៅលើភាពបន្ទាន់របស់ដំណើរការនីតិវិធីនោះ។ មជ្ឈត្តករបន្ទាន់ អាចសម្រេចលើរបៀបអនុវត្តវិធាននេះដោយសមរម្យ ហើយសេចក្ដីសម្រេចនោះគឺស្ថាពរ និងមិនអាចជាកម្មវត្ថុនៃការប្ដឹងតវ៉ា ការស្នើសុំពិនិត្យឡើងវិញ ឬការប្ដឹងជំទាស់ក្នុងទម្រង់ណាមួយឡើយ។ អគ្គលេខាធិការដ្ឋានអាចបន្ថយរយៈពេលកំណត់ក្រោមវិធាននេះ ដោយអនុលោមតាមដំណើរការនីតិវិធីដែលបានចាប់ផ្ដើមក្រោមប្រការ ៥.២ *(ការកែប្រែពេលវេលាកំណត់)* និងជំពូកទី ៣ *(មជ្ឈត្តករបន្ទាន់)*។

ជំពូកទី ៤

# ការបង្កើតវេទិកាមជ្ឈត្តកម្ម

## ប្រការ ២៤. ចំនួនមជ្ឈត្តករ

នៅគ្រប់ករណីទាំងអស់ វេទិកាមជ្ឈត្តកម្មត្រូវមានសមាសភាពមជ្ឈត្តករជាចំនួនសេស។ វេទិកាមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករចំនួន ៣ (បី) រូប លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ។

## ប្រការ ២៥. ការតែងតាំងមជ្ឈត្តករ

*២៥.១.កិច្ចព្រមព្រៀងផ្សេងរបស់គូភាគីវិវាទ*

គូភាគីវិវាទអាចព្រមព្រៀងលើនីតិវិធីតែងតាំងវេទិកាមជ្ឈត្តកម្ម ដែលខុសពីនីតិវិធីដូចមានកំណត់ក្នុងប្រការ ២៥.២ *(ការតែងតាំងវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករបីរូប ឬវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប)* ដល់ប្រការ ២៥.៦ *(គ្មានការប្តឹងជំទាស់)*។ ប្រសិនបើវេទិកាមជ្ឈត្តកម្មមិនត្រូវបានតែងតាំងក្នុងអំឡុងពេល ដែលកំណត់ដោយគូភាគីវិវាទ ឬប្រសិនបើគូភាគីវិវាទមិនបានព្រមព្រៀងលើអំឡុងពេលកំណត់សម្រាប់ការតែងតាំងទេនោះ ការតែងតាំងត្រូវធ្វើឡើងស្របតាមប្រការ ២៥.២ *(ការតែងតាំងវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករបីរូប ឬវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប)* ដល់ប្រការ ២៥.៦ *(គ្មានការប្តឹងជំទាស់)* ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលការជូនដំណឹងអំពីសេចក្តីជូនដំណឹងអំពីការឆ្លើយតប ដូចមានកំណត់ក្នុងប្រការ ៨.៧ *(ការជូនដំណឹងអំពីការទទួលបានសេចក្តីជូនដំណឹងអំពីការឆ្លើយតប)*។

### ២៥.២.ការតែងតាំងវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករបីរូប ឬវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប

ចំពោះវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ៣ (បី) រូប ឬវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប ប្រសិនបើការតែងតាំងមិនត្រូវបានធ្វើឡើងតាមរយៈសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ឬសេចក្តីជូនដំណឹងអំពីការឆ្លើយតបទេនោះ ភាគីវិវាទនីមួយៗត្រូវតែងតាំងមជ្ឈត្តករម្នាក់មួយរូប ឬច្រើនរូបស្មើៗគ្នា ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលការជូនដំណឹងអំពីការទទួលបានការឆ្លើយតបចំពោះសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ដូចមានកំណត់ក្នុងប្រការ ៨.៧ *(ការជូនដំណឹងអំពីការទទួលបានសេចក្តីជូនដំណឹងអំពីការឆ្លើយតប)* ឬក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីផុតអំឡុងពេលតម្រូវតាមប្រការ ២៥.១ *(កិច្ចព្រមព្រៀងផ្សេងរបស់គូភាគីវិវាទ)*។ ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិនបន្ទាប់ពីមានការតែងតាំងមជ្ឈត្តកររូបចុងក្រោយ មជ្ឈត្តករដែលត្រូវបានតែងតាំងទាំងអស់ត្រូវរួមគ្នាតែងតាំងមជ្ឈត្តករមួយរូបផ្សេងទៀតជាប្រធានវេទិកាមជ្ឈត្តកម្ម។

ប្រសិនបើភាគីវិវាទណាមួយខកខានក្នុងការតែងតាំងមជ្ឈត្តករតាមការតម្រូវ ឬមជ្ឈត្តករដែលត្រូវបានតែងតាំងដោយភាគីវិវាទនោះខកខានមិនបានតែងតាំងប្រធានវេទិកាមជ្ឈត្តកម្មក្នុងអំឡុងពេលដែលបានកំណត់ក្នុងវិធាននេះ នោះគណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវតែងតាំងមជ្ឈត្តករ ឬ/និងប្រធានវេទិកាមជ្ឈត្តកម្ម។

### ២៥.៣.ការតែងតាំងវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករមួយរូប

ចំពោះវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករមួយរូប ប្រសិនបើមជ្ឈត្តករមិនទាន់ត្រូវបានតែងតាំងតាមរយៈសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ឬសេចក្តីជូនដំណឹងអំពីការឆ្លើយតបទេនោះ គូភាគីវិវាទត្រូវរួមគ្នាតែងតាំងមជ្ឈត្តករមួយរូប ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិនបន្ទាប់ពីបានទទួលការជូនដំណឹងអំពីសេចក្តីជូនដំណឹងអំពីការឆ្លើយតបពេញលេញ ដូចមានចែងក្នុងប្រការ ៨.៧ *(ការជូនដំណឹងអំពីការទទួលបានសេចក្តីជូនដំណឹងអំពីការឆ្លើយតប)* ឬក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីផុតអំឡុងពេលនៃប្រការ ២៥.១ *(កិច្ចព្រមព្រៀងផ្សេងរបស់គូភាគីវិវាទ)*។ ប្រសិនបើភាគីវិវាទទាំងពីរខកខានក្នុងការរួមគ្នាតែងតាំងមជ្ឈត្តករក្នុងអំឡុងពេលដែលមានបញ្ជាក់នៅក្នុងវិធាននេះ គណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវតែងតាំងមជ្ឈត្តករមួយរូបដើម្បីបង្កើតវេទិកាមជ្ឈត្តកម្ម។

### ២៥.៤.ការតែងតាំងមជ្ឈត្តករដោយពហុភាគីវិវាទ

ប្រសិនបើភាគីវិវាទមានលើសពី ២ (ពីរ) ភាគី ក្នុងមជ្ឈត្តកម្ម និងវេទិកាមជ្ឈត្តកម្មជាវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ៣ (បី) រូប ឬច្រើនរូបដែលនឹងត្រូវបានតែងតាំង ភាគីប្តឹងទាមទារទាំងអស់ត្រូវរួមគ្នាតែងតាំងមជ្ឈត្តករ ១ (មួយ) រូប ឬច្រើនរូប និងភាគីឆ្លើយតបទាំងអស់ត្រូវរួមគ្នាតែងតាំងមជ្ឈត្តករ ១ (មួយ) រូប ឬច្រើនរូប។

ប្រសិនបើភាគីវិវាទណាមួយខកខានក្នុងការរួមគ្នាតែងតាំងក្នុងអំឡុងពេលដូចមានកំណត់ក្នុងប្រការ ២៥.២ *(ការតែងតាំងវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករបីរូប ឬវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប)* គណៈកម្មាធិការតែងតាំង និងនីតិវិធីក្នុងនាមរបស់ភាគីវិវាទដែលខកខានមិនបានតែងតាំង ត្រូវតែងតាំងមជ្ឈត្តករ ១ (មួយ) រូប ឬច្រើនរូបស្របតាមប្រការ ២៥.៥ *(ការខកខានក្នុងការតែងតាំងមជ្ឈត្តករ និងការតែងតាំងមជ្ឈត្តករដោយ ម.ជ.ម.)*។ ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីមានការតែងតាំងមជ្ឈត្តករចុងក្រោយ មជ្ឈត្តករដែលត្រូវបានតែងតាំងទាំងអស់ត្រូវរួមគ្នាតែងតាំងមជ្ឈត្តករម្នាក់ទៀត ដែលត្រូវបំពេញតួនាទីជាប្រធានវេទិកាមជ្ឈត្តកម្ម។

ប្រសិនបើមជ្ឈត្តករដែលត្រូវបានតែងតាំងទាំងអស់ខកខានក្នុងការរួមគ្នាតែងតាំងប្រធានវេទិកាមជ្ឈត្តកម្មក្នុងអំឡុងពេលកំណត់ គណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវតែងតាំងមជ្ឈត្តករម្នាក់ទៀតជាប្រធានវេទិកាមជ្ឈត្តកម្ម។

ប្រសិនបើភាគីវិវាទមានលើសពី ២ (ពីរ) ភាគី ក្នុងមជ្ឈត្តកម្ម និងវេទិកាមជ្ឈត្តកម្មជាវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករមួយរូប គូភាគីវិវាទត្រូវព្រមព្រៀងគ្នាក្នុងការតែងតាំងមជ្ឈត្តកររូបណាម្នាក់។ ប្រសិនបើការតែងតាំងរួមគ្នានោះមិនត្រូវបានធ្វើឡើងក្នុងអំឡុងពេលដូចមានកំណត់ក្នុងប្រការ ២៥.៣ *(ការតែងតាំងវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករមួយរូប)* ទេនោះ គណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវតែងតាំងមជ្ឈត្តករស្របតាមប្រការ ២៥.៥ *(ការខកខានក្នុងការតែងតាំងមជ្ឈត្តករ និងការតែងតាំងមជ្ឈត្តករដោយ ម.ជ.ម. )*។

### *២៥.៥.ការខកខានក្នុងការតែងតាំងមជ្ឈត្តករ និងការតែងតាំងមជ្ឈត្តករដោយ ម.ជ.ម.*

ដោយមិនមានការជូនដំណឹងទៅអគ្គលេខាធិការដ្ឋាន អំពីការតែងតាំងក្នុងអំឡុងពេលដូចមានកំណត់ក្នុងប្រការ ២៥.២ *(ការតែងតាំងវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករបីរូប ឬវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប)* ឬប្រការ ២៥.៣ *(ការតែងតាំងវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករមួយរូប)* ឬក្នុងករណីដែល ភាគីវិវាទណាមួយមានបំណងផ្តល់សមត្ថកិច្ចនៃការតែងតាំងនោះទៅ ម.ជ.ម. គណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវតែងតាំងមជ្ឈត្តករ ដោយផ្អែកលើលក្ខណសម្បត្តិ រួមបញ្ចូលទាំងសញ្ជាតិរបស់មជ្ឈត្តករដែលតម្រូវ ឬត្រូវបានស្នើឡើងដោយភាគីវិវាទ និងតាមលក្ខណៈជាក់លាក់នៃវិវាទ។ នៅក្នុងករណីនេះ គណៈកម្មាធិការតែងតាំង និងនីតិវិធី មិនត្រូវតែងតាំងសមាជិកណាម្នាក់របស់ក្រុមប្រឹក្សាប្រតិបត្តិរបស់ ម.ជ.ម. ឬរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធី ជាមជ្ឈត្តករសម្រាប់វេទិកាមជ្ឈត្តកម្មឡើយ។

### *២៥.៦.គ្មានការប្តឹងជំទាស់*

ស្របតាមប្រការ ២៦ *(បុគ្គលដែលអាចត្រូវបានតែងតាំងជាមជ្ឈត្តករ)* គណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវធ្វើការតែងតាំងមជ្ឈត្តករដែលត្រូវបានតម្រូវ ឬត្រូវបានស្នើឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ អាស្រ័យតាមប្រការ

២៨ *(ការជំទាស់ទៅនឹងមជ្ឈត្តករ)* ការតែងតាំងឬការសម្រេចរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធីក្រោមវិធាននេះ គឺជាការសម្រេចចុងក្រោយ និងមិនមែនជាកម្មវត្ថុនៃការប្ដឹងជំទាស់ឡើយ។

### *២៥.៧.ការជូនដំណឹងអំពីការបង្កើតវេទិកាមជ្ឈត្តកម្ម*

រាល់ការតែងតាំង ត្រូវធ្វើឡើងតាមរយៈការជូនដំណឹងទៅអគ្គលេខាធិការដ្ឋាន។ ភ្លាមបន្ទាប់ពីមជ្ឈត្តករត្រូវបានតែងតាំង អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅគូភាគីវិវាទថាវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត និងត្រូវជូនដំណឹងដល់គូភាគីអំពីឈ្មោះ និងព័ត៌មានលម្អិតសម្រាប់ទាក់ទងមជ្ឈត្តករដែលត្រូវបានតែងតាំងទាំងអស់។ បន្ទាប់មកអគ្គលេខាធិការដ្ឋានត្រូវផ្ញើសំណុំរឿងនោះទៅវេទិកាមជ្ឈត្តកម្ម។

## ប្រការ ២៦. បុគ្គលដែលអាចត្រូវបានតែងតាំងជាមជ្ឈត្តករ

២៦.១.ភាគីវិវាទ ឬមជ្ឈត្តករដែលត្រូវបានតែងតាំងដោយភាគីវិវាទ អាចតែងតាំងបុគ្គលខាងក្រោមជាមជ្ឈត្តករ៖

(ក) មជ្ឈត្តករណាម្នាក់ដែលបានចុះបញ្ជីជាមួយ ម.ជ.ម. ឬ

(ខ) បុគ្គលណាម្នាក់ដែលបានបំពេញតួនាទី ឬបានចុះបញ្ជីជាមជ្ឈត្តករផ្នែកពាណិជ្ជកម្មជាមួយស្ថាប័នមជ្ឈត្តការផ្នែកពាណិជ្ជកម្មក្នុងប្រទេស ឬអន្តរជាតិ ដែលត្រូវបានទទួលស្គាល់ដោយ ម.ជ.ម. ។

២៦.២.លក្ខខណ្ឌតម្រូវបន្ថែមដូចខាងក្រោមត្រូវតែបំពេញ៖

(ក) បុគ្គលដែលត្រូវបានតែងតាំងជាមជ្ឈត្តករត្រូវដាក់សេចក្ដីថ្លែងមួយ ដែលមានចុះហត្ថលេខាបញ្ជាក់ថា៖

(i) ខ្លួនស្ម័គ្រចិត្ត និងមានលទ្ធភាពក្នុងការទទួលតួនាទីជាមជ្ឈត្តករ និង

(ii) ខ្លួនមាន និងនៅតែរក្សាអព្យាក្រឹតភាព និងឯករាជភាពរបស់ខ្លួន និងខ្លួនបានប្រកាស និងត្រូវប្រកាសបង្ហាញអំពីស្ថានភាពនានាដូចមានកំណត់ក្នុងប្រការ ២៧.២ *(ការប្រកាសបង្ហាញ)*។

(ខ) បុគ្គលដែលត្រូវបានតែងតាំងជាមជ្ឈត្តករ ដូចមានកំណត់ក្នុងប្រការ ២៦.១(ខ) ត្រូវបំពេញលក្ខខណ្ឌដូចមានចែងខាងក្រោម៖

(i) បន្ថែមលើសេចក្ដីថ្លែងកំណត់ក្នុងប្រការ ២៦.២(ក) ខាងលើ៖

- ភស្តុតាងនៃមជ្ឈត្តវិនិច្ឆ័យចំនួន ៣ (បី) និងភស្តុតាងបញ្ជាក់អំពីសមាជិកភាពជាមជ្ឈត្តករបច្ចុប្បន្ន ដែលចេញដោយស្ថាប័នមជ្ឈត្តការផ្នែកពាណិជ្ជកម្មក្នុងប្រទេស ឬអន្តរជាតិដែលត្រូវបានទទួលស្គាល់ដោយ ម.ជ.ម. និង

- ការបញ្ជាក់ថា ខ្លួនយល់ព្រមចំពោះ និងត្រូវគោរពតាមក្រមសីលធម៌វិជ្ជាជីវៈរបស់ ម.ជ.ម. និងវិធានផ្សេងៗរបស់ ម.ជ.ម. រួមបញ្ចូលទាំងវិធាននេះ។

(ii) ម.ជ.ម. យល់ថាបុគ្គលនោះបំពេញលក្ខខណ្ឌដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ម.ជ.ម. ពាក់ព័ន្ធនឹងវិសមភាព ក្នុងការបំពេញតួនាទីជាមជ្ឈត្តករ។

២៦.៣.នៅគ្រប់ករណីទាំងអស់ ក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃប្រតិទិនបន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងអំពីការតែងតាំងមជ្ឈត្តករពីគូភាគីវិវាទ អគ្គលេខាធិការដ្ឋានអាចជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបណ្តាភាគីវិវាទពាក់ព័ន្ធ អំពីកង្វះខាតនូវចំណុចណាមួយនៃលក្ខណសម្បត្តិដែលតម្រូវខាងលើ។ ភាគីវិវាទដែលពាក់ព័ន្ធនោះត្រូវធ្វើការពិចារណា និងសម្រេចអំពីការតែងតាំងមជ្ឈត្តករក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងនោះ។

២៦.៤. ប្រសិនបើភាគីវិវាទដែលពាក់ព័ន្ធនោះបដិសេធ ឬខកខានក្នុងការតែងតាំងមជ្ឈត្តករថ្មីដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃប្រតិទិន គណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវមានសមត្ថកិច្ចក្នុងការតែងតាំងមជ្ឈត្តករថ្មីសម្រាប់បំពេញតួនាទីជាមជ្ឈត្តករដែលត្រូវបានបដិសេធនោះបាន ប្រសិនបើភាគីវិវាទខកខានមិនបានតែងតាំងមជ្ឈត្តករក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងអំពីការបដិសេធ។

## ប្រការ ២៧. ឯករាជភាព និងអព្យាក្រឹតភាពរបស់មជ្ឈត្តករ និងការប្រកាសបង្ហាញ

### *២៧.១.ឯករាជភាព និងអព្យាក្រឹតភាព*

មជ្ឈត្តករដែលបំពេញតួនាទីក្រោមវិធាននេះ ត្រូវតែឯករាជ្យ និងអព្យាក្រឹត្យ និងមិនត្រូវបំពេញតួនាទីជាអ្នកគាំទ្រ ឬជាទីប្រឹក្សារបស់ភាគីវិវាទណាមួយឡើយ ចាប់ពីពេលដែលត្រូវបានតែងតាំងជាមជ្ឈត្តករ រហូតដល់បញ្ចប់ដំណើរការមជ្ឈត្តការទាំងមូលនៃសំណុំរឿង គឺនៅពេលដែលមជ្ឈត្តវិនិច្ឆ័យស្ថាពរត្រូវបានចេញ និងរួមបញ្ចូលទាំងអំឡុងពេលដែលត្រូវបានអនុញ្ញាត ឬកំណត់នៅក្នុងវិធាននេះ សម្រាប់ការស្នើសុំ ឬការចេញការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ ឬមជ្ឈត្តវិនិច្ឆ័យបន្ថែម។

### *២៧.២.ការប្រកាសបង្ហាញ*

មជ្ឈត្តករដែលអាចត្រូវបានតែងតាំង ត្រូវបង្ហាញដោយមិនបង្អង់ដល់បុគ្គលទាំងឡាយដែលមកទាក់ទងអំពីលទ្ធភាពក្នុងការតែងតាំងខ្លួនជាមជ្ឈត្តករនៃវេទិកាមជ្ឈត្តកម្ម អំពីកាលៈទេសៈទាំងឡាយណាដែលអាចបង្កឱ្យមានការសង្ស័យសមហេតុសមផលណាមួយពាក់ព័ន្ធនឹងឯករាជភាព និងអព្យាក្រឹតភាពរបស់ខ្លួន។

បន្ទាប់ពីត្រូវបានតែងតាំងហើយ មជ្ឈត្តករត្រូវប្រកាសបង្ហាញដោយមិនបង្អង់អំពីកាលៈទេសៈទាំងឡាយណា ដែលអាចបង្កឱ្យមានការសង្ស័យសមហេតុសមផលណាមួយ ពាក់ព័ន្ធនឹងឯករាជភាព ឬអព្យាក្រឹតភាពរបស់ខ្លួនដល់គូភាគីវិវាទ អគ្គលេខាធិការដ្ឋាន និងសមាជិកដទៃទៀតរបស់វេទិកាមជ្ឈត្តកម្ម។

ប្រសិនបើក្នុងដំណាក់កាលណាមួយនៃដំណើរការមជ្ឈត្តការ កាលៈទេសៈថ្មីកើតមានឡើងបង្កឱ្យមានការសង្ស័យពាក់ព័ន្ធនឹងឯករាជភាព និងអព្យាក្រឹតភាពរបស់មជ្ឈត្តករ មជ្ឈត្តកររូបនោះត្រូវប្រកាសបង្ហាញភ្លាមអំពីកាលៈទេសៈនោះ ដល់គូភាគីវិវាទ អគ្គលេខាធិការដ្ឋាន និងសមាជិកដទៃទៀតរបស់វេទិកាមជ្ឈត្តកម្ម។

### *២៧.៣.ក្រមសីលធម៌វិជ្ជាជីវៈរបស់ ម.ជ.ម.*

មជ្ឈត្តករដែលបំពេញតួនាទីក្រោមវិធាននេះ ត្រូវគោរពតាមក្រមសីលធម៌វិជ្ជាជីវៈមជ្ឈត្តកររបស់ ម.ជ.ម.។

## ប្រការ ២៨. ការជំទាស់ទៅនឹងមជ្ឈត្តករ

### *២៨.១.កាលៈទេសៈពាក់ព័ន្ធ*

មជ្ឈត្តករអាចត្រូវបានជំទាស់ ប្រសិនបើមានកាលៈទេសៈណាមួយបង្កឱ្យមានការសង្ស័យសមហេតុផលចំពោះឯករាជភាព ឬអព្យាក្រឹតភាពរបស់មជ្ឈត្តករ។ មជ្ឈត្តករអាចត្រូវបានជំទាស់ផងដែរ ប្រសិនបើមជ្ឈត្តកររូបនោះមិនមានលក្ខណ-សម្បត្តិដូចដែលបានព្រមព្រៀងដោយគូភាគីវិវាទ។

ភាគីវិវាទមួយអាចជំទាស់ទៅនឹងមជ្ឈត្តករ ដែលខ្លួនបានតែងតាំង ឬដែលខ្លួនបានចូលរួមក្នុងការតែងតាំង តែក្នុងករណីដែលភាគីវិវាទនោះបានដឹងអំពីមូលហេតុដើម្បីជំទាស់នោះក្រោយការតែងតាំងតែប៉ុណ្ណោះ។

### *២៨.២.សេចក្តីជូនដំណឹងអំពីការជំទាស់ទៅនឹងមជ្ឈត្តករ ពេលវេលាកំណត់ និងកម្រៃសេវាជំទាស់*

ភាគីវិវាទដែលមានបំណងជំទាស់ទៅនឹងមជ្ឈត្តករ ត្រូវបញ្ជូនសេចក្តីជូនដំណឹងអំពីការជំទាស់របស់ខ្លួនដោយបញ្ជាក់អំពីមូលហេតុនៃការជំទាស់ទៅវេទិកាមជ្ឈត្តកម្ម ភាគីវិវាទម្ខាងទៀត ឬគូភាគីវិវាទ និងអគ្គលេខាធិការដ្ឋាន ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលការជូនដំណឹងដូចមានកំណត់ក្នុងប្រការ ២៥.៧ *(ការជូនដំណឹងអំពីការបង្កើតវេទិកាមជ្ឈត្តកម្ម)* ឬក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីភាគីវិវាទបានដឹងអំពីកាលៈទេសៈនានា ដូចមានកំណត់ក្នុងប្រការ ២៨.១ *(កាលៈទេសៈពាក់ព័ន្ធ)*។

រាល់ការដាក់សេចក្តីជូនដំណឹងអំពីការជំទាស់ទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវការបង់កម្រៃសេវាជំទាស់ដោយយោងតាមតារាងកម្រៃសេវារបស់ ម.ជ.ម.។

ប្រសិនបើសេចក្ដីជូនដំណឹងអំពីការជំទាស់នោះត្រូវបានដាក់ដោយភាគីវិវាទលើសពីមួយ ភាគីវិវាទទាំងនោះត្រូវបង់ចំណែករបស់ខ្លួនស្មើគ្នា លើកលែងតែគូភាគីវិវាទព្រមព្រៀងផ្សេងពីនេះ។ ភាគីវិវាទនីមួយៗអាចបង់សរុបនូវកម្រៃសេវាជំទាស់ ប្រសិនបើភាគីវិវាទណាមួយខកខានមិនបានបង់ចំណែកខ្លួនត្រូវបង់។ ប្រសិនបើកម្រៃសេវាជំទាស់មិនត្រូវបានបង់ដោយភាគីវិវាទណាមួយដែលដាក់សេចក្ដីជូនដំណឹងអំពីការជំទាស់នោះទេ អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅនិងឱ្យភាគីវិវាទម្ខាងទៀតបង់ទឹកប្រាក់ដែលត្រូវបង់ ក្នុងរយៈពេលដែលបានកំណត់ដោយអគ្គលេខាធិការដ្ឋាន។

ប្រសិនបើកម្រៃសេវាជំទាស់មិនត្រូវបានបង់ទាំងស្រុងតាមកាលកំណត់ក្នុងវិធាននេះទេ វេទិកាមជ្ឈត្តកម្មត្រូវចាត់ទុកការជំទាស់នោះថាបានដក ដោយមិនប៉ះពាល់ដល់ការដាក់ការជំទាស់នេះជាថ្មីនៅពេលក្រោយ។

### *២៨.៣. យោបល់ចំពោះការជំទាស់ទៅនឹងមជ្ឈត្តករ*

មជ្ឈត្តករដែលត្រូវបានជំទាស់ ភាគីវិវាទម្ខាងទៀត និងសមាជិកដទៃទៀតរបស់វេទិកាមជ្ឈត្តកម្ម ប្រសិនបើមាន អាចផ្ដល់យោបល់របស់ខ្លួនអំពីការជំទាស់ទៅនឹងមជ្ឈត្តករទៅវេទិកាមជ្ឈត្តកម្ម ភាគីវិវាទម្ខាងទៀត ឬគូភាគីវិវាទ និងអគ្គលេខា-ធិការដ្ឋាន ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន ក្រោយពីបានទទួលសេចក្ដីជូនដំណឹងអំពីការជំទាស់ និងការបញ្ជាក់ពីអគ្គលេខាធិការដ្ឋានអំពីការទទួលបានការបង់កម្រៃសេវាជំទាស់ទាំងស្រុង ដូចមានចែងក្នុងប្រការ ២៨.២ *(សេចក្ដីជូនដំណឹងអំពីការជំទាស់ ពេលវេលាកំណត់ និងកម្រៃសេវាជំទាស់)*។

### *២៨.៤.ការដកខ្លួនរបស់មជ្ឈត្តករដែលត្រូវបានជំទាស់ និងការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម*

ក្នុងករណីដែលភាគីវិវាទម្ខាងយល់ស្របចំពោះការជំទាស់ទៅនឹងមជ្ឈត្តករ ដែលស្នើឡើងដោយភាគីវិវាទម្ខាងទៀត មជ្ឈត្តករដែលត្រូវបានជំទាស់នោះត្រូវដកខ្លួនចេញ។ ទោះបីជាគ្មានការព្រមព្រៀងរវាងគូភាគីវិវាទចំពោះការជំទាស់ក៏ដោយ ក៏មជ្ឈត្តករដែលត្រូវបានជំទាស់អាចដកខ្លួនចេញផងដែរ។ ការដកខ្លួនចេញរបស់មជ្ឈត្តករក្នុងករណីទាំងពីរមិនត្រូវបានចាត់ទុកជាការទទួលស្គាល់សុពលភាពនៃមូលហេតុនៃការជំទាស់ឡើយ។

មជ្ឈត្តករដែលត្រូវបានជំទាស់ត្រូវជូនដំណឹងទៅគូភាគីវិវាទ សមាជិកផ្សេងទៀតនៃវេទិកាមជ្ឈត្តកម្ម និងអគ្គលេខាធិការដ្ឋាន អំពីការឆ្លើយតបរបស់ខ្លួនចំពោះការជំទាស់ក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលយោបល់ចំពោះការជំទាស់ ឬបន្ទាប់ពីផុតអំឡុងពេលកំណត់សម្រាប់បញ្ជូនការផ្ដល់យោបល់ចំពោះការជំទាស់។

ក្នុងករណីដែលវេទិកាមជ្ឈត្តកម្មជាវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករមួយរូប ប្រសិនបើមជ្ឈត្តករដែលត្រូវបានជំទាស់បានជូនដំណឹងទៅភាគីដែលបានជំទាស់ថាខ្លួនបដិសេធក្នុងការដកខ្លួនចេញពីវេទិកាមជ្ឈត្តកម្ម ភាគីវិវាទដែលបានជំទាស់នោះ

អាចដាក់ពាក្យតវ៉ាទៅ ម.ជ.ម. តាមរយៈអគ្គលេខាធិការដ្ឋាន ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងអំពីការបដិសេធលើការជំទាស់នោះ។

ក្នុងករណីដែលវេទិកាមជ្ឈត្តកម្មជាវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប ប្រសិនបើមជ្ឈត្តករដែលត្រូវបានជំទាស់បានជូនដំណឹងទៅសមាជិកផ្សេងទៀតនៃវេទិកាមជ្ឈត្តកម្មថា ខ្លួនបដិសេធក្នុងការដកខ្លួនចេញពីវេទិកាមជ្ឈត្តកម្ម វេទិកាមជ្ឈត្តកម្មត្រូវសម្រេចលើការជំទាស់នោះក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងអំពីការបដិសេធលើការជំទាស់នោះ។ ក្នុងករណីដែលវេទិកាមជ្ឈត្តកម្ម សម្រេចបដិសេធការជំទាស់ទៅនឹងមជ្ឈត្តករ ភាគីវិវាទដែលបានជំទាស់អាចប្តឹងតវ៉ាទៅ ម.ជ.ម. តាមរយៈអគ្គលេខាធិការដ្ឋាន ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តកម្ម។

### *២៨.៥.សេចក្តីសម្រេចរបស់ ម.ជ.ម. លើការជំទាស់ទៅនឹងមជ្ឈត្តករ*

គណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវសម្រេចលើការតវ៉ាចំពោះការជំទាស់ទៅនឹងមជ្ឈត្តករក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីអគ្គលេខាធិការដ្ឋានបានទទួលការតវ៉ាចំពោះការជំទាស់ទៅនឹងមជ្ឈត្តករ។

ប្រសិនបើគណៈកម្មាធិការតែងតាំង និងនីតិវិធី បដិសេធការជំទាស់ទៅនឹងមជ្ឈត្តករ មជ្ឈត្តករដែលត្រូវបានជំទាស់នោះត្រូវបន្តបំពេញតួនាទីរបស់ខ្លួនជាមជ្ឈត្តករតទៅទៀត។ ប្រសិនបើគណៈកម្មាធិការតែងតាំង និងនីតិវិធីយល់ស្របចំពោះការជំទាស់ អាណត្តិរបស់មជ្ឈត្តករដែលត្រូវបានជំទាស់នោះនឹងត្រូវបញ្ចប់ដោយមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចនោះ ហើយប្រការ ៣០ *(ការដាក់មជ្ឈត្តករជំនួស)* ត្រូវអនុវត្ត។

### *២៨.៦.ការបិទផ្លូវតវ៉ា និងការជូនដំណឹង*

សេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធី មិនចាំបាច់បង្ហាញហេតុផលឡើយ។ សេចក្តីសម្រេចនោះ គឺជាសេចក្តីសម្រេចស្ថាពរ និងបិទផ្លូវតវ៉ា។ អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅគូភាគីវិវាទ និងវេទិកាមជ្ឈត្តកម្មអំពីសេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធីនោះ។

## ប្រការ ២៩. ការខកខាន ឬអលទ្ធភាពក្នុងការបំពេញតួនាទី

### *២៩.១.ការបញ្ចប់អាណត្តិរបស់មជ្ឈត្តករ តាមសំណើរបស់ភាគីវិវាទណាមួយ*

ប្រសិនបើមជ្ឈត្តករណាមួយពុំអាចបំពេញមុខងាររបស់ខ្លួនបានដោយមូលហេតុតាមផ្លូវច្បាប់ ឬមូលហេតុជាក់ស្តែងណាមួយ ឬដោយមូលហេតុណាមួយផ្សេងទៀត ខកខានក្នុងការបំពេញមុខងារដោយមិនមានការពន្យារពេលហួសហេតុ អាណត្តិរបស់មជ្ឈត្តករនោះត្រូវបានបញ្ចប់ ប្រសិនបើមជ្ឈត្តករនោះដកខ្លួនពីមុខ

តំណែង ឬប្រសិនបើគូភាគីវិវាទព្រមព្រៀងបញ្ចប់អាណត្តិនោះ។ ការដកខ្លួន ឬការព្រមព្រៀងបញ្ចប់អាណត្តិនេះ មិនត្រូវបានចាត់ទុកជាការទទួលស្គាល់ចំពោះសុពលភាពនៃមូលហេតុដែលនាំឱ្យមានការដកខ្លួននោះទេ។

ប្រសិនបើការមិនយល់ស្របគ្នានៅតែបន្តមានពាក់ព័ន្ធនឹងមូលហេតុណាមួយក្នុងចំណោមមូលហេតុទាំងនេះ ឬប្រសិនបើមជ្ឈត្តករណាម្នាក់ខកខានមិនបានបំពេញអាណត្តិរបស់ខ្លួនស្របតាមវិធាននេះ ភាគីវិវាទណាមួយអាចដាក់សំណើទៅអគ្គលេខាធិការដ្ឋានសុំឱ្យគណៈកម្មាធិការតែងតាំង និងនីតិវិធី សម្រេចបញ្ចប់អាណត្តិរបស់មជ្ឈត្តករូបនោះ។

*២៩.២.យោបល់ចំពោះសំណើឱ្យបញ្ចប់អាណត្តិរបស់មជ្ឈត្តករ*

មជ្ឈត្តករ ភាគីវិវាទម្ខាងទៀត និងសមាជិកដទៃទៀតរបស់វេទិកាមជ្ឈត្តកម្មអាចផ្តល់យោបល់របស់ខ្លួនឆ្លើយតបនឹងសំណើនោះទៅអគ្គលេខាធិការដ្ឋាន ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសំណើនោះ។

*២៩.៣.សេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធី ចំពោះសំណើសុំបញ្ចប់អាណត្តិរបស់មជ្ឈត្តករ*

គណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវសម្រេចលើសំណើសុំបញ្ចប់អាណត្តិរបស់មជ្ឈត្តករ ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីផុតអំឡុងពេលកំណត់សម្រាប់ផ្តល់យោបល់ឆ្លើយតបនឹងសំណើសុំបញ្ចប់អាណត្តិរបស់មជ្ឈត្តករ។

ប្រសិនបើគណៈកម្មាធិការតែងតាំង និងនីតិវិធី បដិសេធសំណើសុំនោះ មជ្ឈត្តកររូបនោះ ត្រូវបន្តបំពេញភារកិច្ចរបស់ខ្លួនជាមជ្ឈត្តករតទៅទៀត។ ប្រសិនបើគណៈកម្មាធិការតែងតាំង និងនីតិវិធី យល់ស្របចំពោះសំណើនោះ អាណត្តិរបស់មជ្ឈត្តករនោះត្រូវបានបញ្ចប់ដោយមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចនោះ ហើយប្រការ ៣០ *(ការដាក់មជ្ឈត្តករជំនួស)* ត្រូវយកមកអនុវត្ត។

*២៩.៤.ការបិទផ្លូវតវ៉ា និងការជូនដំណឹង*

សេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធី មិនចាំបាច់បង្ហាញហេតុផលឡើយ។ សេចក្តីសម្រេចនោះ គឺជាសេចក្តីសម្រេចស្ថាពរ និងបិទផ្លូវតវ៉ា។ អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅគូភាគីវិវាទ និងវេទិកាមជ្ឈត្តកម្មអំពីសេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធីនោះ។

## ប្រការ ៣០. ការដាក់មជ្ឈត្តករជំនួស

*៣០.១.មូលហេតុនៃការដាក់ជំនួស*

មជ្ឈត្តករអាចត្រូវបានដាក់ជំនួស នៅពេលមជ្ឈត្តករនោះទទួលមរណភាព ដកខ្លួន ឬលាលែងពីតំណែង ឬនៅពេលបញ្ចប់អាណត្តិរបស់មជ្ឈត្តករណាម្នាក់ ដោយមូលហេតុផ្សេងៗស្របតាមវិធាននេះ។

## ៣០.២.ការតែងតាំងមជ្ឈត្តករជំនួសដោយភាគីវិវាទ

ស្របតាមប្រការ ៣០.៣ *(ការតែងតាំងមជ្ឈត្តករជំនួសដោយ ម.ជ.ម.)* នៅពេលដែលមជ្ឈត្តករណាម្នាក់ត្រូវដាក់ជំនួស នៅក្នុងអំឡុងពេលនៃដំណើរការមជ្ឈត្តការ ការតែងតាំងមជ្ឈត្តករជំនួសនោះត្រូវធ្វើឡើង ស្របតាមនីតិវិធីដូចគ្នាដូចមានចែងនៅក្នុងប្រការ ២៥ *(ការតែងតាំងមជ្ឈត្តករ)* ដែលត្រូវអនុវត្តសម្រាប់ការតែងតាំងមជ្ឈត្តករជំនួស ដោយត្រូវចាប់ផ្តើមមិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន ក្រោយពីភាគីវិវាទដែលត្រូវតែងតាំងមជ្ឈត្តករជំនួស បានទទួលសេចក្តីជូនដំណឹងអំពីការដាក់មជ្ឈត្តករជំនួស។ គ្មានភាគីវិវាទណាមួយ ត្រូវបានរារាំងមិនឱ្យចូលរួមក្នុងការតែងតាំងមជ្ឈត្តករជំនួស ដោយមូលហេតុថាភាគីវិវាទនោះ ខកខានមិនបានចូលរួមពីដំបូងក្នុងការតែងតាំងមជ្ឈត្តករដែលនឹងត្រូវបានដាក់ជំនួសនោះទេ។

## ៣០.៣.ការតែងតាំងមជ្ឈត្តករជំនួសដោយ ម.ជ.ម.

តាមរយៈសំណើរបស់ភាគីវិវាទណាមួយទៅអគ្គលេខាធិការដ្ឋាន ប្រសិនបើគណៈកម្មាធិការតែងតាំង និងនីតិវិធី កំណត់ថាដើម្បីធានាភាពឆាប់រហ័សនៃដំណើរការមជ្ឈត្តការ ឬដើម្បីជៀសវាងការពន្យារពេលដែលមិនចាំបាច់ ដោយគិតពិចារណាអំពីកាលៈទេសៈពិសេសនានានៅក្នុងសំណុំរឿង គណៈកម្មាធិការតែងតាំង និងនីតិវិធី ជំនួសឱ្យគូភាគីវិវាទ អាចតែងតាំងមជ្ឈត្តករជំនួសណាម្នាក់ បន្ទាប់ពីបានទុកឱកាសឱ្យគូភាគីវិវាទ និងមជ្ឈត្តករដទៃទៀតនៃវេទិកាមជ្ឈត្តកម្ម ផ្តល់យោបល់រួចហើយ។

## ៣០.៤.លទ្ធផលនៃការដាក់មជ្ឈត្តករជំនួស

ប្រសិនបើមជ្ឈត្តករតែមួយរបស់វេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករមួយរូប ឬប្រធានវេទិកាមជ្ឈត្តកម្មរបស់វេទិកាមជ្ឈត្តកម្មនៃសមាជិកមជ្ឈត្តករច្រើនរូបត្រូវបានដាក់ជំនួស សវនាការដែលបានធ្វើហើយត្រូវធ្វើសារជាថ្មី លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ។ ប្រសិនបើមជ្ឈត្តកររូបណាផ្សេងទៀតនៃវេទិកាមជ្ឈត្តកម្មដែលមានសមាជិកមជ្ឈត្តករច្រើនរូបត្រូវបានដាក់ជំនួស សវនាការដែលបានធ្វើឡើងពីមុនអាចត្រូវបានធ្វើឡើងសារជាថ្មីផ្អែកតាមឆន្ទានុសិទ្ធិរបស់វេទិកាមជ្ឈត្តកម្ម បន្ទាប់ពីបានពិភាក្សាជាមួយគូភាគីវិវាទរួចហើយ។ ប្រសិនបើវេទិកាមជ្ឈត្តកម្មបានចេញមជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន ឬមជ្ឈត្តវិនិច្ឆ័យដោយផ្នែករួចហើយ សវនាការដែលពាក់ព័ន្ធទាំងស្រុងនឹងមជ្ឈត្តវិនិច្ឆ័យទាំងនោះមិនត្រូវធ្វើសារឡើងវិញទេ ហើយមជ្ឈត្តវិនិច្ឆ័យទាំងនោះ ត្រូវបន្តមានសុពលភាពដដែល។

ជំពូកទី ៥

# ដំណើរការមជ្ឈត្តការ

## ប្រការ ៣១. ទីកន្លែងធ្វើមជ្ឈត្តការ

លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ឬដោយសារកាលៈទេសៈនានានៃសំណុំរឿងដែលវេទិកាមជ្ឈត្តកម្មសម្រេចថាទីកន្លែងធ្វើមជ្ឈត្តការផ្សេងទៀតមានលក្ខណៈសមស្របជាង ទីកន្លែងធ្វើមជ្ឈត្តការនៃមជ្ឈត្តកម្មទាំងអស់ដែលធ្វើឡើងក្រោមវិធាននេះ គឺរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ដូចមានចែងនៅក្នុងប្រការ ៣៩.៣ *(ទីកន្លែងសម្រាប់ប្រជុំ និងសវនាការ)* ទីកន្លែងធ្វើមជ្ឈត្តការមិនកំណត់អំពីទីកន្លែងដែលវេទិកាមជ្ឈត្តកម្មអាចជួបប្រជុំ និងធ្វើសវនាការនោះទេ។

## ប្រការ ៣២. ច្បាប់អនុវត្ត និងសមធម៌

### *៣២.១.ច្បាប់អនុវត្ត*

គូភាគីវិវាទ មានសេរីភាពក្នុងការព្រមព្រៀងយកច្បាប់ ឬបទប្បញ្ញត្តិគតិយុត្តិណាមួយ ដែលវេទិកាមជ្ឈត្តកម្មត្រូវយកមកអនុវត្តចំពោះខ្លឹមសារនៃវិវាទ។ ក្នុងករណីដែលមិនមានការព្រមព្រៀងគ្នា វេទិកាមជ្ឈត្តកម្មត្រូវកំណត់យកច្បាប់ ឬបទប្បញ្ញត្តិគតិយុត្តិណាមួយ ដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្របមកអនុវត្ត។

### *៣២.២.សមធម៌ និងការសម្រុះសម្រួល*

វេទិកាមជ្ឈត្តកម្មត្រូវធ្វើមជ្ឈត្តវិនិច្ឆ័យតាមសមធម៌ ឬតាមការសម្រុះសម្រួល តែក្នុងករណី និងក្នុងកម្រិត ដែលគូភាគីវិវាទបានអនុញ្ញាតយ៉ាងច្បាស់លាស់ឱ្យវេទិកាមជ្ឈត្តកម្មធ្វើដូច្នោះតែប៉ុណ្ណោះ។

*៣២.៣.បញ្ញត្តិក្នុងកិច្ចសន្យា និងទម្លាប់ពាណិជ្ជកម្ម*

នៅគ្រប់ករណីទាំងអស់ វេទិកាមជ្ឈត្តកម្មត្រូវយកមកពិចារណានូវបញ្ញត្តិនានាដែលមានចែងក្នុងកិច្ចសន្យា ប្រសិនបើមាន និងរួមទាំងទម្លាប់ពាណិជ្ជកម្មនានាដែលពាក់ព័ន្ធ។

## ប្រការ ៣៣. ភាសា

*៣៣.១.ភាសានៃដំណើរការមជ្ឈត្តការ*

គូភាគីវិវាទមានសេរីភាពក្នុងការព្រមព្រៀងយកភាសាណាមួយ ឬច្រើនមកប្រើក្នុងដំណើរការមជ្ឈត្តការ។ ក្នុងករណីដែលគ្មានការព្រមព្រៀងគ្នា វេទិកាមជ្ឈត្តកម្មអាចសម្រេចយកភាសាណាមួយជាភាសាសម្រាប់ដំណើរការមជ្ឈត្តការ ដោយគិតពិចារណាលើកាលៈទេសៈនានាដែលពាក់ព័ន្ធទាំងអស់ រួមបញ្ចូលទាំងភាសានៃកិច្ចសន្យាផងដែរ។

*៣៣.២.ការបកប្រែ*

វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យភាគីវិវាទណាមួយធ្វើការបកប្រែ ការទាក់ទងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ណាមួយ ទៅជាភាសាណាមួយ និងក្នុងទម្រង់ណាមួយដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប។

*៣៣.៣.ភាសានៃមជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីបង្គាប់*

ប្រសិនបើភាសានៃដំណើរការមជ្ឈត្តការ ទោះតាមរយៈការជ្រើសរើសរបស់គូភាគីវិវាទ ឬតាមការកំណត់របស់វេទិកាមជ្ឈត្តកម្ម ស្របតាមប្រការ ៣៣ *(ភាសា)* គឺជាភាសាផ្សេងក្រៅពីភាសាខ្មែរ ឬភាសាអង់គ្លេសក៏ដោយ ក៏ភាសានៃមជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីបង្គាប់ ដែលចេញដោយវេទិកាមជ្ឈត្តកម្មត្រូវតែជាភាសាខ្មែរ ឬភាសាអង់គ្លេស បន្ទាប់ពីបានពិភាក្សាជាមួយគូភាគីវិវាទរួចហើយ។

## ប្រការ ៣៤. ទទ្បីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម

*៣៤.១.ការកំណត់អំពីយុត្តាធិការរបស់ ម.ជ.ម. មុនពេលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត*

មុនពេលដែលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត ប្រសិនបើភាគីវិវាទបដិសេធចំពោះអត្ថិភាព ឬសុពលភាពនៃកិច្ចសន្យាមជ្ឈត្តកម្ម ឬចំពោះយុត្តាធិការរបស់ ម.ជ.ម. ក្នុងការចាត់ចែងធ្វើមជ្ឈត្តការលើសំណុំរឿង គណៈកម្មាធិការតែងតាំង និងនីតិវិធី ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងអំពីការបដិសេធនោះ ត្រូវសម្រេចថាតើដោយផ្អែកលើសេចក្តីបញ្ជាក់ដំបូង មជ្ឈត្តការត្រូវមានដំណើរការទៅមុខដែរឬទេ។ មជ្ឈត្តការត្រូវតែបញ្ចប់ ប្រសិនបើគណៈកម្មាធិការតែងតាំង និងនីតិវិធី សម្រេចថា សេចក្តីបញ្ជាក់ដំបូងនោះមិនបាន

បំពេញលក្ខខណ្ឌដើម្បីឱ្យមជ្ឈត្តការអាចដំណើរការបាន។ រាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធី ដែលសម្រេចថាដំណើរការនីតិវិធីមជ្ឈត្តការត្រូវបន្ត មិនត្រូវប៉ះពាល់ដល់អំណាចរបស់វេទិកាមជ្ឈត្តកម្មក្នុងការចេញសេចក្តីសម្រេចអំពីយុត្តាធិការរបស់ខ្លួនឡើយ។

### *៣៤.២.ការសម្រេចរបស់វេទិកាមជ្ឈត្តកម្មអំពីយុត្តាធិការរបស់ខ្លួន*

វេទិកាមជ្ឈត្តកម្មមានអំណាចក្នុងការសម្រេចយុត្តាធិការរបស់ខ្លួនរួមទាំងការជំទាស់នានាដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ឬវិសាលភាពអនុវត្តនៃកិច្ចសន្យាមជ្ឈត្តកម្ម។

ប្រសិនបើវេទិកាមជ្ឈត្តកម្មសម្រេចថាខ្លួនមានយុត្តាធិការ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងអំពីការសម្រេចនោះ ភាគីវិវាទអាចស្នើឱ្យតុលាការមានសមត្ថកិច្ចធ្វើការសម្រេច ដែលការសម្រេចរបស់តុលាការអំពីបញ្ហានេះ គឺជាការសម្រេចដែលបិទផ្លូវតវ៉ា។ នៅពេលសំណើសុំការសម្រេចរបស់តុលាការ ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្មនៅមិនទាន់ត្រូវបានសម្រេចនៅឡើយ វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការមជ្ឈត្តការ និងចេញមជ្ឈត្តវិនិច្ឆ័យបាន។

### *៣៤.៣.កិច្ចសន្យា និងខចែងស្តីពីមជ្ឈត្តកម្ម*

សម្រាប់គោលបំណងនៃប្រការ ៣៤ *(ទទ្បីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម)* ប្រសិនបើខចែងស្តីពីមជ្ឈត្តកម្មជាផ្នែកមួយនៃកិច្ចសន្យា ខចែងស្តីពីមជ្ឈត្តកម្មនោះ ត្រូវចាត់ទុកជាការព្រមព្រៀងដោយឡែក ដែលមិនទាក់ទងនឹងលក្ខខណ្ឌ និងខចែងផ្សេងទៀតនៃកិច្ចសន្យាឡើយ។ ការសម្រេចរបស់វេទិកាមជ្ឈត្តកម្មដែលចាត់ទុកកិច្ចសន្យាថាមោឃៈ និងអសារឥតការ មិននាំឱ្យខចែងស្តីពីមជ្ឈត្តកម្មនោះបាត់សុពលភាពឡើយ។

### *៣៤.៤.ទទ្បីករណ៍បញ្ជាក់ថាវេទិកាមជ្ឈត្តកម្មពុំមានយុត្តាធិការ*

ទទ្បីករណ៍ដែលបញ្ជាក់ថា វេទិកាមជ្ឈត្តកម្មពុំមានយុត្តាធិការ ត្រូវលើកឡើងមុនពេលដាក់សេចក្តីថ្លែងដោះសា សម្រាប់បញ្ហាយុត្តាធិការទាក់ទងនឹងការទាមទារ ឬមុនពេលដាក់សេចក្តីថ្លែងដោះសាចំពោះបណ្តឹងតប សម្រាប់បញ្ហាយុត្តាធិការទាក់ទងនឹងបណ្តឹងតប។ វេទិកាមជ្ឈត្តកម្ម អាចទទួលយកទទ្បីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម ដែលត្រូវបានលើកឡើងក្រោយពេលកំណត់ខាងលើបាន ប្រសិនបើវេទិកាមជ្ឈត្តកម្មយល់ថា ការយឺតយ៉ាវក្នុងការដាក់ទទ្បីករណ៍នោះមានមូលហេតុត្រឹមត្រូវ។

មិនត្រូវហាមឃាត់ភាគីវិវាទណាមួយមិនឱ្យលើកឡើងពីទទ្បីករណ៍ខាងលើ ដោយហេតុថាភាគីវិវាទនោះបានតែងតាំង ឬចូលរួមក្នុងការតែងតាំងមជ្ឈត្តករឡើយ។

*៣៤.៥.ទឡ្ហីករណ៍បញ្ជាក់ថាវេទិកាមជ្ឈត្តកម្មធ្វើហួសក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន*

ទឡ្ហីករណ៍បញ្ជាក់ថា វេទិកាមជ្ឈត្តកម្មធ្វើហួសក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន ក្នុងពេលដំណើរការមជ្ឈត្តការត្រូវលើកឡើងភ្លាមៗ បន្ទាប់ពីកើតឡើងនូវបញ្ហាដែលត្រូវបានចោទថា ហួសក្របខណ្ឌសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្ម។ វេទិកាមជ្ឈត្តកម្មអាចទទួលយកទឡ្ហីករណ៍នោះក្រោយពេលកំណត់ខាងលើបាន ប្រសិនបើវេទិកាមជ្ឈត្តកម្មយល់ថាការយឺតយ៉ាវក្នុងការដាក់ទឡ្ហីករណ៍នោះមានមូលហេតុត្រឹមត្រូវ។

*៣៤.៦.ការសម្រេចលើទឡ្ហីករណ៍ជាបញ្ហាបឋម ឬជាមជ្ឈត្តវិនិច្ឆ័យសម្រេចលើអង្គសេចក្តី*

វេទិកាមជ្ឈត្តកម្មអាចសម្រេចលើទឡ្ហីករណ៍ពាក់ព័ន្ធនឹងយុត្តាធិការរបស់ខ្លួន ដោយចាត់ទុកជាបញ្ហាបឋម ឬជាមជ្ឈត្តវិនិច្ឆ័យសម្រេចលើអង្គសេចក្តីរបស់ខ្លួន។

## ប្រការ ៣៥. បញ្ញត្តិទូទៅអំពីដំណើរការមជ្ឈត្តការ

*៣៥.១.ដំណើរការមជ្ឈត្តការ សេចក្តីបង្គាប់ និងសេចក្តីណែនាំ*

បន្ទាប់ពីពិភាក្សាជាមួយគូភាគីវិវាទ ដោយផ្អែកលើភាពសាំញ៉ាំ និងតម្លៃនៃវិវាទ វេទិកាមជ្ឈត្តកម្មត្រូវអនុវត្តដំណើរការមជ្ឈត្តការក្នុងលក្ខណៈ ដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប ដើម្បីធានាភាពយុត្តិធម៌ ឆាប់រហ័ស ចំណាយអស់តិច និងផ្តល់ដំណោះស្រាយចុងក្រោយនៃវិវាទ។ នៅក្នុងគ្រប់ករណីទាំងអស់ វេទិកាមជ្ឈត្តកម្មត្រូវដំណើរការក្នុងលក្ខណៈ ដែលគូភាគីវិវាទត្រូវបានទទួលការយកចិត្តទុកដាក់ស្មើៗគ្នា និងភាគីវិវាទនីមួយៗត្រូវបានផ្តល់ឱកាសសមរម្យដើម្បីបង្ហាញរឿងរ៉ាវរបស់ខ្លួន។

វេទិកាមជ្ឈត្តកម្មអាចចេញសេចក្តីបង្គាប់ ឬសេចក្តីណែនាំ ដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប ដោយសេចក្តីបង្គាប់ និងសេចក្តីណែនាំនោះមិនត្រូវផ្ទុយនឹងវិធាននេះ ឬច្បាប់ដែលគ្រប់គ្រងមជ្ឈត្តការឡើយ។ ស្របតាមប្រការ ៤.១ *(ការទាក់ទងជាលាយលក្ខណ៍អក្សរ)* រាល់សេចក្តីបង្គាប់ និងសេចក្តីណែនាំទាំងអស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

លើកលែងតែវេទិកាមជ្ឈត្តកម្មបានកំណត់ផ្សេងពីនេះ គូភាគីវិវាទយល់ព្រមក្នុងការគោរពតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំដោយមិនបង្អង់។

*៣៥.២.ការប្រជុំត្រៀម និងការប្រជុំបន្ថែមនានា*

ភ្លាមៗតាមដែលធ្វើទៅបាន វេទិកាមជ្ឈត្តកម្មអាចរៀបចំការប្រជុំត្រៀមជាមួយគូភាគីវិវាទដោយផ្ទាល់ ឬដោយមធ្យោបាយផ្សេងៗទៀត ដើម្បីរៀបចំ និងកំណត់កាលវិភាគនៃដំណើរការមជ្ឈត្តការបន្ទាប់ ឬ/និង ដើម្បីពិភាក្សាអំពីនីតិវិធីដែលមានភាពសមស្រប និងចំណាយអស់តិចបំផុតសម្រាប់សំណុំរឿង។

បន្ថែមលើការប្រជុំត្រៀម ផេទិកាមជ្ឈត្តកម្មអាចរៀបចំឱ្យមានការប្រជុំបន្ថែម ឧទាហរណ៍ ដូចជាដើម្បីពិនិត្យទីតាំង វត្ថុ ឬឯកសារនានា ដូចមានចែងក្នុងប្រការ ៤០.២ *(ការសាកសួរ សេចក្តីបង្គាប់ និងការពិនិត្យភស្តុតាង)* ឬពិនិត្យលើភាពរីកចម្រើននៃដំណើរការមជ្ឈត្តការ។

ប្រការ ៣៩ *(សវនាការ និងការប្រជុំ)* ត្រូវអនុវត្តចំពោះការប្រជុំត្រៀម និងការប្រជុំបន្ថែមនានាដូចមានចែងក្នុងប្រការនេះ។

### *៣៥.៣.ការស្វែងរកដំណោះស្រាយដោយស្រុះស្រួលគ្នា*

មុនពេល ឬក្នុងអំឡុងពេលប្រជុំត្រៀម ផេទិកាមជ្ឈត្តកម្មត្រូវពិភាក្សាជាមួយគូភាគីវិវាទ ដើម្បីស្វែងរកលទ្ធភាពក្នុងការដោះស្រាយវិវាទដោយស្រុះស្រួលគ្នា និងត្រូវជួយគូភាគីវិវាទក្នុងលក្ខណៈណាមួយដែលផេទិកាមជ្ឈត្តកម្មយល់ថាសមស្រប។

### *៣៥.៤.ការបំបែកដំណើរការមជ្ឈត្តការដាច់ៗពីគ្នា*

បន្ទាប់ពីបានពិភាក្សាជាមួយគូភាគីវិវាទ ផេទិកាមជ្ឈត្តកម្ម តាមរយៈឆន្ទានុសិទ្ធិរបស់ខ្លួន អាចបំបែកដំណើរការមជ្ឈត្តការដាច់ៗពីគ្នា និងកំណត់ឱ្យគូភាគីវិវាទផ្តោតការបង្ហាញនានារបស់ពួកគេលើបញ្ហានានា ដែលសេចក្តីសម្រេចលើបញ្ហាទាំងនោះអាចបំបែកសំណុំរឿងទាំងមូល ឬជាផ្នែក។

### *៣៥.៥.ការចូលរួមពីតតិយជន*

ផេទិកាមជ្ឈត្តកម្មមានអំណាចក្នុងការអនុញ្ញាតឱ្យតតិយជនចូលរួមជាភាគីវិវាទក្នុងដំណើរការមជ្ឈត្តការ ប្រសិនបើគូភាគីវិវាទ រួមទាំងតតិយជនបានព្រមព្រៀងចំពោះការចូលរួមនោះជាលាយលក្ខណ៍អក្សរ។ ក្នុងករណីនេះ ផេទិកាមជ្ឈត្តកម្មអាចចេញជាមជ្ឈត្តវិនិច្ឆ័យស្ថាពរតែមួយ ឬមជ្ឈត្តវិនិច្ឆ័យដោយឡែក សម្រាប់ដោះស្រាយរាល់វិវាទរបស់គូភាគីវិវាទ។

## ប្រការ ៣៦. ការរួមបញ្ចូលមជ្ឈត្តការ

### *៣៦.១.លក្ខខណ្ឌសម្រាប់ការរួមបញ្ចូល*

តាមសំណើរបស់ភាគីវិវាទណាមួយ និងដោយមានការយល់ព្រមពីគូភាគីវិវាទ អគ្គលេខាធិការដ្ឋានអាចរួមបញ្ចូលមជ្ឈត្តការ ២ (ពីរ) ឬច្រើន ដែលត្រូវបានផ្តួចផ្តើមឡើងក្រោមវិធាននេះឱ្យទៅជាមជ្ឈត្តការតែមួយបាន។ អគ្គលេខាធិការ-ដ្ឋានអាចកែប្រែដោយដំឡើង ឬបន្ថយកម្រៃសេវារដ្ឋបាល និងកម្រៃសេវាផេទិកាមជ្ឈត្តកម្ម ផ្អែកតាមកាលៈទេសៈ ដំណាក់កាល និងផលប៉ះពាល់នៃការរួមបញ្ចូលនោះលើសេវាកម្មនានារបស់ ម.ជ.ម. និងរបស់ផេទិកាមជ្ឈត្តកម្ម។

*៣៦.២.កាលៈទេសៈពាក់ព័ន្ធ*

ដើម្បីសម្រេចលើការរួមបញ្ចូលមជ្ឈត្តការ អគ្គលេខាធិការដ្ឋានអាចពិចារណា កាលៈទេសៈផ្សេងៗជាច្រើន ដែលអគ្គលេខាធិការដ្ឋានយល់ថាពាក់ព័ន្ធ រួមបញ្ចូលទាំងកាលៈទេសៈដូចខាងក្រោម៖

(ក) តើការទាមទារទាំងអស់នៅក្នុងមជ្ឈត្តការនានាត្រូវបានធ្វើឡើងក្រោមកិច្ចសន្យាមជ្ឈត្តកម្មតែមួយដែរឬទេ

(ខ) ប្រសិនបើការទាមទារត្រូវបានធ្វើឡើងក្រោមកិច្ចសន្យាមជ្ឈត្តកម្មផ្សេងគ្នា ហើយមជ្ឈត្តការធ្វើឡើងរវាងភាគីវិវាទដូចគ្នា តើវិវាទនានានៅក្នុងមជ្ឈត្តការទាំងនោះ កើតឡើងពាក់ព័ន្ធនឹងទំនាក់ទំនងគតិយុត្តិដូចគ្នាតែមួយ និងកិច្ចសន្យាមជ្ឈត្តកម្មទាំងនោះត្រូវបានចាត់ទុកថាមិនផ្ទុយគ្នាដែរឬទេ និង

(គ) តើមជ្ឈត្តករត្រូវបានតែងតាំងសម្រាប់មជ្ឈត្តការលើសពីមួយដែរឬទេ និងប្រសិនបើបានតែងតាំង តើមជ្ឈត្តករដែលត្រូវបានតែងតាំងនោះជាមជ្ឈត្តករតែមួយ ឬផ្សេងគ្នា។

*៣៦.៣.ការរួមបញ្ចូលមជ្ឈត្តការនានាទៅក្នុងមជ្ឈត្តការដំបូងដែលបានទទួល និងចាប់ផ្តើម*

លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ នៅពេលរួមបញ្ចូលគ្នានូវមជ្ឈត្តការនានា មជ្ឈត្តការទាំងនោះត្រូវរួមបញ្ចូលទៅក្នុងមជ្ឈត្តការមួយដែលអគ្គលេខាធិការដ្ឋានបានទទួលដំបូងគេបង្អស់នូវសេចក្តីជូនដំណឹងអំពីមជ្ឈត្តការនោះ ប្រសិនបើមិនទាន់មានមជ្ឈត្តការណាមួយត្រូវបានចាប់ផ្តើមដំណើរការនៅឡើយទេនោះ ឬទៅក្នុងមជ្ឈត្តការមួយដែលបានដំណើរការមុនគេ ប្រសិនបើមជ្ឈត្តការនៃសំណុំរឿងត្រូវបានចាប់ផ្តើមហើយនោះ។

## ប្រការ ៣៧. ការដាក់សេចក្តីថ្លែងដោយគូភាគីវិវាទ

*៣៧.១.ការដាក់សេចក្តីថ្លែង*

លើកលែងតែវេទិកាមជ្ឈត្តកម្មបានកំណត់ផ្សេងពីនេះ ក្រោយពីបានពិភាក្សាជាមួយគូភាគីវិវាទ ការដាក់សេចក្តីថ្លែងត្រូវធ្វើឡើងស្របតាមប្រការ ៣៧ *(ការដាក់សេចក្តីថ្លែងដោយគូភាគីវិវាទ)*។

*៣៧.២.សេចក្តីថ្លែងទាមទារ*

លើកលែងតែសេចក្តីថ្លែងទាមទារត្រូវបានដាក់រួចហើយស្របតាមប្រការ ៧.៤ *(ការភ្ជាប់សេចក្តីថ្លែងទាមទារ)* ភាគីប្តឹងទាមទារ ក្នុងអំឡុងពេលដែលនឹងត្រូវកំណត់ដោយវេទិកាមជ្ឈត្តកម្ម ត្រូវដាក់សេចក្តីថ្លែងទាមទារដែលមានបញ្ជាក់សេចក្តីលម្អិតដូចខាងក្រោម៖

(ក) អង្គហេតុដែលគាំទ្រការទាមទារនោះ

(ខ) មូលដ្ឋានច្បាប់ ឬទឡ្ហីករណ៍តាមផ្លូវច្បាប់ដែលគាំទ្រការទាមទារនោះ និង

(គ) សំណងការខូចខាត ឬការសង្គ្រោះដែលទាមទារ ព្រមជាមួយចំនួនទឹកប្រាក់នៃការទាមទារដែលអាចកំណត់បានទាំងអស់។

## *៣៧.៣.សេចក្ដីថ្លែងដោះសា និងបណ្ដឹងតប*

លើកលែងតែសេចក្ដីថ្លែងដោះសាត្រូវបានប្រគល់រួចហើយស្របតាមប្រការ ៨.៤ *(ការភ្ជាប់សេចក្ដីថ្លែងដោះសា និងទឡ្ហីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម)* ភាគីឆ្លើយតប ក្នុងអំឡុងពេលដែលនឹងត្រូវកំណត់ដោយវេទិកាមជ្ឈត្តកម្ម ត្រូវដាក់សេចក្ដីថ្លែងដោះសាដែលមានបញ្ជាក់សេចក្ដីលម្អិតដូចខាងក្រោមៈ

(ក) អង្គហេតុ និងអំណះអំណាងតាមផ្លូវច្បាប់ក្នុងសេចក្ដីថ្លែងទាមទារដែលភាគីឆ្លើយតបទទួលស្គាល់

(ខ) អង្គហេតុ និងអំណះអំណាងតាមផ្លូវច្បាប់ក្នុងសេចក្ដីថ្លែងទាមទារដែលភាគីឆ្លើយតបបដិសេធ និងមូលហេតុនៃការបដិសេធនោះ និង

(គ) អង្គហេតុ និងអំណះអំណាងតាមផ្លូវច្បាប់ផ្សេងទៀត ដែលភាគីឆ្លើយតបផ្អែកជាមូលដ្ឋាន។

សេចក្ដីថ្លែងដោះសាអាចមានបញ្ចូលផងដែរនូវបណ្ដឹងតប ឬការដោះសាតាមការកាត់កងល្មើកណាបណ្ដឹងតប ឬការដោះសាតាមការកាត់កងនោះស្ថិតក្នុងយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម ដែលត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនានានៃប្រការ ៣៧.២ *(សេចក្ដីថ្លែងទាមទារ)*។

## *៣៧.៤.សេចក្ដីថ្លែងដោះសាចំពោះបណ្ដឹងតប*

ប្រសិនបើបណ្ដឹងតបត្រូវបានធ្វើឡើង ភាគីប្ដឹងទាមទារ ក្នុងកំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្ដីថ្លែងដោះសា ត្រូវបញ្ជូនសេចក្ដីថ្លែងដោះសាចំពោះបណ្ដឹងតបនោះ ដោយសេចក្ដីថ្លែងដោះសានោះត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនានានៃប្រការ ៣៧.៣ *(សេចក្ដីថ្លែងដោះសា និងបណ្ដឹងតប)*។

## *៣៧.៥.ការដាក់សេចក្ដីថ្លែងបន្ថែម*

វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថា តើសេចក្ដីថ្លែងបន្ថែមណាមួយ ប្រសិនបើមានដែលត្រូវតម្រូវពីគូភាគីវិវាទ ឬដែលអាចបង្ហាញដោយគូភាគីវិវាទ។ វេទិកាមជ្ឈត្តកម្មត្រូវកំណត់រយៈពេលសម្រាប់ការដាក់សេចក្ដីថ្លែងបន្ថែមទាំងនោះ។

*៣៧.៦.ឯកសារយោង*

ការដាក់សេចក្តីថ្លែងដូចមានចែងក្នុងប្រការ ៣៧ *(ការដាក់សេចក្តីថ្លែងដោយគូភាគីវិវាទ)* ត្រូវអមដោយសំណៅចម្លងនៃឯកសារយោងទាំងអស់ដែលភាគីវិវាទណាមួយមិនទាន់បានដាក់ពីមុន។

*៣៧.៧.ការបំពានកាតព្វកិច្ច និងការមិនគោរពតាមវិធាន*

ប្រសិនបើភាគីប្តឹងទាមទារខកខានក្នុងការដាក់សេចក្តីថ្លែងទាមទារដោយមិនបានបង្ហាញពីមូលហេតុគ្រប់គ្រាន់នៅក្នុងអំឡុងពេលកំណត់ និងប្រសិនបើសមស្រប វេទិកាមជ្ឈត្តកម្មត្រូវចេញសេចក្តីបង្គាប់ឱ្យបញ្ឈប់ដំណើរការមជ្ឈត្តការ បន្ទាប់ពីសម្រេចលើបញ្ហាផ្សេងទៀតដែលនៅសេសសល់ និងដែលត្រូវដោះស្រាយ។

នៅគ្រប់ករណីទាំងអស់ ដោយមិនបានបង្ហាញពីមូលហេតុគ្រប់គ្រាន់ ប្រសិនបើភាគីវិវាទណាមួយខកខាន ឬបដិសេធក្នុងការដាក់សេចក្តីថ្លែងនានាដែលតម្រូវក្នុងការចូលរួមក្នុងវេទិកាមជ្ឈត្តកម្ម ឬក្នុងការគោរពតាមវិធាននេះ ឬសេចក្តីបង្គាប់ សេចក្តីណែនាំ ឬមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម វេទិកាមជ្ឈត្តកម្ម តាមការសមស្រប អាចដំណើរការមជ្ឈត្តកម្ម និងចេញមជ្ឈត្តវិនិច្ឆ័យដោយផ្អែកតាមសេចក្តីថ្លែង និងភស្តុតាងដែលបានដាក់មកវេទិកាមជ្ឈត្តកម្ម។

## ប្រការ ៣៨. ការដកពាក្យបណ្តឹង ការកែប្រែ និងការដោះសា

*៣៨.១.ការដកពាក្យបណ្តឹង*

បន្ទាប់ពីមានសេចក្តីជូនដំណឹងទៅវេទិកាមជ្ឈត្តកម្ម ភាគីប្តឹងទាមទារមានសិទ្ធិក្នុងការដកពាក្យបណ្តឹងរបស់ខ្លួន លើកលែងតែភាគីឆ្លើយតបជំទាស់ និងវេទិកាមជ្ឈត្តកម្មទទួលស្គាល់ផលប្រយោជន៍ស្របច្បាប់របស់ភាគីឆ្លើយតបក្នុងការទទួលបានសេចក្តីសម្រេចស្ថាពរលើវិវាទ។ ក្នុងករណីដែលមានការដកពាក្យបណ្តឹង វេទិកាមជ្ឈត្តកម្មត្រូវចេញសេចក្តីបង្គាប់បញ្ឈប់ដំណើរការមជ្ឈត្តការ។

*៣៨.២.ការកែប្រែពាក្យបណ្តឹង និងការកែប្រែការដោះសា*

ក្នុងដំណើរការមជ្ឈត្តការ ភាគីវិវាទណាមួយអាចកែប្រែ ឬបន្ថែមការទាមទារ ការដោះសាបណ្តឹងតប ឬការដោះសាតាមការកាត់កង លើកលែងតែវេទិកាមជ្ឈត្តកម្មយល់ថាការកែប្រែ ឬការបន្ថែមនោះមិនសមស្របដោយសារការកែប្រែ ឬការបន្ថែមនោះនឹងពន្យារដំណើរការមជ្ឈត្តការ និងបង្កឱ្យមានសេចក្តីលំអៀងដល់ភាគីវិវាទម្ខាងទៀត ឬកាលៈទេសៈផ្សេងទៀត។ ទោះបីជាយ៉ាងណាក៏ដោយភាគីវិវាទមួយមិនអាចកែប្រែ ឬបន្ថែមលើពាក្យបណ្តឹង ឬការដោះសាបានឡើយ ប្រសិនបើការកែប្រែ ឬការបន្ថែមលើពាក្យបណ្តឹង ឬការដោះសានោះស្ថិតនៅក្រៅយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម។

## ប្រការ ៣៩. សវនាការ និងការប្រជុំ

### *៣៩.១.សវនាការ*

លើកលែងតែគូភាគីវិវាទបានព្រមព្រៀងអំពីរបៀបនៃការធ្វើសវនាការ (ដូចជាការព្រមព្រៀងធ្វើសវនាការដោយផ្ទាល់មាត់ ឬដោយផ្អែកលើឯកសារ និងលិខិតស្នាមផ្សេងៗ) វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថាតើត្រូវធ្វើសវនាការដោយផ្ទាល់មាត់ ឬត្រូវដំណើរការមជ្ឈត្តការដោយផ្អែកលើឯកសារ និងលិខិតស្នាមផ្សេងៗតែប៉ុណ្ណោះ។

ប្រសិនបើមានការស្នើសុំដោយភាគីវិវាទណាមួយ វេទិកាមជ្ឈត្តកម្មត្រូវធ្វើសវនាការដោយផ្ទាល់មាត់នៅដំណាក់កាលសមរម្យណាមួយនៃដំណើរការមជ្ឈត្តការ។

ក្នុងករណីដែលសវនាការដោយផ្ទាល់មាត់នឹងត្រូវធ្វើឡើង វេទិកាមជ្ឈត្តកម្មអាចសម្រេចថា សវនាការនោះត្រូវធ្វើឡើងដោយមានការចូលរួមដោយផ្ទាល់ ឬពីចម្ងាយតាមរយៈសន្និសីទវីដេអូ ទូរស័ព្ទ ឬមធ្យោបាយទាក់ទងអេឡិចត្រូនិចផ្សេងទៀតជាមួយអ្នកចូលរួមដែលស្ថិតនៅទីកន្លែងមួយ ឬច្រើន (ឬក្នុងទម្រង់រួមបញ្ចូលគ្នា) បន្ទាប់ពីបានពិភាក្សាជាមួយគូភាគីវិវាទ និងដោយផ្អែកលើអង្គហេតុពាក់ព័ន្ធ និងកាលៈទេសៈរបស់សំណុំរឿង។

### *៣៩.២.សវនាការបន្ថែម*

លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ នៅក្នុងដំណាក់កាលណាមួយនៃដំណើរការមជ្ឈត្តការ និងនៅមុនពេលចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ វេទិកាមជ្ឈត្តកម្មអាចសម្រេចឱ្យមានសវនាការបន្ថែម ប្រសិនបើកាលៈទេសៈនៃមជ្ឈត្តការតម្រូវ។

### *៣៩.៣.ទីកន្លែងប្រជុំ និងសវនាការ*

ទោះបីជាទីកន្លែងធ្វើមជ្ឈត្តការត្រូវបានកំណត់ដូចមានចែងក្នុងប្រការ ៣១ *(ទីកន្លែងធ្វើមជ្ឈត្តការ)* ក៏ដោយ ក៏វេទិកាមជ្ឈត្តកម្មអាចរៀបចំការប្រជុំ និងសវនាការតាមមធ្យោបាយណាមួយផ្សេងទៀត និងនៅទីកន្លែងណាមួយផ្សេងទៀតដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប។

### *៣៩.៤.សេចក្តីជូនដំណឹងអំពីសវនាការ*

វេទិកាមជ្ឈត្តកម្មត្រូវកំណត់កាលបរិច្ឆេទ ពេលវេលា ទីកន្លែង និងរបៀបនៃការធ្វើសវនាការ និងត្រូវផ្តល់ដំណឹងជាមុនទៅគូភាគីវិវាទអំពីបញ្ហាទាំងនេះយ៉ាងហោចណាស់ ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន មុនកាលបរិច្ឆេទធ្វើសវនាការ។

ប្រសិនបើភាគីវិវាទនៃដំណើរការមជ្ឈត្តការខកខានក្នុងការបង្ហាញខ្លួននៅក្នុងសវនាការដោយផ្ទាល់មាត់ដោយមិនបានបង្ហាញមូលហេតុគ្រប់គ្រាន់នៃការខក-ខាននេះ វេទិកាមជ្ឈត្តកម្មអាចបន្តធ្វើមជ្ឈត្តកម្ម និងអាចចេញមជ្ឈត្តវិនិច្ឆ័យដោយផ្អែកលើសេចក្តីថ្លែង និងភស្តុតាងដែលបានដាក់មកវេទិកាមជ្ឈត្តកម្ម។

### *៣៩.៥.បញ្ជីនៃចំណុចវិវាទ និងសំណួរមុនពេលមានសវនាការ*

យ៉ាងហោចណាស់ ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន មុនពេលធ្វើសវនាការ វេទិកាមជ្ឈត្តកម្ម អាចផ្ដល់ដល់គូភាគីវិវាទនូវបញ្ជីនៃចំណុចវិវាទ ឬសំណួរដែលវេទិកាមជ្ឈត្តកម្ម មានបំណងឱ្យភាគីវិវាទទាំងអស់ពិចារណាជាពិសេស។

### *៣៩.៦.វត្តមានក្នុងពេលសវនាការ ការបកប្រែ និងការកត់ត្រា*

វេទិកាមជ្ឈត្តកម្មត្រូវទទួលបន្ទុកគ្រប់គ្រងទាំងស្រុងលើសវនាការ ដែលគូភាគីវិវាទ ទាំងអស់ត្រូវមានសិទ្ធិចូលរួម។ លើកលែងតែមានការឯកភាពពីវេទិកាមជ្ឈត្តកម្ម និងគូភាគីវិវាទ អ្នកដែលមិនពាក់ព័ន្ធនឹងដំណើរការនីតិវិធីមិនត្រូវអនុញ្ញាតឱ្យ ចូលរួមឡើយ។

គ្រប់សវនាការទាំងអស់ត្រូវធ្វើឡើងជាលក្ខណៈឯកជន លើកលែងតែភាគីវិវាទបាន ព្រមព្រៀងផ្សេងពីនេះ។ ស្របតាមប្រការ ៣៣.២ *(ការបកប្រែ)* វេទិកាមជ្ឈត្តកម្មអាច បង្គាប់ឱ្យបកប្រែការទាក់ទងដោយផ្ទាល់មាត់ ឬការទាក់ទងជាលាយលក្ខណ៍អក្សរ ណាមួយដែលត្រូវបានធ្វើឡើង ឬត្រូវបានដាក់ក្នុងពេលសវនាការ។

វេទិកាមជ្ឈត្តកម្មអាចសម្រេចថា តើសវនាការដោយផ្ទាល់មាត់នឹងត្រូវកត់ត្រា និង ថាតើការកត់ត្រានោះនឹងត្រូវធ្វើដោយរបៀបណា។

## ប្រការ ៤០. បញ្ញត្តិទូទៅអំពីភស្តុតាង

### *៤០.១.បន្ទុកបង្ហាញភស្តុតាង*

ភាគីវិវាទនីមួយៗត្រូវមានបន្ទុកបង្ហាញអង្គហេតុ វិធានដែលត្រូវអនុវត្ត និងទម្លាប់ ពាណិជ្ជកម្មនានាដែលជាមូលដ្ឋាននៃការទាមទារ ឬបណ្ដឹងតប ឬការដោះសា របស់ភាគីវិវាទ។

### *៤០.២.ការសាកសួរ សេចក្ដីបង្គាប់ និងការពិនិត្យភស្តុតាង*

នៅពេលណាមួយនៃអំឡុងពេលនៃដំណើរការមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មអាច រៀបចំឱ្យមានការសាកសួរ ឬបង្គាប់ភាគីវិវាទណាមួយផ្ដល់ការបង្ហាញផ្សេងៗ ដែលវេទិកាមជ្ឈត្តកម្មយល់ថាចាំបាច់ ឬសមស្រប ដូចជា៖

(ក) ផ្ដល់ឯកសារ វត្ថុតាង ឬភស្តុតាងផ្សេងទៀត

(ខ) ផ្ដល់តារាងរៀបតាមអក្សរ ឬសេចក្ដីសង្ខេបរបស់ឯកសារ ឬភស្តុតាងផ្សេង ទៀតដែលភាគីវិវាទនោះបានបង្ហាញ ឬមានបំណងបង្ហាញ

(គ) ផ្ដល់ទីកន្លែង វត្ថុ ឬឯកសារនានាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន សម្រាប់វេទិកាមជ្ឈត្តកម្ម ភាគីវិវាទម្ខាងទៀត ឬអ្នកជំនាញដែលត្រូវបាន តែងតាំងដោយវេទិកាមជ្ឈត្តកម្មធ្វើការត្រួតពិនិត្យ និង

(ឃ) រៀបចំការយកគំរូដែលត្រូវយកពីទីកន្លែង វត្ថុ ឬឯកសារ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគីវិវាទ ឬរៀបចំឱ្យមានការអង្កេតលើ ឬការពិសោធលើដែលគំរូនោះនឹងត្រូវយកទៅពិនិត្យ ឬសម្រាប់ការពិសោធណាមួយទាំងនោះ។

ភាគីវិវាទមានសិទ្ធិក្នុងការត្រួតពិនិត្យភស្តុតាងដែលបង្ហាញដោយភាគីវិវាទម្ខាងទៀត។

*៤០.៣.ភាពអាចទទួលយកបាននៃភស្តុតាង*

វេទិកាមជ្ឈត្តកម្មត្រូវកំណត់អំពីភាពអាចទទួលយកបាន ទំនាក់ទំនង សារៈសំខាន់ និងទម្ងន់នៃភស្តុតាងទាំងអស់។ វេទិកាមជ្ឈត្តកម្មមិនត្រូវបានតម្រូវឱ្យអនុវត្តវិធាននៃភស្តុតាងនៃច្បាប់ណាមួយឡើយក្នុងការធ្វើការកំណត់នោះ។

## ប្រការ ៤១. សាក្សី

*៤១.១.សេចក្តីជូនដំណឹងជាមុនដោយភាគីវិវាទ*

នៅមុនពេលដំណើរការសវនាការ វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យភាគីវិវាទនីមួយៗផ្តល់សេចក្តីជូនដំណឹងជាមុនអំពីអត្តសញ្ញាណរបស់សាក្សី ដោយរួមបញ្ចូលទាំងសាក្សីជំនាញផងដែរនៅក្នុងប្រការ ៤១ *(សាក្សី)* នេះ ដែលភាគីវិវាទនីមួយៗមានបំណងកោះហៅ ក៏ដូចជាអំពីកម្មវត្ថុ និងទំនាក់ទំនងនៃសក្ខីកម្មរបស់សាក្សី រួមទាំងភាសាដែលសាក្សីនោះនឹងប្រើក្នុងការធ្វើសក្ខីកម្ម។

*៤១.២.ការអនុញ្ញាត ការកម្រិត ឬការបដិសេធការបង្ហាញរបស់សាក្សី*

វេទិកាមជ្ឈត្តកម្មមានឆន្ទានុសិទ្ធិក្នុងការអនុញ្ញាត ការកម្រិត ឬការបដិសេធការបង្ហាញរបស់សាក្សី។

*៤១.៣.សក្ខីកម្មជាលាយលក្ខណ៍អក្សរ*

វេទិកាមជ្ឈត្តកម្មអាចកំណត់ឱ្យសាក្សីធ្វើសក្ខីកម្មជាលាយលក្ខណ៍អក្សរ ឬក្នុងទម្រង់ផ្សេងទៀតសម្រាប់ធ្វើកំណត់ត្រា។ ស្របតាមប្រការ ៤១.២ *(ការអនុញ្ញាត ការកម្រិត ឬការបដិសេធការបង្ហាញរបស់សាក្សី)* ភាគីវិវាទអាចស្នើឱ្យសាក្សីចូលរួមក្នុងការសាកសួរផ្ទាល់មាត់។ ប្រសិនបើសាក្សីខកខានក្នុងការចូលរួមការសាកសួរផ្ទាល់មាត់ វេទិកាមជ្ឈត្តកម្មអាចដាក់ទម្ងន់នៃការពិចារណារបស់ខ្លួនលើសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប ឬទាត់ចោល ឬលុបចោល សក្ខីកម្មនោះទាំងស្រុង។

*៤១.៤.ការសាកសួរសាក្សី*

សាក្សីណាម្នាក់ ដែលផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ អាចត្រូវបានសាកសួរដោយវេទិកាមជ្ឈត្តកម្ម និងដោយភាគីវិវាទនីមួយៗក្នុងទម្រង់ណាមួយដែលវេទិកាមជ្ឈត្តកម្មបានកំណត់។

*៤១.៥.ការស្បថ ឬការអះអាង*

សាក្សីណាម្នាក់អាចត្រូវបានវេទិកាមជ្ឈត្តកម្មតម្រូវឱ្យធ្វើសក្ខីកម្មក្រោមសម្បថ ឬការអះអាង។

*៤១.៦.ការចាកចេញរបស់សាក្សី*

វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យសាក្សីណាម្នាក់ចាកចេញពីសវនាការក្នុងអំឡុងពេលសាកសួរសាក្សីដទៃទៀត។

## ប្រការ ៤២. អ្នកជំនាញដែលតែងតាំងដោយវេទិកាមជ្ឈត្តកម្ម

*៤២.១.ការតែងតាំងអ្នកជំនាញ*

លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ក្រោយពីការពិភាក្សាជាមួយគូភាគីវិវាទ វេទិកាមជ្ឈត្តកម្មអាចតែងតាំងអ្នកជំនាញឯករាជ្យមួយរូប ឬច្រើនរូបឱ្យធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅវេទិកាមជ្ឈត្តកម្ម អំពីចំណុចវិវាទជាក់លាក់ណាមួយដែលវេទិកាមជ្ឈត្តកម្មបានកំណត់។ វេទិកាមជ្ឈត្តកម្មត្រូវផ្តល់ដល់គូភាគីវិវាទនូវការកំណត់របស់ខ្លួនអំពីចំណុចវិវាទជាក់លាក់ដែលតម្រូវឱ្យអ្នកជំនាញឯករាជ្យធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរនោះ។

វេទិកាមជ្ឈត្តកម្មអាចតម្រូវភាគីវិវាទផ្តល់ព័ត៌មានពាក់ព័ន្ធដល់អ្នកជំនាញ ឬបង្ហាញ ឬអនុញ្ញាតឱ្យអ្នកជំនាញពិនិត្យទីតាំង ទំនិញ ទ្រព្យ ឬឯកសារផ្សេងៗ។

*៤២.២.របាយការណ៍ជាលាយលក្ខណ៍អក្សរ និងយោបល់របស់គូភាគីវិវាទ*

អ្នកជំនាញដែលត្រូវបានតែងតាំង ត្រូវដាក់របាយការណ៍ជាលាយលក្ខណ៍អក្សររបស់ខ្លួនទៅវេទិកាមជ្ឈត្តកម្ម។ ក្រោយពីបានទទួលរបាយការណ៍នោះហើយ វេទិកាមជ្ឈត្តកម្មត្រូវបញ្ជូនរបាយការណ៍មួយច្បាប់ទៅគូភាគីវិវាទ និងស្នើឱ្យគូភាគីវិវាទផ្តល់យោបល់របស់ពួកគេជាលាយលក្ខណ៍អក្សរលើរបាយការណ៍នោះ។

*៤២.៣.ការចូលរួមរបស់អ្នកជំនាញក្នុងសវនាការ*

លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ប្រសិនបើវេទិកាមជ្ឈត្តកម្មយល់ថាចាំបាច់ អ្នកជំនាញត្រូវចូលរួមក្នុងសវនាការតាមប្រការ ៤២.១ *(ការតែងតាំងអ្នកជំនាញ)* បន្ទាប់ពីបានដាក់របាយការណ៍ជាលាយលក្ខណ៍អក្សររបស់ខ្លួនរួចហើយ។ ក្នុងពេលធ្វើសវនាការ គូភាគីវិវាទត្រូវមានឱកាសក្នុងការសាកសួរអ្នកជំនាញនោះ។

## ប្រការ ៤៣. វិធានការបណ្តោះអាសន្ន

### *៤៣.១.វិធានការបណ្តោះអាសន្ន*

តាមសំណើរបស់ភាគីវិវាទណាមួយ ផលទិកាមជ្ឈត្តកម្មអាចចាត់វិធានការបណ្តោះអាសន្នតាមរយៈការចេញមជ្ឈត្តវិនិច្ឆ័យដែលមានមូលហេតុ ឬសេចក្តីបង្គាប់នៅពេលណាមួយមុនពេលចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ។

### *៤៣.២.គោលបំណងនៃវិធានការបណ្តោះអាសន្ន*

វិធានការបណ្តោះអាសន្នមានលក្ខណៈជាវិធានការដែលចាំបាច់ និងបន្ទាន់ ដែលមិនត្រូវប៉ះពាល់ដល់សេចក្តីសម្រេចស្ថាពររបស់ផលទិកាមជ្ឈត្តកម្មចំពោះអង្គសេចក្តីនៃសំណុំរឿងឡើយ។ ជាឧទាហរណ៍ វិធានការបណ្តោះអាសន្នរួមមានជាអាទិ៍ នូវសេចក្តីបង្គាប់នានា៖

(ក) ដើម្បីថែរក្សា និងស្តារស្ថានភាពឡើងវិញក្នុងពេលដែលវិវាទមិនទាន់ត្រូវបានដោះស្រាយ

(ខ) ដើម្បីចំណាត់ការសកម្មភាពក្នុងគោលបំណងរារាំង ឬទប់ស្កាត់ការធ្វើសកម្មភាពដែលអាចបង្កឱ្យមាន (i) ការខូចខាតបច្ចុប្បន្ន ឬបន្ទាន់ ឬ (ii) សេចក្តីលម្អៀងចំពោះដំណើរការមជ្ឈត្តការ

(គ) ដើម្បីផ្តល់មធ្យោបាយក្នុងការថែរក្សាទ្រព្យសម្បត្តិដែលអាចទាក់ទងនឹងការបំពេញតាមមជ្ឈត្តវិនិច្ឆ័យបន្ទាប់ ឬ

(ឃ) ដើម្បីរក្សាទុកភស្តុតាងដែលអាចពាក់ព័ន្ធ និងដែលមានសារៈសំខាន់សម្រាប់ការដោះស្រាយវិវាទ។

### *៤៣.៣.សំណើតាមរយៈសេចក្តីថ្លែងដោយឡែក*

សំណើសុំវិធានការបណ្តោះអាសន្នត្រូវបញ្ជូនទៅផលទិកាមជ្ឈត្តកម្មតាមរយៈសេចក្តីថ្លែងដោយឡែក។ សេចក្តីថ្លែងត្រូវមានការពណ៌នាច្បាស់លាស់អំពីវិធានការបណ្តោះអាសន្នដែលស្នើសុំ និងមូលហេតុនៃសំណើក៏ដូចជាភាពចាំបាច់ និងភាពបន្ទាន់ដែលត្រូវបានអះអាង។ ប្រសិនបើអាច ភស្តុតាងដែលជាមូលដ្ឋាននៃការស្នើសុំត្រូវបញ្ជូនរួមគ្នាជាមួយសេចក្តីថ្លែង ប្រសិនបើសេចក្តីថ្លែងនោះមិនទាន់ត្រូវបានបញ្ជូនទៅផលទិកាមជ្ឈត្តកម្មនៅឡើយក្នុងដំណើរការមជ្ឈត្តការ។

### *៤៣.៤.នីតិវិធីបន្ថែម*

បន្ទាប់ពីបានទទួលសំណើសុំវិធានការបណ្តោះអាសន្នហើយ ផលទិកាមជ្ឈត្តកម្ម ដោយមិនពន្យារពេល ត្រូវជូនដំណឹងទៅគូភាគីវិវាទអំពីរបៀបដែលផលទិកាមជ្ឈត្តកម្មនឹងចាត់ដំណើរការ ជាពិសេសថាតើនឹងមានសវនាការ ឬក៏តម្រូវឱ្យមានសេចក្តីថ្លែងបន្ថែម។

### ៤៣.៥.ការផ្តល់ការធានា

លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មអាចតម្រូវថា ការចេញវិធានបណ្តោះអាសន្នត្រូវមានការធានាសមស្របណាមួយ ដែលផ្តល់ដោយភាគីវិវាទដែលបានស្នើ ដើម្បីធានាសោហ៊ុយចំណាយ ឬការខូចខាតនានា ដែលទទួលរងដោយភាគីវិវាទម្ខាងទៀតដោយសារវិធានការបណ្តោះអាសន្ន ដែលចេញដោយវេទិកាមជ្ឈត្តកម្ម។

ភាគីវិវាទដែលស្នើសុំវិធានការបណ្តោះអាសន្ន អាចត្រូវទទួលខុសត្រូវចំពោះសោហ៊ុយចំណាយ និងការខូចខាត ដែលកើតចេញពីវិធានការបណ្តោះអាសន្ន ទៅភាគីម្ខាងទៀត ប្រសិនបើនាពេលក្រោយមក វេទិកាមជ្ឈត្តកម្មយល់ឃើញថា នៅក្នុងកាលៈទេសៈជាទូទៅ វិធានការបណ្តោះអាសន្នមិនគួរត្រូវបានផ្តល់ឱ្យនោះទេ។ វេទិកាមជ្ឈត្តកម្មអាចសម្រេចឱ្យសងសោហ៊ុយចំណាយ និងការខូចខាតទាំងនោះនៅក្នុងពេលណាមួយនៃដំណើរការមជ្ឈត្តការ។

### ៤៣.៦.ការសម្រេចដោយវេទិកាមជ្ឈត្តកម្ម

វេទិកាមជ្ឈត្តកម្មត្រូវផ្តល់វិធានការបណ្តោះអាសន្នតាមការស្នើសុំ តែក្នុងករណីដែលវេទិកាមជ្ឈត្តកម្មយល់ថា វិធានការបណ្តោះអាសន្ននោះត្រូវការជាចាំបាច់ និងបន្ទាន់។ ប្រសិនបើវេទិកាមជ្ឈត្តកម្មកំណត់ថា បញ្ហានោះមិនចាំបាច់ និងបន្ទាន់ដែលត្រូវសម្រេចដោយវិធានការបណ្តោះអាសន្នទេនោះ វេទិកាមជ្ឈត្តកម្មត្រូវបដិសេធសំណើនោះទាំងស្រុង ឬដោយផ្នែក ហើយវេទិកាមជ្ឈត្តកម្មអាចកំណត់ថាបញ្ហានោះត្រូវសម្រេចនៅក្នុងមជ្ឈត្តកម្មលើអង្គសេចក្តី។

វេទិកាមជ្ឈត្តកម្មអាចចាត់ទុកសំណើសុំវិធានការបណ្តោះអាសន្នថាមានភាពចាំបាច់ និងបន្ទាន់ ប្រសិនបើភាគីវិវាទដែលស្នើសុំវិធានការបណ្តោះអាសន្នអាចបង្ហាញថា៖

(ក) ការខូចខាតដែលមិនអាចត្រូវបានជួសជុលដោយសំណងក្នុងមជ្ឈត្តវិនិច្ឆ័យ ទំនងជានឹងកើតមានឡើង ប្រសិនបើវិធានការបណ្តោះអាសន្នមិនត្រូវបានចាត់ឡើង ហើយការខូចខាតនោះមានលក្ខណៈធ្ងន់ធ្ងរជាងការខូចខាតរបស់ភាគីវិវាទម្ខាងទៀតដែលអាចទទួលរងដោយសារវិធានការបណ្តោះអាសន្ន ប្រសិនបើវិធានការបណ្តោះអាសន្ននោះត្រូវបានផ្តល់ឱ្យ និង

(ខ) មានលទ្ធភាពសមហេតុសមផលដែលភាគីស្នើសុំនឹងឈ្នះលើអង្គសេចក្តីនៃការទាមទារ។ ការកំណត់អំពីលទ្ធភាពនេះមិនប៉ះពាល់ដល់ឆន្ទានុសិទ្ធិរបស់វេទិកាមជ្ឈត្តកម្មក្នុងការធ្វើសេចក្តីសម្រេចណាមួយនាពេលបន្ទាប់ឡើយ។

### *៤៣.៧.ការកែប្រែ ការផ្អាក ឬការបញ្ឈប់វិធានការបណ្ដោះអាសន្ន*

វេទិកាមជ្ឈត្តកម្មអាចកែប្រែ ផ្អាក ឬបញ្ឈប់វិធានការបណ្ដោះអាសន្នដែលវេទិកាមជ្ឈត្តកម្មបានចាត់នៅពេលមានការស្នើសុំពីភាគីវិវាទណាមួយ។

វេទិកាមជ្ឈត្តកម្មអាចស្នើសុំឱ្យភាគីណាមួយបង្ហាញជាបន្ទាន់នូវការផ្លាស់ប្ដូរសំខាន់ណាមួយនៃកាលៈទេសៈដែលជាមូលដ្ឋាននៃការស្នើសុំ ឬការផ្ដល់វិធានការបណ្ដោះអាសន្ននោះ។

### *៤៣.៨.សំណើទៅតុលាការសុំវិធានការបណ្ដោះអាសន្ន*

សំណើសុំវិធានការបណ្ដោះអាសន្នដែលធ្វើឡើងមុន ឬក្នុងអំឡុងពេលដំណើរការមជ្ឈត្តការដោយភាគីវិវាទណាមួយទៅតុលាការមិនមានវិសមិតភាពជាមួយការព្រមព្រៀងក្នុងការធ្វើមជ្ឈត្តការ ឬមិនត្រូវចាត់ទុកជាការបោះបង់ការព្រមព្រៀងនោះទេ និងមិនត្រូវប៉ះពាល់ដល់អំណាចពាក់ព័ន្ធរបស់វេទិកាមជ្ឈត្តកម្មឡើយ។

ភ្លាមតាមដែលអាចធ្វើទៅបាន ភាគីវិវាទដែលបានដាក់សំណើសុំវិធានការបណ្ដោះអាសន្នទៅតុលាការត្រូវជូនដំណឹងទៅវេទិកាមជ្ឈត្តកម្មអំពីសំណើនោះ និងអំពីការសម្រេចរបស់តុលាការអំពីបញ្ហានោះ។

## ប្រការ ៤៤. ការបញ្ចប់ និងការបើកដំណើរការមជ្ឈត្តការជាថ្មី

បន្ទាប់ពីបានពិភាក្សាជាមួយគូភាគីវិវាទ វេទិកាមជ្ឈត្តកម្មត្រូវប្រកាសបញ្ចប់ដំណើរការមជ្ឈត្តការនៅពេលដែលវេទិកាមជ្ឈត្តកម្មយល់ថា គូភាគីវិវាទមិនមានភស្តុតាងពាក់ព័ន្ធ និងសំខាន់បន្ថែមដែលត្រូវបង្ហាញ ឬត្រូវបញ្ជូនមកវេទិកាមជ្ឈត្តកម្មទៀតទេ។ បន្ទាប់ពីនោះ មិនត្រូវដាក់ ឬបង្ហាញភស្តុតាងបន្ថែមឡើយ។ ការប្រកាសរបស់វេទិកាមជ្ឈត្តកម្មអំពីការបញ្ចប់ដំណើរការមជ្ឈត្តការត្រូវបញ្ជូនជាដំណឹងទៅគូភាគីវិវាទ និងទៅអគ្គលេខាធិការដ្ឋាន។

វេទិកាមជ្ឈត្តកម្មត្រូវប្រកាសបញ្ចប់ដំណើរការមជ្ឈត្តការក្នុងអំឡុងពេល ៤៥ (សែសិបប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីថ្ងៃសវនាការចុងក្រោយ ឬថ្ងៃដាក់សេចក្ដីថ្លែងចុងក្រោយដែលត្រូវបានអនុញ្ញាតឱ្យដាក់លើចំណុចដែលត្រូវធ្វើសេចក្ដីសម្រេចក្នុងមជ្ឈត្តវិនិច្ឆ័យ។ តាមការផ្ដួចផ្ដើមផ្ទាល់ខ្លួន ឬតាមសំណើរបស់វេទិកាមជ្ឈត្តកម្ម អគ្គលេខាធិការដ្ឋានអាចពន្យារពេលកំណត់ខាងលើបាន ប្រសិនបើអគ្គលេខាធិការ-ដ្ឋានយល់ថាចាំបាច់។

យ៉ាងណាមិញ តាមការផ្ដួចផ្ដើមផ្ទាល់ខ្លួន ឬតាមសំណើរបស់ភាគីវិវាទ ក្នុងកាលៈ-ទេសៈពិសេស វេទិកាមជ្ឈត្តកម្មអាចបើកដំណើរការមជ្ឈត្តការជាថ្មីនៅក្នុងពេលវេលាណាមួយមុនពេលចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ។

## ប្រការ ៤៥. ការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត

ប្រសិនបើមុនពេលចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ គូភាគីវិវាទព្រមព្រៀងដោះស្រាយវិវាទដោយស្ម័គ្រចិត្ត វេទិកាមជ្ឈត្តកម្មត្រូវចេញសេចក្តីបង្គាប់បញ្ឈប់ដំណើរការមជ្ឈត្តការ ឬប្រសិនបើមានសំណើរបស់ភាគីវិវាទទាំងពីរ និងតាមវិសាលភាពនៃសំណើនោះ និងតាមការទទួលយល់ព្រមរបស់វេទិកាមជ្ឈត្តកម្ម វេទិកាមជ្ឈត្តកម្មត្រូវកត់ត្រាដំណោះស្រាយវិវាទដោយស្ម័គ្រចិត្តនោះក្នុងទម្រង់ជាមជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀង។ វេទិកាមជ្ឈត្តកម្មមិនមានកាតព្វកិច្ចក្នុងការផ្តល់មូលហេតុចំពោះមជ្ឈត្តវិនិច្ឆ័យបែបនេះនោះទេ។

ការដោះស្រាយវិវាទដោយស្ម័គ្រចិត្តត្រូវរួមបញ្ចូលផងដែរនូវការដោះស្រាយពាក់ព័ន្ធនឹងការបង់កម្រៃសេវាមជ្ឈត្តកម្ម។

## ប្រការ ៤៦. មូលហេតុផ្សេងទៀតសម្រាប់បញ្ចប់ដំណើរការមជ្ឈត្តការ

ក្រៅពីមូលហេតុនានាដែលកំណត់ក្នុងវិធាននេះ វេទិកាមជ្ឈត្តកម្មត្រូវចេញសេចក្តីបង្គាប់បញ្ឈប់ដំណើរការមជ្ឈត្តការផងដែរ ប្រសិនបើគូភាគីវិវាទព្រមព្រៀងក្នុងការបញ្ចប់ដំណើរការមជ្ឈត្តការនោះ ឬដោយមូលហេតុណាមួយ វេទិកាមជ្ឈត្តកម្មយល់ថាការបន្តដំណើរការមជ្ឈត្តការគឺមិនចាំបាច់ ឬមិនអាចទៅរួច។

ជំពូកទី ៦

# ការសម្រេច និងមជ្ឈត្តវិនិច្ឆ័យ

## ប្រការ ៤៧. ការសម្រេច

*៤៧.១.ការសម្រេចដោយសម្លេងភាគច្រើនដោយប្រៀប*

ក្នុងករណីវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប មជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីសម្រេចផ្សេងៗ ត្រូវធ្វើឡើងដោយមតិភាគច្រើនដោយប្រៀបនៃមជ្ឈត្តករជាសមាជិកនៃវេទិកាមជ្ឈត្តកម្មទាំងអស់។

*៤៧.២.សេចក្តីសម្រេចលើបញ្ហានីតិវិធី*

ដោយមានការយល់ព្រមជាមុនពីវេទិកាមជ្ឈត្តកម្ម ប្រធានវេទិកាមជ្ឈត្តកម្មអាចសម្រេចលើបញ្ហានីតិវិធីតែម្នាក់ឯងបាន។

## ប្រការ ៤៨. មជ្ឈត្តវិនិច្ឆ័យស្ថាពរ មជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន និងមជ្ឈត្តវិនិច្ឆ័យដោយផ្នែក

បន្ថែមលើការចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរដែលដោះស្រាយចំណុចវិវាទទាំងអស់ (ដែលនៅសេសសល់) វេទិកាមជ្ឈត្តកម្មមានសិទ្ធិក្នុងការចេញមជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន ឬមជ្ឈត្តវិនិច្ឆ័យដោយផ្នែកលើចំណុចវិវាទផ្សេងក្នុងពេលវេលាផ្សេងៗគ្នា។

## ប្រការ ៤៩. ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ

*៤៩.១.មជ្ឈត្តវិនិច្ឆ័យជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ*

មជ្ឈត្តវិនិច្ឆ័យត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនោះ និងស្របតាមប្រការ ៤៥ *(ការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត)* មជ្ឈត្តវិនិច្ឆ័យត្រូវមានសំអាងហេតុដែលជាមូលដ្ឋាននៃការសម្រេច។

*៤៩.២.ទីកន្លែង និងកាលបរិច្ឆេទ*

មជ្ឈត្តវិនិច្ឆ័យត្រូវមានចុះកាលបរិច្ឆេទ និងទីកន្លែងដែលមជ្ឈត្តវិនិច្ឆ័យនោះត្រូវបានចេញ។

*៤៩.៣.ហត្ថលេខា*

មជ្ឈត្តវិនិច្ឆ័យត្រូវចុះហត្ថលេខាដោយមជ្ឈត្តករទាំងអស់។ ចំពោះវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប ហត្ថលេខារបស់សមាជិកភាគច្រើននៃវេទិកាមជ្ឈត្តកម្មត្រូវចាត់ទុកថាគ្រប់គ្រាន់ ល្គឹកណាមានការបញ្ជាក់ពីមូលហេតុដែលមជ្ឈត្តករដទៃទៀតមិនបានចុះហត្ថលេខា។

*៤៩.៤.ការសហការក្នុងការរៀបចំធ្វើមជ្ឈត្តវិនិច្ឆ័យ*

ប្រសិនបើបន្ទាប់ពីបានទទួលឱកាសគ្រប់គ្រាន់ក្នុងការសហការហើយ មជ្ឈត្តករណាម្នាក់ខកខានមិនបានសហការក្នុងការរៀបចំធ្វើមជ្ឈត្តវិនិច្ឆ័យ មជ្ឈត្តករផ្សេងៗទៀតត្រូវរៀបចំធ្វើមជ្ឈត្តវិនិច្ឆ័យដោយគ្មានវត្តមានមជ្ឈត្តកររូបនោះ។

*៤៩.៥.ការឯកភាពលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ*

វេទិកាមជ្ឈត្តកម្មមិនត្រូវចេញមជ្ឈត្តវិនិច្ឆ័យណាមួយឡើយ ប្រសិនបើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យនោះមិនទាន់ត្រូវបានពិនិត្យពិច័យ និងឯកភាពដោយអគ្គ-លេខាធិការដ្ឋាន។

## ប្រការ ៥០. ការពិនិត្យពិច័យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ

*៥០.១.ការបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យសម្រាប់ការពិនិត្យពិច័យលើទម្រង់*

(ក) នៅមុនពេលចេញមជ្ឈត្តវិនិច្ឆ័យ វេទិកាមជ្ឈត្តកម្មត្រូវបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យទៅអគ្គលេខាធិការដ្ឋាន ដើម្បីឱ្យអគ្គលេខាធិការដ្ឋានពិនិត្យពិច័យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ។ លើកលែងតែអគ្គលេខាធិការដ្ឋានពន្យារវេលាកំណត់ស្របតាមសំណើរបស់វេទិកាមជ្ឈត្តកម្ម ឬគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មត្រូវបញ្ជូនសេចក្តីព្រាងមជ្ឈត្ត-វិនិច្ឆ័យទៅអគ្គលេខាធិការដ្ឋានក្នុងអំឡុងពេល ៤៥ (សែសិបប្រាំ) ថ្ងៃប្រតិទិន ចាប់ពីកាលបរិច្ឆេទដែលវេទិកាមជ្ឈត្តកម្មបានប្រកាសបិទដំណើរការមជ្ឈត្តកម្ម។

ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន ចាប់ពីបានទទួលសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យ អគ្គលេខាធិការដ្ឋានអាចស្នើកែប្រែលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ និងដោយមិនប៉ះពាល់ដល់សេរីភាពក្នុងការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម អាចស្នើឱ្យវេទិកាមជ្ឈត្តកម្មយកចិត្តទុកដាក់លើចំណុចសារជាតុនានានៃមជ្ឈត្តវិនិច្ឆ័យ។

(ខ) ប្រការ ៥០.១(ក) មិនអនុវត្តចំពោះមជ្ឈត្តវិនិច្ឆ័យដែលចេញពាក់ព័ន្ធនឹងវិធានការបណ្តោះអាសន្នដូចមានចែងក្នុងប្រការ ៤៣ *(វិធានការបណ្តោះអាសន្ន)* ឬមជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀងដូចមានចែងក្នុងប្រការ ៤៥ *(ការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត)* ឡើយ។

### *៥០.២. ការបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យសម្រាប់ការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ ឬមជ្ឈត្តវិនិច្ឆ័យបន្ថែមសម្រាប់ការពិនិត្យពិច័យលើទម្រង់*

មុនពេលចេញមជ្ឈត្តវិនិច្ឆ័យសម្រាប់ការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ ឬមជ្ឈត្តវិនិច្ឆ័យបន្ថែមដូចមានចែងក្នុង ប្រការ ៥៣ *(ការកែតម្រូវ ការបំភ្លឺលម្អិត និងការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម)* វេទិកាមជ្ឈត្តកម្មត្រូវបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យនោះទៅអគ្គលេខាធិការដ្ឋានសម្រាប់ការពិនិត្យពិច័យលើទម្រង់។

ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន នៃការទទួលបានសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យសម្រាប់ការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ ឬសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យបន្ថែម អគ្គលេខាធិការដ្ឋានអាចស្នើកែប្រែលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ និងដោយមិនប៉ះពាល់ដល់សេរីភាពក្នុងការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម អាចស្នើឱ្យវេទិកាមជ្ឈត្តកម្មយកចិត្តទុកដាក់លើចំណុចសារជាតុនានានៃមជ្ឈត្តវិនិច្ឆ័យ។

## ប្រការ ៥១. ការចេញមជ្ឈត្តវិនិច្ឆ័យ

នៅពេលវេទិកាមជ្ឈត្តកម្មបានចេញមជ្ឈត្តវិនិច្ឆ័យស្របតាមប្រការ ៤៩ *(ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ)* រួចហើយ អគ្គលេខាធិការដ្ឋានត្រូវបោះត្រា ម.ជ.ម. លើមជ្ឈត្តវិនិច្ឆ័យដោយមិនបង្អង់ និងបញ្ជូនមជ្ឈត្តវិនិច្ឆ័យនោះទៅភាគីវិវាទទាំងអស់ ប្រសិនបើការបង់ប្រាក់ជាមុនដែលតម្រូវត្រូវបានបង់ទៅ ម.ជ.ម. ស្របតាមប្រការ ៦៤ *(ប្រាក់បង់ជាមុន)* ឬប្រសិនបើកម្រៃសេវាទាំងអស់លើមជ្ឈត្តការត្រូវបានបង់គ្រប់ចំនួនទៅ ម.ជ.ម. សម្រាប់ករណីមជ្ឈត្តវិនិច្ឆ័យស្ថាពរ។

## ប្រការ ៥២. អានុភាព និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ

ស្របតាមប្រការ ៥៣ *(ការកែតម្រូវ ការបំភ្លឺលម្អិត និងការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម)* មជ្ឈត្តវិនិច្ឆ័យនឹងក្លាយជាមជ្ឈត្តវិនិច្ឆ័យស្ថាពរ និងមាន

អានុភាពអនុវត្តចំពោះគូភាគីវិវាទ ចាប់ពីកាលបរិច្ឆេទដែលមជ្ឈត្តវិនិច្ឆ័យនោះត្រូវបានចេញ និងបោះត្រា។

គូភាគីវិវាទត្រូវអនុវត្តមជ្ឈត្តវិនិច្ឆ័យដោយមិនបង្អង់។ គូភាគីវិវាទទទួលស្គាល់ថាខ្លួនមិនមានសិទ្ធិក្នុងការប្ដឹងជំទាស់ផ្សេង ក្រៅពីស្របតាមបញ្ញត្តិច្បាប់ដែលមានអានុភាពចាប់បង្ខំ ហើយដោយមិនអាចដកហូតវិញបាន គូភាគីវិវាទធ្វើការបោះបង់សិទ្ធិក្នុងការប្ដឹងជំទាស់របស់ខ្លួន ដរាបណាសិទ្ធិក្នុងការប្ដឹងជំទាស់នោះអាចបោះបង់បានដោយមានសុពលភាព។

## ប្រការ ៥៣. ការកែតម្រូវ ការបំភ្លឺលម្អិត និងការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម

### *៥៣.១.សំណើសុំការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ ឬមជ្ឈត្តវិនិច្ឆ័យបន្ថែម*

លើកលែងតែមានការពន្យារអំឡុងពេលបន្ថែមផ្សេងពីនេះតាមការព្រមព្រៀងរវាងគូភាគីវិវាទ មុនពេលបិទដំណើរការមជ្ឈត្តការ និងដោយមានសេចក្ដីជូនដំណឹងទៅភាគីវិវាទម្ខាងទៀត ក៏ដូចជាទៅកាន់អគ្គលេខាធិការដ្ឋាន និងវេទិកាមជ្ឈត្តកម្ម ភាគីវិវាទណាមួយអាចស្នើសុំវេទិកាមជ្ឈត្តកម្មឱ្យកែតម្រូវកំហុសក្នុងការគណនា កំហុសផ្នែកការងារ លេខាធិការ ឬកំហុសក្នុងការបោះពុម្ព ឬកំហុសផ្សេងៗ ដែលមានលក្ខណៈស្រដៀងនោះ ដែលមានក្នុងមជ្ឈត្តវិនិច្ឆ័យ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានមជ្ឈត្តវិនិច្ឆ័យ។

លើកលែងតែមានការពន្យារអំឡុងពេលបន្ថែមផ្សេងពីនេះតាមការព្រមព្រៀងរវាងគូភាគីវិវាទ មុនពេលបិទដំណើរការមជ្ឈត្តការ និងដោយមានសេចក្ដីជូនដំណឹងទៅភាគីវិវាទម្ខាងទៀត ក៏ដូចជាទៅកាន់អគ្គលេខាធិការដ្ឋាន និងវេទិកាមជ្ឈត្តកម្ម ភាគីវិវាទណាមួយ អាចស្នើសុំវេទិកាមជ្ឈត្តកម្មឱ្យបកស្រាយ ឬបំភ្លឺលម្អិត លើចំណុចជាក់លាក់ណាមួយ ឬផ្នែកណាមួយនៃមជ្ឈត្តវិនិច្ឆ័យ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលមជ្ឈត្តវិនិច្ឆ័យ។

លើកលែងតែមានការពន្យារអំឡុងពេលបន្ថែមផ្សេងពីនេះតាមការព្រមព្រៀងរវាងគូភាគីវិវាទ មុនពេលបិទដំណើរការមជ្ឈត្តការ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទដែលបានជូនដំណឹងទៅភាគីវិវាទម្ខាងទៀតអាចស្នើវេទិកាមជ្ឈត្តកម្មឱ្យចេញមជ្ឈត្តវិនិច្ឆ័យបន្ថែមលើចំណុចដែលត្រូវបានបង្ហាញក្នុងដំណើរការមជ្ឈត្តការ ប៉ុន្តែមិនបានដាក់បញ្ចូលនៅក្នុងមជ្ឈត្តវិនិច្ឆ័យដែលបានទទួល។

ភាគីវិវាទម្ខាងទៀតអាចផ្ដល់មតិរបស់ខ្លួនពាក់ព័ន្ធនឹងសំណើនេះក្នុងអំឡុងពេលសមរម្យណាមួយដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម។

*៥៣.២.សេចក្ដីសម្រេចលើការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម*

ប្រសិនបើវេទិកាមជ្ឈត្តកម្មយល់ថាសំណើណាមួយសមរម្យ វេទិកាមជ្ឈត្តកម្មត្រូវកែតម្រូវ ធ្វើការបំភ្លឺលម្អិត ឬផ្ដល់ការបកស្រាយជាលាយលក្ខណ៍អក្សរ ឬចេញមជ្ឈត្តវិនិច្ឆ័យបន្ថែមក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសំណើនោះ។ ស្របតាមប្រការ ៥.២ *(ការកែប្រែពេលវេលាកំណត់)* វេទិកាមជ្ឈត្តកម្មអាចពន្យារអំឡុងពេលដែលវេទិកាមជ្ឈត្តកម្មត្រូវកែតម្រូវធ្វើការបំភ្លឺលម្អិត ផ្ដល់ការបកស្រាយជាលាយលក្ខណ៍អក្សរ ឬចេញមជ្ឈត្តវិនិច្ឆ័យបន្ថែមបានតាមការចាំបាច់ និងដោយមានការជូនដំណឹងទៅគូភាគីវិវាទ។

បញ្ញត្តិចាប់ពីប្រការ ៥០ *(ការពិនិត្យពិច័យលើទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ)* ដល់ប្រការ ៥២ *(អានុភាព និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ)* ត្រូវអនុវត្តដូចគ្នាចំពោះការផ្លាស់ប្ដូរដែលចាំបាច់ ឬសមស្របដែលពាក់ព័ន្ធនឹងការកែតម្រូវមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម។

*៥៣.៣.ការផ្ដួចផ្ដើមរបស់វេទិកាមជ្ឈត្តកម្មក្នុងការកែតម្រូវ*

ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីចេញមជ្ឈត្តវិនិច្ឆ័យ វេទិកាមជ្ឈត្តកម្មអាចផ្ដួចផ្ដើមក្នុងការកែតម្រូវកំហុសដូចមានកំណត់ក្នុងប្រការ ៥៣.១ *(សំណើសុំការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ ឬមជ្ឈត្តវិនិច្ឆ័យបន្ថែម)* បាន។

*៥៣.៤.ផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ*

ការកែតម្រូវ ការបំភ្លឺលម្អិត ឬការបកស្រាយមជ្ឈត្តវិនិច្ឆ័យ គឺជាផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ។

## ប្រការ ៥៤. ការរក្សាឯកសាររបស់សំណុំរឿងដោយអគ្គលេខាធិការដ្ឋាន

នៅពេលវេទិកាមជ្ឈត្តកម្មយល់ថា មិនមានសកម្មភាពតម្រូវផ្សេងទៀតដែលវេទិកាមជ្ឈត្តកម្មត្រូវបំពេញទេនោះ វេទិកាមជ្ឈត្តកម្មត្រូវធានាថាអគ្គលេខាធិការ-ដ្ឋានមានឯកសារពេញលេញទាំងស្រុងរបស់សំណុំរឿង។

## ប្រការ ៥៥. អំណាចរបស់វេទិកាមជ្ឈត្តកម្ម

ក្រៅពីអំណាចដូចមានកំណត់ក្នុងវិធាននេះ និងអំណាចដែលមិនមានបដិប្បញ្ញត្តិនៃវិធានដែលមានអានុភាពចាប់បង្ខំរបស់ច្បាប់ដែលគ្រប់គ្រងមជ្ឈត្តការទេនោះ វេទិកាមជ្ឈត្តកម្មត្រូវមានអំណាចក្នុងការ៖

(ក) បង្គាប់ឱ្យមានការកែប្រែកិច្ចសន្យាណាមួយ ក្នុងកម្រិតដែលតម្រូវឱ្យមានការកែតម្រូវកំហុស ដែលវេទិកាមជ្ឈត្តកម្មយល់ថាជាការធ្វើឡើងដោយភាគីទាំងអស់នៃកិច្ចសន្យានោះ។ សេចក្តីបង្គាប់នេះត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌនៃច្បាប់គ្រប់គ្រងកិច្ចសន្យាដែលអនុញ្ញាតឱ្យមានការកែប្រែកិច្ចសន្យា

(ខ) បង្គាប់ឱ្យមានការរក្សា ស្តុក លក់ ឬការប្រើប្រាស់ទ្រព្យ ឬវត្ថុណាមួយ ដែលជាកម្មវត្ថុនៃវិវាទ ឬជាផ្នែកណាមួយនៃកម្មវត្ថុនៃវិវាទ

(គ) តាមការស្នើសុំរបស់ភាគីវិវាទ ដើម្បីចេញមជ្ឈត្តវិនិច្ឆ័យឱ្យបង់កម្រៃសេវាមជ្ឈត្តកម្មដែលមិនទាន់បានបង់

(ឃ) បង្គាប់ភាគីវិវាទឱ្យធានាថា មជ្ឈត្តវិនិច្ឆ័យដែលនឹងចេញក្នុងដំណើរការមជ្ឈត្តការមិនត្រូវក្លាយជាគ្មានប្រសិទ្ធភាពដោយសារការបំបាត់ទ្រព្យដោយភាគីវិវាទណាមួយឡើយ

(ង) បង្គាប់ភាគីវិវាទឱ្យផ្តល់ប្រាក់កក់សម្រាប់សោហ៊ុយចំណាយលើសេវាផ្នែកច្បាប់ ឬចំណាយផ្សេងទៀតក្នុងទម្រង់ណាមួយដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប

(ច) បង្គាប់ភាគីវិវាទឱ្យផ្តល់ប្រាក់កក់សម្រាប់មួយផ្នែកនៃទឹកប្រាក់ណាមួយនៃវិវាទ ឬទឹកប្រាក់ទាំងអស់នៃវិវាទនៅមជ្ឈត្តការ

(ឆ) កំណត់ទណ្ឌកម្មដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្របចំពោះភាគីវិវាទដែលខកខាន ឬបដិសេធមិនគោរពវិធាននេះ សេចក្តីបង្គាប់ ឬសេចក្តីណែនាំរបស់វេទិកាមជ្ឈត្តកម្ម ឬមជ្ឈត្តវិនិច្ឆ័យដោយផ្នែក ឬខកខាន ឬបដិសេធចូលរួម ការប្រជុំ ឬសវនាការ

(ជ) តាមការសមស្រប សម្រេចលើចំណុចវិវាទដែលមិនត្រូវបានបង្ហាញ ឬដែលត្រូវបានលើកឡើងដោយតុល្យភាពក្នុងឯកសារនានាដូចមានចែងក្នុងប្រការ ៣៧ *(ការដាក់សេចក្តីថ្លែងដោយគូភាគីវិវាទ)* ប្រសិនបើចំណុចវិវាទនោះត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ដល់ភាគីវិវាទម្ខាងទៀត និងភាគីវិវាទម្ខាងទៀតត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ក្នុងការឆ្លើយតប

(ឈ) សម្រេចអំពីច្បាប់ដែលគ្រប់គ្រងដំណើរការមជ្ឈត្តការ និង

(ញ) សម្រេចលើការទាមទារ ឬបុព្វសិទ្ធិតាមផ្លូវច្បាប់ ឬបុព្វសិទ្ធិផ្សេងទៀត។

ជំពូកទី ៧

# កម្រៃសេវា

## ប្រការ ៥៦. កម្រៃសេវាមជ្ឈត្តកម្ម

*៥៦.១.កម្រៃសេវាមជ្ឈត្តកម្ម និងតារាងកម្រៃសេវារបស់ ម.ជ.ម.*

កម្រៃសេវាមជ្ឈត្តកម្ម រួមមាន៖

(ក) កម្រៃសេវាចុះបញ្ជីសំណុំរឿង និងកម្រៃសេវាលើពាក្យសុំនានា

(ខ) កម្រៃសេវារដ្ឋបាល

(គ) កម្រៃសេវាតែងតាំងមជ្ឈត្តករ

(ឃ) កម្រៃសេវាវេទិកាមជ្ឈត្តកម្ម

(ង) កម្រៃសេវានានាសម្រាប់នីតិវិធីមជ្ឈត្តករបន្ទាន់ និង

(ច) កម្រៃចំណាយផ្សេងៗរបស់មជ្ឈត្តករបន្ទាន់ វេទិកាមជ្ឈត្តកម្ម និង ម.ជ.ម.

ដូចមានកំណត់ចាប់ពីប្រការ ៥៦ *(កម្រៃសេវាមជ្ឈត្តកម្ម)* ដល់ប្រការ ៦២ *(ការចំណាយផ្សេងៗ របស់មជ្ឈត្តករបន្ទាន់ វេទិកាមជ្ឈត្តកម្ម និង ម.ជ.ម.)*។

អគ្គលេខាធិការដ្ឋានត្រូវកំណត់កម្រៃសេវាមជ្ឈត្តកម្មដោយអនុលោមតាមជំពូកនេះ និងតារាងកម្រៃសេវារបស់ ម.ជ.ម. ដែលត្រូវបានអនុម័តដោយ ម.ជ.ម. ស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ ម.ជ.ម.។ ការកំណត់កម្រៃសេវាមជ្ឈត្តកម្មរបស់អគ្គលេខាធិការដ្ឋានជាការកំណត់ស្ថាពរ។ ក្នុងករណីដែលមជ្ឈត្តកម្មត្រូវបានដោះស្រាយដោយស្ម័គ្រចិត្ត ឬត្រូវបានបញ្ចប់ដោយមិនមានការធ្វើសវនាការអគ្គលេខាធិការដ្ឋានត្រូវកំណត់កម្រៃសេវាជាស្ថាពរសម្រាប់មជ្ឈត្តកម្មនៃករណីនោះ។ អគ្គលេខាធិការដ្ឋានត្រូវកំណត់កម្រៃសេវាមជ្ឈត្តកម្មនៃករណីនេះដោយពិចារណារាល់កាលៈទេសៈនៃ

សំណុំរឿងរាប់បញ្ចូលទាំងដំណាក់កាលនៃដំណើរការមជ្ឈត្តការដែលមជ្ឈត្តកម្មត្រូវបានដោះស្រាយដោយស្ម័គ្រចិត្ត ឬត្រូវបានបញ្ចប់។ ក្នុងករណីដែលកម្រៃសេវាមជ្ឈត្តកម្មដែលកំណត់មានតំលៃទាបជាងប្រាក់បង់ជាមុន ម.ជ.ម. ត្រូវបង្វិលសងទៅគូភាគីវិវាទវិញនូវទឹកប្រាក់ទៅតាមសមាមាត្រដែលគូភាគីវិវាទបានព្រមព្រៀងគ្នា ឬតាមសមាមាត្រដូចគ្នានឹងសមាមាត្រដែលប្រាក់បង់ជាមុនត្រូវបានបង់ ប្រសិនបើមិនមានការព្រមព្រៀងរវាងគូភាគីវិវាទទេនោះ។

*៥៦.២.ការកែប្រែ និងការអនុវត្តតារាងកម្រៃសេវារបស់ ម.ជ.ម.*

ក្រុមប្រឹក្សាប្រតិបត្តិរបស់ ម.ជ.ម. អាចធ្វើកែប្រែតារាងកម្រៃសេវារបស់ខ្លួននៅពេលណាមួយដែលក្រុមប្រឹក្សាប្រតិបត្តិយល់ថាសមស្រប។ តារាងកម្រៃសេវារបស់ ម.ជ.ម. ដែលត្រូវអនុវត្ត គឺតារាងកម្រៃសេវាដែលមានសុពលភាពជាធរមាននៅកាលបរិច្ឆេទដែលអគ្គលេខាធិការដ្ឋានបានទទួលសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញស្របតាមប្រការ ៧.១ *(សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម)*។

*៥៦.៣.ការបែងចែកកម្រៃសេវាមជ្ឈត្តកម្ម*

វេទិកាមជ្ឈត្តកម្មត្រូវកំណត់ឱ្យបានច្បាស់លាស់នូវកម្រៃសេវាសរុបសម្រាប់មជ្ឈត្តកម្មនៅក្នុងមជ្ឈត្តវិនិច្ឆ័យរបស់ខ្លួន។ លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ឱ្យជាក់លាក់អំពីការបែងចែកកម្រៃសេវាសម្រាប់មជ្ឈត្តកម្មរវាងគូភាគីវិវាទនៅក្នុងមជ្ឈត្តវិនិច្ឆ័យ។

អនុលោមតាមបញ្ញត្តិខាងលើ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ចំនួនទឹកប្រាក់ដែលភាគីវិវាទម្ខាងត្រូវបង់ទៅភាគីវិវាទម្ខាងទៀត។ សម្រាប់ការកំណត់នេះ វេទិកាមជ្ឈត្តកម្មត្រូវយកមកពិចារណានូវចំនួនទឹកប្រាក់បង់ជាមុន ដែលគូភាគីវិវាទបានបង់ទៅ ម.ជ.ម. ដូចមានកំណត់ក្នុងប្រការ ៦៤ *(ប្រាក់បង់ជាមុន)*។

*៥៦.៤.ការទទួលខុសត្រូវរួមគ្នា និងដោយឡែកពីគ្នា*

គូភាគីវិវាទត្រូវទទួលខុសត្រូវរួមគ្នា និងដោយឡែកពីគ្នាក្នុងការបង់កម្រៃសេវាសរុបសម្រាប់មជ្ឈត្តកម្មទៅ ម.ជ.ម.។

## ប្រការ ៥៧. កម្រៃសេវាចុះបញ្ជីសំណុំរឿង និងកម្រៃសេវាលើពាក្យសុំនានា

*៥៧.១.អត្រាឆាការ (អត្រាថេរ)*

កម្រៃសេវាចុះបញ្ជីសំណុំរឿង និងកម្រៃសេវាលើពាក្យសុំនានាត្រូវបានកំណត់ជាអត្រាឆាការ (អត្រាថេរ) ដូចមានកំណត់ក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម.។

*៥៧.២.ការបង់កម្រៃសេវាឱ្យទាន់ពេលវេលា*

ភាគីប្តឹងទាមទារត្រូវបង់កម្រៃសេវាចុះបញ្ជីនៅពេលដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម។ ភាគីប្តឹងទាមទារនៃបណ្តឹងតបត្រូវបង់កម្រៃសេវាបន្ថែមសម្រាប់ការចុះបញ្ជីនៅពេលដាក់បណ្តឹងតប។

ការខកខានក្នុងការបង់កម្រៃសេវាចុះបញ្ជីឱ្យបានគ្រប់ចំនួនទាន់ពេលវេលា ត្រូវចាត់ទុកជា ការខកខានក្នុងការដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មដូចមានកំណត់ក្នុងប្រការ ៧.៥ *(ភាពមិនពេញលេញនៃសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម)* ឬអាចប្រឈមនឹងហានិភ័យដែលបណ្តឹងតបរបស់ភាគីវិវាទមិនត្រូវបានលើកយកមកពិចារណាក្នុងដំណើរការមជ្ឈត្តការ។

រាល់ពាក្យសុំនានា ដែលធ្វើឡើងក្រោមវិធាននេះត្រូវភ្ជាប់មកជាមួយកម្រៃសេវាលើពាក្យសុំដូចមានកំណត់ក្នុងតារាងកម្រៃសេវា ម.ជ.ម.។ ការខកខានក្នុងការបង់កម្រៃសេវាលើពាក្យសុំឱ្យបានគ្រប់ចំនួនទាន់ពេលវេលា ពាក្យសុំទាំងនោះមិនត្រូវបានលើកយកមកពិចារណាក្នុងដំណើរការមជ្ឈត្តការ។

*៥៧.៣. ការមិនសងប្រាក់វិញ*

កម្រៃសេវាចុះបញ្ជី គឺជាកម្រៃដែលមិនត្រូវសងវិញនោះទេ។

## ប្រការ ៥៨. កម្រៃសេវារដ្ឋបាល

*៥៨.១.ការកំណត់កម្រៃសេវារដ្ឋបាល*

កម្រៃសេវារដ្ឋបាលត្រូវកំណត់ដោយផ្អែកលើតម្លៃកម្មវត្ថុនៃវិវាទដូចមានកំណត់ក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម. ។

*៥៨.២.ការគណនាតម្លៃកម្មវត្ថុនៃវិវាទ*

តម្លៃកម្មវត្ថុនៃវិវាទ គឺជាតម្លៃកម្មវត្ថុនៃរាល់ការទាមទារ និងបណ្តឹងតបទាំងអស់។ ប្រសិនបើភាគីវិវាទបានដាក់ការដោះសាតាមការកាត់កង អគ្គលេខាធិការដ្ឋានត្រូវបញ្ចូលទឹកប្រាក់នោះក្នុងការគណនាតម្លៃកម្មវត្ថុនៃវិវាទ ប្រសិនបើការដោះសាតាមការកាត់កងនោះបណ្តាលឱ្យវេទិកាមជ្ឈត្តកម្មមានបន្ទុកការងារច្រើនបន្ថែមទៀត។

*៥៨.៣.ការកែប្រែការទាមទារ និងការដោះសា*

ទោះបីជាតម្លៃនៃការទាមទារ បណ្តឹងតប ឬការដោះសាតាមការកាត់កង ប្រសិនបើពាក់ព័ន្ធ ត្រូវបានកាត់បន្ថយស្របតាមប្រការ ៣៨.២ *(ការកែប្រែពាក្យបណ្តឹង និងការកែប្រែការដោះសា)* ក៏ដោយ ក៏កម្រៃសេវារដ្ឋបាលមិនត្រូវបានកាត់បន្ថយឡើយ។ ប្រសិនបើចំនួនទឹកប្រាក់នៃ ការទាមទារ បណ្តឹងតប ឬការដោះសាតាមការកាត់កង ប្រសិនបើពាក់ព័ន្ធ ត្រូវបានដំឡើងស្របតាមប្រការ ៣៨.២ *(ការកែប្រែពាក្យបណ្តឹង និងការកែប្រែការដោះសា)* នោះកម្រៃសេវារដ្ឋបាលនឹងត្រូវដំឡើងស្របតាមតារាងកម្រៃសេវារបស់ ម.ជ.ម. ផងដែរ។

### *៥៨.៤.តម្លៃកម្មវត្ថុនៃវិវាទដែលមិនអាចកំណត់បាន*

ប្រសិនបើតម្លៃកម្មវត្ថុនៃវិវាទដែលជាតម្លៃនៃការទាមទារ ឬបណ្តឹងតបមិនអាចកំណត់បាន នៅពេលដែលប្រាក់បង់ជាមុនត្រូវដល់កំណត់បង់ អគ្គលេខាធិការដ្ឋានត្រូវប៉ាន់ស្មានកម្រៃសេវាបណ្តោះអាសន្នសម្រាប់មជ្ឈត្តកម្មដោយផ្អែកលើលក្ខណៈនៃវិវាទ និងកាលៈទេសៈនៃសំណុំរឿងនីមួយៗ។ ការប៉ាន់ស្មានបណ្តោះអាសន្ននេះអាចត្រូវបានកែប្រែស្របតាមព័ត៌មានដែលទទួលបាននាពេលក្រោយៗមក។

### *៥៨.៥.ការកែប្រែកម្រៃសេវារដ្ឋបាល*

សម្រាប់កាលៈទេសៈពិសេសណាមួយដែលអគ្គលេខាធិការដ្ឋានយល់ឃើញថាសមហេតុផលក្នុងការបន្ថយ ឬដំឡើងកម្រៃសេវារដ្ឋបាលដែលមានកំណត់ក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម. អគ្គលេខាធិការដ្ឋានអាចកែប្រែកម្រៃសេវារដ្ឋបាលរបស់សំណុំរឿងនីមួយៗបាន។ កាលៈទេសៈពិសេសអាចរួមមានជាអាទិ៍បរិមាណការងារតិចតួចរបស់វេទិកាមជ្ឈត្តកម្មដោយសារតែការបញ្ចប់ដំណើរការមជ្ឈត្តការមុនកាលកំណត់ ឬបរិមាណការងារបន្ថែមដែល ម.ជ.ម. ត្រូវបំពេញ។ ការដំឡើងកម្រៃសេវារដ្ឋបាលនេះមិនត្រូវលើសពី ៣០% (សាមសិបភាគរយ) នៃកម្រៃសេវារដ្ឋបាលដែលមានកំណត់ក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម. ឡើយ។

## ប្រការ ៥៩. កម្រៃសេវាតែងតាំងមជ្ឈត្តករ

ក្នុងករណីដែលការតែងតាំងមជ្ឈត្តករដោយ ម.ជ.ម. ត្រូវបានតម្រូវ ឬស្នើឡើង ភាគីវិវាទដែលស្នើឡើងនោះត្រូវបង់កម្រៃសេវាតែងតាំងមជ្ឈត្តករទៅ ម.ជ.ម. ដូចមានកំណត់ក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម. សម្រាប់ការតែងតាំងមជ្ឈត្តករដែលធ្វើឡើងដោយគណៈកម្មាធិការតែងតាំងនិង នីតិវិធី។

## ប្រការ ៦០. កម្រៃសេវាវេទិកាមជ្ឈត្តកម្ម

### *៦០.១.ការកំណត់កម្រៃសេវាវេទិកាមជ្ឈត្តកម្ម*

កម្រៃសេវាវេទិកាមជ្ឈត្តកម្មត្រូវកំណត់ដោយផ្អែកលើតម្លៃកម្មវត្ថុនៃវិវាទដូចមានកំណត់ក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម.។ មុនពេលវេទិកាមជ្ឈត្តកម្មត្រូវបានរៀបចំបង្កើត គូភាគីវិវាទអាចព្រមព្រៀងផ្សេងលើវិធីសាស្ត្រក្នុងការកំណត់កម្រៃសេវាវេទិកាមជ្ឈត្តកម្មបាន។

### *៦០.២.ការគណនាតម្លៃកម្មវត្ថុនៃវិវាទ*

តម្លៃកម្មវត្ថុនៃវិវាទ គឺជាតម្លៃកម្មវត្ថុនៃរាល់ការទាមទារ និងបណ្តឹងតប។ ប្រសិនបើភាគីវិវាទមានដាក់ការដោះសាតាមការកាត់កង អគ្គលេខាធិការដ្ឋានត្រូវបញ្ចូលទឹកប្រាក់នោះក្នុងការគណនាតម្លៃកម្មវត្ថុនៃវិវាទ ប្រសិនបើការដោះសាតាមការកាត់កងនោះបណ្តាលឱ្យវេទិកាមជ្ឈត្តកម្មមានបន្ទុកការងារច្រើនបន្ថែមទៀត។

### *៦០.៣.ការកែប្រែការទាមទារ និងការដោះសា*

ទោះបីជាតម្លៃនៃ ការទាមទារ បណ្ដឹងតប ឬការដោះសាតាមការកាត់កង ប្រសិនបើពាក់ព័ន្ធ ត្រូវបានកាត់បន្ថយស្របតាមប្រការ ៣៨.២ *(ការកែប្រែ ពាក្យបណ្ដឹង និងការកែប្រែការដោះសា)* ក៏ដោយ ក៏កម្រៃសេវាផទិកាមជ្ឈត្តកម្មមិនត្រូវបានកាត់បន្ថយឡើយ។ ប្រសិនបើចំនួនទឹកប្រាក់នៃ ការទាមទារ បណ្ដឹងតប ឬការដោះសាតាមការកាត់កង ប្រសិនបើពាក់ព័ន្ធ ត្រូវបានដំឡើងស្របតាមប្រការ ៣៨.២ *(ការកែប្រែ ពាក្យបណ្ដឹង និងការកែប្រែការដោះសា)* នោះ កម្រៃសេវាផទិកាមជ្ឈត្តកម្មនឹងត្រូវដំឡើងស្របតាមតារាងកម្រៃសេវារបស់ ម.ជ.ម. ផងដែរ។

### *៦០.៤.តម្លៃកម្មវត្ថុនៃវិវាទដែលមិនអាចកំណត់បាន*

ប្រសិនបើតម្លៃកម្មវត្ថុនៃវិវាទ ដែលជាតម្លៃនៃការទាមទារ ឬបណ្ដឹងតប មិនអាចកំណត់បាននៅពេលដែលប្រាក់បង់ជាមុនត្រូវដល់កំណត់បង់ អគ្គលេខាធិការដ្ឋានត្រូវប៉ាន់ស្មានកម្រៃសេវាបណ្ដោះអាសន្នសម្រាប់មជ្ឈត្តកម្មដោយផ្អែកលើលក្ខណៈនៃវិវាទ និងកាលៈទេសៈនៃសំណុំរឿងនីមួយៗ។ ការប៉ាន់ស្មានបណ្ដោះអាសន្ននេះអាចត្រូវបានកែប្រែស្របតាមព័ត៌មានដែលទទួលបាននាពេលក្រោយៗមក។

### *៦០.៥.គ្មានកិច្ចព្រមព្រៀងដោយឡែកជាមួយភាគីវិវាទលើកម្រៃសេវា និងការចំណាយ*

មជ្ឈត្តករមានសិទ្ធិទទួលបានត្រឹមតែកម្រៃសេវាផទិកាមជ្ឈត្តកម្ម និងការសងត្រលប់មកវិញនូវការចំណាយនានាដែលបែងចែក និងកំណត់ដោយអគ្គលេខាធិការដ្ឋានតែប៉ុណ្ណោះ។ មជ្ឈត្តករមិនអាចចុះកិច្ចព្រមព្រៀងជាមួយ ឬទទួលកម្រៃដោយផ្ទាល់ ឬដោយប្រយោលពីភាគីវិវាទណាមួយ ឬអ្នកតំណាងរបស់គូភាគីវិវាទ សម្រាប់កម្រៃសេវា ឬការចំណាយរបស់ខ្លួនឡើយ។

### *៦០.៦.ការបែងចែកផ្ទៃក្នុងចំពោះកម្រៃសេវាផទិកាមជ្ឈត្តកម្ម*

មជ្ឈត្តករមានសេរីភាពក្នុងការព្រមព្រៀងលើការបែងចែកកម្រៃសេវារបស់ខ្លួន។ ប្រសិនបើគ្មានការព្រមព្រៀងអំពីបញ្ហានេះ អគ្គលេខាធិការដ្ឋានត្រូវអនុវត្តវិធានខាងក្រោម៖

(ក) ក្នុងករណីផទិកាមជ្ឈត្តកម្មនៃសមាជិកមជ្ឈត្តករ ៣ (បី) រូប៖ ៤០% (សែសិបភាគរយ) នៃកម្រៃសេវាផទិកាមជ្ឈត្តកម្មសរុបត្រូវបែងចែកទៅប្រធានផទិកាមជ្ឈត្តកម្ម និង៦០% (ហុកសិបភាគរយ) ដែលនៅសល់ត្រូវបែងចែកស្មើគ្នារវាងមជ្ឈត្តករផ្សេងទៀត។

(ខ) ក្នុងករណីដទៃទៀតរបស់ផទិកាមជ្ឈត្តកម្មនៃសមាជិកមជ្ឈត្តករច្រើនរូប៖ ៥% (ប្រាំភាគរយ) នៃកម្រៃសេវាផទិកាមជ្ឈត្តកម្មសរុបត្រូវបែងចែកទៅប្រធានផទិកាមជ្ឈត្តកម្ម និង៩៥% (កៅសិបប្រាំភាគរយ) ដែលនៅសល់ត្រូវបែងចែកស្មើគ្នារវាងមជ្ឈត្តករទាំងអស់ រួមទាំងប្រធានផទិកាមជ្ឈត្តកម្មផងដែរ។

*៦០.៧.កម្រៃសេវាក្នុងករណីមានការដាក់មជ្ឈត្តករជំនួស*

ដោយផ្អែកលើការងារជាក់ស្តែងរបស់មជ្ឈត្តករបានបំពេញ និងកាលៈទេសៈពាក់ព័ន្ធផ្សេងទៀត អគ្គលេខាធិការដ្ឋានត្រូវកំណត់កម្រៃដែលត្រូវបង់ទៅមជ្ឈត្តករដែលបានបញ្ចប់តួនាទីរបស់ខ្លួនមុនពេលដំណើរការសវនាការត្រូវបានបញ្ចប់ ទោះការបញ្ចប់នោះដោយសារមូលហេតុអ្វីក៏ដោយ និងទៅមជ្ឈត្តករដែលត្រូវបានដាក់ជំនួស។

កម្រៃសេវាសរុបរបស់មជ្ឈត្តករដែលឈប់ពីតួនាទី និងមជ្ឈត្តករដែលជំនួស មិនអាចលើសពី ១២០% (មួយរយម្ភៃភាគរយ) នៃកម្រៃសេវាដែលមជ្ឈត្តករដែលត្រូវបានតែងតាំងដំបូងអាចនឹងទទួលបាន ប្រសិនបើមជ្ឈត្តកររូបនោះបានកាន់សំណុំរឿងរហូតដល់ទីបញ្ចប់ឡើយ។

*៦០.៨.ការកែប្រែកម្រៃសេវាវេទិកាមជ្ឈត្តកម្ម*

សម្រាប់កាលៈទេសៈពិសេសណាមួយដែលអគ្គលេខាធិការដ្ឋានយល់ឃើញថាសមហេតុផលក្នុងការបន្ថយ ឬដំឡើងកម្រៃសេវាវេទិកាមជ្ឈត្តកម្មដែលមានកំណត់ក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម. អគ្គលេខាធិការដ្ឋានអាចកែប្រែកម្រៃសេវាវេទិកាមជ្ឈត្តកម្មនៃសំណុំរឿងនីមួយៗបាន។ កាលៈទេសៈពិសេសរួមមានជាអាទិ៍បរិមាណការងារតិចតួចដែលវេទិកាមជ្ឈត្តកម្មត្រូវបំពេញដោយសារតែការបញ្ចប់ដំណើរការមជ្ឈត្តការមុនកាលកំណត់ ឬបរិមាណការងារច្រើនបន្ថែម ដែល ម.ជ.ម. ត្រូវបំពេញពាក់ព័ន្ធនឹងសំណើជាបន្តបន្ទាប់នានាសម្រាប់វិធានការបណ្តោះអាសន្នការជំទាស់ទៅនឹងមជ្ឈត្តករ ឬទទ្បីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម។ ការដំឡើងកម្រៃសេវាវេទិកាមជ្ឈត្តកម្មនេះមិនត្រូវលើសពី ៣០% (សាមសិបភាគរយ) នៃកម្រៃសេវាវេទិកាមជ្ឈត្តកម្មដែលមានកំណត់ក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម. ឡើយ។

## ប្រការ ៦១. កម្រៃសេវានានា សម្រាប់នីតិវិធីមជ្ឈត្តករបន្ទាន់

ភាគីវិវាទដែលស្នើសុំវិធានបណ្តោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់ត្រូវបង់កម្រៃសេវានានា សម្រាប់នីតិវិធីមជ្ឈត្តករបន្ទាន់ដែលមានកំណត់ក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម.។ កម្រៃសេវានេះត្រូវបង់ឱ្យគ្រប់ចំនួននៅពេលដែលដាក់ពាក្យសុំនោះ។

## ប្រការ ៦២. ការចំណាយផ្សេងៗ របស់មជ្ឈត្តករបន្ទាន់ វេទិកាមជ្ឈត្តកម្ម និង ម.ជ.ម.

ការចំណាយផ្សេងៗ របស់មជ្ឈត្តករបន្ទាន់ វេទិកាមជ្ឈត្តកម្ម និង ម.ជ.ម. រួមមាន៖

(ក) ចំណាយជាក់ស្តែងផ្សេងៗ ដែលមជ្ឈត្តករប្រើប្រាស់ក្នុងដំណើរការមជ្ឈត្តការរួមមានការចំណាយសមហេតុផលសម្រាប់ ការធ្វើដំណើរ សណ្ឋាគារ អាហារ និងការចំណាយចាំបាច់ផ្សេងទៀត

(ខ) ចំណាយសម្រាប់អ្នកជំនាញដែលត្រូវបានតែងតាំងដោយមជ្ឈត្តករបន្ទាន់ ឬវេទិកាមជ្ឈត្តកម្ម ឬជំនួយដទៃទៀត ដែលជាតម្រូវការរបស់មជ្ឈត្តករបន្ទាន់ ឬវេទិកាមជ្ឈត្តកម្ម និង

(គ) ចំណាយសម្រាប់ថ្លៃសំភារៈបរិក្ខារនានា ឬសេវាកម្មបន្ថែម ដែលផ្តល់ដោយ ម.ជ.ម.។

ក្រុមប្រឹក្សាប្រតិបត្តិរបស់ ម.ជ.ម. អាចចេញសេចក្តីណែនាំអំពីការចំណាយដូចបានបញ្ជាក់ខាងដើម។

## ប្រការ ៦៣. សោហ៊ុយចំណាយលើសេវាផ្នែកច្បាប់ និងការចំណាយផ្សេងៗរបស់ភាគីវិវាទ

លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មត្រូវមានសមត្ថកិច្ចបង្គាប់ ក្នុងមជ្ឈត្តវិនិច្ឆ័យរបស់ខ្លួន ឱ្យភាគីវិវាទម្ខាងបង់ការចំណាយសម្រាប់ សេវាផ្លូវច្បាប់ និងការចំណាយផ្សេងៗ មួយផ្នែក ឬទាំងស្រុងរបស់ភាគីវិវាទម្ខាងទៀត។

## ប្រការ ៦៤. ប្រាក់បង់ជាមុន

### *៦៤.១.ប្រាក់បង់ជាមុនសម្រាប់កម្រៃសេវាមជ្ឈត្តកម្ម*

គូភាគីវិវាទត្រូវបង់ទៅ ម.ជ.ម. នូវប្រាក់បង់ជាមុនសម្រាប់កម្រៃសេវាមជ្ឈត្តកម្មក្នុងតម្លៃប៉ាន់ស្មានណាមួយ លើកលែងតែកម្រៃសេវាចុះបញ្ជីដែលត្រូវបង់ទាំងស្រុងស្របតាមប្រការ ៥៧.២ *(ការបង់កម្រៃសេវាឱ្យទាន់ពេលវេលា)*។

អគ្គលេខាធិការដ្ឋានមានសមត្ថកិច្ចកំណត់តម្លៃនៃប្រាក់បង់ជាមុន។ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ភាគីប្តឹងទាមទារ និងភាគីឆ្លើយតប ត្រូវបង់ប្រាក់បង់ជាមុនម្នាក់ពាក់កណ្តាល។ ការបង់ត្រូវធ្វើក្នុងទម្រង់ជាមូលប្បទានបត្រ ឬការផ្ទេរចូលគណនីធនាគារ ដែលកំណត់ដោយ ម.ជ.ម. ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានការជូនដំណឹងពីអគ្គលេខាធិការដ្ឋាន។

### *៦៤.២.ការបង់បន្ថែមនូវប្រាក់បង់ជាមុន*

នៅក្នុងដំណើរការមជ្ឈត្តការ រួមមានជាអាទិ៍ ក្នុងករណីដែលមានការកើនឡើងនៃតម្លៃកម្មវត្ថុនៃវិវាទ សំណើនានាដែលស្នើឱ្យមានវិធានការបណ្តោះអាសន្ន ការជំទាស់ទៅនឹងមជ្ឈត្តករ ឬទឡ្ហីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម អគ្គលេខាធិការដ្ឋានអាចស្នើឱ្យគូភាគីវិវាទបង់បន្ថែមនូវប្រាក់បង់ជាមុន។ ការបង់បន្ថែមនេះត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានការជូនដំណឹងពីអគ្គលេខាធិការដ្ឋាន។

## ៦៤.៣.ការផ្អាក ឬការបញ្ឈប់ដំណើរការមជ្ឈត្តការ

ក្នុងករណីដែលប្រាក់បង់ជាមុនមិនត្រូវបានបង់ទាំងស្រុងតាមកាលកំណត់ដែលត្រូវបង់ទេនោះ អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងដល់គូភាគីវិវាទដើម្បីឱ្យភាគីវិវាទណាមួយបង់នូវទឹកប្រាក់ដែលត្រូវបង់។ ប្រសិនបើប្រាក់នៅតែមិនត្រូវបានបង់ក្នុងរយៈពេលដែលបានកំណត់ដោយអគ្គលេខាធិការដ្ឋាន អគ្គលេខាធិការដ្ឋានក្រោយពីបានពិភាក្សាជាមួយវទិកាមជ្ឈត្តកម្ម អាចឱ្យវទិកាមជ្ឈត្តកម្មផ្អាកការងារ និងកំណត់អំឡុងពេលមួយដែលការទាមទារ ឬបណ្តឹងតប ដែលពាក់ព័ន្ធនោះត្រូវចាត់ទុកថាបានដកនៅពេលផុតកំណត់អំឡុងពេលនោះ។ ការកំណត់អំពីការដកការទាមទារ ឬបណ្តឹងតបនេះ មិនត្រូវប៉ះពាល់ដល់ការដាក់ ការទាមទារ ឬបណ្តឹងតបនេះជាថ្មីដោយភាគីវិវាទណាមួយនៅក្នុងដំណើរការមជ្ឈត្តការផ្សេងទៀតឡើយ។

ភាគីវិវាទនីមួយៗអាចបង់សរុបនូវប្រាក់បង់ជាមុនសម្រាប់កម្រៃសេវាមជ្ឈត្តកម្មពាក់ព័ន្ធនឹងការទាមទារ ឬបណ្តឹងតប ប្រសិនបើភាគីវិវាទណាមួយខកខានមិនបានបង់ចំណែកដែលខ្លួនត្រូវបង់។ វទិកាមជ្ឈត្តកម្ម ឬអគ្គលេខាធិការដ្ឋានអាចផ្អាកការងារខ្លួន មួយផ្នែក ឬទាំងស្រុង ឬក៏បញ្ឈប់ដំណើរការមជ្ឈត្តការតែម្តង ប្រសិនបើប្រាក់បង់ជាមុនដែលតម្រូវក្រោមវិធាននេះ មួយចំណែក ឬទាំងស្រុងមិនត្រូវបានបង់ទេនោះ។

## ៦៤.៤.ការបង់បណ្តោះអាសន្ន

អគ្គលេខាធិការដ្ឋាន អាចបង្គាប់ថាការបង់បណ្តោះអាសន្នអាចធ្វើពីពេលមួយទៅពេលមួយ ដោយដកចេញពីក្នុងកញ្ចប់ប្រាក់បង់ជាមុន សម្រាប់កម្រៃសេវាប៉ាន់ស្មានសម្រាប់ ម.ជ.ម. ឬមជ្ឈត្តករ ឬចំណាយនានាដែល ម.ជ.ម. ឬមជ្ឈត្តករ បានចំណាយរួចហើយ។

## ៦៤.៥.ទិនានុប្បវត្តន៍ចំណាយសង្ខេបរបស់ប្រាក់បង់ជាមុន ការសងទៅវិញនូវទឹកប្រាក់ដែលមិនបានចំណាយ និងការប្រាក់

បន្ទាប់ពីចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ ឬមជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀង ឬសេចក្តីបង្គាប់បញ្ឈប់ដំណើរការមជ្ឈត្តការ អគ្គលេខាធិការដ្ឋានត្រូវផ្តល់ទៅគូភាគីវិវាទនូវទិនានុប្បវត្តន៍ចំណាយសង្ខេបរបស់ប្រាក់បង់ជាមុនដែលបានទទួល និងប្រើប្រាស់។ ម.ជ.ម. ត្រូវសងទៅគូភាគីវិវាទវិញនូវទឹកប្រាក់ដែលមិនបានចំណាយតាមសមាមាត្រដែលគូភាគីវិវាទបានព្រមព្រៀង ឬតាមសមាមាត្រដូចគ្នានឹងសមាមាត្រដែលប្រាក់បង់ជាមុនត្រូវបានបង់ ប្រសិនបើមិនមានការព្រមព្រៀងរវាងគូភាគីវិវាទទេនោះ។ ការប្រាក់នៃប្រាក់បង់ជាមុន ឬប្រាក់កក់ធានាត្រូវរក្សាទុកជាចំណូលរបស់ ម.ជ.ម.។

### *៦៤.៦.ការមិនទទួលខុសត្រូវចំពោះការចំណាយ ដែលហួសពីប្រាក់បង់ជាមុន ឬ ប្រាក់កក់ដើម្បីធានា*

ម.ជ.ម. រួមបញ្ចូលទាំង សមាជិក អភិបាល ទីប្រឹក្សា លេខា និងបុគ្គលិករបស់ ម.ជ.ម. មិនទទួលខុសត្រូវបង់នូវការចំណាយណាមួយដែលហួសពីប្រាក់បង់ជាមុន ឬប្រាក់កក់ដើម្បីធានាឡើយ។

## ប្រការ ៦៥. កម្រៃសេវាមជ្ឈត្តកម្មដំណើរការក្រោមវិធានផ្សេង ក្រៅពីវិធានស្ដីពីមជ្ឈត្តការ ម.ជ.ម.

លើកលែងអគ្គលេខាធិការដ្ឋានកំណត់ផ្សេងពីនេះ តារាងកម្រៃសេវា ម.ជ.ម. ត្រូវអនុវត្តផងដែរចំពោះដំណើរការមជ្ឈត្តការដែលចាត់ចែងដោយ ម.ជ.ម. ក្រោមវិធានផ្សេងក្រៅពីវិធានស្ដីពីមជ្ឈត្តការ ម.ជ.ម. ។

ជំពូកទី ៨

# បទប្បញ្ញត្តិផ្សេងៗ

## ប្រការ ៦៦. ការសម្ងាត់

*៦៦.១.ភាពឯកជននៃដំណើរការមជ្ឈត្តការ*

លើកលែងតែគូភាគីវិវាទមានការព្រមព្រៀងផ្សេងពីនេះ រាល់ការប្រជុំ និងសវនាការនានា ត្រូវធ្វើឡើងជាលក្ខណៈឯកជន និងកំណត់ត្រាផ្សេងៗ ប្រតិចារិក ឬឯកសារនានាត្រូវតែរក្សាជាការសម្ងាត់។

*៦៦.២.ការរក្សាការសម្ងាត់នៃការជំនុំពិភាក្សារបស់វេទិកាមជ្ឈត្តកម្ម*

ការជំនុំពិភាក្សារបស់វេទិកាមជ្ឈត្តកម្មត្រូវតែរក្សាជាការសម្ងាត់។

*៦៦.៣.ការសម្ងាត់ និងការមិនបង្ហាញអង្គហេតុ*

ប្រសិនបើមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីគូភាគីវិវាទទេ បុគ្គលគ្រប់រូប ដែលបានចូលរួមដោយផ្ទាល់ ឬដោយប្រយោល ក្នុងមជ្ឈត្តការត្រូវជាប់កាតព្វកិច្ចរក្សាការសម្ងាត់ និងមិនត្រូវបង្ហាញអង្គហេតុដែលពាក់ព័ន្ធ ឬដែលខ្លួនបានដឹងតាមរយៈសំណុំរឿងមជ្ឈត្តការឡើយ លើកលែងតែក្នុងករណី៖

(ក) ការបង្ហាញនោះធ្វើឡើងសម្រាប់ការដាក់ពាក្យទៅតុលាការមានសមត្ថកិច្ចនៃរដ្ឋណាមួយដើម្បីសុំការអនុវត្ត ឬប្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ

(ខ) ស្របតាមដីកាបង្គាប់ ឬដីកាកោះរបស់តុលាការនៃយុត្តាធិការដែលមានសមត្ថកិច្ច

(គ) ក្នុងគោលបំណង គោរពតាម ឬអនុវត្តសិទ្ធិ ឬការទាមទារស្របច្បាប់

(ឃ) ស្របតាមបញ្ញត្តិច្បាប់របស់រដ្ឋណាមួយដែលមានអានុភាពចាប់បង្ខំចំពោះភាគីវិវាទដែលត្រូវបង្ហាញ ឬ

(ង) ស្របតាមសេចក្តីបង្គាប់របស់វេទិកាមជ្ឈត្តកម្ម តាមការដាក់ពាក្យរបស់ភាគីវិវាទណាមួយ ដោយមានការជូនដំណឹងត្រឹមត្រូវ ទៅភាគីវិវាទម្ខាងទៀត។

### *៦៦.៤.មិនមានការដាក់បណ្តឹងពីបទបរិហារកេរ្តិ៍*

គូភាគីវិវាទ និងវេទិកាមជ្ឈត្តកម្ម ព្រមព្រៀងថាខ្លួនមិនផ្អែកលើ ឬប្រើប្រាស់ សេចក្តីថ្លែង ក៏ដូចជាយោបល់នានា ទោះបីជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ដែលត្រូវបានធ្វើឡើងក្នុងដំណើរការមជ្ឈត្តការដើម្បីធ្វើ ឬចាប់ផ្តើម ឬរក្សា បណ្តឹងពីបទបរិហារកេរ្តិ៍ បទបរិហារកេរ្តិ៍ជាលាយលក្ខណ៍អក្សរ បទបរិហារកេរ្តិ៍តាមសំដី ឬបណ្តឹងតវ៉ាក្នុងរូបភាពផ្សេងទៀត ដែលមានលក្ខណៈបែបនេះ។

## ប្រការ ៦៧. ការផ្សព្វផ្សាយមជ្ឈត្តវិនិច្ឆ័យ

ម.ជ.ម. អាចផ្សព្វផ្សាយមជ្ឈត្តវិនិច្ឆ័យរបស់ខ្លួន ទោះទាំងស្រុង ឬជាទម្រង់អត្ថបទដកស្រង់ ឬជាសេចក្តីសង្ខេប នៅលើគេហទំព័ររបស់ខ្លួន ឬតាមមធ្យោបាយដទៃទៀតក្នុងលក្ខខណ្ឌខាងក្រោម៖

(ក) រាល់ការយោងដែលមានឈ្មោះភាគីវិវាទ និងសេចក្តីលម្អិតដទៃទៀត ដែលបណ្តាលឱ្យសាធារណៈជនអាចស្គាល់ពីអត្តសញ្ញាណរបស់គូភាគីវិវាទ ត្រូវបានលុបចោលតាមសំណូមពរ ឬការកំណត់ជាក់លាក់របស់ភាគីវិវាទ និង

(ខ) ប្រសិនបើមិនមានភាគីវិវាទណាមួយបានជំទាស់ទៅនឹងការផ្សព្វផ្សាយមជ្ឈត្តវិនិច្ឆ័យក្នុងអំឡុងពេល ៩០ (កៅសិប)ថ្ងៃប្រតិទិន បន្ទាប់ពីចេញមជ្ឈត្តវិនិច្ឆ័យ។

## ប្រការ ៦៨. ការបោះបង់សិទ្ធិ

ភាគីវិវាទណាមួយដែលដឹងថាបញ្ញត្តិដែលមិនមានអានុភាពចាប់បង្ខំតាមផ្លូវច្បាប់ដែលគ្រប់គ្រងមជ្ឈត្តការ ឬការតម្រូវណាមួយក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការ រួមទាំងវិធានស្តីពីមជ្ឈត្តការមិនត្រូវបានគោរព ប៉ុន្តែនៅបន្តមជ្ឈត្តការដោយមិនបានជំទាស់ក្នុងពេលវេលាដែលបញ្ញត្តិ ឬកិច្ចព្រមព្រៀងនោះបានកំណត់ នឹងត្រូវសន្មតថាបានបោះបង់សិទ្ធិប្តឹងជំទាស់របស់ខ្លួន។

ស្របតាមប្រការ ៥៣ *(ការកែតម្រូវ ការបំភ្លឺលម្អិត និងការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម)* ការព្រមព្រៀងក្នុងការធ្វើមជ្ឈតកម្មក្រោមវិធាននេះមានន័យថា គូភាគីវិវាទយល់ព្រមអនុវត្តមជ្ឈត្តវិនិច្ឆ័យភ្លាមៗ ដោយមិនបង្អង់ និងដោយមិនដកហូតវិញ គូភាគីវិវាទបោះបង់ផងដែរនូវសិទ្ធិក្នុងការប្តឹងជំទាស់

របស់ខ្លួនសម្រាប់សិទ្ធិក្នុងការប្តឹងជំទាស់ណាដែលអាចបោះបង់បានដោយមានសុពលភាព។ គូភាគីវិវាទព្រមព្រៀងបន្ថែមទៀតថា មជ្ឈត្តវិនិច្ឆ័យ គឺស្ថាពរ និងមានអានុភាពអនុវត្តចំពោះគូភាគីវិវាទ។

## ប្រការ ៦៩. ជម្រើសរវាងតុលាការ និង ម.ជ.ម.

នៅពេលដែលទីកន្លែងធ្វើមជ្ឈត្តការស្ថិតក្នុងព្រះរាជាណាចក្រកម្ពុជា និងគូភាគីវិវាទបានអនុលោមតាមមាត្រា ២១ ទាក់ទងនឹងការជំទាស់ទៅនឹងមជ្ឈត្តករ ឬមាត្រា ២២ ទាក់ទងនឹងការបញ្ចប់អាណត្តិរបស់មជ្ឈត្តករ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ក្នុងជម្រើសដោះស្រាយវិវាទចំពោះមុខតុលាការផ្នែកពាណិជ្ជកម្ម សាលាឧទ្ធរណ៍ ឬតុលាការកំពូល ឬនៅចំពោះមុខ ម.ជ.ម. គូភាគីវិវាទ តាមរយៈវិធាននេះ យល់ព្រមយ៉ាងដាក់លាក់ក្នុងការដាក់វិវាទជាសមត្ថកិច្ចដោះស្រាយផ្តាច់មុខរបស់ ម.ជ.ម.។ សេចក្តីសម្រេចរបស់ ម.ជ.ម. ក្រោមវិធាននេះ ត្រូវចាត់ទុកថាជាសេចក្តីសម្រេចរបស់ ម.ជ.ម. ក្រោមមាត្រាច្បាប់ដែលរៀបរាប់ខាងដើម ដែលជាសេចក្តីសម្រេចស្ថាពរ និងបិទផ្លូវតវ៉ា។

## ប្រការ ៧០. ករណីដែលមិនមានចែងច្បាស់លាស់ក្នុងវិធាន

សម្រាប់ករណីណាមួយដែលមិនមានចែងច្បាស់លាស់ក្នុងវិធាននេះ ម.ជ.ម. វេទិកាមជ្ឈត្តកម្ម និងគូភាគីវិវាទ ត្រូវធ្វើសកម្មភាពស្ថិតក្នុងស្មារតីនៃវិធាននេះ និងត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាព ធានានូវដំណោះស្រាយវិវាទប្រកបដោយយុត្តិធម៌ ឆាប់រហ័ស និងចំណាយអស់តិច។

## ប្រការ ៧១. ការមិនទទួលខុសត្រូវ

ម.ជ.ម. ដោយរាប់បញ្ចូលទាំងសមាជិក អភិបាល ទីប្រឹក្សា លេខា និងបុគ្គលិករបស់ ម.ជ.ម. មជ្ឈត្តករបន្ទាន់ និងសមាជិករបស់វេទិកាមជ្ឈត្តកម្ម ៖

(ក) មិនទទួលខុសត្រូវចំពោះបុគ្គលណាម្នាក់ឡើយ សម្រាប់សកម្មភាព ការខកខានមិនបានបំពេញកាតព្វកិច្ច ឬការធ្វេសប្រហែស ដែលពាក់ព័ន្ធនឹងការធ្វើមជ្ឈត្តកម្ម ស្របតាមវិធាននេះឡើយ ឬបំពេញមុខងារណាមួយដូចមានចែងក្នុងវិធាននេះ និង

(ខ) មិនមានកាតព្វកិច្ចក្នុងការធ្វើសេចក្តីថ្លែងការណ៍ពាក់ព័ន្ធទៅនឹងមជ្ឈត្តការដែលដំណើរការស្របតាមវិធាននេះ ឬបំពេញមុខងារណាមួយដូចមានចែងក្នុងវិធាននេះ និងមិនមានភាគីវិវាទណាមួយអាចស្នើឱ្យបុគ្គលណាម្នាក់ខាងលើធ្វើជាសាក្សីក្នុងនីតិវិធីផ្លូវច្បាប់ណាមួយពាក់ព័ន្ធនឹងមជ្ឈត្តការដែលធ្វើឡើងស្របតាមវិធាននេះ ឬបំពេញមុខងារណាមួយដូចមានចែងក្នុងវិធាននេះនោះទេ។

## ប្រការ ៧២. វិសោធនកម្មទៅលើវិធាន

វិធាននេះអាចត្រូវបានធ្វើវិសោធនកម្មជារឿយៗដោយ ម.ជ.ម.។ លើកលែងតែមានចែងផ្សេងពីនេះ កិច្ចព្រមព្រៀងក្នុងការធ្វើមជ្ឈត្តការដូចមានកំណត់ក្នុងប្រការ ២.១(ក) មានន័យថាជាការព្រមព្រៀងក្នុងការធ្វើមជ្ឈត្តការស្របតាមវិធានទាំងឡាយរបស់ ម.ជ.ម. ដែលមានសុពលភាពជាធរមាននៅកាលបរិច្ឆេទ ដែលអគ្គលេខាធិការដ្ឋានបានទទួលសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម។

## ប្រការ ៧៣. សេចក្ដីណែនាំសម្រាប់អនុវត្ត

ក្នុងករណីចាំបាច់ ឬដែលមានប្រយោជន៍ ក្រុមប្រឹក្សាប្រតិបត្តិរបស់ ម.ជ.ម. អាចចេញសេចក្ដីណែនាំសម្រាប់អនុវត្ត ដើម្បីបំពេញបន្ថែម ធ្វើនិយ័តកម្ម និងអនុវត្តវិធាននេះក្នុងគោលបំណងសម្រួលកិច្ចការរដ្ឋបាលនៃមជ្ឈត្តការដែលគ្រប់គ្រងដោយវិធាននេះ។

ជំពូកទី ៩

# អវសានប្បញ្ញត្តិ

## ប្រការ ៧៤. អវសានប្បញ្ញត្តិ

៧៤.១.វិធាននេះត្រូវបានអនុម័តដោយមហាសន្និបាតរបស់ ម.ជ.ម. នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។ បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងវិធាននេះត្រូវទុកជានិរាករណ៍។

៧៤.២.វិធាននេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ តទៅ។

ថ្ងៃអាទិត្យ ១៥ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១
**មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**
**ប្រធាន**

**ប៊ុន យូឌី**

ឧបសម្ព័ន្ធ ១

# តារាងកម្រៃសេវារបស់ ម.ជ.ម.

(សូមមើលជំពូកទី ៧ *(កម្រៃសេវា)* នៃវិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម.)

១. *កម្រៃសេវាចុះបញ្ជីសំណុំរឿង*

១.១ នៅពេលដាក់សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម ឬបណ្ដឹងតប ភាគីប្ដឹងទាមទារ ឬភាគីប្ដឹងទាមទារនៃបណ្ដឹងតបនោះត្រូវបង់រៀងៗខ្លួននូវកម្រៃសេវាចុះបញ្ជីសំណុំរឿងចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក សម្រាប់ការចុះបញ្ជីការទាមទារ ឬបណ្ដឹងតបនោះ។

១.២ ប្រសិនបើភាគីប្ដឹងទាមទារ ឬភាគីប្ដឹងទាមទារនៃបណ្ដឹងតប ខកខានក្នុងការបង់កម្រៃសេវាចុះបញ្ជី ម.ជ.ម. នឹងមិនចាប់ដំណើរការមជ្ឈត្តការដោះស្រាយការទាមទារ ឬបណ្ដឹងតបនោះនោះទេ។

១.៣ កម្រៃសេវាចុះបញ្ជីសំណុំរឿងមិនអាចត្រូវបានបង់សងវិញទេ។

២. *កម្រៃសេវាសំណើសុំឱ្យមានការចូលរួមពីតតិយជន*

២.១ នៅពេលដាក់សំណើសុំឱ្យមានការចូលរួមពីតតិយជនក្រោមប្រការ ៣៥.៥ *(ការចូលរួមពីតតិយជន)* ភាគីដែលដាក់សំណើនោះត្រូវបង់នូវកម្រៃសេវាសំណើសុំឱ្យមានការចូលរួមពីតតិយជនចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក។

២.២ ប្រសិនបើភាគីដែលដាក់សំណើនោះខកខានក្នុងការបង់កម្រៃសេវាសំណើសុំឱ្យមានការចូលរួមពីតតិយជន សំណើសុំឱ្យមានការចូលរួមពីតតិយជននោះមិនត្រូវបានលើកយកមកពិចារណាក្នុងដំណើរការមជ្ឈត្តការឡើយ។

២.៣ កម្រៃសេវាសំណើសុំឱ្យមានការចូលរួមពីតតិយជនមិនអាចត្រូវបានបង់សងវិញទេ។

## ៣. *កម្រៃសេវាតែងតាំងមជ្ឈត្តករ*

៣.១ ភាគីវិវាទត្រូវបង់កម្រៃសេវាចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក សម្រាប់ការតែងតាំងមជ្ឈត្តករមួយរូបដែលធ្វើឡើងដោយ ម.ជ.ម. តាមរយៈ គណៈកម្មាធិការតែងតាំង និងនីតិវិធី នៅពេលដែលភាគីវិវាទ ឬគូភាគីវិវាទ ខកខានក្នុងការតែងតាំងមជ្ឈត្តករ ឬមជ្ឈត្តករដែលគូភាគីវិវាទបានតែងតាំង ខកខានក្នុងការតែងតាំងប្រធានវេទិកាមជ្ឈត្តកម្ម ស្របតាមវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. ហើយ ម.ជ.ម. តាមរយៈគណៈកម្មាធិការតែងតាំង និងនីតិវិធី ត្រូវបានស្នើ ឬតម្រូវឱ្យធ្វើការតែងតាំងមជ្ឈត្តករ។

៣.២ កម្រៃសេវាតែងតាំងមជ្ឈត្តករ ត្រូវអនុវត្តចំពោះសំណុំរឿងដែលចាត់ចែងដោយ ម.ជ.ម. ឬក្នុងសំណុំរឿងពិសេស ដែលទាមទារឱ្យគណៈកម្មាធិការតែងតាំង និងនីតិវិធី តែងតាំងមជ្ឈត្តករស្របតាមវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. ឬក្នុងករណីដែលសំណើសុំឱ្យមានការតែងតាំងមជ្ឈត្តករត្រូវបានបញ្ជូនទៅអគ្គលេខាធិការដ្ឋាន។

៣.៣ កម្រៃសេវាតែងតាំងមជ្ឈត្តករនេះមិនត្រូវអនុវត្តលើការតែងតាំងមជ្ឈត្តករជំនួសណាមួយឡើយ ក្នុងករណីដែលមជ្ឈត្តករត្រូវបានជំនួសដូចមានចែងក្នុងប្រការ ៣០ *(ការដាក់មជ្ឈត្តករជំនួស)* ត្រូវបានតែងតាំងដោយគណៈកម្មាធិការតែងតាំង និងនីតិវិធី។

៣.៤ សម្រាប់សំណុំរឿងពិសេស កម្រៃសេវាតែងតាំងមជ្ឈត្តករត្រូវផ្ទេរចូលគណនីដែលកំណត់ដោយ ម.ជ.ម. មុនពេលចាប់ផ្តើមការតែងតាំង។

៣.៥ កម្រៃសេវាតែងតាំងមជ្ឈត្តករមិនអាចត្រូវបានបង់សងវិញឡើយ។

## ៤.- *កម្រៃសេវាជំទាស់*

៤.១ នៅពេលដាក់សេចក្តីជូនដំណឹងអំពីការជំទាស់ទៅនឹងមជ្ឈត្តករដូចមានចែងក្នុងប្រការ ២៨.២ *(សេចក្តីជូនដំណឹងអំពីការជំទាស់ទៅនឹងមជ្ឈត្តករ ពេលវេលាកំណត់ និងកម្រៃសេវាជំទាស់)* ភាគីវិវាទនោះត្រូវបង់នូវកម្រៃសេវាជំទាស់ចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក។

៤.២ កម្រៃសេវាជំទាស់មិនអាចត្រូវបានបង់សងវិញឡើយ។

## ៥. *កម្រៃសេវារដ្ឋបាល*

៥.១ កម្រៃសេវារដ្ឋបាលត្រូវយោងតាមកម្រិតនៃកម្រៃសេវា ដែលប្រែប្រួលទៅតាមតម្លៃកម្មវត្ថុនៃវិវាទ និងត្រូវកំណត់ស្របតាមតារាងខាងក្រោម។

៥.២ តម្លៃកម្មវត្ថុនៃវិវាទ គឺជាតម្លៃកម្មវត្ថុនៃរាល់ការទាមទារ និងបណ្តឹងតបទាំងអស់។ ការដោះសាតាមការកាត់កងត្រូវបានបញ្ចូលសម្រាប់ការគណនាតម្លៃកម្មវត្ថុនៃវិវាទ និងកម្រៃសេវារដ្ឋបាល ប្រសិនបើការដោះសាតាមការកាត់កងនោះបណ្តាលឱ្យវេទិកាមជ្ឈត្តកម្មមានបន្ទុកការងារបន្ថែមទៀត។

## កម្រៃសេវារដ្ឋបាល (គិតជាដុល្លារអាមេរិក)

| តម្លៃកម្មវត្ថុនៃវិវាទ | | | | | កម្រៃសេវារដ្ឋបាល | | | | |
|---|---|---|---|---|---|---|---|---|---|
| រហូត | ៥០.០០០ | | | = | ៧៥០ | | | | |
| ចាប់ពី | ៥០.០០១ | ដល់ | ១០០.០០០ | = | ១.៥០០ | + | 0,៨០% | នៃចំនួនដែលលើសពី | ៥០.០០០ |
| ចាប់ពី | ១០០.០០១ | ដល់ | ៥០០.០០០ | = | ១.៩០០ | + | 0,៧០% | នៃចំនួនដែលលើសពី | ១០០.០០០ |
| ចាប់ពី | ៥០០.០០១ | ដល់ | ១.០០០.០០០ | = | ៤.៧០០ | + | 0,៥០ % | នៃចំនួនដែលលើសពី | ៥០០.០០០ |
| ចាប់ពី | ១.០០០.០០១ | ដល់ | ៣.០០០.០០០ | = | ៧.២០០ | + | 0,២០% | នៃចំនួនដែលលើសពី | ១.០០០.០០០ |
| ចាប់ពី | ៣.០០០.០០១ | ដល់ | ៥.០០០.០០០ | = | ១១.២០០ | + | 0,១២% | នៃចំនួនដែលលើសពី | ៣.០០០.០០០ |
| ចាប់ពី | ៥.០០០.០០១ | ដល់ | ១០.០០០.០០០ | = | ១៣.៦០០ | + | 0,០៨% | នៃចំនួនដែលលើសពី | ៥.០០០.០០០ |
| ចាប់ពី | ១០.០០០.០០១ | ដល់ | ៥០.០០០.០០០ | = | ១៧.៦០០ | + | 0,០៤% | នៃចំនួនដែលលើសពី | ១០.០០០.០០០ |
| លើសពី | ៥០.០០០.០០០ | | | = | ៣៣.៦០០ | | | | |

៥.៣ កម្រៃសេវារដ្ឋបាលនៃសំណុំរឿងនីមួយៗ អាចនឹងត្រូវបានកែប្រែដោយអគ្គលេខាធិការដ្ឋាន ដោយពិចារណាទៅលើកាលៈទេសៈពិសេសណាមួយ ដែលអគ្គលេខាធិការដ្ឋានយល់ឃើញថា សមហេតុផលក្នុងការបន្ថយ ឬដំឡើងកម្រៃសេវារដ្ឋបាល ដែលមានកំណត់នៅក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម.។ កាលៈទេសៈពិសេស រួមមានជាអាទិ៍ បរិមាណការងារដែល ម.ជ.ម. ត្រូវបំពេញមានតិចតួចដោយសារតែការបញ្ចប់ដំណើរការមជ្ឈត្តការមុនកាលកំណត់ ឬសេវាកម្មផ្សេងៗ ដែល ម.ជ.ម. ត្រូវផ្ដល់បន្ថែម។ ការដំឡើងកម្រៃសេវារដ្ឋបាលមិនត្រូវលើសពី ៣០% (សាមសិបភាគរយ) នៃកម្រៃសេវារដ្ឋបាលដែលមានកំណត់ក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម. នោះទេ។

## ៦. *កម្រៃសេវាវេទិកាមជ្ឈត្តកម្ម*

៦.១ កម្រៃសេវាវេទិកាមជ្ឈត្តកម្មត្រូវយោងតាមកម្រិតនៃកម្រៃសេវាដែលប្រែប្រួលទៅតាមតម្លៃកម្មវត្ថុនៃវិវាទ និងត្រូវកំណត់ស្របតាមតារាងខាងក្រោម។

៦.២ តម្លៃកម្មវត្ថុនៃវិវាទ គឺជាតម្លៃនៃរាល់ការទាមទារ និងបណ្ដឹងតបទាំងអស់។ ការដោះសាតាមការកាត់កងត្រូវបានបញ្ចូលសម្រាប់ការគណនាតម្លៃកម្មវត្ថុនៃវិវាទ និងកម្រៃសេវាវេទិកាមជ្ឈត្តកម្ម ប្រសិនបើការកាត់កងតាមការដោះសានោះបណ្ដាលឱ្យវេទិកាមជ្ឈត្តកម្មមានបន្ទុកការងារបន្ថែមទៀត។

៦.៣ កម្រៃសេវាវេទិកាមជ្ឈត្តកម្មនៃសំណុំរឿងនីមួយៗ ត្រូវបានអគ្គលេខាធិការដ្ឋានកែប្រែដោយពិចារណាទៅលើកាលៈទេសៈពិសេសណាមួយ ដែលអគ្គលេខាធិការដ្ឋានយល់ឃើញថា សមហេតុផលក្នុងការបន្ថយ ឬដំឡើងកម្រៃសេវាវេទិកាមជ្ឈត្តកម្ម ដែលមានកំណត់នៅក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម.។ កាលៈទេសៈពិសេស រួមមានជាអាទិ៍ បរិមាណការងារដែលវេទិកាមជ្ឈត្តកម្មត្រូវបំពេញមានតិចតួចដោយសារតែការបញ្ចប់ដំណើរការមជ្ឈត្តការមុនកាលកំណត់ ឬមានការងារបន្ថែម ដែលវេទិកាមជ្ឈត្តកម្មត្រូវបំពេញពាក់ព័ន្ធនឹងសំណើជាបន្តបន្ទាប់នានាសម្រាប់វិធានការបណ្ដោះអាសន្ន ការជំទាស់ទៅនឹងមជ្ឈត្តករ ឬទទ្បីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម។ ការដំឡើងកម្រៃសេវាវេទិកាមជ្ឈត្តកម្មមិនត្រូវលើសពី ៣០% (សាមសិបភាគរយ) នៃកម្រៃសេវាវេទិកាមជ្ឈត្តកម្មដែលមានកំណត់ក្នុងតារាងកម្រៃសេវារបស់ ម.ជ.ម. ឡើយ។

## កម្រៃសេវាវេទិកាមជ្ឈត្តកម្ម (គិតជាដុល្លារអាមេរិក)

| តម្លៃកម្មវត្ថុនៃវិវាទ | | | | | កម្រៃសេវាវេទិកាមជ្ឈត្តកម្ម ( សម្រាប់មជ្ឈត្តករមួយរូប ) | | | | |
|---|---|---|---|---|---|---|---|---|---|
| រហូត | ៥០.០០០ | | | = | ១.០០០ | | | | |
| ចាប់ពី | ៥០.០០១ | ដល់ | ១០០.០០០ | = | ២.៧៥០ | + | ២% | នៃចំនួនដែលលើសពី | ៥០.០០០ |
| ចាប់ពី | ១០០.០០១ | ដល់ | ៥០០.០០០ | = | ៣.៧៥០ | + | ១,៧០% | នៃចំនួនដែលលើសពី | ១០០.០០០ |
| ចាប់ពី | ៥០០.០០១ | ដល់ | ១.០០០.០០០ | = | ១០.៥៥០ | + | ១,៥០% | នៃចំនួនដែលលើសពី | ៥០០.០០០ |
| ចាប់ពី | ១.០០០.០០១ | ដល់ | ៣.០០០.០០០ | = | ១៨.០៥០ | + | ០,៧៥% | នៃចំនួនដែលលើសពី | ១.០០០.០០០ |
| ចាប់ពី | ៣.០០០.០០១ | ដល់ | ៥.០០០.០០០ | = | ៣៣.០៥០ | + | ០,៥០% | នៃចំនួនដែលលើសពី | ៣.០០០.០០០ |
| ចាប់ពី | ៥.០០០.០០១ | ដល់ | ១០.០០០.០០០ | = | ៤៣.០៥០ | + | ០,៣០% | នៃចំនួនដែលលើសពី | ៥.០០០.០០០ |
| ចាប់ពី | ១០.០០០.០០១ | ដល់ | ៥០.០០០.០០០ | = | ៥៨.០៥០ | + | ០,១៥% | នៃចំនួនដែលលើសពី | ១០.០០០.០០០ |
| លើសពី | ៥០.០០០.០០០ | | | = | ១១៨.០៥០ | | ០,០៧៥% | នៃចំនួនដែលលើសពី | ៥០.០០០.០០០ |

## *៧. កម្រៃសេវានៃការស្នើសុំវិធានការបណ្ដោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់*

៧.១ កម្រៃស្នើសុំសម្រាប់សំណើសុំឱ្យតែងតាំងមជ្ឈត្តករបន្ទាន់ (រួមបញ្ចូលទាំងកម្រៃសេវាតែងតាំង និងកម្រៃសេវារដ្ឋបាលនានាដោយអគ្គលេខាធិការដ្ឋានសម្រាប់វិធានការបណ្ដោះអាសន្នចេញដោយមជ្ឈត្តករបន្ទាន់) មកគណៈកម្មាធិការតែងតាំង និងនីតិវិធី ក្រោមជំពូក ៣ *(មជ្ឈត្តករបន្ទាន់)* មានចំនួន ១.៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក និងត្រូវបង់គ្រប់ចំនួននៅពេលដាក់សំណើសុំឱ្យតែងតាំងមជ្ឈត្តករបន្ទាន់មកគណៈកម្មាធិការតែងតាំង និងនីតិវិធី។

៧.២ កម្រៃស្នើសុំមិនអាចត្រូវបានបង់សងវិញឡើយ ហើយក៏មិនមែនជាចំណែកមួយនៃកម្រៃសេវារដ្ឋបាលដែលមានកំណត់ក្នុងចំណុច ៥ (*កម្រៃសេវារដ្ឋបាល*)។

៧.៣ កម្រៃសេវាមជ្ឈត្តករបន្ទាន់មានចំនួន ៣.៥០០ (បីពាន់ប្រាំរយ) ដុល្លារអាមេរិក និងត្រូវបង់គ្រប់ចំនួននៅពេលដាក់សំណើសុំឱ្យតែងតាំងមជ្ឈត្តករបន្ទាន់មកគណៈកម្មាធិការតែងតាំង និងនីតិវិធី។

## *៨. កាលបរិច្ឆេទសុពលភាព*

៨.១ តារាងកម្រៃសេវារបស់ ម.ជ.ម. នេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់ ម.ជ.ម. នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។

៨.២ តារាងកម្រៃសេវារបស់ ម.ជ.ម. នេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ តទៅ។

**សម្គាល់៖** កម្រៃសេវាដូចមានកំណត់ខាងលើមិនរាប់បញ្ចូលការចំណាយផ្សេងៗរបស់ ម.ជ.ម. វេទិកាមជ្ឈត្តកម្ម និងមជ្ឈត្តករបន្ទាន់ ក៏ដូចជាអាករលើតំលៃបន្ថែមលើកម្រៃសេវារដ្ឋបាលរបស់ ម.ជ.ម. និងពន្ធកាត់ទុកលើសេវារបស់មជ្ឈត្តករឡើយ។ មុនពេលបង្កើតវេទិកាមជ្ឈត្តកម្ម គូភាគីវិវាទអាចព្រមព្រៀងផ្សេងពីនេះលើកម្រៃសេវាវេទិកាមជ្ឈត្តកម្ម ប្រសិនបើវេទិកាមជ្ឈត្តកម្មឯកភាពចំពោះកម្រៃសេវាដែលព្រមព្រៀងនោះ។

ថ្ងៃអាទិត្យ ១៥ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១
**មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**
**ប្រធាន**




**ម៉ុន យូឌី**

ឧបសម្ព័ន្ធ ២

# គំរូខចែងរបស់ ម.ជ.ម.

**ខចែងស្ដីពីមជ្ឈត្តការ**

រាល់វិវាទទាំងអស់ដែលកើតចេញពី ឬដែលទាក់ទងនឹងកិច្ចសន្យានេះ រួមបញ្ចូលវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត ឬការបញ្ចប់កិច្ចសន្យានេះ ត្រូវបញ្ជូនទៅដោះស្រាយជាស្ថាពរតាមរយៈមជ្ឈត្តការចាត់ចែងដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (វិធានស្តីពីមជ្ឈត្តការ ម.ជ.ម.) ដែលមានសុពលភាពអនុវត្តនៅពេលចាប់ផ្តើមដំណើរការមជ្ឈត្តការ ហើយតាមរយៈការយោងក្នុងប្រការនេះ វិធានស្តីពីមជ្ឈត្តការ ម.ជ.ម. ត្រូវចាត់ទុកថាបានរួមបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។

ទីកន្លែងធ្វើមជ្ឈត្តការគឺ [រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]។*

វេទិកាមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករចំនួន__________**រូប។

ភាសានៃមជ្ឈត្តការគឺ ________________ ។

**ខចែងស្ដីពីច្បាប់គ្រប់គ្រងកិច្ចសន្យា**

ច្បាប់ដែលត្រូវយកមកអនុវត្តលើកិច្ចសន្យានេះគឺច្បាប់នៃ________________***។

* គូភាគីវិវាទគួរបញ្ជាក់អំពីជម្រើស នៃទីកន្លែងធ្វើមជ្ឈត្តការរបស់ខ្លួន។ ប្រសិនបើគូភាគីវិវាទមានបំណងចង់ជ្រើសរើសទីកន្លែងធ្វើមជ្ឈត្តការផ្សេងពីរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា គូភាគីវិវាទត្រូវជំនួស "[រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]" ដោយឈ្មោះទីក្រុង និងប្រទេសនៃជម្រើសរបស់ខ្លួន (ឧទាហរណ៍ "[ទីក្រុង ប្រទេស]")។

** ចំនួនមជ្ឈត្តករត្រូវកំណត់ជាចំនួនសេស។

*** បញ្ជាក់ឈ្មោះប្រទេស ឬយុត្តាធិការ។

WWW.NCAC.ORG.KH